# វិធានជាមូលដ្ឋាន ស្ដីពីការប្រមូល និង សរសេរដំណឹង

បោះពុម្ពលើកទីពីរ





និពន្ធដោយលោក PETER ENG និងលោក JEFF HODSON
សម្រាប់ THE INDOCHINA MEDIA MEMORIAL FOUNDATION

និពន្ធដោយលោក PETER ENG និងលោក JEFF HODSON

សម្រាប់

**THE INDOCHINA MEDIA MEMORIAL FOUNDATION**

*បោះពុម្ពលើកទីពីរ*

ផ្ទៀងផ្ទាត់ការនិពន្ធដោយលោក DOMINIC FAULDER

ផលិតក្រោមការឧបត្ថម្ភពីសំណាក់

**THE OPEN SOCIETY NETWORK MEDIA PROGRAMME**

និង

**THE MCGEE FOUNDATION**


រក្សាសិទ្ធិឆ្នាំ ២០០៩ ដោយ The Indochina Media Memorial Foundation

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ គ្មានផ្នែកណាមួយនៃសៀវភៅនេះ ត្រូវបានយកទៅផលិតឡើងវិញ ឬបញ្ជូនបន្ត ទោះក្នុងទម្រង់ណាក៏ដោយ បើគ្មានការអនុញ្ញាតជាលាយល័ក្ខអក្សរពីសំណាក់ IMMF



សៀវភៅណែនាំសម្រាប់បង្ហាត់អ្នកសារព័ត៌មាន ដែលជាកម្មសិទ្ធិរបស់ IMMF ត្រូវបានផលិតជាភាសា អង់គ្លេស ភូមា ខ្មែរ ថៃ និងវៀតណាម ហើយក៏អាចទាញយកបានតាមរយៈគេហទំព័រ

http://www.immf.or.th/download/manual.aspx

The Indochina Media Memorial Foundation
c/o The Foreign Correspondents' Club of Thailand
Penthouse, Maneeya Centre Building
518/5 Ploenchit Road, Pathumwan
Bangkok 10330, Thailand

Tel: +66(0)2652 0580-1 l Fax: +66(0)2652 0582
E-mail: info@fcctthai.com l Web: www.fccthai.com

បកប្រែជាភាសាខ្មែរដោយលោក កែ មុនធិត

Khmer edition's design by: Graphic Roots
www.graphicroots.com.kh

# មាតិកាសង្ខេប


បុព្វកថា xi

សេចក្តីផ្តើម xiii

សន្ទានុក្រម xvi

**ភាគទី ១ : មូលដ្ឋានគ្រឹះវិស័យសារព័ត៌មាន**

ជំពូកទី ១ អ្នកសារព័ត៌មាន និងដំណឹង ១៩

ជំពូកទី ២ ការស្វែងរកប្រភពព័ត៌មាន និងគោលគំនិតរឿង ២៣

ជំពូកទី ៣ គ្រោងជាមូលដ្ឋាននៃរឿង ២៨

ជំពូកទី ៤ តម្រូវការជាមូលដ្ឋានសម្រាប់ធ្វើរឿងឲ្យបានល្អ ៤០

**ភាគទី ២ : ការប្រមូលព័ត៌មាន**

ជំពូកទី ៥ ការសង្កេត ៥០

ជំពូកទី ៦ តិចនិចសម្ភាសន៍ ៥៤

ជំពូកទី ៧ ការប្រើប្រាស់ឯកសារ និងអ៊ិនធឺណិត ៦៣

**ភាគទី ៣ : ផ្គុំព័ត៌មានចូលគ្នា**

ជំពូកទី ៨ សេចក្តីផ្តើម ៦៧

ជំពូកទី ៩ ការរៀបរៀងសាច់រឿង ៧៧

**ភាគទី ៤ : ការសរសេររឿងឲ្យបានល្អ**

ជំពូកទី ១០ ការប្រើប្រាស់សម្រង់សម្តីដើម (Using Quotations) ៩១

ជំពូកទី ១១ តម្រុយសម្រាប់ការសរសេរឲ្យបានល្អ ៩៦

**ភាគទី ៥ : រឿងទូទៅ តែគួរឲ្យធុញ**

ជំពូកទី ១២ សេចក្តីប្រកាសព័ត៌មាន ១០២

ជំពូកទី ១៣ យកព័ត៌មានអំពីកិច្ចប្រជុំ សុន្ទរកថា សន្និសីទព័ត៌មាន ១០៩

**ភាគទី ៦**

ជំពូកទី ១៤ សរសេរសម្រាប់ការផ្សាយតាមរលកធាតុអាកាស ១២៣

**ភាគទី ៧**

ជំពូកទី ១៥ ក្រមសីលធម៌ ១៣២

សេចក្តីសន្និដ្ឋាន ១៣៨

ឯកសារអានបន្ថែម ១៤០

សេចក្តីថ្លែងអំណរគុណ ១៤២

អំពីអ្នកនិពន្ធ ១៤៣

# មាតិកាលម្អិត


**បុព្វកថា** xi

**សេចក្តីផ្តើម** xiii

**សន្ទានុក្រម** xvi

**ភាគទី ១ :  មូលដ្ឋានគ្រឹះវិស័យសារព័ត៌មាន**

**ជំពូកទី ១ :  អ្នកសារព័ត៌មាន និងដំណឹង ១៩**

តួនាទីរបស់អ្នកសារព័ត៌មាន ១៩
សារៈសំខាន់នៃអ្នកអាន ២០
លក្ខណៈសម្បត្តិនៃអ្នកសារព័ត៌មានល្អ ២១
តើអ្វីជាដំណឹង ? ២១

**ជំពូកទី ២ :  ការស្វែងរកប្រភពព័ត៌មាន និងគោលគំនិតរឿង ២៣**

រកមុំថ្មីដើម្បីសរសេររឿង ២៤
តើពីកន្លែងណាខ្លះ ដែលអ្នកកាសែតប្រមូលបានគំនិត ដើម្បីសរសេររឿង ? ២៦
គួរមានប្រភពព័ត៌មានច្រើន តែជាប្រភពល្អៗ ២៧
គួរមានបញ្ជីប្រភពព័ត៌មាន ២៨

**ជំពូកទី ៣ :  គ្រោងជាមូលដ្ឋាននៃរឿង ២៨**

ដំណឹងទាន់ហេតុការណ៍ និងបទពិពណ៌នា (Hard News and Features) ២៨
សេចក្តីផ្តើម និងតួសេចក្តី ២៩
5Ws និង H ៣៤
ចុះវាយ៉ាងម៉េច ? (So what?) ៣៧
បរិបទ និងសាវតារ ៣៩

**ជំពូកទី ៤ :  តម្រូវការជាមូលដ្ឋានសម្រាប់ធ្វើរឿងឲ្យបានល្អ ៤០**

ភាពទៀងត្រង់ជាក់លាក់ (Accuracy) ៤០
ការផ្ទៀងផ្ទាត់ (Verification) ៤១
កម្មវិស័យភាព (Objectivity) ៤៣
បន្ទុកព័ត៌មាន (Attribution) ៤៤
ព័ត៌មានក្នុងកំណត់ត្រា និងក្រៅកំណត់ត្រា (On and Off the Record) ៤៦

ប្រភពអនាមិក (Anonymous Sources) ៤៧
តុល្យភាព និងភាពត្រឹមត្រូវមិនលម្អៀង (Balance and Fairness) ៤៨
ភាពច្បាស់សេចក្តី (Clarity) ៤៨
ភាពពេញសេចក្តី (Completeness) ៤៩

**ភាគទី ២ :  ការប្រមូលព័ត៌មាន**

**ជំពូកទី ៥ :  ការសង្កេត ៥០**

**ជំពូកទី ៦ :  តិចនិចសម្ភាសន៍ ៥៤**

ការសុំបទសម្ភាសន៍ ៥៤
ត្រៀមជាមុន ៥៥
ទៅឲ្យទាន់ពេល ៥៦
ផ្តើមបទសម្ភាសន៍ ចូរបង្ហាញអត្តសញ្ញាណខ្លួន ៥៦
ធ្វើកំណត់ត្រា និងឧបករណ៍ថតសម្លេង ៥៦
សួរសំណួរ “ហេតុអ្វី?” និង “ដោយដូចម្តេច?” ៥៨
សួរសំណួរខ្លីៗ ៥៨
ប្រឹងស្តាប់ តាំងស្មារតី ហើយរក្សាទឹកមុខប្រុងប្រយ័ត្ន ៥៨
កុំញញើតនឹងសួរសំណួរ “ភ្លើៗ” ៥៩
របៀបលៃលកជាមួយចម្លើយ “គ្មានអត្ថាធិប្បាយ” ៦០
ពេលដែលប្រភពនៅតែមិនព្រមឆ្លើយ ៦០
សាកល្បងនៅស្ងៀមស្ងាត់ ៦០
ពេលដែលប្រភពនិយាយបូរបាច់ច្រើន ៦០
សំណួរបន្ថែម : ឈ្លេចយកចំណុចជាក់លាក់ ៦១
សំណួរពិបាកៗ ៦១
បទសម្ភាសន៍អំពីបុគ្គលភាព (Profile interviews) ៦២
របៀបបញ្ចប់បទសម្ភាសន៍ ៦២

**ជំពូកទី ៧ :  ការប្រើប្រាស់ឯកសារ និងអ៊ិនធឺណិត ៦៣**

ចូរផ្ទៀងផ្ទាត់ ៦៥
គួរសួរនាំមនុស្សម្នាថែមទៀត ៦៥

# មាតិកាលម្អិត


**ភាគទី ៣ :   ផ្តុំព័ត៌មានចូលគ្នា**

ភាពប្រឈម ៦៦
ដំណើរការសំណេរ ៦៦

**ជំពូកទី ៨ :   សេចក្តីផ្តើម ៦៧**

សេចក្តីផ្តើមត្រង់ ៦៧
សេចក្តីផ្តើមដំអក់ ៦៨
កុំ “កប់” សេចក្តីផ្តើម ៧០
កុំ “ញាត់” សេចក្តីផ្តើមឲ្យណែនក្តន់ ៧៣
តើមានអ្វីខុសគ្នាត្រង់នេះ ? ៧៤
ជ្រើសរើស “មុំ” ៧៥
តម្រុយសម្រាប់ការរកសេចក្តីផ្តើម ៧៦

**ជំពូកទី ៩ :   ការរៀបរៀងសាច់រឿង ៧៧**

ផ្តុំកំណត់ហេតុ និងគំនិតរបស់អ្នកចូលគ្នា ៧៨
រឿងស្តីអំពីដំណឹងទាន់ហេតុការណ៍ ៧៩
ពេលដែលមានប្រធានបទច្រើនជាងមួយ ៨២
អត្ថបទពិពណ៌នា ៨៣
ទ្រង់ទ្រាយផ្សេងៗទៀត ៩០

**ភាគទី ៤ :   ការសរសេររឿងឲ្យបានល្អ**

**ជំពូកទី ១០ :  ការប្រើប្រាស់សម្រង់សម្តីដើម ៩១**

ពេលណាគួរ និងពេលណាមិនគួរប្រើសម្រង់សម្តីដើម ៩១
ចៀសវាងការផ្តើមសាច់រឿងជាមួយនឹងសម្រង់សម្តីដើម ៩៤
តើអ្នកណាកំពុងនិយាយ ? ៩៤
ពាក្យ “និយាយ” វាគ្រប់គ្រាន់ណាស់ទៅហើយ (“Said” is enough) ៩៥
កុំដូរសម្តីដើមឲ្យសោះ ! ៩៥
សូមប្រយ័ត្នជាមួយសម្តីដើមជាត្រណោត ៩៥

**ជំពូកទី ១១ : តម្រុយសម្រាប់ការសរសេរឲ្យបានល្អ ៩៦**

មូលដ្ឋាន : ការប្រមូលព័ត៌មាន ៩៦
ធ្វើឲ្យច្បាស់សេចក្តី ធ្វើឲ្យសាមញ្ញសេចក្តី (Clarify, Simplify) ៩៦
ប្រើកិរិយាស័ព្ទ និងនាមខ្លាំងរស់រវើក (Using strong verbs and nouns) ៩៧
ចូរបង្ហាញ កុំប្រាប់ (Show, Don’t Tell) ៩៧
របៀបលៃលកជាមួយតួលេខ ៩៩
ចង្វាក់ចុងចួន និងចម្រុះភាព (Rhythm and Variety) ១០០
សូរស័ព្ទ (Tone) ១០១
ការសរសេរឡើងវិញ (Re-write) ១០១
សៀវភៅស្ទីល ១០១

**ភាគទី ៥ : រឿងទូទៅ តែគួរឲ្យធុញ**

**ជំពូកទី ១២ : សេចក្តីប្រកាសព័ត៌មាន ១០២**

**ជំពូកទី ១៣ : ការយកព័ត៌មានអំពីកិច្ចប្រជុំ សុន្ទរកថា សន្និសីទព័ត៌មាន ១០៩**

កិច្ចប្រជុំ ១០៩
សន្និសីទ ១១៦
សុន្ទរកថា និងសន្និសីទព័ត៌មាន : ចូរស្វែងរកតុល្យភាព ១១៧
ចូរផ្តោតលើអ្នកណានិយាយអ្វី ១១៧
ត្រៀមជាមុន ១១៩
ពិធីផ្លូវការ ១២២

**ភាគទី ៦ :**

**ជំពូកទី ១៤ : សរសេរសម្រាប់ការផ្សាយតាមរលកធាតុអាកាស ១២៣**

សរសេរការផ្សាយឲ្យច្បាស់ ព្រោះឱកាសមានតែម្តងទេ ១២៤
សូមផ្តោតលើបច្ចុប្បន្នភាព ១២៤
វិធានមួយចំនួនសម្រាប់អនុវត្តន៍ ១២៤

# មាតិកាលម្អិត

**ភាគទី ៧ :**

**ជំពូកទី ១៥ : ក្រមសីលធម៌ ១៣២**

ការទទួលខុសត្រូវចំពោះក្រមសីលធម៌ ១៣២
សូមនិយាយតែការពិត ១៣២
កុំបំផ្លើស ឬបង្កអារម្មណ៍សៅហ្មង ១៣៣
បម្រើសាធារណជន កុំបម្រើខ្លួនឯង ១៣៤
កុំលួចស្នាដៃរបស់អ្នកដទៃ ១៣៤
ប្រកាន់ភាពត្រឹមត្រូវមិនលម្អៀង ១៣៥
រក្សាភាពគប្បី និងមានសមានចិត្ត ១៣៥
គោរពសិទ្ធិឯកជនភាពរបស់អ្នកដទៃ ១៣៦
គោរពប្រភពព័ត៌មានរបស់អ្នក ១៣៦
ពិភាក្សាជាមួយសហសេវិក ១៣៦
ក្រមសីលធម៌ ១៣៧

**សេចក្តីសន្និដ្ឋាន ១៣៨**

**ឯកសារអានបន្ថែម ១៤០**

សៀវភៅ ១៤០
កម្រងកូនសៀវភៅ ១៤០
វិបសៃត៍ ១៤០

**សេចក្តីថ្លែងអំណរគុណ ១៤២**

ម្ចាស់រូបថត ១៤២

**អំពីអ្នកនិពន្ធ ១៤៣**

# បុព្វកថា

និពន្ធនាយកកាសែតអាមេរិកម្នាក់ឈ្មោះ ស្តេនលី វ៉កឃើរ (Stanley Walker) ធ្លាប់ធ្វើការកត់សម្គាល់ថា"ពេលណាមានអ្នកកាសែតល្បីល្បាញណាម្នាក់ស្លាប់ មនុស្សម្នានាំគ្នាសម្តែងសេចក្តីសោកស្តាយ ហើយមានអ្នកខ្លះនៅនឹកឃើញរូបគាត់ជាច្រើនថ្ងៃកន្លងមកទៀតផង"។

ក្នុងន័យនេះហើយ ទើបមូលនិធិ Indochina Media Memorial Foundation (IMMF) ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសថៃ កាលពីឆ្នាំ ១៩៩២ ដើម្បីជាការគោរពវិញ្ញាណក្ខ័ន្ធរបស់អ្នកកាសែតប្រមាណ ៣២០ នាក់ ដែលបានទទួលមរណភាពក្នុងអធិករណ៍ដែលកើតមាននៅឥណ្ឌូចិនតាំងពីក្រោយឆ្នាំ ១៩៤៥ មក។

មូលនិធិ IMMF គ្មានរបៀបវារៈនយោបាយ ហើយក៏គ្មានភាពលម្អៀងសាសនា ពូជសាសន៍ និងសង្គម ទៅខាងណាដែរ។ មូលនិធិនេះទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុពីសំណាក់រដ្ឋាភិបាល អង្គការមិនមែនស្វែងរកផលចំណេញ និងបុគ្គលឯកជនជាច្រើននាក់ ហើយមូលនិធិនេះត្រូវបានគ្រប់គ្រងដោយគណៈនាយកមួយនៅទីក្រុងបាងកក ដែលសមាជិកភាគច្រើន សុទ្ធតែជាអ្នកកាសែតកំពុងធ្វើការ តែពួកគេបានស្ម័គ្រចិត្តចំណាយពេលវេលារបស់ខ្លួនសម្រាប់ជួយមូលនិធិនេះ។ ក្នុងនោះមានការជួយលើកកំពស់ស្តង់ដារអ្នកកាសែត និងស្ថាបនាស្ថានភ្ជាប់ប្រព័ន្ធផ្សព្វផ្សាយនៃប្រទេសទាំងប្រាំជាសមាជិកអ្វី ដែលគេច្រើនហៅថា អាងទន្លេមេគង្គក្រោម ក្នុងនោះ មានប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។

ថ្វីបើប្រទេសទាំងនេះ ត្រូវបានផ្សារភ្ជាប់គ្នាដោយទន្លេមេគង្គ ដែលជាទន្លេធំមួយក្នុងចំណោមទន្លេធំៗជាច្រើនក្នុងលោកនេះក្តី ប្រវត្តិសាស្ត្ររបស់ប្រទេសទាំងនេះ ក្នុងពាក់កណ្តាលទីពីរនៃសតវត្សរ៍ទី ២០ មានភាពខុសគ្នាមែនទែន។ បទពិសោធន៍ជីវិតរបស់ពួកគេមានគ្រប់បែបយ៉ាង រាប់ចាប់ពីអំពើប្រល័យពូជសាសន៍ រហូតដល់សេដ្ឋកិច្ចផុសផុល សោកនាដកម្មពុកចាប់ខ្លោចផ្សារទល់នឹងសេចក្តីសុខដុមរមនា។ តើមានសហគមន៍សារព័ត៌មានណាដែលអាចវិវត្តន៍ចេញពីទិដ្ឋភាពបែបនេះបាន? បើតាមបទពិសោធន៍របស់ IMMF វាពិតជាអាចធ្វើទៅរួច។

តាំងពីឆ្នាំ ១៩៩៤ មក មានសិស្សជាង ២០០ នាក់ ពីតំបន់នេះដែលបានមករៀននៅប្រទេសថៃ ដែលជាមជ្ឈមណ្ឌលប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងបរទេសធំមួយ។ ពួកគេបានទទួលការហ្វឹកហ្វឺនក្នុងវគ្គនីមួយៗ ដែលមានរយៈពេលរហូតដល់ទៅមួយខែ នៅទីក្រុងបាងកក ឈៀងម៉ៃ សុងក្លា និងផ្នែកដទៃទៀតនៃព្រះរាជាណាចក្រនេះ។ មានសិស្សជាង ២០០ នាក់ ផ្សេងទៀត បានឆ្លងកាត់ការហ្វឹក-ហ្វឺននៅក្នុងប្រទេសរបស់ពួកគេតែម្តង។ វគ្គបណ្តុះ-បណ្តាលរបស់ IMMF ធ្លាប់ទាក់ទាញបាននូវនិពន្ធនាយក អ្នកយកព័ត៌មាន ស្មេរ អ្នកផ្សាយតាមរលកធាតុអាកាស និងអ្នកថតរូបជាច្រើននាក់ ហើយវគ្គសិក្សាទាំងនោះបានផ្តោតទៅលើបញ្ហាបរិស្ថាន ធុរកិច្ច សង្គម និងបញ្ហាផ្សេងៗទៀត។

វគ្គបណ្តុះបណ្តាលទាំងនោះ ជាការហ្វឹកហ្វឺនផ្លូវការជាលើកដំបូងសម្រាប់សិស្សខ្លះ ហើយសិស្សដែលរៀនចប់ជាច្រើននាក់បានរៀបរាប់ឲ្យដឹងថា ពេលវេលា ដែលពួកគេបានចំណាយជាមួយនឹងវគ្គរបស់ IMMF ពិតជាបទពិសោធន៍មួយធ្វើឲ្យជីវិតរបស់ពួកគេមានការផ្លាស់ប្តូរមែន។ គ្រូបង្ហាត់ភាគច្រើនរបស់ IMMF ក៏បានធ្វើការសង្កេតប្រហាក់-ប្រហែលគ្នានេះដែរ។ បើទោះជាពួកគេសុទ្ធតែជាអ្នកអាជីពមានបទពិសោធន៍ពេញខ្លួនមកពីប្រទេស

ផ្សេងៗលើពិភពលោកក្តី ក៏ពួកគេចាកចេញទៅដោយពាំនាំយកទៅជាមួយនូវខណិកទស្សន៍សម្បូរបែបថែមទៀត ដែលពួកគេមិនដែលនឹកស្មានដល់ ហើយបើសិនជាពួកគេមិនបានមកប្រឡូកជាមួយសិស្សទាំងនោះ។ កម្មវិធីរបស់ IMMF បានរីកចម្រើនលូតលាស់ក៏ដោយសារតែការរួមរំលែកបទពិសោធន៍បែបនេះ។

អ្នកថតរូបវៀតណាមឈ្មោះ Tran Quang Tuan បាននិយាយដូច្នេះថា "ក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាលរបស់យើង ពួកយើងលែងជាសញ្ជាតិប្រាំផ្សេងគ្នាទៀតហើយ។ យើងស្ថិតក្នុងប្រទេសតែមួយ នោះ គឺទឹកដីរបស់ IMMF"។

សៀវភៅវិធាននេះ ត្រូវបានរៀបរៀងឡើងដោយផ្អែកលើបទពិសោធន៍ដោយឡែកមួយរបស់ IMMF ក្នុងការបណ្តុះបណ្តាលអ្នកសារព័ត៌មាន ដោយលាតត្រដាងគោលគំនិតគ្រឹះក្នុងរបៀបមួយច្បាស់ ហើយសាមញ្ញ។ មិនដូចសៀវភៅជំនួយក្នុងការបណ្តុះ-បណ្តាលផ្សេងទៀត សៀវភៅនេះត្រូវបានផលិតឡើងជាមួយអ្នកសារព័ត៌មានកំពុងប្រកបអាជីព ជាពិសេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះតែម្តង។

យើងមិនដែលគិតថា សៀវភៅនេះជាកិច្ចការស្ពាពរនោះទេ។ យើងគ្រាន់តែសង្ឃឹមថា វានឹងក្លាយជាសេចក្តីពន្យល់សង្ខេបមួយមិនអាចខ្វះបានសម្រាប់សិស្ស IMMF នាពេលអនាគត ហើយសម្រាប់អ្នកណាក៏ដោយ ដែលប្រាថ្នាចង់ក្លាយខ្លួនជាអ្នកសារព័ត៌មាន។ តាមរយៈការបកប្រែជាភាសា ភូមា ខ្មែរ ឡាវ ថៃ និងវៀតណាម សៀវភៅនេះអាចបម្រើជាសំណៅយោងរួមមួយមានអត្ថប្រយោជន៍ ហើយបើទោះជាតិចតួចក្តី និងជួយបង្កើននូវចំណងអាជីពយូរអង្វែងនៅក្នុងតំបន់មួយ ដែលបច្ចុប្បន្នស្ថិតក្នុងសន្តិភាពស្ទើរតែទាំងស្រុងហើយនោះ។

**DENIS GRAY** និង **DOMINIC FAULDER**
*សហប្រធានរបស់ IMMF*

អ្នកស្រី **SARAH MCLEAN**
*ប្រធានគម្រោងរបស់ IMMF*

បាងកក ខែធ្នូ ឆ្នាំ២០០១

# សេចក្តីផ្តើម

នេះជាដំណាក់កាលមួយគួរឲ្យរំភើប និងចង់ធ្វើជាអ្នកសារព័ត៌មាននៅតំបន់អាស៊ីអាគ្នេយ៍។ កាលៈទេសៈនយោបាយ សេដ្ឋកិច្ច និងសង្គម កំពុងតែវិវត្តន៍ផ្លាស់ប្តូរយ៉ាងរហ័ស។ ប្រទេសនានាកំពុងអភិវឌ្ឍន៍ ហើយជីវភាពរស់នៅ ក៏កំពុងតែមានភាពស្មុគស្មាញជាងមុន។ មនុស្សម្នាត្រូវការព័ត៌មាន ដែលមានភាពជាក់លាក់ ទាន់ពេលវេលា និងស៊ីជម្រៅ ដើម្បីឲ្យពួកគេយល់បានអំពីការផ្លាស់ប្តូរទាំងអម្បាលមាណនោះ និងធ្វើឲ្យជីវភាពរបស់ពួកគេកាន់តែប្រសើរជាងមុន។ ដូច្នេះពួកគេពឹងអាស្រ័យលើអ្នកសារព័ត៌មានឲ្យផ្តល់ព័ត៌មានដល់ពួកគេ។

តែជាអកុសល វិស័យសារព័ត៌មាននៅក្នុងតំបន់នេះ មិនសូវជាមានការវិវឌ្ឍវែងឆ្ងាយប៉ុន្មានទេ ដោយសារតែវិវាទស៊ីវិល សង្គ្រាម ភាពក្រីក្រ និងភាពឯកោ។

នៅមានសេចក្តីត្រូវការច្រើនទៀត ឲ្យមានការបណ្តុះបណ្តាលអ្នកសារព័ត៌មាន និងសម្ភារៈសិក្ខាបករណ៍សម្រាប់ការបណ្តុះបណ្តាល ដែលសមនឹងតម្រូវការរបស់អ្នកសារព័ត៌មាននៅតំបន់អាស៊ីអាគ្នេយ៍។ សម្ភារៈសិក្ខាបករណ៍ដែលមានបច្ចុប្បន្នច្រើនបានមកពីសហរដ្ឋអាមេរិក និងពីបណ្តាបស្ចិមប្រទេស។ សិក្ខាបករណ៍ទាំងនោះ វាទាក់ទិនទៅនឹងស្ថានភាពរបស់ប្រទេសទាំងនោះច្រើនជាងតំបន់អាស៊ីអាគ្នេយ៍ ហើយសុទ្ធតែជាភាសាអង់គ្លេសដែលពិបាកយល់ដល់អ្នកមិនចេះភាសាបរទេស។

ដោយសារហេតុនេះហើយ ទើប Indochina Media Memorial Foundation ផលិតសៀវភៅវិធាននេះឡើង។

យើងនាំគ្នាតាក់តែងវិធាននេះ ជាពិសេស គឺសម្រាប់អ្នកសារព័ត៌មាននៅក្នុងប្រទេសទាំងប្រាំរបស់ IMMF។ យើងប្រើភាសាអង់គ្លេសសាមញ្ញ ហើយច្បាស់ជាមួយនឹងឧទាហរណ៍ជាក់ស្តែងពីបណ្តាញសារព័ត៌មានក្នុងស្រុក ទាំងជាភាសាអង់គ្លេស និងភាសាកំណើត។ យើងផ្តោតទៅលើកំហុសទាំងឡាយ ដែលអ្នកសារព័ត៌មានក្នុងស្រុកបានប្រព្រឹត្ត។ ជាមួយគ្នានេះ យើងក៏យកមកពិចារណាផងដែរ នូវលក្ខខណ្ឌនយោបាយ សង្គម និងសេដ្ឋកិច្ចក្នុងប្រទេស ដែលអ្នកសារព័ត៌មានទាំងនោះកំពុងធ្វើការ។

សៀវភៅនេះនិយាយអំពីគោលការណ៍ជាមូលដ្ឋាននៃរបៀបប្រមូល និងសរសេរព័ត៌មាន។ យើងរៀបរៀងសៀវភៅនេះជាចម្បងសម្រាប់អ្នកសារព័ត៌មានបោះពុម្ពដែលផ្សាយដំណឹងទូទៅ។ ប៉ុន្តែគោលការណ៍ជារួមក្នុងសៀវភៅនេះ ក៏អាចយកទៅប្រើបានក្នុងសារព័ត៌មានផ្សាយតាមរលកធាតុអាកាសបានផងដែរ។

គោលការណ៍ខ្លះក្នុងសៀវភៅនេះ អាចខុសគ្នាពីអ្វី ដែលអ្នកសារព័ត៌មានអាស៊ីអាគ្នេយ៍មានទម្លាប់ជាមួយរួចមកហើយ។ ប៉ុន្តែវាសុទ្ធតែជាគោលការណ៍ដែលអ្នកសារព័ត៌មានល្អៗលើពិភពលោកយកមកប្រតិបត្តិ។ ប្រហែលជាអ្នកទាំងអស់គ្នាមិនអាចធ្វើតាមគោលការណ៍ទាំងអស់នេះបានទេនៅក្នុងអង្គភាពរបស់ខ្លួននាពេលនេះ។ ប៉ុន្តែបើលោកអ្នកធ្វើតាមគោលការណ៍ណាដែលអាចប្រើបាន លោកអ្នកនៅតែអាចក្លាយខ្លួនជាអ្នកសារព័ត៌មានដ៏ប្រពៃជាមិនខាន មិនថាលោកអ្នកធ្វើការនៅកន្លែងណានោះឡើយ។

ក្នុងសៀវភៅនេះ យើងបានប្រើនូវសម្រង់ខ្លីៗពីសៀវភៅផ្សេងៗជាច្រើននៅក្នុងតំបន់នេះ។ យើងរក្សាទុកនូវស្ទីលសរសេរ និងរបៀបប្រើរបស់វាក្នុងទម្រង់ដើមដដែល។ ស្ទីល និងរបៀបប្រើរបស់វាអាចមិនមានសង្គតិភាពជាមួយនឹងស្ទីល និងរបៀបប្រើដែលយើងបានប្រកាន់យកសម្រាប់សៀវភៅនេះ។

ជាសំណូមពររបស់យើង អ្នកសារព័ត៌មានទាំងឡាយ គួររៀនពីរសៀវភៅនេះ ដើម្បីត្រៀមខ្លួនជាមុនសម្រាប់វគ្គបណ្តុះបណ្តាល ដែលធ្វើឡើងដោយ IMMF និងក្រុមផ្សេងទៀត។ ភាគច្រើននៃវគ្គបណ្តុះបណ្តាលទាំងនោះ ផ្តោតលើការយកព័ត៌មានអំពីប្រធានបទពិសេសៗ ដូចជាធុរកិច្ច និងបរិស្ថានជាដើម។ លោកអ្នកនឹងត្រងត្រាប់បានច្រើនពីវគ្គទាំងនោះ ប្រសិនបើលោកអ្នករៀនអំពីគោលការណ៍ជាមូលដ្ឋានរបស់វិស័យសារព័ត៌មានជាមុនសិន។

ដូចគ្នាដែរ គ្រូអាចប្រើសៀវភៅវិធាននេះបានក្នុងការបង្រៀននៅសាលា និងសាកលវិទ្យាល័យ។ និពន្ធនាយក ក៏អាចប្រើវាក្នុងអង្គភាពរបស់ខ្លួនបានផងដែរ។

ក៏ប៉ុន្តែសៀវភៅនេះ មិនទាន់អាចជាសៀវភៅដែលមានលក្ខណៈពេញលេញជាស្ថាពរនោះទេ។ ក្នុងនេះ យើងនិយាយតែអំពីគោលការណ៍មូលដ្ឋានតែប៉ុណ្ណោះ។ របៀបសរសេររឿងមានច្រើនយ៉ាង។ ក្នុងវិធានទូទៅ ក៏មានករណីលើកលែងច្រើនដែរ។ យើងសំណូមពរថា អ្នកទាំងអស់គ្នាប្រើប្រាស់សៀវភៅនេះ ដោយមានជំនួយពីសំណាក់និពន្ធនាយក ឬក៏គ្រូ ហើយជាមួយនឹងការពិភាក្សា និងអនុវត្តឲ្យបានច្រើនផង។

ចាប់ផ្តើមឡើងយើងពិពណ៌នាអំពីថា តើអ្នកសារព័ត៌មានធ្វើអ្វី ហើយថាតើគុណធម៌ធ្វើខ្លួនឲ្យក្លាយជាអ្នកសារព័ត៌មានល្អប្រពៃនោះ មានអ្វីខ្លះទៅ។ បន្ទាប់មកទៀត យើងនិយាយអំពីថាតើពួកគេរកគំនិតសរសេររឿងរបៀបម៉េច ហើយប្រមែប្រមូលព័ត៌មានដោយវិធីណា ដើម្បីយកមកសរសេរចេញជារឿង។ បន្ទាប់ យើងនិយាយទៅដល់ដំណើរការក្នុងការសរសេរ ជាពិសេសតើធ្វើសេចក្តីផ្តើម និងរៀបរៀងសាច់រឿងដោយវិធីណា។ បន្ទាប់ពីនោះ គឺមានជំពូកនានា ដែលមានប្រយោជន៍ដល់អ្នកសារព័ត៌មានក្នុងតំបន់នេះ ដូចជា ការប្រើសម្រង់សម្តីដើម តើលៃលកជាមួយសេចក្តីប្រកាសព័ត៌មានរបៀបម៉េច ការយកព័ត៌មាននៅសន្និសីទសារព័ត៌មាន សុន្ទរកថា និងកិច្ចប្រជុំ។ ជំពូកមួយស្តីអំពីរបៀបសរសេរឲ្យបានល្អ ពន្យល់អំពីវិធីបង្ហាញព័ត៌មានឲ្យលេចធ្លោ។ ក្រៅពីនោះ យើងពន្យល់ពីភាពខុសគ្នារវាងការសរសេរសម្រាប់សារព័ត៌មានបោះពុម្ព និងការសរសេរសម្រាប់ការផ្សាយតាមវិទ្យុ និងទូរទស្សន៍។

ប៉ុន្តែការងារជាអ្នកសារព័ត៌មាន វាទៅហួសពីការប្រមូល និងសរសេរដំណឹងទៅទៀត។ ហេតុដូច្នេះហើយ បានជាយើងបញ្ចូលជំពូកសំខាន់មួយស្តីអំពីក្រមសីលធម៌។ នៅចុងបញ្ចប់ នៅពេលដែលយើងសម្លឹងទៅអនាគត ភាពប្រឈមមួយក្នុងបំណោមភាពប្រឈមជាច្រើនសម្រាប់អ្នកសារព័ត៌មាននៅក្នុងតំបន់នេះ គឺការដេញតាមឲ្យទាន់ប្រទេសដទៃទៀត ក្នុងការប្រើប្រាស់ធនធានព័ត៌មានដ៏អស្ចារ្យនៅលើអ៊ិនធឺណិត។

យើងសូមថ្លែងអំណរគុណដល់ **International Center for Journalists** និង **John S. and James L. Knight Foundation** ដែលបានឧបត្ថម្ភដល់ការងាររបស់លោក Jeff Hodson នៅក្នុងការរៀបរៀងសៀវភៅនេះ ហើយក៏សូមថ្លែងអំណរគុណផងដែរដល់ **Freedom Forum** ដែលបានគាំទ្រដល់ការងាររបស់ លោក Peter Eng។ យើងសូមដឹងគុណជាអនេកដល់ **Friedrich-Ebert-Stiftung (Friedrich Ebert Foundation)** របស់ប្រទេសអាល្លឺម៉ង់ និង **United States Infomration Service** ប្រចាំប្រទេសថៃ ដែលបានផ្តល់មូលនិធិសម្រាប់ថ្លៃបោះពុម្ពសៀវភៅនេះ។

យើងទាំងពីរនាក់ ក៏ជាអ្នកសារព័ត៌មានដូចលោកអ្នកទាំងអស់គ្នាដែរ។ បរិយាយដូច្នេះ មានន័យថា យើងជឿថា វានៅតែមានកន្លែងដែលយើងអាចធ្វើឲ្យមានភាពប្រសើរឡើងថែមទៀតនៅក្នុងសៀវភៅនេះ។

យើងចង់ឲ្យសៀវភៅនេះមានអត្ថប្រយោជន៍ច្រើនតាមតែអាចធ្វើទៅបាន។ សូមទាក់ទងមកយើងទាំងពីរនាក់នៅ IMMF បើសិនជាលោកអ្នកមានអត្ថាធិប្បាយ ឬក៏សំណើអ្វី ដែលអាចជួយធ្វើឲ្យសៀវភៅនេះ កាន់តែប្រសើរជាងមុន។

**PETER** ENG
*Independent Journalist*

**JEFF HODSON**
*Knight Fellow*

*Bangkok, December 2001*

# សេចក្តីបន្ថែម

## *បោះពុម្ពលើកទីពីរ ឆ្នាំ ២០០៩*

*វិធានជាមូលដ្ឋានស្តីពីការប្រមូល និងសរសេរដំណឹង*របស់ IMMF មិនយូរប៉ុន្មានក៏បានក្លាយជាជំនួយការសម្រាប់ការបង្រៀនមួយ ដែលមិនអាចខ្វះបាន។ វាត្រូវបានអង្គការជាច្រើនប្រើសម្រាប់បង្កើនស្តង់ដារវិស័យសារព័ត៌មាននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយជួនកាលនៅឆ្ងាយក្រៅពីតំបន់ថែមទៀតផង។ ជារឿយៗ សិស្សទាំងឡាយរបស់ IMMF ដែលនឹងត្រូវចូលរួមវគ្គបណ្តុះបណ្តាលក្នុងតំបន់ តែងបានទទួលជាមុននូវសៀវភៅនេះ ដើម្បីជាជំនួយដល់ការត្រៀមពួកគេ មុនមានការពិភាក្សានៅក្នុងថ្នាក់រៀន។ សៀវភៅនេះក៏ត្រូវបានបកប្រែជាភាសានានានៅក្នុងអាស៊ីអាគ្នេយ៍នេះដែរ ជាពិសេសភាសា ភូមា ខ្មែរ ឡាវ ថៃ និងវៀតណាម ដែលទាំងអស់នេះអាចទាញយកបានតាមអាសយដ្ឋាន http://www.immf.or.th/download/manual.aspx

កាលពីចុងឆ្នាំ ២០០៨ លោក Jeff Hodson បានធ្វើការពិនិត្យសើរើឡើងវិញទាំងស្រុងនូវខ្លឹមសាររបស់សៀវភៅនេះ ហើយធ្វើបច្ចុប្បន្នភាពនូវរាល់កន្លែងណាដែលអាចធ្វើទៅបាន។ បន្ទាប់មកសៀវភៅនេះ ត្រូវបានធ្វើរចនាបទឡើងវិញ ហើយរូបភាពមួយចំនួន ក៏ត្រូវបានធ្វើការផ្លាស់ប្តូរផងដែរ។ កិច្ចការកែសម្រួលធ្វើបច្ចុប្បន្នភាពនេះ បានទទួលមូលនិធិគាំទ្រពី **The Open Society Network Media Programme** និង **The McGee Foundation** ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក។

**DOMINIC FAULDER**
*Editor, IMMF Journalism Training Manuals*
*Co-President, IMMF, 1994-2008*

Bangkok, May 2009

# សន្ទានុក្រម

***សេចក្តីនិទានខ្លី*** *(Anecdote)*

ជាសេចក្តីដំណាលរឿងអង្គហេតុខ្លីៗនៅក្នុងបទពិពណ៌នា។ តាមធម្មតា វាមានតែប៉ុន្មានកថាខណ្ឌទេ ដែលឆ្លុះបញ្ចាំងអំពីចំណុចគំនិតសំខាន់ៗដែលអ្នកសរសេរចង់និយាយ។

***មុំ*** *(Angle)*

ជារបៀប ឬចំណុចទស្សនៈជាក់លាក់មួយក្នុងការសរសេររឿង។ ព្រឹត្តិការណ៍ខ្លះអាចមានទិដ្ឋភាពគួរចាប់អារម្មណ៍ប្រហាក់ប្រហែលគ្នាច្រើន ហើយអ្នកសារព័ត៌មានអាចជ្រើសរើសយកទិដ្ឋភាពណាមួយក្នុងចំណោមទិដ្ឋភាពទាំងនោះ មកធ្វើជាចំណុចផ្តោតការសរសេររបស់គេ។

***ប្រភពអនាមិក*** *(Anonymous source)*

ជាប្រភពដែលផ្តល់ព័ត៌មានតែក្នុងករណីដែលអ្នកយកព័ត៌មានមិនបង្ហាញឈ្មោះរបស់ពួកគេ ទោះប្រុសក្តី ស្រីក្តី នៅក្នុងអត្ថបទរឿង។

***បន្ទុកព័ត៌មាន*** *(Attribution)*

ជាវិធីដែលអ្នកសារព័ត៌មានពិពណ៌នាអំពីប្រភពរបស់សម្តីដើម ឬព័ត៌មាននៅក្នុងអត្ថបទរឿង។

***សាវតារ*** *(Background)*

ជាព័ត៌មាននៅក្នុងរឿង ដែលប្រាប់អ្នកអាននូវអ្វីដែលបានកើតឡើងពីអតីតកាល ហើយដែលនៅមានទំនាក់ទំនងជាមួយនឹងព្រឹត្តិការណ៍ ដែលកំពុងតែត្រូវបានគេរាយការណ៍នៅក្នុងរឿងនាបច្ចុប្បន្ន។ សាវតារជួយអ្នកអានឲ្យកាន់តែយល់សាច់រឿងបានកាន់តែច្បាស់ឡើង។

***តុល្យភាព និងភាពទៀងត្រង់***

*(Balance and Fairness)*

ជាលក្ខណៈសម្បត្តិមានសារៈសំខាន់សម្រាប់រឿងល្អមួយ គឺជាអ្នកយកព័ត៌មានប្រាប់ដល់អ្នកអាននូវជ្រុងទាំងសងខាងនៃបញ្ហាដោយមិនលម្អៀងទៅខាងភាគីណាមួយ។

***តួសេចក្តី*** *(Body)*

ជាផ្នែកធំមួយរបស់អត្ថបទដំណឹង ដែលក្នុងនោះមានសេចក្តីលម្អិត សម្តីដើម និងជាតុផ្សំផ្សេងទៀត។

***បរិបទ*** *(Context)*

ជាព័ត៌មានក្នុងសាច់រឿង ដែលប្រាប់ដល់អ្នកអាននូវស្ថានភាពទូទៅបច្ចុប្បន្ន ដែលមានទំនាក់ទំនងជាមួយនឹងព្រឹត្តិការណ៍ កំពុងត្រូវបានរាយការណ៍នៅក្នុងរឿងនោះ។

***វិចារណកថា*** *(Editorial)*

ជាអត្ថបទ ដែលក្នុងនោះ អ្នកសរសេរបង្ហាញនូវមតិរបស់ខ្លួន ឬក៏យោបល់របស់កាសែតមួយថាតើបញ្ហា ឬរឿងមួយ នឹងវាល្អ ឬអាក្រក់។ ក្នុងបណ្តាកាសែតដែលទទួលបានការគោរពច្រើន គេញែកបទវិចារណកថាចេញពីអត្ថបទដំណឹង ហើយគេចុះផ្សាយវានៅលើអ្វី ដែលគេហៅថា ទំព័រវិចារណកថា។

***បម្រាមផ្សាយមុនកាលបរិច្ឆេទ*** *(Embargo)*

ជាបម្រាមការផ្សាយនូវសេចក្តីប្រកាសព័ត៌មាន ឬរបាយការណ៍មួយមុនថ្ងៃ ឬម៉ោងកំណត់។ ក្នុងករណីនេះ អ្នកសារព័ត៌មានត្រូវបានគេឲ្យឯកសារជាមុន (ដូចជាពង្រាងសុន្ទរកថាសំខាន់ៗ) មុននឹងការបញ្ចេញជាផ្លូវការរបស់វាក្នុងលក្ខខណ្ឌថា ពួកគេនឹងមិនយកទៅចុះផ្សាយមុនកាលបរិច្ឆេទ។

**បទពិពណ៌នា** ( *Feature*)

ជាអត្ថបទមានលក្ខណៈជូនព័ត៌មាន (informative) និងកំសាន្ត (entertaining) ដែលមិនចាំបាច់ជាប់ទាក់ទិននឹងព្រឹត្តិការណ៍ណាមួយដែលទើបនឹងកើតឡើងនោះទេ ហើយជាធម្មតាអត្ថបទប្រភេទនេះ ត្រូវការការស្រាវជ្រាវច្រើន។

**រឿងចំណាប់អារម្មណ៍ មនុស្សជាតិ**
*(Human interest)*

ជាព្រឹត្តិការណ៍ ឬស្ថានការណ៍ណាមួយដែលអាចមានឥទ្ធិពលលើមនោសញ្ចេតនារបស់អ្នកអាន។

**ពីរ៉ាមីដផ្ការ** *(Inverted pyramid)*

ជាគ្រោងរបស់រឿង ដែលក្នុងនោះ ព័ត៌មានដែលសំខាន់ជាងគេ ត្រូវបានដាក់នៅលើគេបំផុត (ឬសេចក្តីផ្តើម) បន្តដោយព័ត៌មានដែលទ្រទ្រង់ដល់សេចក្តីផ្តើមនោះ និងព័ត៌មានដែលមានសារៈសំខាន់បន្ទាប់បន្សំផ្សេងទៀត។

**ពាក្យឯកទេស** *(Jargon)*

ជាពាក្យពិសេសប្រើដោយក្រុមមនុស្សដែលមានការងារដូចគ្នា ដូចជាមន្ត្រីរដ្ឋាភិបាល សេដ្ឋវិទូ និងអ្នកសារព័ត៌មាន។ មនុស្សទូទៅមិនសូវយល់ពាក្យទាំងនោះទេ។

**សេចក្តីផ្តើម** *(Lead)*

ជាក្បាលរបស់អត្ថបទ។ សេចក្តីផ្តើមត្រង់នាំអ្នកអានទៅដល់ចំណុចចម្បងរបស់សាច់រឿងភ្លាមគ្មានដំអក់ទេ។ ភាគច្រើននៃដំណឹងព្រឹត្តិការណ៍ចាប់ផ្តើមដោយសេចក្តីផ្តើមត្រង់។ សេចក្តីផ្តើមដំអក់នាំអ្នកអានទៅដល់ចំណុចសំខាន់ និងសាច់រឿង បន្ទាប់ពីអ្នកសរសេរបង្ហាញនូវឧទាហរណ៍ ឬសេចក្តីដំណាលខ្លីៗ ឬក៏រៀបរាប់ឆាកសិន។ ភាគច្រើននៃបទពិពណ៌នាប្រើសេចក្តីផ្តើមដំអក់។

**ដំណឹង** *(News)*

ជារឿងស្តីអំពីព្រឹត្តិការណ៍ ដែលទើបនឹងកើតឡើង ហើយគួរត្រូវបានរាយការណ៍ជូនអ្នកអានភ្លាមៗតែម្តង។ ជួនកាលគេហៅវាថា "ដំណឹងទាន់ហេតុការណ៍" ឬ "ដំណឹងភ្លាមៗ" ។

**បទពិពណ៌នាដំណឹង** *(News feature)*

ជារឿងដែលកសាងឡើងលើព្រឹត្តិការណ៍ ដោយប្រើតិចនិកសរសេរបទពិពណ៌នា រួមបញ្ចូលដោយចំណុចចាប់អារម្មណ៍មនុស្សជាតិ។

**កម្មវិស័យភាព** *(Objectivity)*

ជាលក្ខណៈសម្បត្តិសំខាន់សម្រាប់រឿងល្អមួយ គឺអ្នកយកព័ត៌មានទុកយោបល់ និងអារម្មណ៍ផ្ទាល់ខ្លួន ដោយឡែកពីសាច់រឿងតាមតែអាចធ្វើទៅបាន ហើយរៀបរាប់ជូនអ្នកអានតែអង្គហេតុតែប៉ុណ្ណោះ។

**ក្នុងកំណត់ត្រា** *(On the record)*

ការរៀបរាប់ព័ត៌មានពីសំណាក់ប្រភពមួយ ដែលប្រភពនោះយល់ព្រមថា អាចប្រើប្រាស់បាននៅក្នុងសាច់រឿង ហើយដាក់បន្ទុកទៅលើពួកគេវិញដោយចំហ។

**ក្រៅកំណត់ត្រា** *(Off the record)*

ការរៀបរាប់ព័ត៌មានពីសំណាក់ប្រភពមួយ ដែលប្រភពនោះ មិនចង់ឲ្យគេយកទៅចុះផ្សាយ ឬយល់ព្រមឲ្យគេយកទៅចុះផ្សាយដែរ តែភ្ជាប់ជាមួយការដាក់កំហិតលើការដាក់បន្ទុកព័ត៌មាន។

***សម្រង់សម្ដីដើម***

*(Quotation)*

ជាពាក្យពេចន៍ដើម សុទ្ធសាធ ដែលប្រភពមួយ បាននិយាយពេលដែល គេធ្វើសុន្ទរកថា ឬផ្ដល់ បទសម្ភាសន៍។ តាមធម្មតា ពាក្យពេចន៍ដើមបែបនេះ ត្រូវប្រើដោយដាក់ក្នុង បន្ទោះអព្ភន្តរសញ្ញានៅ ក្នុងអត្ថបទដំណឹង ឬ បទពិពណ៌នា។



*ចូរគិតដោយប្រយ័ត្នប្រយែងអំពីពាក្យពេចន៍ដែលអ្នកយកមកប្រើ*

***ហើយវាយ៉ាងម៉េច?***

*(So what?)*

ឃ្លានេះមានន័យ គ្រើនរម្លឹកអ្នកយកព័ត៌មាន ឲ្យបញ្ចូលក្នុងរឿងរបស់ពួកគេនូវសារៈសំខាន់នៃ ព្រឹត្តិការណ៍ដំណឹង ឬបទពិពណ៌នារបស់ពួកគេ។ ឃ្លានេះជួយប្រាប់ដល់អ្នកអានថា ហេតុអ្វីពួកគេគួរ ខ្វល់នឹងរឿងនោះ ហើយថា តើរឿងនោះ វាអាចមាន ឥទ្ធិពលមកលើមនុស្សម្នាដូចម្ដេចខ្លះទៅ។

***ការផ្ទៀងផ្ទាត់*** *(Verification)*

ជាបណ្ដាជំហានទាំងឡាយ ដែលអ្នកយក ព័ត៌មានធ្វើ ដើម្បីធានាឲ្យបានថា ព័ត៌មានដែល ប្រភពមួយផ្ដល់ឲ្យនោះមានសច្ចៈ។ ការផ្ទៀងផ្ទាត់ នោះ អាចមានការសង្កេត ការនិយាយជាមួយប្រភព ដទៃទៀត ឬក៏ការពិនិត្យមើលឯកសារ។

# ភាគទី ១

*មូលដ្ឋានគ្រឹះនៃវិស័យសារព័ត៌មាន*

# ជំពូកទី ១ អ្នកសារព័ត៌មាន និងដំណឹង

## តួនាទីរបស់អ្នកសារព័ត៌មាន

អ្នកសារព័ត៌មានជាអ្នកប្រកបនូវមុខងារមួយក្នុងចំណោមមុខងារសំខាន់ៗជាច្រើននៅក្នុងសង្គម។

ប៉ុន្តែលក្ខខណ្ឌរបស់ពួកគេមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ នៅក្នុងប្រទេសខ្លះ រដ្ឋាភិបាល ឬក៏គណបក្សជាម្ចាស់កម្មសិទ្ធិនៃប្រព័ន្ធផ្សព្វផ្សាយ។ នៅប្រទេសដទៃ បុគ្គល ឯកជន ឬក៏ក្រុមហ៊ុន គឺជាម្ចាស់កម្មសិទ្ធិលើប្រព័ន្ធផ្សព្វផ្សាយ។ ក្នុងប្រទេសជាច្រើន គឺមានទិដ្ឋភាពលាយឡំគ្នាទាំងពីរនេះតែម្តង។

មិនថាស្ថានភាពរបស់ពួកគេយ៉ាងណានោះទេ អ្នកសារព័ត៌មានល្អៗទាំងឡាយ មានបេសកកម្មជាមូលដ្ឋានរួមមួយ។ ពួកគេផ្តល់ឲ្យមនុស្សទូទៅនូវព័ត៌មាន ដែលពួកគេត្រូវការចាំបាច់សម្រាប់យល់ដឹងអំពីពិភពលោកដែលនៅជុំវិញខ្លួនពួកគេ និងដើម្បីធ្វើសេចក្តីសម្រេចក្នុងជីវិតរបស់ខ្លួន។ ប្រជាជនពឹងពាក់លើអ្នកសារព័ត៌មានក្នុងការទទួលបានព័ត៌មានអំពីសហគមន៍របស់ពួកគេ អំពីរដ្ឋាភិបាល ធុរកិច្ច កីឡា សុខភាព និងអំពីអ្វីផ្សេងៗទៀត។ ជាមួយនឹងព័ត៌មានបែបនេះ ពួកគេអាចធ្វើការសម្រេចចិត្តបានថា តើស្អីដែលពួកគេចង់មើលលើកញ្ចក់ទូរទស្សន៍ អ្វីដែលពួកគេចង់ហូប ទោចក្រយានយន្តប្រភេទណាដែលត្រូវទិញ តើត្រូវបញ្ជូនកូនរបស់ពួកគេទៅរៀននៅសាលាណា ហើយថាតើអ្នកណាដែលពួកគេគួរបោះឆ្នោតឲ្យនារដូវបោះឆ្នោតពេលខាងមុខ។

ពេលខ្លះ ព័ត៌មានក៏មានសារៈសំខាន់រស់ស្លាប់ផងដែរ។ នាចុងឆ្នាំ ២០០៤ ជីវិតរាប់សិបពាន់នាក់ប្រហែលជាត្រូវគេអាចសង្គ្រោះបាននៅប្រទេសថៃ និងនៅប្រទេសដទៃទៀត បើសិនជាបណ្តាញសារព័ត៌មានបានដឹងមុនបន្តិចថា នឹងមានរលកស៊ូណាមិ កំពុងបោកបក់ក្នុងមហាសាគរឥណ្ឌា។ បួនឆ្នាំក្រោយមកទៀត សេចក្តីប្រកាសស្រដៀងនេះក៏ប្រហែលជានឹងអាចសង្គ្រោះបានជីវិតមនុស្សឲ្យរួចផុតពីព្យុះស៊ីក្លូនណាហ្គីស ដែលបានបក់បោកមកលើតំបន់ដីសណ្តអៀរ៉ាវ៉ាឌី នៅប្រទេសមីយ៉ានម៉ា។ ក្នុងន័យនេះ អ្នកព្យាករណ៍អាកាសធាតុត្រូវការប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ឲ្យជួយផ្សាយសាររបស់ពួកគេទៅកាន់មនុស្សម្នាគ្រប់ៗរូបឲ្យបានឆាប់ និងប្រកបដោយប្រសិទ្ធភាពបំផុត។

ដោយសារថាមនុស្សច្រើនណាស់ដែលអាន ឬក៏ស្តាប់រឿងរបស់ពួកគេ អ្នកសារព័ត៌មានត្រូវតែមានការទទួលខុសត្រូវ។ *កាតព្វកិច្ចដំបូងបង្អស់របស់អ្នកសារព័ត៌មានល្អប្រពៃម្នាក់ គឺមានបំពោះប្រជាជន។*

ចូរយើងនាំគ្នាត្រិះរិះអំពីនិយមន័យខាងក្រោមនេះ ដែលផ្តល់ដោយអ្នកសារព័ត៌មានពីប្រទេសវៀតណាម កម្ពុជា ថៃ ឡាវ និងមីយ៉ាន់ម៉ា អំពីតួនាទីរបស់អ្នកសារព័ត៌មាន ៖

- ស្វែងរកសច្ចភាព
- ធ្វើជាស្ពានរវាងរដ្ឋាភិបាល និងប្រជាជន
- ផ្តល់ព័ត៌មានអំពីបញ្ហាថ្មីៗដល់ប្រជាជន
- ផ្តល់ការអប់រំ កំសាន្ត និងពន្យល់
- ការពារផលប្រយោជន៍របស់ពលរដ្ឋ
- ផ្ទៀងផ្ទាត់ព័ត៌មាន
- សរសេររឿងដែលជាទីចំណាប់អារម្មណ៍
- សរសេរសម្រាប់អ្នកអាន តែមិនមែនសម្រាប់ប្រភពព័ត៌មានទេ

# សារៈសំខាន់នៃអ្នកអាន

មានអ្នកសារព័ត៌មានច្រើនអ្នកណាស់ ដែលតែងភ្លេចគិតអំពីអ្នកអានរបស់គេ។ ផ្ទុយទៅវិញ ពួកគេច្រើនតែសរសេរ ដើម្បីបំពេញចិត្តនាយកនិពន្ធរបស់ពួកគេ ឬ "ប្រភព" គឺក្រុមមនុស្សដែលពួកគេទទួលបានព័ត៌មានសម្រាប់សរសេររឿង ក្នុងនោះ មានមន្ត្រីរដ្ឋាភិបាលផង។ អ្នកសារព័ត៌មានជាច្រើនធ្វើដូច្នេះ ដោយគេជួបនាយកនិពន្ធ និងប្រភពរបស់ពួកគេរៀងរាល់ថ្ងៃ។ ពួកគេចង់តម្រូវចិត្តអ្នកទាំងនោះ។ ប៉ុន្តែបើអ្នកសារព័ត៌មានសរសេរសម្រាប់តែនិពន្ធនាយក និងប្រភពរបស់ខ្លួនពួកគេមានទំនោរដាក់បញ្ចូលក្នុងអត្ថបទរបស់គេ តែសេចក្ដីលម្អិតក្បោះ-ក្បាយទាំងឡាយណា ដែលនិពន្ធនាយក និងប្រភពរបស់គេចង់ឃើញតែប៉ុណ្ណោះ។ ក្នុងករណីនេះ រឿងនឹងមិនមានសារធាតុ និងការពន្យល់នានា ដែលអ្នកអានទូទៅត្រូវការនោះទេ។

អ្នកសារព័ត៌មានបំណានៗ មិនដែលភ្លេចទេថា គេសរសេរសម្រាប់អ្នកណានោះ។ កាសែតប្រចាំថ្ងៃដែលបោះពុម្ពផ្សាយច្រើនច្បាប់ ដូចជាកាសែតឈ្មោះ Thai Rath (រដ្ឋថៃ) ក្នុងប្រទេសថៃមានអ្នកអានច្រើនប្រភេទ ដូចជា មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ធុរកិច្ចមានស្តុកស្តម្ភ អ្នករត់តាក់ស៊ី អ្នកលក់បន្លែត្រីក្រ។ កាសែត Thai Rath នេះចុះផ្សាយព័ត៌មានច្រើនប្រភេទណាស់ ស្តីអំពីសេដ្ឋកិច្ច នយោបាយ និងសង្គម។ អ្នកសារព័ត៌មានរបស់វាព្យាយាមសរសេរក្នុងរបៀបមួយច្បាស់ ហើយសាមញ្ញ ដើម្បីឲ្យអ្នកអានងាយយល់។

ផ្ទុយពីនេះវិញ អ្នកសារព័ត៌មានរបស់ទស្សនាវដ្ដីវប្បធម៌ប្រជាប្រិយ និងកំសាន្តមួយ តួយ៉ាងទស្សនា-វដ្ដីប្រជាប្រិយនៅប្រទេសកម្ពុជាដឹងថា ភាគច្រើននៃអ្នកអានរបស់គេ គឺជាយុវវ័យដែលមានចំណាប់អារម្មណ៍ជាមួយនឹងការបង្ហាញម៉ូត តូរ្យតន្ត្រី តារាភាពយន្ត។ ដូច្នេះពួកគេផ្តោតទៅលើកម្មវត្ថុទាំងអស់នេះ ហើយសរសេរអំពីវាក្នុងស្ទីលកំសាន្ត។ ពួកគេមិនផ្តោតទៅលើរឿងនយោបាយ និងរដ្ឋាភិបាលប៉ុន្មានទេ។



*អាពីនោក់នេះពិតជាមិនខាំទេ*

អ្នកសរសេរសម្រាប់សារព័ត៌មានជាភាសាអង់គ្លេសឈ្មោះ *Vietnam Investment Review* ផ្តោតទៅលើរឿងអំពីធុរកិច្ច និងហិរញ្ញវត្ថុសម្រាប់វិនិយោគិននៅក្រៅស្រុក។ នេះបានន័យថា គេស្គាល់ច្បាស់ណាស់ថា អ្នកណាជាសវនជនរបស់ពួកគេ។

អ្នកសារព័ត៌មានចំណានក៏ដឹងខ្លួនដែរថា ពួកគេត្រូវតែជាអ្នកដំណាលរឿងចំណានផងដែរ។ បើពួកគេមិនបង្ហាញព័ត៌មានតាមរបៀបមួយគួរឲ្យចាប់អារម្មណ៍នោះទេ ជនានុជនទាំងឡាយនឹងមិនអានរឿងរបស់គេឡើយ។

## លក្ខណៈសម្បត្តិនៃអ្នកសារព័ត៌មានល្អ

អ្នកសារព័ត៌មានអាជីព គឺជាមនុស្សដែល ៖

- សួរសំណួរច្រើន
- មានតុល្យភាព និងត្រឹមត្រូវមិនលម្អៀងក្នុងការសរសេរ
- ជាមនុស្សគួរទុកចិត្តបាន ហើយទទួលខុសត្រូវចំពោះអ្នកអានរបស់គេ
- ទទួលព័ត៌មានពីប្រភពច្រើន ហើយផ្ទៀង-ផ្ទាត់ព័ត៌មាន
- មានភាពទៀងត្រង់ ហើយមិនចម្លងរឿងពីប្រព័ន្ធផ្សព្វផ្សាយដទៃទៀត
- ដែលមានគំនិតច្នៃប្រឌិត និងគួរឲ្យចាប់អារម្មណ៍សម្រាប់សរសេររឿង

អ្នកសារព័ត៌មានចំណាន ក៏ជាមនុស្សចេះងឿងឆ្ងល់ដែរ។ ពួកគេតែងចង់ដឹង តើអ្វីៗវាប្រព្រឹត្តទៅដោយរបៀបណា ហើយតែងតែអានដំណឹងជានិច្ច។ ពួកគេជាអ្នកសង្កេត។ ពួកគេចេះធ្វើការកត់សម្គាល់លើសញ្ញាអធម្មតានៅតាមដងផ្លូវ ដែលមនុស្សដទៃទៀតមិនរវីរវល់ជាមួយ។ ពួកគេពូកែស្ដាប់ ប៉ុន្តែក៏ពូកែមន្ទិលផងដែរ។ ពួកគេមិនចេះតែទទួលថា រឿងមួយនឹងវាពិត ព្រោះមន្ត្រីម្នាក់និយាយថា វាពិតនោះទេ។ ពួកគេជាមនុស្សឯករាជ្យ។ ពួកគេមិនបណ្ដោយខ្លួនឲ្យអ្នកដទៃប្រើប្រាស់ពួកគេ ដើម្បីផលប្រយោជន៍ខ្លួននោះឡើយ។ ពួកគេស្វែងរកជ្រុងទាំងសងខាងនៃរឿង ហើយផ្ទៀងផ្ទាត់ព័ត៌មានដើម្បីធានាថាវាត្រឹមត្រូវជាក់លាក់។ ពួកគេមានវិន័យដោយមិនបណ្ដោយឲ្យអ្វីផ្សេងមកបង្វែរអារម្មណ៍របស់គេបានឡើយ ដើម្បីគេអាចបញ្ចប់រឿងតាមកាលបរិច្ឆេទទៀងទាត់។ ពេលណាជួបឧបសគ្គ ពួកគេមិនចុះញ៉មទេ។ ពួកគេតែងព្យាយាមរកផ្លូវផ្សេងៗ ដើម្បីរកឲ្យបាននូវអង្គហេតុក្នុងរឿង។ ហើយពួកគេសរសេរតែអំពីអង្គហេតុ ព្រោះថានោះគឺជាអ្វីដែលអ្នកអានរបស់គេចង់បាន និងត្រូវការ ពួកគេមិនយកមតិរបស់ខ្លួនមកឡូកឡំក្នុងសាច់រឿងទេ។

អ្នកសារព័ត៌មានចំណានៗ ក៏ជាមនុស្សមានមេត្តាករុណាដែរ។ ពួកគេមិនចូលចិត្តទេ ពេលឃើញមនុស្សបំពានលើអ្នកដទៃ។ ពួកគអាចទទួលអារម្មណ៍ឈឺចាប់របស់អ្នកដទៃ ហើយស្វែងយល់អំពីបញ្ហារបស់អ្នកទាំងនោះ។ ពួកគេចង់ធ្វើសេចក្ដីរាយការណ៍អំពីបញ្ហាទាំងនោះ ដើម្បីឲ្យពិភពលោកទាំងមូលបានដឹង បានជ្រាប ហើយជួយរកវិធីដោះស្រាយវា។

## តើអ្វីជាដំណឹង?

កិច្ចការរបស់អ្នកសារព័ត៌មាន គឺ "យកដំណឹង"។ ប៉ុន្តែមានព្រឹត្តិការណ៍ច្រើនណាស់កើតឡើងរៀងរាល់ថ្ងៃ ហើយក៏មិនមែនព្រឹត្តិការណ៍ទាំងអស់ គួរតែត្រូវបានគេយកមករាយការណ៍ផ្សព្វផ្សាយដែរ។ ដូច្នេះ តើអ្វីទៅជាដំណឹង? តើព័ត៌មានប្រភេទណាខ្លះទៅដែលអ្នកអានចង់បាន និងត្រូវការ?

នេះជាការសេចក្ដីសម្រេចដែលអ្នកសារព័ត៌មានត្រូវធ្វើជារៀងរាល់ថ្ងៃ។ មុននឹងចាប់ផ្ដើមចេញទៅយកព័ត៌មានអំពីរឿងមួយ អ្នកសារព័ត៌មានសួរខ្លួនឯងថា "តើរឿងមួយហ្នឹង ជារឿងដែលមនុស្សម្នានឹងនាំគ្នាយកមកនិយាយរកែញែកទៀតលើកក្រោយ?" ហើយថាតើ "នេះជាដំណឹងដែលពួកគេចង់ដឹងឬ?"

*ដំណឹង គឺជាព័ត៌មានដែលមានសារៈសំខាន់ ឬជាទីចាប់អារម្មណ៍ដល់មនុស្សម្នាភាគច្រើន។* វាខុសគ្នាទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងគ្រប់ពេលជារៀងរាល់ថ្ងៃ។

ដំណឹង គឺអ្វីដែលអធម្មតា។ និយមន័យពេញនិយមមួយរបស់ដំណឹង គឺ៖ ៉ប្រសិនបើឆ្កែខាំមនុស្ស អាហ្នឹងមិនមែនជាដំណឹងទេ។ ប៉ុន្តែបើសិនជាមនុស្សខាំឆ្កែវិញ អាហ្នឹងហើយជាដំណឹង៉ ។ រឿងមួយដែលចុះផ្សាយលើទំព័រមុខរបស់កាសែត Bangkok Post និយាយអំពីបុរសម្នាក់ ដែលត្រូវបានគេចាប់ខ្លួន ដោយសារតែគាត់បានខាំឆ្កែរបស់ខ្លួន។ បុរសនោះធ្វើដូច្នោះ ដោយគាត់ចង់បង្ហាញអ្នកឯទៀតថា គាត់ជាចៅហ្វាយរបស់ឆ្កែនោះ។

ដំណឹងក៏ជាអ្វីមួយ ដែលមានឥទ្ធិពលប៉ះពាល់ទៅលើមនុស្សភាគច្រើនដែរ។ វាអាចជារឿងស្តីអំពីទឹកជំនន់ធំ ដែលបានបំផ្លិចបំផ្លាញផ្ទះសម្បែង និងដំណាំ។ វាអាចជារឿងស្តីអំពីការឡើងថ្លៃប្រេងឥន្ធនៈ ដែលមានន័យថា បំណាយកាន់តែខ្ពស់ថែមទៀតក្នុងការបើកបរទោចក្រយានយន្ត។ ជារឿយៗ រឿងធំៗ គឺជារឿងទាំងឡាយណា ដែលបង្កឥទ្ធិពលប៉ះពាល់ទៅលើមនុស្សម្នា។

មានពេលខ្លះ ដំណឹង គឺគ្រាន់តែជាអ្វីដែល *មនុស្សសំខាន់ លេចធ្លោ ឬល្បីឈ្មោះ* បានធ្វើ ឬនិយាយតែប៉ុណ្ណោះ។ អ្នកកាសែតតែងតែដើរតាមមន្រ្តីជាន់ខ្ពស់ ដូចជា នាយករដ្ឋមន្រ្តី ប្រធានាធិបតី ឬរដ្ឋមន្រ្តីការបរទេស។ អ្នកទាំងនេះជា មនុស្សមានអំណាច និងមានឥទ្ធិពល ដូច្នេះមតិរបស់ពួកគេត្រូវបានគេយកទៅផ្សាយច្រើនជាងមតិរបស់ជនសាមញ្ញ។ រីឯអ្នកសារព័ត៌មានដទៃទៀតនាំគ្នាតាមតារាភាពយន្ត និងអ្នកចម្រៀង ពីព្រោះពួកគេដឹងថា អ្នកអានរបស់ខ្លួនចាប់អារម្មណ៍នឹងជីវិតរបស់អ្នកមាន និងអ្នកល្បីឈ្មោះ។

ដំណឹងមាន *កាលិក* (timeliness) របស់វា។ ធម្មតា ដំណឹង គឺអ្វីដែលកើតឡើងថ្ងៃនេះ។ អ្នកអានចង់ដឹងអំពីព្រឹត្តិការណ៍ថ្មីៗ ហើយពួកគេចង់ដឹងឲ្យបានលឿនបំផុតតាមតែអាចធ្វើទៅបាន។ ប្រសិនបើមានអគ្គីភ័យធំ ឬព្រឹត្តិការណ៍ណាមួយក្នុងទីក្រុង អ្នកសារព័ត៌មាននឹងនាំគ្នាបញ្ជូនរឿងរបស់ពួកគេទៅកាន់ស្ថានីយវិទ្យុ ទូរទស្សន៍ ឬក៏បង្ហោះលើវិបសៃត៍ភ្លាមមួយរំពេច។ អ្នកឯទៀតសរសេររឿង ដើម្បីចុះផ្សាយក្នុងកាសែតពេលព្រឹក។

ជារឿយៗ ដំណឹងតែងនិយាយអំពី *វិវាទ*។ វិវាទរំខានដល់ជីវភាពប្រចាំថ្ងៃ។ មនុស្សឈ្លោះគ្នា ដោយសាររឿងដីធ្លី។ គណបក្សនយោបាយប្រជែងគ្នា ដើម្បីគ្រប់គ្រងរដ្ឋាភិបាល។ ប្រទេសនានាធ្វើសង្គ្រាមដោយសារឈ្លោះគ្នា។

ដំណឹងក៏មាន *មុំ* ក្នុងស្រុករបស់វាដែរ។ មនុស្សចង់ដឹងអំពីព្រឹត្តិការណ៍ដែលកើតឡើងក្នុង ឬក៏ជិតកន្លែងដែលគេរស់នៅ។ ឧទាហរណ៍ កាសែតមួយក្នុងទីក្រុងវៀងច័ន្ទ ពិតជាចាប់អារម្មណ៍នឹងបញ្ហាទឹកជំនន់ជិតទីក្រុងវៀងច័ន្ទ។ វាពិតជាមិនសូវចាប់អារម្មណ៍ជាមួយរឿងទឹកជំនន់នៅទីក្រុងប៉េកាំងទេ។ មនុស្សនានាក៏ចង់ដឹងអំពីព្រឹត្តិការណ៍ដែលប៉ះទង្គិចទៅលើមនុស្សដែលមានស្ថានភាពប្រហាក់ប្រហែលពួកគេដែរ។ ប្រជាជនឡាវ ពិតជាចង់ដឹងអំពីអ្វីដែលកើតមានទៅលើជនជាតិឡាវឯទៀត។ ការធ្លាក់យន្តហោះមួយនៅប្រទេសចិន ប្រហែលជាមិនសូវគេយកមកផ្សាយក្នុងកាសែតក្នុងប្រទេសឡាវទេមើលទៅ។ ប៉ុន្តែ បើសិនជាមានជនជាតិឡាវបីនាក់នៅលើយន្តហោះនោះ វានឹងក្លាយជារឿងមួយធំមិនខាន។

ពេលខ្លះ ដំណឹង គឺជាព័ត៌មានដែលមាន *ប្រយោជន៍*។ វាអាចជារឿងអំពីថា តើរកការងារថ្មីបានដោយវិធីណា។ បើមិនដូច្នោះទេ វាជារឿងអំពីរបៀបហាត់ប្រាណ និងការថែទាំសុខភាព។

ក្រៅពីនោះ ដំណឹង គឺគ្រាន់តែជាអ្វីដែលជាព័ត៌មាន *កំសាន្ត* តែប៉ុណ្ណោះ។ ក្នុងនោះ មានរឿងអំពីសត្វ រឿងគួរឲ្យចង់សើច ដែលមនុស្សនានាបានធ្វើការថតភាពយន្តថ្មីជាដើម។

គេពិបាកឲ្យនិយមន័យដំណឹងណាស់។ អ្នកយកព័ត៌មានថ្មីម្នាក់ ដែលទើបនឹងចាប់ផ្តើមការងារប្រហែលជាអាចវង្វេង នៅពេលដែលឮនិពន្ធនាយកប្រាប់ពួកគេថា ចេញទៅហើយ "ពេលត្រឡប់មកវិញនាំសាច់រឿងមកជាមួយផង"។ ប៉ុន្តែជាមួយបទពិសោធន៍ អ្នកសារព័ត៌មាននឹងអភិវឌ្ឍន៍បាននូវសមត្ថភាពក្នុងរកឃើញដំណឹងបានភ្លាមៗមកសរសេរជារឿង។

# ជំពូកទី ២
# ការស្វែងរកប្រភពព័ត៌មាន និងគោលគំនិតរឿង

ដំណឹងច្រើនតែនៅក្បែរៗខ្លួនរបស់យើងហ្នឹងឯង ដូចជា អគ្គីកំពុងឆាបឆេះអគារមួយ នគរបាលចាប់បានឧក្រិដ្ឋជន ដងផ្លូវត្រូវបានលិចលង់ក្នុងទឹក បន្ទាប់ពីមានភ្លៀងមួយមេធំ។ ប៉ុន្តែមានដំណឹងច្រើនណាស់ដែលមិនសូវប្រត្យក្ស។ អ្នកសារព័ត៌មានមិនត្រូវអង្គុយចាំព្រឹត្តិការណ៍កើតឡើងនោះទេ ហើយក៏មិនគួរចាំនិពន្ធនាយករបស់ខ្លួនចាត់តាំងកិច្ចការបានទៅរករឿងមកសរសេរនោះឡើយ។ ពួកគេគួរបណ្តុះគំនិតរឿងយកមកសរសេរដោយខ្លួនឯង។ អ្នកសារព័ត៌មានណាដែលចេះបណ្តុះគំនិតដោយខ្លួនឯង តែងត្រូវបាននិពន្ធនាយកឲ្យតម្លៃខ្ពស់។ ជាទូទៅ អ្នកសារព័ត៌មានច្រើនតែមានបំណងចង់រកគំនិតរឿងដោយខ្លួនឯងក្នុងការធ្វើរឿង។

អ្នកសារព័ត៌មានអាចស្វែងរកគោលគំនិតរឿងដោយធែកជាទៀងទាត់ជាមួយការិយាល័យព័ត៌មានរបស់រដ្ឋាភិបាល ឬជាមួយក្រសួងនានា។ ការិយាល័យខ្លះមានចុះកាលវិភាគព្រឹត្តិការណ៍ប្រចាំថ្ងៃរបស់គេ។

សេចក្តីប្រកាសព័ត៌មានខ្លះ អាចធ្វើជាមូលដ្ឋានសម្រាប់សរសេររឿងល្អបានដែរ។ វាមានចេញពីអង្គការមិនមែនរដ្ឋាភិបាល ឬក៏ទីភ្នាក់ងារអន្តរជាតិដូចជាអង្គការសហប្រជាជាតិជាដើម។ សេចក្តីប្រកាសព័ត៌មានខ្លះទៀត ចេញពីក្រុមធុរកិច្ច សាលារៀន ឬបុគ្គលឯកជន។ រដ្ឋាភិបាល និងស្ថាប័ននានាក៏តែងចេញផ្សាយឯកសារ ឬរបាយការណ៍ជាច្រើនដែរ។ សេចក្តីប្រកាសព័ត៌មាន ឬក៏ឯកសារមួយគួរត្រូវបានចាត់ទុកថាជាចំណុចចាប់ផ្តើមសម្រាប់អត្ថបទរឿង។ ឧទាហរណ៍ ក្រុមបរិស្ថានមួយបានចេញសេចក្តីថ្លែងការណ៍អំពីស្ថានភាពទន្លេមេគង្គ។ អ្នកសារព័ត៌មានដែលស្វាហាប់ម្នាក់ អាចសុខចិត្តទៅចំណាយពេលលើទន្លេមេគង្គ ដើម្បីមើលថាតើទឹកហ្នឹងវាស្អាត ឬកខ្វក់ប៉ុណ្ណា ឬក៏តើវាមានមច្ឆាតិចជាងមុនប៉ុណ្ណាទៅបើប្រៀបនឹងពេលមុន។ គេអាចជជែកជាមួយអ្នកនេសាទ ក្រុមហ៊ុនដឹកជញ្ជូន និងអ្នកឯទៀតដែលរស់នៅតាមដងទន្លេនោះ។ (ជំពូកទី ១២ នឹងពន្យល់បានក្បោះក្បាយថែមទៀតអំពីរបៀបសរសេររឿងដោយផ្អែកលើសេចក្តីប្រកាសព័ត៌មាន)។

អ្នកគួរតែធ្វើឲ្យបានប្រាកដថា អ្នកយល់អំពីប្រធានបទ ឬស្ថាប័ន ដែលអ្នកយកព័ត៌មាននោះ។ គួរស្វែងយល់ឲ្យបានប្រាដកថា តើនឹងមានការវិវត្តអ្វីបន្ទាប់មកទៀត។ គួររៀបចំឲ្យហើយនូវព័ត៌មានសាវតារទាំងឡាយ ដែលអ្នកនឹងត្រូវការនៅពេលដែលសភាអនុម័តច្បាប់វិនិយោគថ្មី ឬធនាគារកណ្តាលប្រកាសកាត់អត្រាការប្រាក់ថ្មីថែមទៀត។

អ្នកសារព័ត៌មានអាចរកគោលគំនិតរឿងបាន ដោយអានកាសែត ទស្សនាវដ្តី វ៉ិបសៃត៍ ស្តាប់វិទ្យុ មើលទូរទស្សន៍។ ពួកគេអាចចាប់ផ្តើមពីសំណួរ ដែលប្រព័ន្ធផ្សព្វផ្សាយដទៃមិនទាន់បានឆ្លើយ ហើយរកមុំថ្មីមកសរសេររឿង។

អ្នកសារព័ត៌មានល្អ តែងតែរៀបផែនការមុនជានិច្ច។ ពួកគេកត់ត្រាទុកព្រឹត្តិការណ៍សំខាន់ៗក្នុងប្រក្រតិទិនរបស់គេ ហើយគិតអំពីរឿងដែលអាចគួរសរសេរបានជាមុន។ បើសិនជាតុលាការត្រូវបានគេរំពឹងថា នឹងចេញសេចក្តីសម្រេចមួយ ដែលគេរង់ចាំជាយូរមកហើយទៅលើករណីសំខាន់មួយ អ្នកសារព័ត៌មានអាចសរសេររឿងអំពីករណីនេះ បុះផ្សាយមួយថ្ងៃមុនបាន។ នេះ គឺអ្វីដែលកាសែតជាច្រើននៅទីក្រុងបាងកកបានធ្វើ មុននឹងអតីតនាយករដ្ឋមន្ត្រីម្នាក់ ត្រូវបានតុលាការរកឃើញថាមានពិរុទ្ធពីបទបំពានអំណាចក្នុងមុខតំណែង។ រឿងដែលចេញផ្សាយមុនមួយថ្ងៃ ជួយឲ្យអ្នកអានត្រៀមខ្លួនសម្រាប់សេចក្តីសម្រេចមុននឹងវាត្រូវបានប្រកាស។

ទិវាអនុស្សាវរីយ៍នៃព្រឹត្តិការណ៍សំខាន់ៗ ក៏ជាវិធីមួយល្អសម្រាប់រំលឹកបញ្ហាទាក់ទង ស្របនឹងពេលវេលានោះដែរ។ មានប្រព័ន្ធផ្សព្វផ្សាយបានសរសេររឿងអំពីព្យុះសមុទ្រស៊ូណាមី នៅប្រាំមួយខែ មួយឆ្នាំ និងពីរឆ្នាំ ក្រោយពីព្រឹត្តិការណ៍នោះកើតនៅឆ្នាំ ២០០៤ ទៅទៀត។ ទីភ្នាក់ងារជាច្រើនបានសរសេររឿង ដោយផ្អែកលើខួបទៅ ១០ នៃវិបត្តិហិរញ្ញវត្ថុ ឆ្នាំ ១៩៩៧។ អ្នកសារព័ត៌មានភូមាម្នាក់បានសរសេររម្លឹកអំពីព្យុះស៊ីក្លូន ឆ្នាំ ២០០៨ ដោយចាប់ផ្តើមដូច្នេះថា ៖

*រយៈពេលប្រាំមួយខែក្រោយពីមានព្យុះស៊ីក្លូន-ណាហ្គីស បោកបក់ទៅលើតំបន់វាលសណ្តរ អ៊ីរ៉ាវ៉ាឌី កង្វល់ចម្បងបំផុតមួយសម្រាប់អង្គការសហប្រជាជាតិ គឺកង្វះដ៏សន្ធឹកសន្ធាប់នូវមូលនិធិដែលគេត្រូវការចាំបាច់សម្រាប់ស្តារនូវរបបចិញ្ចឹមជីវិតរបស់មនុស្សរាប់សិបពាន់នាក់ ដែលបានរស់រានមានជីវិតពីព្យុះកំណាចនោះ។*

ការសម្រាកប្រចាំឆ្នាំពីការងារ ក៏ជាប្រភពមួយដែរសម្រាប់ធ្វើរឿង។ ប្រទេសនីមួយៗប្រារព្ធទិវាពិសេសរបស់ខ្លួន ប៉ុន្តែក៏នៅមានទិវាអន្តរជាតិពិសេសច្រើនដែរ ដែលអង្គការសហប្រជាជាតិទទួលស្គាល់។ ឧទាហរណ៍ ទិវាបរិស្ថានអន្តរជាតិ ថ្ងៃទី ៥ មិថុនា ទិវានារីអន្តរជាតិថ្ងៃទី ៨ មិនា និងទិវាពិភពលោកប្រឆាំងនឹងជំងឺអេដស៍ ថ្ងៃទី ១ ធ្នូ។ ទាំងអស់នេះសុទ្ធតែអាចធ្វើជាទំពក់សម្រាប់ធ្វើរឿងបាន។

# រកមុំថ្មីដើម្បីសរសេររឿង

ភាពប្រឈមមួយក្នុងចំណោមភាពប្រឈមធំៗជាច្រើន គឺវាស្ថិតក្នុងការថា តើធ្វើដូចម្តេចរកឲ្យបាននូវរបៀបថ្មីៗក្នុងការសរសេររឿង ដែលមានលក្ខណៈដដែលៗ ដូចជា ការបោះឆ្នោត កិច្ចប្រជុំ ឬក៏ការឈប់សម្រាកប្រចាំឆ្នាំ។ មុនពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រថៃ ដែលក៏ត្រូវបានប្រារព្ធផងដូចនឹងទិវាបិតា (Father's Day) ផងដែរនោះ អ្នកយកព័ត៌មានកាសែត Bangkok Post បានរៀបចំកញ្ចប់អត្ថបទចំនួនបី។ រឿងមួយនិយាយអំពីឪពុកទាំងឡាយ ដែលទទួលបានការស្រឡាញ់ពីសំណាក់កូនៗរបស់គេ។ រឿងមួយទៀតនិយាយអំពីកូនទាំងឡាយ ដែលត្រូវបានឪពុកបុះបោល ផ្ទះសម្បែង ទទួលមរណភាព ឬត្រូវជាប់ពន្ធនាគារ។ អ្នកយកព័ត៌មានទីបីបានសរសេរអំពីបុរសម្នាក់ ដែលការងាររបស់គាត់ គឺត្រូវចងអំពូលភ្លើងរាប់ពាន់តាមដងវិថី Ratchadamnoen ក្នុងទីក្រុង Bangkok ដែលធ្វើឲ្យដងវិថីនោះ នៅពេលយប់មានពន្លឺភ្លឺចិញ្ចាចដូចថ្ងៃ។

នៅឯប្រទេសកូមាំងណោះវិញ អ្នកសារព័ត៌មានម្នាក់ ដែលធ្វើការឲ្យកាសែតប្រចាំសប្តាហ៍ឈ្មោះ 7-Day News បានយកព័ត៌មានធ្វើរឿងអំពីមរណភាពរបស់បុគ្គលល្បីឈ្មោះម្នាក់ ដោយផ្តោតទៅលើក្រុមបម្រើបុណ្យសព្វ រៀបចំពិធីបុណ្យ និងទៅលើមនុស្សម្នា ដែលគេរំពឹងថានឹងមកចូលរួម។ អ្នកអានចូលចិត្តអានរបៀបសរសេរដែលមិនធម្មតារបស់គាត់។

នៅឯទីក្រុងភ្នំពេញ កាសែត The Cambodia Daily បានបញ្ជូនអ្នកយកព័ត៌មានទៅសម្ភាសន៍ប្រជាជនគ្មានលំនៅដ្ឋាន ដែលមិនព្រមចាកចេញពីអគារមួយក្នុងទីក្រុង។ មន្ត្រីក្រុងបានបញ្ជាឲ្យ "អ្នកតាំងលំនៅខុសច្បាប់" ចេញពីអគារនោះ។ អ្នកយកព័ត៌មានបានធ្វើការរ៉ាយរ៉ាប់រឿងនោះតាមអ្វី ដែលក្រុមគ្រួសារទាំងនោះបានជួបប្រទះ។ រឿងនោះចាប់ផ្តើម ដូច្នេះ ៖

*កាលពីសប្តាហ៍មុន នាងចាន់ ថន បានភ្ញាក់ពីដំណេក ដោយសារតែកណ្តុរខាំមេជើងរបស់គាត់។*

*ប៉ុន្តែនាងមិនបានធោឡោឡើយ។ ផ្ទុយទៅវិញ នាងគ្រាន់តែធ្វើនូវអ្វីដែលគាត់ធ្លាប់បានធ្វើប្រាំពីរដងរួចមកហើយ គឺនាងគ្រាន់តែជូតឈាម ព្យាបាលមុខរបួស ហើយចូលដំណេកវិញ។*

*ដោយបង្ហាញស្នាមរបួសនៅលើម្រាមដៃ និងម្រាមជើងរបស់ខ្លួន នាងចាន់ ថន និយាយថា "ទីនេះមានកណ្តុរច្រើនពេក ទាល់តែសម្លាប់ទាំងអស់ទើបបាន។"*

*មានគ្រួសារចំនួន ៨៨ គ្រួសារ ដែលបានតាំងលំនៅនៅខាងក្នុង ឬខាងលើដំបូលរោងភាពយន្តហេមជាតិ ដែលស្ថិតនៅកែងផ្លូវលេខ ១៣០ និងលេខ ១៥ ក្នុងកណ្តាលទីក្រុងភ្នំពេញ។ ពួកគេបានធ្លាប់រួចទៅហើយជាមួយនឹងការវាយប្រហារដោយហ្វូងកណ្តុរនាពេលយប់។*



*ចូរសួរសំណួរឲ្យបានកាន់តែច្រើន កាលណាឆាកឧបទ្ទវហេតុមានភាពច្របូកច្របល់*

រឿងនោះបានបន្តរ៉ាយរ៉ាប់អំពីវិវាទរវាងសាលាក្រុង និង"អ្នកតាំងលំនៅខុសច្បាប់" និងលក្ខខណ្ឌដីកខ្វក់ ដែលពួកគេជ្រើសរើសរស់នៅ។

## តើពីកន្លែងណាខ្លះ ដែលអ្នកកាសែតប្រមូលបានគំនិត ដើម្បីសរសេររឿង?

ពួកគេពិគ្រោះយោបល់ជាមួយនិពន្ធនាយក និងសហសេវិករបស់គេ។ មានន័យថា អង្គុយចែករំលែកគំនិតជាមួយគ្នា បើទោះជាថាគំនិតខ្លះស្តាប់ពីដំបូងទៅដូចជាគំនិតល្ងីល្ងើក្តី តែគេអាចពិភាក្សាគ្នា ហើយបង្វែរគំនិតនោះឲ្យរឿងជាទីចាប់អារម្មណ៍។ ឧទាហរណ៍ បន្ទាប់ពីមានពីធីបុណ្យទាន តើសំរាមទៅណាអស់ទៅ? តើអស់ថ្លៃប៉ុន្មានក្នុងការបោសសម្អាតសំរាមទាំងនោះ? តើទីក្រុងបង្កើតសំរាមច្រើនប៉ុណ្ណាក្នុងមួយឆ្នាំៗ? តើកន្លែងចាក់សំរាមជិតពេញហើយ ឬយ៉ាងម៉េច? តើគេនឹងយកសំរាមទៅដាក់ឯណានាពេលអនាគត? តើគេអាចយកសំរាមនោះ ទៅបម្លែងទៅជាប្រភពថាមពលជំនួសបានច្រើនថែមទៀតទេ?

វិធីមួយទៀតប្រមើលថា តើអ្នកណាខ្លះដែលអាចនឹងរងផលប៉ះពាល់ ដោយសារបញ្ហា ឬព្រឹត្តិការណ៍មួយ ហើយសរសេររឿងចេញពីទស្សនៈទានរបស់អ្នកទាំងនោះ។ ឧទាហរណ៍ បន្ទាប់ពីមានការឡើងថ្លៃប្រេងឥន្ធនៈ អ្នកយកព័ត៌មាន អាចជជែកសួរម្ចាស់យានជំនិះ អ្នកបើកបរតាក់ស៊ី និងក្រុមហ៊ុនដឹកជញ្ជូនអំពីបញ្ហានេះ។ បើសិនជាសាលាក្រុងប្រកាសនូវគម្រោងអភិវឌ្ឍន៍ធំមួយ តើអ្នកណាខ្លះនឹងបានទទួលផល? តើអ្នកណាខ្លះនឹងបាត់បង់ផលប្រយោជន៍? ក្នុងពេលយុទ្ធនាការបោះឆ្នោត តើអ្នកបោះឆ្នោតគិតដូចម្តេចខ្លះអំពីបេក្ខជន និងបញ្ហានានា ដែលលើកឡើងក្នុងពេលនោះ? តើពួកគេនឹងទទួលរងផលបែបម៉េចខ្លះពីសំណាក់គោលនយោបាយថ្មី ដែលបានស្នើឡើងក្នុងយុទ្ធនាការនោះ?

អ្នកកាសែតខ្លះអានទស្សនាវដ្តីបច្ចេកទេស ដើម្បីស្វែងយល់អំពីការអភិវឌ្ឍក្នុងវិស័យ ដែលពួកគេសរសេរ។ អ្នកកាសែតដែលសរសេរអំពីវិស័យបរិស្ថានអាចនឹងអានព្រឹត្តិបត្រ ដែលចេញផ្សាយដោយអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការផ្នែកបរិស្ថាន ឬក៏ព្រឹត្តិបត្ររបស់អង្គការស្បៀង និងកសិកម្មរបស់អង្គការសហប្រជាជាតិ។ ពួកគេក៏អាចជាវដំណឹងបន្ទាន់អ៊ីនធឺណេតផងដែរ។ ពួកគេធ្វើយ៉ាងណាអប់រំខ្លួនឯងឲ្យបានច្រើនតាមតែអាចធ្វើទៅបាន អំពីប្រធានបទដែលពួកគេសរសេរ។ នៅពេលដែលពួកគេរៀនដឹងអំពីរឿងថ្មី ពួកគេនឹងចែករំលែកចំណេះដឹងនោះជាមួយអ្នកអាន។

នៅប្រទេសកម្ពុជា អ្នកកាសែតតែងនាំគ្នាអានប្លុកអ៊ិនធឺណិតរបស់អតីតព្រះមហាក្សត្រ ព្រះបាទសម្តេច នរោត្តម សីហនុ។ ព្រះអង្គសម្តេចឪ បានសម្តែងព្រះរាជយោបល់របស់ព្រះអង្គលើប្រធានបទជាច្រើន ដូចជា បញ្ហាសាលាក្តីខ្មែរក្រហម ឬក៏បញ្ហារបស់កសិករក្រីក្រជាដើម។ ព្រះរាជយោបល់ទាំងនេះ តែងផ្តល់នូវជាតុផ្សំល្អៗសម្រាប់ធ្វើរឿង។

អ្នកយកព័ត៌មានចំណានអាចរករឿងល្អមកសរសេរបាន ដោយស្តាប់អ្នកជទៃនៅតាមផ្ទះ ទីផ្សារ ឬកន្លែងជប់លៀង។ តើមនុស្សម្នានាំគ្នានិយាយអំពីអ្វី? តើពួកគេកំពុងខ្វល់ខ្វាយអំពីបញ្ហាទំនិញឡើងថ្លៃ ហើយចំណូលធ្លាក់ចុះ? គេខ្វល់ខ្វាយអំពីគុណភាពសាលារៀន? ពួកគេបារម្ភថា តើគេមានលទ្ធភាពនឹងចូលនិវត្តន៍បានទេ? គំនិត និងកង្វល់របស់ពួកគេអាចក្លាយជាមូលដ្ឋានសម្រាប់ធ្វើរឿងបាន។

អ្នកកាសែត ក៏អាចសម្បូរណ៍គំនិតធ្វើរឿងដែរ ដោយគ្រាន់តែរវាសរវៃភ្នែកតែបន្តិចប៉ុណ្ណោះ។ ពួកគេថ្ងៃណាមួយ អាចធ្វើដំណើរតាមផ្លូវផ្សេងទៅ

ធ្វើការ ដើម្បីសម្លឹងមើលអ្វីៗថ្មីខុសពីផ្លូវដែលគេធ្លាប់ធ្វើដំណើរញឹកញាប់។ បើពួកគេប្រទះភ្នែកនឹងអគារគួរចាប់អារម្មណ៍មួយកំពុងសាងសង់ គេអាចទូរស័ព្ទទៅកាន់នាយកដ្ឋានរបស់សាលាក្រុង ដែលទទួលបន្ទុកក្នុងការចេញអាជ្ញាប័ណ្ណសាងសង់។ តាមរយៈនោះ ពួកគេអាចដឹងបានថានោះប្រហែលជានោះជាការសាងសង់រោងភាពយន្តថ្មី ឬសារមន្ទីរថ្មីមួយផងក៏មិនដឹង។ នោះហើយជារឿងដែលមនុស្សជាច្រើនក្នុងក្រុងនឹងចាប់អារម្មណ៍ចង់អាន។

## គួរមានប្រភពព័ត៌មានច្រើន តែជាប្រភពល្អៗ

ប្រភពព័ត៌មានជាមនុស្សផ្ដល់នូវគំនិតជាច្រើនសម្រាប់ធ្វើរឿង។ ពួកគេក៏ផ្ដត់ផ្គង់ផងដែរនូវព័ត៌មានដែលចាំបាច់សម្រាប់សរសេររឿងទាំងនោះ។ វាសំខាន់ណាស់ក្នុងការមានប្រភពព័ត៌មានច្រើន។ ប៉ុន្តែវាកាន់តែសំខាន់ថែមទៀតក្នុងការមានប្រភពល្អៗ។ អ្នកកាសែត គួរតែធ្វើយ៉ាងណាឲ្យខ្លួនមានប្រភពនានា ដែលគេអាចពឹងពាក់បានក្នុងទទួលព័ត៌មានត្រឹមត្រូវប្រកបដោយកម្មវិស័យ និងអព្យាក្រឹត។ តើព័ត៌មានដែលប្រភពបានឲ្យពីអតីតកាលមានភាពត្រឹមត្រូវមែនទេ? តើប្រភពទាំងនោះ ជាមនុស្សដែលទទួលបានការគោរពពីមនុស្សដទៃទេ? តើពួកគេស្ថិតក្នុងស្ថានភាពដែលគេដឹងរឿងរ៉ាវ ដែលពួកគេបាននិយាយនោះទេ? តើពួកគេមានហេតុផលនិយាយកុហកទេ?

អ្នកសារព័ត៌មាន ក៏ចាំបាច់ធ្វើឲ្យប្រាកដដែរថាពួកគេត្រូវមានប្រភពព័ត៌មាន ដែលជាអ្នកឯកទេសក្នុងវិស័យផ្សេងៗគ្នាផងដែរ។ ក្នុងនោះមានសេដ្ឋកិច្ចវិទូ។ ប្រសិនបើអ្នកសារព័ត៌មានត្រូវការសរសេរអំពីធុរកិច្ច តែមិនយល់នូវវាក្យស័ព្ទណាមួយនោះ ពួកគេអាចទូរស័ព្ទទៅរកអ្នកឯកទេសហិរញ្ញវត្ថុ ឬសេដ្ឋកិច្ច-វិទូ ដើម្បីឲ្យគេជួយពន្យល់។

ក្នុងការកសាងប្រភពព័ត៌មានឲ្យបានច្រើន អ្នកសារព័ត៌មានចាំបាច់ត្រូវជួបប្រាស្រ័យជាមួយមនុស្សនានាឲ្យបានញឹកញាប់ដោយផ្ទាល់ក្ដី ឬតាមរយៈទូរស័ព្ទក្ដី។ ពេលដែលប្រភពព័ត៌មានស្គាល់អ្នកយកព័ត៌មានហើយ នោះគេនឹងអាចជឿទុកចិត្តមកលើអ្នកសារព័ត៌មានបាន។ ដូចគ្នាដែរ អ្នកកាសែតក៏អាចដឹងបានដែរថា តើប្រភពមួយនោះអាចទុកចិត្តបានដែរ ឬក៏អត់។

អ្នកសារព័ត៌មានខ្លះកសាងទំនាក់ទំនងស្គាល់គ្នាជាមួយមន្ត្រីថ្នាក់កណ្ដាលរបស់ស្ថាប័ន ដែលពួកគេយកព័ត៌មាន។ ជារឿយៗ មន្ត្រីក្នុងកម្រិតនេះសុទ្ធតែជាអ្នកដែលដឹងថា មានអ្វីខ្លះកើតឡើងក្នុងកន្លែងធ្វើការរបស់ពួកគេ។ លេខាធិការ ឬទីប្រឹក្សា អាចជាប្រភពព័ត៌មានល្អដែរ ព្រោះថាពួកគេពួកមន្ត្រីធំៗកំពុងធ្វើអ្វីខ្លះ។ ពួកគេក៏អាចជួយចាត់ចែងឲ្យមានបទសម្ភាសន៍ផងដែរ។

អ្នកកាសែតមានថ្វីដៃ តែងតែកសាងរឿងរបស់គេលើព័ត៌មានដែលបានមកពីប្រភពច្រើន។ ពេលប្រភពមួយផ្ដល់ព័ត៌មានឲ្យ គេតែងឆែកជាមួយប្រភពដទៃទៀត ដើម្បីធ្វើឲ្យប្រាកដថា ព័ត៌មាននោះវាសុក្រឹតត្រឹមត្រូវ។ បើមិនដូច្នោះទេ ពួកគេស្វែងរកអត្ថាធិប្បាយពីប្រភពដទៃទៀត ដើម្បីសរសេររឿងឲ្យបានពេញលេញ។ ពួកគេមិនចេះតែស្រង់សម្ដីមន្ត្រីរដ្ឋាភិបាលតែមួយមុខនោះទេ។ ពួកគេជជែកជាមួយអ្នកឯកទេស ដូចជាអ្នកធ្វើការក្នុងអង្គការមិនមែនរដ្ឋាភិបាល និងសាស្ត្រាចារ្យសកលវិទ្យាល័យជាដើម។ ពួកគេក៏ជជែកផងដែរ ជាមួយប្រជាជនសាមញ្ញដែលទទួលរងនូវផលប៉ះពាល់ពីព្រឹត្តការណ៍អ្វីមួយ។

អ្នកសារព័ត៌មានល្អៗ តែងតែឆែកជាមួយប្រភពនានាឲ្យបានទៀងទាត់ ដើម្បីមើលថាតើមានអ្វីខ្លះដែលកំពុងកើតឡើង។

ខាងក្រោមនេះ ជាប្រភពព័ត៌មានមួយចំនួនសម្រាប់អ្នកសារព័ត៌មានក្នុងតំបន់អាស៊ីអាគ្នេយ៍ ៖

- សេចក្តីប្រកាសព័ត៌មាន
- ការិយាល័យរដ្ឋាភិបាល
- នាយកដ្ឋាននគរបាល និងមន្ទីរពេទ្យ
- ទីភ្នាក់ងារអន្តរជាតិ
- អ្នកការទូត
- អង្គការមិនមែនរដ្ឋាភិបាល
- ធុរកិច្ច និងសមាគមធុរកិច្ច
- សាលារៀន
- ព្រឹត្តិបត្រព័ត៌មាន ទស្សនាវដ្តី កាសែត និងវិបសៃត៍
- ការផ្សាយវិទ្យុ និងទូរទស្សន៍ក្នុងស្រុក និងអន្តរជាតិ
- ក្រុមយុវជន
- ក្រុមអ្នកនយោបាយ
- វិហារសាសនាព្រះពុទ្ធ សាសនាគ្រឹស្ត សាសនាអ៊ីស្លាម

## គួរមានបញ្ជីប្រភពព័ត៌មាន

ការមានបញ្ជីប្រភពព័ត៌មានមួយ ដែលមានរបៀបរៀបរយ គឺមានសារៈសំខាន់ណាស់។ អ្នកយកព័ត៌មាន គួរតែសុំនាមប័ណ្ណពីមនុស្សទាំងឡាយណាដែលពួកគេបានសម្ភាសន៍ ហើយយកវាទៅបញ្ចូលក្នុងប្រអប់នាមប័ណ្ណ ឬក្នុងកុំព្យូទ័រ។ ពួកគេក៏គួររក្សាទុកផងដែរនូវបញ្ជីលេខទូរស័ព្ទ និងបញ្ជីលេខទាក់ទងជាមួយស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ ព្រោះថា ក្នុងខណៈណាមួយក្នុងការងារ ពួកគេចាំបាច់ត្រូវទូរស័ព្ទទៅរកប្រភពណាមួយជាបន្ទាន់។ ពួកគេនឹងមិនមានពេលច្រើនទេ សម្រាប់ដើរស្វែងរកឈ្មោះមនុស្សណាមួយដើម្បីទាក់ទងយកព័ត៌មាននោះ។

# ជំពូកទី ៣ គ្រោងជាមូលដ្ឋាននៃរឿង

## ដំណឹងទាន់ហេតុការណ៍ និងអត្ថបទពិពណ៌នា (Hard News and Features)

អត្ថបទរឿងមានទម្រង់ជាមូលដ្ឋានពីរបែប : ដំណឹងទាន់ហេតុការណ៍ និងអត្ថបទពិពណ៌នា។ ដំណឹងទាន់ហេតុការណ៍ជាធម្មតា ជាហេតុការណ៍ដែលទើបនឹងកើតឡើង ហើយគេត្រូវតែរាយការណ៍ជូនអ្នកអានភ្លាមជាបន្ទាន់ ឧទាហរណ៍ អគ្គីភ័យ ការប្រកាសរបស់រដ្ឋាភិបាល សេចក្តីសម្រេចរបស់តុលាការ មរណភាពរបស់មនុស្សល្បីឈ្មោះ។

អត្ថបទពិពណ៌នា មិនចាំបាច់ពាក់ព័ន្ធជាមួយនឹងព្រឹត្តិការណ៍ដែលទើបនឹងកើតឡើងនោះទេ។ អត្ថបទប្រភេទនេះ មិនត្រឹមតែជម្រាបដល់អ្នកអានប៉ុណ្ណោះទេ ប៉ុន្តែក៏ជំរុញឲ្យពួកគេត្រិះរិះឲ្យបានស៊ីជម្រៅអំពីស្ថានការណ៍ ឬបញ្ហាណាមួយ។

អត្ថបទពិពណ៌នា ច្រើនតែជារឿងមានប្រធានបទជាទីចំណាប់អារម្មណ៍របស់មនុស្ស។ វាអាចជារឿងនិយាយអំពីនិន្នាការសង្គម ដូចជា ប្រជាប្រិយភាពរបស់ភាពយន្តកូរ៉េ ឬមួយក៏ស្តីអំពីបញ្ហាសុខភាពធំៗ ដូចជាថាតើអ្នកភូមិនាំគ្នាលៃលកយ៉ាងដូចម្តេចជាមួយនឹងការផ្ទុះជំងឺគ្រុនក្តៅបក្សី។ បទពិពណ៌នាក៏អាចជាការរ៉ាយរ៉ាប់អំពីបុគ្គលិកលក្ខណៈមនុស្សកំពុងធ្វើអ្វីមួយដែលជាទីចាប់អារម្មណ៍ ដូចជាថាតើនាយកប្រតិបត្តិម្នាក់ព្យាយាមដូចម្តេច ដើម្បីប្រែក្លាយក្រុមហ៊ុនតូចឲ្យក្លាយជាធុរកិច្ចអន្តរជាតិមួយបាន។ អត្ថបទបែបនេះអាចពិពណ៌នាអំពីចរិតរបស់មនុស្ស ឬក៏បរិយាកាសរបស់ទីកន្លែងមួយ។

ជាទូទៅ អត្ថបទពិពណ៌នាមានលក្ខណៈស៊ីជម្រៅជាងអត្ថបទដំណឹងទាន់ហេតុការណ៍។ ដើម្បីរាយការណ៍អំពីបទពិពណ៌នាមួយ អ្នកយកព័ត៌មានម្នាក់អាចត្រូវចំណាយពេលច្រើនថ្ងៃ ដើម្បីធ្វើការសម្ភាសន៍ និងស្រាវជ្រាវ។

## សេចក្តីផ្តើម និងតួសេចក្តី

ភាគច្រើនរឿងផ្តុំឡើងដោយពីរផ្នែក។ ដំបូង គឺសេចក្តីផ្តើម ដែលជួនកាលគេហៅថា "ក្បាល"។ រីឯផ្នែកដទៃទៀត ហៅថា "ដងខ្លួន"។ រឿងភាគច្រើននិយាយអំពីមូលបទធំមួយ។ ទាំង "ក្បាល" និង "ដងខ្លួន" ត្រូវមានទំនាក់ទំនងជាមួយនឹងមូលបទនោះ។

សម្រាប់រឿងដំណឹងធម្មតា សេចក្តីផ្តើមជាទូទៅមានតែមួយឃ្លាទេ។ សេចក្តីផ្តើមប្រាប់អ្នកអានឲ្យដឹងតែម្តងថា តើរឿងនឹងនិយាយពីអ្វី រួមទាំងធាតុផ្សំសំខាន់ៗរបស់រឿងនោះផង។ សេចក្តីផ្តើមដែលល្អ គឺជាសេចក្តីផ្តើម ដែលប្បាមយកការចាប់អារម្មណ៍របស់អ្នកអានភ្លាមៗ ហើយលើកទឹកចិត្តពួកគេឲ្យអានផ្នែកឯទៀតក្នុងរឿងនោះ។

ដងខ្លួន ដែលអាចហៅម្យ៉ាងទៀតបានថា តួសេចក្តីនៃរឿង ផ្ទុកទៅដោយព័ត៌មាន ដែលធ្វើការពន្យល់ និងទ្រទ្រង់ដល់សេចក្តីផ្តើម។ ក្នុងនោះមានសេចក្តីក្បោះក្បាយ សម្រង់សម្តី និងសាវតារនៃព្រឹត្តិការណ៍ ដែលត្រូវបានរាយការណ៍ក្នុងរឿងនោះ។ ដាក់ព័ត៌មានសំខាន់នៅលើគេ បន្ទាប់មកព័ត៌មានណាដែលមានសារៈសំខាន់បន្ទាប់បន្សំ។

ខាងក្រោមជាឧទាហរណ៍នៃរឿងល្អមួយ។ សូមធ្វើការកត់សម្គាល់នូវការប្រើភាសា និងការរៀបរៀបចំព័ត៌មានក្នុងរបៀបមួយដែលច្បាស់ សាមញ្ញ និងយ៉ាងទំនងសមហេតុផល។



*ទាហាន និងអ្នកទោស ជារឿងដំណឹងទាន់ហេតុការណ៍បន្ទាន់មួយ*

### *កម្មកររោងចក្រកាត់ដេរនៅកម្ពុជាត្រដរក្នុងការចិញ្ចឹមជីវិត*

*Phnom Penh, Cambodia (AP) - លោក **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និយាយថា ការធ្លាក់ចុះនៃសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក បានបង្ខំឲ្យរោងចក្រកាត់ដេរចំនួន ១២ បិទទ្វារជាបណ្ដោះអាសន្នក្នុងឆ្នាំនេះ។*

*លោករដ្ឋមន្ត្រីនិយាយថា កម្មករកាត់ដេរប្រមាណ ៣.000 នាក់ ត្រូវបានផ្អាកពីការងារជាបណ្ដោះ-អាសន្ន ហើយថានឹងមានការងារច្រើនថែមទៀត ដែលនឹងអាចបាត់បង់ បើសិនជាស្ថានភាពមិនមានភាពប្រសើរឡើងវិញទេនោះ។*

*លោករដ្ឋមន្ត្រីបានបន្ថែមទៀតថា ទន្ទឹមនឹងនេះ កម្មកររាប់ពាន់នាក់ទៀត ត្រូវបានបង្ខំចិត្តធ្វើការតិចម៉ោងជាងមុន ដោយសារថារោងចក្រជាង ២00 បានកាត់បន្ថយម៉ោងថែម និងវេនការងារពីពីរវេនមកមួយវេនវិញ។*

*លោករដ្ឋមន្ត្រីនិយាយថា "បញ្ហាសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក ធ្វើឲ្យយើងមានកង្វល់ច្រើនអំពីប្រតិបត្តិការរបស់រោងចក្រ និងការងាររបស់កម្មករ"។*

*ឧស្សាហកម្មកាត់ដេរនៅកម្ពុជាមានកម្មករធ្វើការប្រមាណ ២00.000 នាក់ ដែលម្នាក់ៗរកចំណូលបានជាមធ្យមតែ ៤0 ដុល្លារអាមេរិកតែប៉ុណ្ណោះក្នុងមួយខែ។ ជាង ៨0 ភាគរយ នៃផលិតផលរបស់ឧស្សាហកម្មនេះ ត្រូវបានគេដឹកទៅលក់នៅសហរដ្ឋអាមេរិក។*

*លោករដ្ឋមន្ត្រីនិយាយថា ជាងពាក់កណ្ដាលឆ្នាំបានកន្លងផុតទៅហើយ ប៉ុន្តែកូតាប្រចាំឆ្នាំសម្រាប់ការនាំចេញផលិតផលកាត់ដេរទៅសហរដ្ឋអាមេរិក បំពេញមិនបាន ៤0 ភាគរយផង។ គាត់បានបន្ថែមទៀតថា កូតាក្នុងការនាំចេញផលិតផលកាត់ដេរទៅសហរដ្ឋអាមេរិកនេះ សឹងត្រូវបានបំពេញរួចបាត់ទៅហើយ ត្រឹមខែមិថុនា ឆ្នាំកន្លងទៅនេះ។*

បទពិពណ៌នាមានភាពទន់ភ្លន់ជាង។ គេអាចសរសេរវាបានតាមរបៀបច្រើនផ្សេងៗគ្នា។

អត្ថបទពិពណ៌នាមិនសូវមានភាពបន្ទាន់ប៉ុន្មានទេ ដូច្នេះអ្នកអានមិនមានភាពចាំបាច់ដឹងព័ត៌មានសំខាន់ៗបំផុតភ្លាមៗនោះទេ។ សេចក្ដីផ្ដើមរបស់វាអាចជាការរៀបរាប់អំពីមនុស្ស ឬអំពីទីកន្លែង ឬមួយក៏រៀបរាប់ព័ត៌មានផ្សេងទៀត ដែលតាក់តែងក្នុងរបៀបមួយ ធ្វើឲ្យអ្នកអានកាន់តែងឿងឆ្ងល់ចង់តាមដានថែមទៀត។ ចំណុចស្នូលក្នុងបទពិពណ៌នានោះត្រូវបានបង្ហាញឲ្យឃើញបន្ទាប់ពីសេចក្ដីផ្ដើមរបស់វា។

ខាងក្រោមជាឧទាហរណ៍បទពិពណ៌នាល្អមួយ។ សូមកត់សម្គាល់នូវសេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់ ដែលត្រូវបានតាក់តែងឡើងដោយមានការត្រិះរិះយ៉ាងល្អិតល្អន់ និងតភ្ជាប់ស៊ីសង្វាក់គ្នា។ សូមធ្វើការកត់សម្គាល់ផងដែរ នូវការប្រើប្រាស់ការពណ៌នា និងសម្រង់សម្ដីយ៉ាងប៉ិនប្រសប់។

### *ទិវាចូលឆ្នាំ គ្មានទេសេចក្ដីរីករាយសម្រាប់កុមារាខាត់ស្បែកជើងនៅវៀតណាម*

*Hanoi, Vietnam (AP) - ឌីន វ៉ាន់ទាន់ អាយុ ១៦ ឆ្នាំ មិនដែលធ្លាប់ស្គាល់អំពីទិវាចូលឆ្នាំម្ដងណាឡើយ។ ស្នូរផ្ទុះផាវដ៏អធិកអធមកងរំពងក្នុងក្រុងហាណូយ បានត្រឹមតែធ្វើឲ្យកុមារានេះកាន់តែភ័យខ្លាចថែមទៀត នៅក្នុងថ្ងៃដ៏កំសត់មួយទៀត ដែលគេកំពុងព្យាយាមរកប្រាក់ល្មមនឹងយកទៅទិញបាយហូប។*

*ព្រលឹមស្រាងឡើង រូបគេបានមកស្ថិតនៅមុខស្នាក់ការទីភ្នាក់ងារព័ត៌មាន The Associated Press ដៃទាំងពីររបស់គេក្ដាប់ជាប់ចម្រឹងដែកនៃរបង*

ខាងមុខ ហើយអើតក្បាលតាមប្រឡោះបង្រួចដែក ជាមួយនឹងទឹកមុខគួរឲ្យអាណិតអាសូរ ដែលមិនគួរមានចំពោះកុមារណាម្នាក់ឡើយ។ ក្នុងខោអាវគគ្រិចដែលជាខោអាវដដុះដែលគេបានទិញហើយ ដែលជាខោអាវតែមួយសម្រាប់គាត់ដែលគេមាន កុមាររូបនេះកំពុងសុំស្បែកជើងយកមកខាត់។

ទាប ហើយស្គម វ៉ាន់ទាន់ មើលទៅសមនឹងអាយុ ៩ ឬ ១០ ឆ្នាំប៉ុណ្ណោះ តែគេចេះជក់បារី។ រាល់ពេលឆ្លើយនឹងសំណួរ គេតែងសម្លឹងទៅរកចិញ្ចើមផ្លូវជាមួយនឹងការចងចិញ្ចើម ហើយសួរបកមកវិញថា តើមានស្បែកជើងសម្រាប់ខាត់ ឬទេ។ ជើងរបស់គេមានការពុកចាប់ដោយសារការដើរត្រាច់ចរ ១១ ម៉ោងក្នុងមួយថ្ងៃ ក្នុងទីក្រុងហាណូយនាសិសិរដូវ ដើម្បីស្វែងរកស្បែកជើងមកខាត់។

នៅថ្ងៃចូលឆ្នាំ កុមារនេះបានហូបតែនំអន្សមផ្អែមមួយគត់ ដែលអ្នកយកព័ត៌មានម្នាក់បានទិញឲ្យគេ និងផឹកទឹក ដែលអ្នកលក់ឥវ៉ាន់តាមដងផ្លូវម្នាក់បានឲ្យរូបគេក្នុងក្តីអាណិតអាសូរ។

វ៉ាន់ទាន់ និយាយថា "ថ្ងៃនេះ ខ្ញុំបានចំណីខ្លះញ៉ាំ តែថ្ងៃស្អែកប្រហែលជាអត់ទេមើលទៅ។ ខ្ញុំប្រាថ្នាថា នឹងរកប្រាក់បានច្រើនបន្តិចនៅថ្ងៃណាមួយ។ ខ្ញុំនឹងឲ្យលុយទៅឪពុកម្តាយរបស់ខ្ញុំ។ ខ្ញុំនឹងទិញរថយន្តមួយគ្រឿង ផ្ទះមួយ ហើយរស់នៅក្នុងជីវិតមួយរីករាយរហូតដល់ថ្ងៃខ្ញុំស្លាប់"។

វ៉ាន់ទាន់ ស្ថិតក្នុងចំណោមកុមារមានសម្លៀក-បំពាក់រយ៉េររយ៉ៃ ប្រដាប់ដោយប្រអប់ឈើកញ្ចាស់ផ្ទុកដោយឧបករណ៍ខាត់ស្បែកជើង ហើយត្រាច់ចររាល់ថ្ងៃតាមដងវិថី Tran Hung Dao កណ្តាលទីក្រុង ដើម្បីស្វែងរកអតិថិជននៅតាមភោជនីយ-ដ្ឋាន បារ ការិយាល័យក្រុមហ៊ុន និងស្ថានទូតបរទេស។

ពួកគេស្វែងរកពួកពាណិជ្ជករវណ្ណៈថ្មី បង្កើតឡើងដោយកំណែទម្រង់ផ្សារសេរីរបស់វៀតណាម ដែលបាននាំគ្នាគ្រវែងចោលស្បែកជើងសង្រែកប្រពៃណីធ្វើអំពីកៅស៊ូប្លាស្ទិក ហើយជ្រើសយកស្បែកជើងខ្មៅរធ្វើអំពីស្បែកសត្វមកជំនួសវិញ។

*"Shoeshine, shoeshine,"* ជាពាក្យអង់គ្លេសតែពីរម៉ាត់គត់ ដែលកុមារទាំងនោះចេះបន្លឺ។

ដូចគ្នានឹង វ៉ាន់ទាន់ ដែរ ភាគច្រើននៃកុមារទាំងនោះ បានចាកចេញពីគ្រួសារកសិករក្រីក្ររបស់ពួកគេនៅតាមជនបទមកកាន់រដ្ឋធានីហាណូយ។ ពួកគេចំណាយពេលមួយចំណែកធំនៃជីវិតប្រចាំថ្ងៃរបស់ពួកគេនៅលើដងវិថី ដោយគ្មានមនុស្សពេញវ័យណាណែនាំពួកគេ ថ្នាក់ថ្នមពួកគេ ឬក៏ឲ្យវត្ថុអនុស្សាវរីយ៍ចូលឆ្នាំដល់ពួកគេឡើយ។

វ៉ាន់ទាន់ បានមកដល់ក្រុងហាណូយកាលពីពីរឆ្នាំមុនជាមួយមិត្តម្នាក់ ឥឡូវមានអាយុ ១៥ ឆ្នាំ ដែលរសាត់អណ្តែតតាមដងវិថីជាមួយគេដែរ។ មុនដំបូងពួកគេលក់អំពៅ តែក្រោយមកក៏នាំគ្នាទិញប្រអប់ខាត់ស្បែកជើងវិញ ក្នុងតម្លៃប្រមាណ ៣០ សេនអាមេរិក។

វ៉ាន់ទាន់ និយាយថា រូបគេជិតស្និទ្ធជាមួយឪពុកម្តាយរបស់គេ ហើយពួកគេចង់ឲ្យវាវិលត្រឡប់ទៅផ្ទះវិញ។ ប៉ុន្តែ វ៉ាន់ទាន់ និយាយថា គេមិនអាចត្រឡប់ទៅវិញដោយគ្រួសាររបស់គេក្រពេក។ គេមិនអាចខាត់ស្បែកជើងបានទេនៅខេត្ត Hai Huang ពីព្រោះនៅទីនោះ "គ្មានអ្នកណាមានស្បែកជើងខ្មៅរពាក់ទេ"។

រូបគេធ្លាប់បានចូលរៀនដែរ តែបានតែពីរឆ្នាំប៉ុណ្ណោះ ហើយមិនចេះអាន ឬសរសេរអក្សរឡើយ។ រូបគេសឹងមិនដែលបានលេងកំសាន្តទេ លើកលែងតែជួនកាលគេទាត់លេងកូនបាល់មួយ ដែលធ្វើអំពីបំពង់បឺត បន្ទះកៅស៊ូ និងកៅស៊ូកង់។

វ៉ាន់ទាន់ ត្រូវបង់ប្រហែល ៩ សេនអាមេរិក ក្នុងមួយថ្ងៃ ដើម្បីដេកក្នុងផ្ទះសំណាក់មួយមានពីរបន្ទប់

*ជាមួយមនុស្ស ២០ នាក់ផ្សេងទៀត ដែលភាគច្រើនជាអ្នកលក់ឥវ៉ាន់កំប៉ិកកំប៉ុកតាមដងផ្លូវ។ នៅទីនោះគ្មានបង្គន់ទេ។ ជារៀងរាល់ថ្ងៃ វ៉ាន់ទាន់ ចំណាយពេលមួយម៉ោង ដើម្បីដើរទៅវិថី Tran Hung Dao និងមួយម៉ោងទៀត សម្រាប់ត្រឡប់មកវិញនាពេលល្ងាច។ ព្រឹកឡើងម៉ោងមិនទាន់ ៦ ផង រូបគេបានមកដល់លើដងវិថីនេះរួចទៅហើយ។*

*ជាធម្មតា អតិថិជនទីមួយៗបង់ឲ្យ វ៉ាន់ទាន់ ប្រហែល ១១ សេនអាមេរិក : បើថ្ងៃណាសំណាងល្អ វ៉ាន់ទាន់ រកបានអតិថិជនពីរ ឬបីនាក់ដែរ។ តែដោយសារនៅលើដងវិថីនោះ មានកុមារខាត់ស្បែកជើងកាន់តែច្រើន ការរកលុយចិញ្ចឹមជីវិតក៏កាន់តែលំបាកផងដែរសម្រាប់ វ៉ាន់ទាន់។ មកទល់នឹងល្ងាចថ្ងៃចូលឆ្នាំថ្មីទៅហើយ វ៉ាន់ទាន់ រកបានអតិថិជនតែម្នាក់គត់ គឺអ្នកយកព័ត៌មានដែលសម្ភាសន៍រូបគេនោះ។*

*វាជាការលំបាកមួយក្នុងការនាំឲ្យវ៉ាន់ទាន់ជជែក : គេមានអារម្មណ៍ថាមិនសូវមានអ្វីនឹងនិយាយទេ។ គេអង្គុយលើដៃយួរនៃប្រអប់របស់គេ។ នៅលើថ្ពាល់ខាងស្តាំមានស្នាមប្រឡាក់ពណ៌ខ្មៅ។ គេពាក់ស្បែកជើងសង្រែកប្លាស្ទិកមានតម្លៃថោក ហើយប្រអប់ជើងរបស់គេ ត្រូវបានគ្របដណ្តប់ដោយល្អងធូលីតាមដងផ្លូវ។ ជារឿយៗ វ៉ាន់ទាន់ ក្បាលរបស់គេយ៉ាងរហ័សក្នុងសភាពវង្វេងវង្វាន់ ពេលណាដែលមានសម្លេងផាវផ្ទុះរំពងលើដងវិថី។*

នៅមានប្រភេទរឿងទីបី ដែលប្រាប់តិចនិកសរសេរបទពិពណ៌នា និងដំណឹងចូលគ្នា។ រឿងប្រភេទនេះ ត្រូវបានជួនកាលគេហៅថា "ដំណឹងពិពណ៌នា"។ ក្នុងអត្ថបទប្រភេទនេះ នាដកម្មក្នុងព្រឹត្តិការណ៍មាន ត្រូវបានគេរៀបរាប់ឡើងវិញជាមួយការរ៉ាយរ៉ាប់ក្បោះក្បាយ សម្រង់សម្តីដែលប្រកបដោយថាមពល។ វិធីរបៀបនេះអាចប្រើក្នុងការសរសេររឿង តាមរយៈក្រសែភ្នែករបស់អ្នកដែលបានពាក់ព័ន្ធផ្ទាល់ក្នុងព្រឹត្តិការណ៍ ដូចជា អ្នកពន្លត់អគ្គីភ័យ ដែលបានសង្គ្រោះគ្រួសារមួយឲ្យរួចផុតពីអគារមួយដែលកំពុងឆាបឆេះ អ្នករស់រានមានជីវិតពីខ្យល់ព្យុះស៊ីក្លូន ដោយតោងខ្លួននឹងដើមត្នោត ឬមួយក៏តាមរយៈស្ត្រីម្នាក់ ដែលបានឃើញដោយផ្ទាល់ភ្នែកនូវអំពើប្លន់ធនាគារ។

ខាងក្រោមនេះ ជាឧទាហរណ៍មួយនៃអត្ថបទដំណឹងពិពណ៌នារបស់អ្នកឆ្លើយឆ្លងព័ត៌មាន The Associated Press ប្រចាំនៅភាគខាងជើងប្រទេសវៀតណាម។ សូមកត់សម្គាល់នូវរបៀបដែលរឿងនេះចាប់ផ្តើមឡើង ដូចបទពិពណ៌នាដោយផ្តោតទៅលើមនុស្សម្នាក់ ដែលត្រូវបានទទួលរងគ្រោះដោយសារទឹកជំនន់ ហើយបន្តផ្នែកឯទៀតនៃសាច់រឿងក្នុងទម្រង់ជាអត្ថបទដំណឹងទាន់ហេតុការណ៍ទៅវិញ។

### *ចំនួនមនុស្សស្លាប់បន្តកើនឡើងក្នុងគ្រោះទឹកជំនន់នៅវៀតណាម*

*Hanoi - លោក ត្រាន់ ស៊ាន់មៀន បានខំប្រឹងចំណាយពេលពេញមួយថ្ងៃរួចទៅហើយ ដើម្បីសម្អាតភក់ និងកំទេចកំទីចេញពីផ្ទះរបស់គាត់ ដែលត្រូវបានលិចដោយសារទឹកជំនន់ ប៉ុន្តែបានត្រឹមតែជាទីបំផុតទឹកនៅតែបន្តហូរចូលផ្ទះរបស់គាត់វិញដដែលនៅថ្ងៃអង្គារ៍កន្លងទៅនេះ។*

*លោក ត្រាន់ ស៊ាន់មៀន ដែលមានអាយុ ៦២ ឆ្នាំ និងរស់នៅក្នុងទីក្រុងហាណូយ មានប្រសាសន៍ថា "ខ្ញុំនឿយហត់ណាស់។ ផ្ទះរបស់ខ្ញុំ ត្រូវបានទឹកហូរចូលពេញទៀតហើយ"។*

*កាលពីថ្ងៃច័ន្ទ កន្លងទៅនេះ ភ្លៀងបានស្ងប់ច្រើនណាស់ទៅហើយ ប៉ុន្តែវាក៏ចាប់បន្តបង្អុរឡើងវិញនៅថ្ងៃអង្គារ៍ ហើយចំនួនមនុស្សស្លាប់ដោយសារទឹកជំនន់ ក៏នៅបន្តកើនទៀតដែរក្នុងប៉ុន្មានថ្ងៃមកនេះ។*



ជនរងគ្រោះនៃគ្រោះមហន្តរាយ ក៏មានសិទ្ធិរក្សាសេចក្ដីថ្លៃថ្នូររបស់គេដែរ

អាជ្ញាធរប្រកាសឲ្យដឹងថាពួកគេបានរកឃើញសពចំនួន ១៩ ថែមទៀត ដែលធ្វើឲ្យចំនួនអ្នកស្លាប់មកទល់ពេលនេះមាន ៨៥ នាក់ហើយ។

ក្នុងពេលជាមួយគ្នានេះដែរ ពលរដ្ឋរស់នៅក្នុងរដ្ឋធានី ជាកន្លែងដែលអ្នកព្យាករណ៍អាកាសធាតុនិយាយថា សន្ទឹកភ្លៀងធ្លាក់មានសភាពធ្ងន់ធ្ងរជាងគេក្នុងរយៈពេល ៣៥ ឆ្នាំមកនេះ កំពុងនាំគ្នាប្រឹងសម្អាតលំនៅស្ថានរបស់ពួកគេ។

លោក ត្រាន់ ស៊ាន់មៀន បានលើកម៉ាស៊ីនបោកគក់ ទូទឹកកក និងទោចក្រយានយន្តពីរគ្រឿងរបស់គាត់ដាក់ទៅលើគំនរឥដ្ឋ ដើម្បីរក្សារបស់ទាំងនោះឲ្យផុតពីទឹក។

គាត់និយាយថា "ខ្ញុំបាន និងកំពុងរស់នៅទីនេះតាំងពីឆ្នាំ ១៩៨៤ មក ប៉ុន្តែខ្ញុំមិនដែលឃើញភ្លៀងច្រើនបែបនេះទេ"។

អ្នកព្យាករណ៍អាកាសធាតុបានព្យាករណ៍ទុកថាភ្លៀងនឹងបន្តមានបន្ថែមទៀតក្នុងថ្ងៃខាងមុខ ប៉ុន្តែវានឹងមានសភាពស្រាលជាងការបង្អុរដោកជាំលើតំបន់កាលពីចុងសប្ដាហ៍កន្លងទៅនេះ។

នៅពេលដែលបណ្ដាដងទន្លេ និងបឹងបួរ ក្នុងតំបន់ដីសណ្ដទន្លេក្រហម មានសភាពជោរជន់ហើយនោះ អាជ្ញាធរមានការខ្វល់ខ្វាយថាទំនប់ទឹកអាចនឹងបាក់។ ទាហានប្រមាណ ៩.០០០ នាក់ត្រូវបានគេពង្រាយ ដើម្បីជួយធ្វើការជួសជុលបន្ទាន់នូវការខូចខាតហេដ្ឋារចនាសម្ព័ន្ធនានា។

មានមនុស្ស ៦.០០០ នាក់ផ្សេងទៀត ត្រូវបានគេបញ្ជូនឲ្យទៅជួយ ៣៥.០០០ គ្រួសារផ្សេងទៀត ដែលទទួលរងនូវការប៉ះពាល់ដោយទឹកជំនន់ក្នុងរដ្ឋធានីហាណូយ ដែលនៅទីនោះភូមិដ្ឋានចំនួន ២៣ ត្រូវបានទឹកលិចក្នុងកំពស់ជាង ៣០ សង់ទីម៉ែត្រ។

*នៅថ្ងៃអង្គារ៍នេះ កំពស់ទឹកក្នុងរដ្ឋធានីហាណូយបានស្រកវិញបន្តិចហើយ ប៉ុន្តែសាលានៅបន្តបិទទ្វារដដែល ហើយនៅកន្លែងខ្លះទៀត សំរាម និងកំទេចកំទីនៅតែបន្តអណ្តែតចូលលំនៅដ្ឋានដែលលិចទឹក។*

*លោកស្រី ង្វៀន ធីលៀន អាយុ ៦៧ ឆ្នាំ និយាយថា "ផ្ទះរបស់ខ្ញុំកំពុងត្រូវបានទឹកហ៊ុំព័ទ្ធនៅឡើយ ហើយទឹកនឹង វាមានក្លិនអាក្រក់ណាស់។ យើងមានទឹកតិចតួចណាស់សម្រាប់ចម្អិនអាហារតែប៉ុណ្ណោះ ហើយពួកយើងមិនបានងូតទឹកចំនួនបួនថ្ងៃរួចមកហើយ"។*

*លោក ង្វៀន ហ៊ុយង៉ា ដែលជាមន្ត្រីក្រសួងសុខាភិបាល និយាយថា អាជ្ញាធរវៀតណាមកំពុងមានក្តីព្រួយបារម្ភអំពីលទ្ធភាពនៃការផ្ទុះជំងឺផ្សេងៗដែលមានប្រភពពីទឹក។*

*គាត់និយាយថា "ជំងឺរាករូស អាសន្នរោគ និងគ្រុនពោះវៀន អាចកើតមានមួយសប្តាហ៍ក្រោយទឹកជំនន់ ហើយជំងឺគ្រុនឈាម ក៏ជាកង្វល់មួយផងដែរ"។*

*ទឹកជំនន់នៅភាគកណ្តាលវៀតណាម បានសម្លាប់មនុស្ស ៤១ នាក់ ហើយ ៤៤ នាក់ផ្សេងទៀតបានស្លាប់នៅខេត្តមួយចំនួននាភាគខាងជើង ក្នុងនោះ ២០ នាក់ នៅក្នុងរដ្ឋធានីហាណូយ។*

*បើទោះជាភ្លៀងបានស្រន់បន្តិចទៅវិញហើយក្តី នៅភូមិភាគកណ្តាល ទឹកជំនន់នៅតែបន្តកាត់ផ្តាច់តំបន់ដាច់ស្រយាលមួយចំនួនទៀតនៅឡើយ។*

*លោក ផាម វៀតភូ មន្ត្រីគ្រោះមហន្តរាយនៅខេត្តង៉េអាន ដែលជាខេត្តទទួលការប៉ះទង្គិចខ្លាំងជាងគេ មានប្រសាសន៍ថា "ផ្លូវទៅកាន់ភូមិទាំងនោះនៅលិចទឹកនៅឡើយ។ ចំនួនមនុស្សស្លាប់អាចកើនថែមទៀត"។*

(យើងនឹងពិនិត្យមើលសេចក្តីផ្តើម និងទម្រង់អត្ថបទដំណឹង និងអត្ថបទពិពណ៌នាឲ្យបានជិតដល់ថែមទៀតនៅក្នុងជំពូកទី ៨ និង ៩)

## រូបមន្ត 5 Ws និង H

គ្រប់រឿងទាំងអស់ ត្រូវតែមានលក្ខណៈគ្របដណ្តប់ទៅលើសំណួរគន្លឹះមួយចំនួន។ គេតែងហៅសំណួរគន្លឹះទាំងនោះថា 5 Ws និង H ។

**WHO -** អ្នកណាខ្លះពាក់ព័ន្ធក្នុងរឿងនេះ?

**WHAT -** មានអ្វីកើតឡើងដែលសំខាន់គួរឲ្យចាប់អារម្មណ៍នោះ?

**WHERE -** ដំណឹងនោះកើតនៅឯណា?

**WHEN -** តើវាកើតឡើងនៅពេលណា?

**WHY -** ហេតុអ្វីបានជាមានរឿងហ្នឹងកើតឡើង? ហើយ

**HOW -** ថាតើវាកើតឡើងដូចម្តេច?

ទាំងនេះជាសំណួរដែលមនុស្សទាំងអស់គេនឹងសួរនៅពេលដែលគេចង់ដឹងថែមទៀតអំពីអ្វី ដែលមួយដែលបានកើតឡើង។ គ្មានរឿងណាមួយនឹងមានភាពពេញលេញបានទេ ដរាបណាដែលវាមិនបានគ្របដណ្តប់លើសំណួរ 5 Ws និង H។ សូម្បីតែអ្នកយកព័ត៌មានដែលមានបទពិសោធន៍រាប់ឆ្នាំក៏ដោយ ក៏ពួកគេនៅប្រើនូវបញ្ជីផ្ទៀងផ្ទាត់រូបមន្តនេះមុននឹងគេប្រគល់រឿងរបស់គេសម្រាប់ធ្វើការបោះផ្សាយ។

ខាងក្រោមនេះ ជារឿងរបស់ក្រុមហ៊ុនផ្សាយតាមរលកធាតុអាកាសប្រចាំតំបន់មួយ ៖

*ប្រទេសចំនួនប្រាំជាប់ដងទន្លេមេគង្គរបស់តំបន់អាស៊ីអាគ្នេយ៍ កំពុងធ្វើការសិក្សាលើផែនការមួយដើម្បីបង្កើតសមាគមន៍ប្រជាជាតិនាំចេញអង្ករ។ នាយករដ្ឋមន្ត្រីវៀតណាម ប្រកាសអំពីផែនការនេះកាលពីម្សិលមិញ បន្ទាប់ពីកិច្ចប្រជុំកំពូលរបស់ប្រជាជាតិដងទន្លេមេគង្គបួនទៀត មានប្រទេសថៃ កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។*



ដែរអំពីសំណួរ Why (គឺថាប្រទេសទាំងនេះដើរតួសំខាន់មួយដែរ ក្នុងការផ្តល់ស្បៀងដល់ពិភពលោក) ប៉ុន្តែវាមិនបានបង្ហាញហេតុផលទាំងអស់នោះទេ។ ធម្មតាគេបង្កើត Cartels ដើម្បីឲ្យក្រុមហ៊ុនអាចគ្រប់គ្រងតម្លៃទំនិញដែលពួកគេនាំចេញ។ ទាក់ទងនឹងសំណួរ How នៅក្នុងរឿងនេះមិនទាន់មានការពន្យល់ច្បាស់លាស់នៅឡើយទេ។

*បុះវាយ៉ាងម៉េច? តើស្អីខ្លះដែលធ្វើឲ្យទៅជារឿង?*

*លោកនាយករដ្ឋមន្ត្រីនិយាយថា ប្រជាជាតិទាំងនេះជាជង្រុកផលិតស្រូវរបស់តំបន់អាស៊ី ហើយការនាំចេញអង្ករបស់ពួកគេរួមគ្នាមានបរិមាណប្រមាណជា ៥០ ភាគរយ នៃទីផ្សារពិភពលោក ដូច្នេះពួកគេមានតួនាទីមួយសំខាន់ក្នុងការធានាសន្តិសុខស្បៀងពិភពលោកដែរ។*

*ប្រទេសថៃ កាលពីខែមេសាកន្លងទៅ បានលើកគំនិតបង្កើតក្រុមប្រទេសនាំអង្ករចេញ នៅពេលដែលតម្លៃលើគ្រាប់ធញ្ញជាតិកំពុងឡើងថ្លៃខ្ពស់ខុសធម្មតា។ ប៉ុន្តែប្រទេសថៃបានដកថយពីផែនការនេះ បន្ទាប់ពីធនាគារអភិវឌ្ឍន៍អាស៊ី និងប្រជាជាតិនាំអង្ករចូលដទៃទៀតបានរិះគន់ផែនការនោះ ដោយនិយាយថាវានឹងបង្កើនភាពអត់ឃ្លាន និងភាពក្រីក្របែមទៀត។*

រឿងនេះមានធាតុផ្សំ Who (ប្រទេសទាំងប្រាំនៅតាមដងទន្លេមេគង្គ នាយករដ្ឋមន្ត្រីវៀតណាម ធនាគារអភិវឌ្ឍន៍ អាស៊ី), What (ការសិក្សាផែនការបង្កើតសមាគមន៍ប្រទេសនាំអង្ករចេញ), Where (អាស៊ីអាគ្នេយ៍ ក្រុងហាណូយ) ហើយនិង When (កាលពីម្សិលមិញ, ខែមេសា)។ មានការពន្យល់ខ្លះ

***បូរនាំគ្នាពិនិត្យមើលរឿងខាងក្រោមរបស់កាសែត The Nation នៃប្រទេសថៃ ៖***

*PATTAYA, Chon Buri - ទេសចរសញ្ជាតិរុស្ស៊ីម្នាក់បានស្លាប់ បន្ទាប់ពីរបូតខ្លួនធ្លាក់ពីលើសំយ៉ាបសណ្ឋាគារមួយនៃទីក្រុងឆ្នេរសមុទ្រមួយនេះ កាលពីថ្ងៃអង្គារ៍។*

*នគរបាលបានឲ្យដឹងអត្តសញ្ញាណទេសចរនោះថាជាបុរសមានអាយុ ២៨ ឆ្នាំ។*

*នគរបាលនិយាយថា បុរសនោះបានរបូតខ្លួនធ្លាក់ពីសំយ៉ាបនៅជាន់ទី ១១ របស់សណ្ឋាគារ Adriatic Palace Hotel Pattaya មកជាន់ទីបី នៅវេលាម៉ោង ១២:២០ នាទី រំលងអាធ្រាតថ្ងៃអង្គារ៍។ បុរសនោះស្នាក់នៅបន្ទប់ជាន់ទី ២៥ ជាមួយនឹងមិត្តស្រីរបស់គាត់។*

*សាក្សីនិយាយថា ទេសចរទាំងពីររូបកំពុងវិលត្រឡប់ទៅកាន់បន្ទប់របស់ពួកគេវិញ ប៉ុន្តែដោយបែជន្យ ពួកគេប្រឡំចេញពីប្រអប់ជណ្តើរយន្តនៅជាន់ទី ១១។ ពេលរង់ចាំជណ្តើរយន្តថ្មីមកដល់ ដើម្បីបន្តដំណើរទៅបន្ទប់ ពួកគេទាំងពីររូបប្រឡែង*

*គ្នាលេងដោយផ្លាស់វេនលីគ្នាម្តងម្នាក់ មុននឹងបុរសនោះរបូតខ្លួនធ្លាក់ពីលើសំយ៉ាប។*

រឿងនេះប្រាប់អំពី Who (ទេសចរសញ្ជាតិរុស្ស៊ីអាយុ ២៨ ឆ្នាំ, មិត្តស្រីរបស់គាត់, នគរបាល, សាក្សី), អំពី What (ស្លាប់បន្ទាប់ពីធ្លាក់ពីសំយ៉ាបសណ្ឋាគារ), អំពី Where (សណ្ឋាគារមួយនៅប៉ាតាយ៉ា), អំពី When (ព្រឹកថ្ងៃអង្គារ៍), និងអំពី Why និង How (ដោយមូលហេតុថាគាត់ និងមិត្តស្រីរបស់គាត់កំពុងលីគ្នាម្តងម្នាក់នៅក្បែរសំយ៉ាប)។

### *ឥឡូវងាកមកមើលសេចក្តីផ្តើមនៃរឿងមួយពីកាសែតកម្ពុជាវិញម្តង ៖*

*ក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមានទីតាំងនៅលើវិថីនរោត្តម ក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ ជិតវត្តភ្នំ បានរលំបាក់ខ្ទេចខ្ទី ហើយធ្វើឲ្យមនុស្សបីនាក់រងរបួស ក្នុងនោះ មានបីនាក់របួសធ្ងន់។*

*យោងតាមលោក អ៊ុក ចាន់ រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន អគារមួយនេះជាបន្ទប់ប្រជុំរបស់លោករដ្ឋមន្ត្រី ឃី តាំងលីម ហើយវារលំនៅម៉ោង ៨:៣០ នាទីព្រឹក នៅថ្ងៃសុក្រទី ២៣ ខែមីនា ២០០១។*

អត្ថបទនេះអូសបន្លាយរាប់រយពាក្យតទៅទៀត។ តែវាមិនប្រាប់ឲ្យយើងដឹងថាអ្នកដែលរងរបួសនោះជាអ្នកណាទេ។ ជាកម្មករ? ជាអ្នកដែលដើរក្បែរនោះ? បុរស? ស្ត្រី? កុមារ? អ្វីដែលយើងអាចដឹងបានអំពីអ្នករបួសមានតែនៅក្នុងសេចក្តីផ្តើមប៉ុណ្ណោះឯង។ អ្នកសរសេរចំណាយភាគច្រើនបំផុតនៃរឿងរបស់គាត់សម្រាប់តែពិពណ៌នាថា តើអគារនោះត្រូវបានគេប្រើធ្វើអ្វី តើវាចាស់ប៉ុណ្ណា និងចោទជាចម្ងល់ខ្លួនឯងថា តើវានឹងទៅជាយ៉ាងណាទៅវិញ បើសិនជាពេលនោះ អង្គប្រជុំមួយកំពុងប្រព្រឹត្តទៅខាងក្នុង ស្រាប់តែអគារនោះរលំ។ អ្នកសរសេរភ្លេចចោលឲ្យឈឹងអំពីជនរងគ្រោះប្រាំពីររូប ហើយហាក់ដូចជាមានការខ្វល់ខ្វាយច្រើនជាង អំពីការដែលថាសំណាងអ្វីម្ល៉េះ ដោយក្នុងឧបទ្ទវហេតុនោះ មិនមានមន្ត្រីជាន់ខ្ពស់ណាម្នាក់រងរបួសទៅវិញ។

សូមមើលរឿងខាងក្រោម ដែលត្រូវបានដកស្រង់ចេញពីផ្នែកអង់គ្លេសនៃកាសែតវៀតណាមមួយ ៖

### *អ្នកប្រណាំងកង់ដណ្តើមបានអាវយឺតពណ៌លឿងក្នុងការប្រណាំងនៅប្រទេសថៃ*

*អ្នកប្រណាំងកង់ពីររូប Hoang Thi Thanh Tam និង Nguyen Nam Cuc ដណ្តើមបានអាវយឺតពណ៌លឿង ក្នុងការប្រណាំងកង់នៅប្រទេសថៃ។*

*Hoang Thi Thanh Tram បានឈ្នះអាវយឺតពណ៌លឿងទីមួយក្នុងការប្រណាំងសម្រាប់ជនវ័យក្មេង។ រីឯកីឡាករ Nguyen Nam Cuc វិញ រូបគេដណ្តើមជ័យជំនះបានអាវលឿងក្នុងការប្រកួតបុរសខ្នាតអន្តរជាតិ។*

*ចូលរួមក្នុងការប្រកួតនោះ មានអ្នកប្រណាំងកង់ ១៤៥ រូប មកពីប្រទេសថៃ អ៊ុសបៀគីស្ថាន ហ្វីលីពីន ហុងកុង ម៉ាឡេស៊ី វៀតណាម និងសាធារណរដ្ឋកូរ៉េ។*

*ពួកគេកំពុងប្រកួតវិញ្ញាសារសម្រាប់បុរស និងស្ត្រីវ័យក្មេង និងក្នុងខ្នាតអន្តរជាតិ។*

តើទូរប្រណាំងកង់នោះឈ្មោះអ្វី? តើវាជាការប្រណាំងប្រជែងធំដុំដែរទេ? ស្អីទៅអាវយឺតពណ៌លឿងហ្នឹង? តើគេប្រកួតក្នុងចម្ងាយប៉ុន្មានគីឡូម៉ែត្រ? តើការប្រកួតនេះធ្វើឡើងពីពេលណា? នៅឯណាក្នុងប្រទេសថៃ? តើមានរង្វាន់ជ័យលាភីទេ?

ហើយបើសិនជាអស់លោកសរសេរកាសែតមួយនៅវៀតណាម តើលោកអ្នកមិនគួរប្រាប់អ្នកអានរបស់អ្នកឲ្យបានដឹងច្រើនបន្តិចអំពីអ្នកប្រណាំងកង់វៀតណាមទាំងពីររូបនោះទេ ឬ? សូមធ្វើការកត់សម្គាល់ផងដែរ អំពីការប្រកបខុសគ្នានូវឈ្មោះតែមួយ Tam និង Tram ។

## ចុះវាយ៉ាងម៉េច? (So what?)

សំណួរថា ចុះវាយ៉ាងម៉េច? (So what?) មានសារៈសំខាន់ដូចគ្នានឹង 5 Ws និង H ដែរ ។ អ្នកបានប្រាប់អ្នកអានរបស់ខ្លួនអំពីដំណឹងរួចហើយ ប៉ុន្តែពួកគេក៏ចង់ដឹងដែរថា ៖ ហេតុអ្វីខ្ញុំគួរខ្វល់នឹងរឿងហ្នុង? ហេតុអ្វី ខ្ញុំគួរទៅអំពល់អានរឿងហ្នុង? កិច្ចការជាអ្នកកាសែត មិនគ្រាន់តែផ្តល់អ្នកអាននូវព័ត៌មានប៉ុណ្ណោះទេ តែត្រូវពន្យល់អំពីសារៈសំខាន់នៃព័ត៌មាននោះឲ្យពួកគេបានជ្រាបផងដែរ ។

ជារឿយៗ អ្នកសារព័ត៌មានរាយការណ៍អំពីការវិវត្តសភាពការណ៍នយោបាយស្មុគស្មាញថ្មីៗ ប៉ុន្តែមិនបានពន្យល់អំពីសារៈសំខាន់នៃការវិវត្តនោះទេ ។ បើមិនដូច្នោះទេ ពួកគេសរសេររឿងដែលពេញទៅដោយការចោទប្រកាន់ពីគ្រប់ភាគីទាំងអស់ តែមិនបានពន្យល់ថាហេតុអ្វីបានជាវិវាទ និងវាសំខាន់ ។

នៅលើរាល់រឿង ចូរសួរខ្លួនឯងថា ៖

- តើអ្វីទៅដែលសំខាន់បំផុតអំពីព្រឹត្តិការណ៍នេះ ឬអំពីការវិវត្តមួយនេះ?
- ហេតុអ្វីអ្នកអាន ឬអ្នកស្តាប់របស់ខ្ញុំចាំបាច់ត្រូវដឹងអំពីរឿងនេះ?
- តើរឿងហ្នឹង វានឹងមានផលប៉ះពាល់បែបណាទៅលើជីវភាពរស់នៅរបស់ពួកគេ?

បើសិនជាលោកអ្នកមិនអាចគិតឃើញវាហេតុអ្វីបានជាអ្នកអានគួរអំពល់អានរឿងរបស់អ្នក ប្រហែលជាលោកអ្នក មិនគួរចំណាយពេលសរសេរវាទេ ។

នៅក្នុងរឿងខាងលើ ដែលនិយាយអំពីការបិទរោងចក្រកាត់ដេរនៅប្រទេសកម្ពុជាដែលយើងបានឃើញរួចមក ហើយនៅក្នុងជំពូកនេះ វាក្យខ័ណ្ឌទីពីរបានឆ្លើយនឹងសំណួរថា ចុះវាយ៉ាងម៉េច? (So what?)

*លោករដ្ឋមន្ត្រីនិយាយថា កម្មករកាត់ដេរប្រមាណ ៣.០០០ នាក់ ត្រូវបានផ្អាកពីការងារជាបណ្តោះអាសន្ន ហើយថានឹងមានការងារច្រើនថែមទៀត ដែលនឹងអាចបាត់បង់ បើសិនជាស្ថានភាពមិនមានភាពប្រសើរឡើងវិញទេនោះ ។*

នៅក្នុងរឿងមួយទៀតស្តីអំពីផែនទីទឹកជំនន់នៅប្រទេសមីយ៉ាន់ម៉ា អ្នកយកព័ត៌មានស្តែងឲ្យឃើញយ៉ាងច្បាស់នៅក្នុងប្រយោគទីមួយតែម្តង (សូមមើលពាក្យដែលមានបន្ទាត់គូសពីក្រោម) ថាហេតុអ្វីបានជាវាសំខាន់ ៖

*ផែនទីស្តីពីគ្រោះថ្នាក់ដោយទឹកជំនន់ ដែលនឹងជួយការពារអគារនានាឲ្យផុតពីការខូចខាតបង្កដោយទឹក កំពុងត្រូវបានធ្វើជិតរួចរាល់ហើយ ។ ការងារធ្វើផែនទីនេះ បានចាប់ផ្តើមកាលពីខែកក្កដា បន្ទាប់ពីមានការបំផ្លិចបំផ្លាញ ដែលបណ្តាលមកពីព្យុះស៊ីក្លូនណាហ្គ្រីស កាលពីខែឧសភា កន្លងទៅ ។*

ខាងក្រោមនេះជារឿងមួយពីក្នុងកាសែត Bangkok Post ដែលបង្ហាញថា ហេតុអ្វីបានជាការផ្ទុះថ្មីនូវជំងឺគ្រុនបក្សី ជាមូលហេតុនៃការព្រួយបារម្ភមួយ ។ សូមអានផ្នែករបស់រឿងដូចតទៅ ៖



ចូរពន្យល់ថាតើគោលនយោបាយសេដ្ឋកិច្ចមានផលប៉ះពាល់ទៅលើប្រជាជនសាមញ្ញដូចម្ដេចខ្លះ

## ករណីជំងឺគ្រុនបក្សីថ្មីផ្ទុះឡើងនៅខេត្តសុខោទ័យ

ជំងឺគ្រុនបក្សី ត្រូវបានគេរកឃើញនៅកន្លែងបិញ្ចឹមមាន់ប្រាំបួនកន្លែងនៅក្នុងខេត្តសុខោទ័យ នាប៉ែកខាងជើងប្រទេស ដែលបណ្ដាលឲ្យមានក្ដីព្រួយបារម្ភថ្មីទៀតអំពីការផ្ទុះមេរោគ H5N1 ។

លោក Sakchai Sribonnsue ប្រធាននាយកដ្ឋានអភិវឌ្ឍន៍បសុសត្វ និយាយថា ការវិភាគមន្ទីរពិសោធន៍លើកាកសំណល់របស់សត្វមាន់ពីស្រុក Thung Saliam បានបង្ហាញឲ្យឃើញថា មាន់ដែលងាប់នោះ មានមេរោគ H5N1 ។

លោក Sakchai និយាយថា មាន់ស្រុកទាំង ១៧ ក្បាល នៅក្នុងកសិដ្ឋានបិញ្ចឹមមាន់នោះ ត្រូវបានសម្លាប់ចោល ដើម្បីទប់ស្កាត់ការឆ្លងជំងឺ ។

គាត់បន្ថែមទៀតថា នាយកដ្ឋានរបស់លោក បានប្រកាសតំបន់ក្បែរកសិដ្ឋាននោះថាជាតំបន់មានការផ្ទុះជំងឺគ្រុនបក្សី ដើម្បីជួយសម្រួលដល់ប្រតិបត្តិការគ្រប់គ្រងជំងឺកាលពីសប្ដាហ៍មុន ក្រោយពីមានមាន់ប្រាំក្បាលងាប់ ។

នេះជាលើកទីបីហើយ ដែលមានករណីផ្ទុះជំងឺគ្រុនបក្សីឆ្នាំនេះ ។ ករណីពីមុននេះ បានកើតឡើងនៅក្នុងស្រុក Chumsaeng នៃខេត្ត Nakhon Sawan និងអនុស្រុក Sak Lek នៃខេត្ត Pichit ក្នុងខែមករា ។

លោកប្រធានបសុសត្វមានប្រសាសន៍ថា "នាយកដ្ឋានរបស់យើងនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីសុខាភិបាល ដើម្បីទប់ស្កាត់ជំងឺមិនឲ្យឆ្លងពីសត្វដែលងាប់ទៅមនុស្សបាន" ។

*នាយកដ្ឋាននោះ ក៏នឹងជូនដំណឹងដល់អង្គការពិភពលោកសម្រាប់សុខភាពបសុសត្វថ្ងៃនេះ អំពីការមានវត្តមានឡើងវិញនៃជំងឺគ្រុនបក្សី។ ការនាំចេញសាច់មាន់បង្កក ក៏នឹងត្រូវបានផ្អាកសិនដែរ។*

*រដ្ឋមន្ត្រីក្រសួងកសិកម្ម លោក Somsak Prissananantakul បានណែនាំឲ្យមានការបង្កើនការតាមដានជំងឺគ្រុនបក្សីថែមទៀត ដោយសារថាវាប្រើនតែផ្ទុះឡើងក្នុងរដូវត្រជាក់។*

*សរុបមានមនុស្សចំនួន ២៥ នាក់ ហើយដែលបានឆ្លងវីរុសនេះតាំងពីឆ្នាំ ២០០៤ ក្នុងនោះ ១៧ នាក់បានស្លាប់បាត់បង់ជីវិត។*

រឿងនេះបានបង្ហាញថា ករណីជំងឺគ្រុនបក្សីមានសារៈសំខាន់ ដោយមូលហេតុមួយចំនួន។ ហេតុផលទីមួយ គឺវាអាចនាំទៅឲ្យផ្ទុះនូវករណីថ្មីទៀតនៃវីរុស H5N1។ ឃ្លាចុងក្រោយបានរម្លឹកដល់អ្នកអានថា វីរុសនេះបានសម្លាប់មនុស្សអស់ ១៧ នាក់ ហើយ ឬត្រូវនឹង ៦៨ ភាគរយ នៃមនុស្សដែលបានឆ្លងមេរោគនេះ។ មេរោគនេះអាចសម្លាប់មនុស្ស។ ហេតុនេះហើយ ដំណឹងនេះមានសារៈសំខាន់។ សំណួរ ចុះវាយ៉ាងម៉េច? (So what?) បន្ទាប់បន្សំទៀតនោះ គឺថាការនាំចេញសាច់មាន់បង្កកនឹងត្រូវបានគេផ្អាកមួយរយៈ។ ម្យ៉ាងវិញទៀត រឿងនេះគួរត្រូវបានប្រាប់ដល់អ្នកអានឲ្យបានដឹងថា ប្រទេសថៃជាប្រទេសមួយក្នុងចំណោមប្រទេសចម្បងៗក្នុងការនាំចេញសាច់មាន់។ វាជាផ្នែកមួយសំខាន់នៃសេដ្ឋកិច្ចរបស់ប្រទេសនេះដែរ។

# បរិបទ និងសាវតារ

ជារឿយៗ អ្នកអានតែងតែចង់ដឹងព័ត៌មានផ្សេងទៀត ដើម្បីឲ្យគេកាន់តែយល់បានថែមទៀតនូវព្រឹត្តិការណ៍ដែលអ្នកកំពុងរាយការណ៍។ អ្នកគួរតែបញ្ចូលនៅក្នុងរឿងរបស់អ្នកនូវសេចក្តីសង្ខេបយ៉ាងខ្លីអំពីបរិបទ និងសាវតាររឿង។ បរិបទ សំដៅទៅលើស្ថានភាពទូទៅបច្ចុប្បន្ន ដែលទាក់ទិនទៅនឹងព្រឹត្តិការណ៍ថ្មីនេះ។ សាវតារ សំដៅទៅលើអ្វីដែលបានកើតឡើងពីអតីតកាល ដែលទាក់ទិននឹងព្រឹត្តិការណ៍នោះ។ ឧទាហរណ៍ ប្រសិនបើអ្នកសរសេរអំពីគោលនយោបាយសេដ្ឋកិច្ចថ្មីរបស់រដ្ឋាភិបាល អ្នកអាចបញ្ចូលនូវវាក្យខណ្ឌថ្មីមួយ ដែលពន្យល់ថារដ្ឋាភិបាលកំពុងប្រឹងធ្វើឲ្យកំណើនសេដ្ឋកិច្ចមានភាពប្រជំប្រសងនឹងសេដ្ឋកិច្ចនៃប្រទេសដទៃទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍ (ត្រង់នេះហៅថា បរិបទ) និងមួយប្រយោគទៀត ដែលរ៉ាយរ៉ាប់ប្រាប់អំពីគោលនយោបាយសេដ្ឋកិច្ចលើកមុនរបស់រដ្ឋាភិបាល (ត្រង់នេះហៅថា សាវតារ)។

រឿងមួយនៅក្នុងទស្សនាវដ្តី ពិនិត្យមើលថាតើការវិលត្រឡប់មកស្រុកកំណើតវិញនូវជនជាតិវៀតណាម ដែលរស់នៅបណ្តាប្រទេសអឺរ៉ុបខាងកើតនឹងនាំឲ្យតម្លៃគេហដ្ឋាននៅក្រុងហាណូយ កាន់តែឡើងថ្លៃ។ អ្នកសរសេរបានបញ្ចូលនូវសាវតារដូចខាងក្រោមនេះ ៖

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ រលកនៃជនជាតិវៀតណាម វិលត្រឡប់មកស្រុកកំណើតពីអតីតប្រទេសអាល្លឺម៉ង់ខាងកើត បាននាំឲ្យតម្លៃអចលនទ្រព្យលំនៅដ្ឋានល្អក្នុងក្រុងហាណូយឡើងថ្លៃទ្វេដង។

ប៉ុន្តែមកដល់ចុងទសវត្សរ៍ឆ្នាំ ១៩៩០ ការប្រញាប់ប្រញាល់យកចំណេញលើសេចក្តីស្រេកឃ្លានចង់បានលំនៅដ្ឋានក្នុងក្រុងហាណូយ តាមរយៈការសាងសង់ផ្ទះថ្មីសម្រាប់អ្នកទិញ ដូចជា អ្នកធ្វើមាតុភូមិនិវត្តន៍ជនបរទេសជាដើម បានធ្វើឲ្យការផ្គត់ផ្គង់ទៅហួសសេចក្តីត្រូវការទៅវិញ។

ឥឡូវ សូមងាកមកមើលប្រយោគពីរដំបូងគេក្នុងរឿងនេះ ដែលជារឿងរបស់ទីភ្នាក់ងារព័ត៌មានស្តីអំពីការប្រារព្ធទិវាបុណ្យឯករាជ្យជាតិរបស់

កម្ពុជា។ ប្រយោគទីមួយ គឺដំណឹង។ ប្រយោគទីពីរ មានបរិបទ សាវតារ និងអ្វីដែលទាក់ទងទៅនឹង សំណួរ ចុះវាយ៉ាងម៉េច? (So what?)។

*ភ្នំពេញ - លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសន្យាថានឹងធ្វើការពង្រឹងកងកម្លាំងប្រដាប់អាវុធរបស់កម្ពុជា ក្នុងពេលដែលលោកបានចូលរួមកាលពីម្សិលមិញ ជាមួយព្រះមហាក្សត្រក្នុងទិវាប្រារព្ធខួបទី ៥៥ នៃការទទួលបានឯករាជ្យពីប្រទេសបារាំង។*

*លោកនាយករដ្ឋមន្ត្រីបានថ្លែងបែបនេះ ស្រប ពេលនឹងមានការប្រឈមមុខតានតឹងរវាងប្រទេសទាហានកម្ពុជា និងប្រទេសថៃនៅតំបន់ក្បែរប្រាសាទព្រះវិហារ ដែលកាលពីខែមុនបានផ្ទុះទៅជាការប៉ះទង្គិចប្រដាប់អាវុធ ដែលវាកាន់តែបង្កើនថែមទៀតនូវសេចក្តីព្រួយបារម្ភថា វានឹងអាចក្លាយទៅជាសង្គ្រាមព្រំដែននៃប្រទេសទាំងពីរ។*

*បរិបទក្នុងរឿងនេះ គឺភាពប្រឈមមុខតានតឹងរវាងប្រទេសទាំងពីរ។ សាវតារ គឺការប៉ះទង្គិចប្រដាប់អាវុធ ដែលបានកើតឡើងរវាងប្រទេសទាំងពីរកាលពីខែមុន។ ឯសំណួរ ហើយវាយ៉ាងម៉េច? (So what?) គឺនៅត្រង់សេចក្តីកង្វល់ថា ការប៉ះទង្គិចនេះ វានឹងអាចនាំទៅដល់ការកើតជាសង្គ្រាម។*

# ជំពូកទី ៤ តម្រូវការជាមូលដ្ឋាន ដើម្បីធ្វើរឿងឲ្យបានល្អ

យើងទើបនឹងបានពិនិត្យមើលរួចហើយនូវទម្រង់ ជាមូលដ្ឋាននៃរឿង។ ឥឡូវនេះ ចូរនាំគ្នាពិចារណានូវតម្រូវការជាមូលដ្ឋានមួយចំនួន ដើម្បីសរសេររឿងឲ្យបានល្អ។ តម្រូវការទាំងនោះមាន ការប្រមូលព័ត៌មានឲ្យបានត្រូវជាក់លាក់ កំណត់អត្តសញ្ញាណប្រភពព័ត៌មាន រក្សាភាពសមរម្យ មានតុល្យភាព និងអព្យាក្រឹត និងសរសេរឲ្យគ្រប់ជ្រុងជ្រោយ។

## ភាពទៀងត្រង់ជាក់លាក់ (Accuracy)

សំខាន់លើសអ្វីៗទាំងអស់ អ្នកសារព័ត៌មានត្រូវតែប្រមូលព័ត៌មានត្រូវពិតប្រាកដ។ កំហុសអាចបង្កនូវផលវិបាកមិនល្អដល់ប្រភព និងអ្នកអានបំផ្លាញកេរ្តិ៍ឈ្មោះ និងនាំមកនូវការបង់ខាតផ្នែកហិរញ្ញវត្ថុទៀតផង។ អ្នកអាន ក៏នឹងអាចបាត់បង់ជំនឿទៅលើអង្គភាពព័ត៌មានផងដែរ ហើយពួកគេនឹងងាកទៅរកប្រភពមួយទៀត ដើម្បីទទួលព័ត៌មាន។ វាជារឿងមិនល្អទេស្ថានភាពបែបនេះ។

*កុំសន្មតជាមុនឲ្យសោះថា អ្វីមួយមានភាពទៀងត្រង់ពិតប្រាកដ។ ជានិច្ចកាល ត្រូវតែសួរ។ ជានិច្ចកាល ត្រូវតែធ្វើការផ្ទៀងផ្ទាត់។*

ភាពត្រឹមត្រូវជាក់លាក់ មានន័យថា យកចិត្តទុកដាក់ទៅលើជាតុផ្សំលម្អិតនីមួយៗ។ ការយកចិត្តទុកដាក់បែបនេះ វាចាប់ផ្តើមតាំងពីរឿងសាមញ្ញឡើងទៅ ដូចជាការប្រកបឈ្មោះ បរមងារ និងទីកន្លែងជាដើម។ តមកទៀត គឺការយកចិត្តទុកដាក់បញ្ជាក់ឡើងវិញនូវព័ត៌មានក្នុងសេចក្តីប្រកាសព័ត៌មាន ការបញ្ជាក់ថាអ្នកបានដកស្រង់សម្តីនរណាម្នាក់ត្រឹមត្រូវជាក់លាក់ ឬបានរាយរ៉ាប់ពិពណ៌នាទស្សនៈរបស់គេត្រឹមត្រូវ។

អ្នកអាចគិតថា កំហុសក្នុងការប្រកបឈ្មោះជារឿង "មិនសូវសំខាន់ប៉ុន្មានទេ"។ ប៉ុន្តែ បើលោកអ្នកប្រកបឈ្មោះមនុស្សម្នាក់ខុសទៅហើយ អ្នកអានណាម្នាក់ដែលស្គាល់មនុស្សហ្នឹង នឹងនិយាយថា

"បើសិនជាអ្នកកាសែតម្នាក់នឹងគ្រាន់តែឈ្មោះក៏សរសេរមិនត្រូវផង ខ្ញុំមិនដឹងថា តើក្នុងរឿងរបស់គាត់នៅមានអ្វី ដែលគាត់សរសេរខុសទៀតនោះ"។ ប្រភពព័ត៌មានក៏អាចខឹងដែរ បើសិនជាអ្នកប្រកបឈ្មោះរបស់គេខុស។ ពួកគេអាចលែងទុកចិត្តអ្នកទៀតហើយ។ ចូរសួរពួកគេ។ សុំនាមប័ណ្ណធុរកិច្ចរបស់ពួកគេទុក។ តើឈ្មោះហ្នឹងសរសេរថា Chuan Leepai ឬ Chuan Leekpai? តើវាជា Jacky Chan ឬ Jackie Chan?

នៅពេលកាសែតមួយប្រព្រឹត្តនូវកំហុស វាអាចបង្កនូវបញ្ហាច្រើនយ៉ាង។ កាសែតកម្ពុជាមួយបានធ្វើឲ្យមនុស្សម្នាក់ភ័យព្រួយ ពេលដែលវារាយការណ៍ថា ស្រោមអនាម័យពេញនិយមមួយប្រភេទ អាចមានជាប់មេរោគដែលបង្កជំងឺអេដស៍។ ក្រោយលេចឮដំណឹងនេះភ្លាម រដ្ឋាភិបាលប្រញាប់ប្រញាល់ធ្វើសន្និសីទសារព័ត៌មានភ្លាម ដើម្បីបដិសេធរឿងនោះ។ កាសែតនោះ ក៏ត្រូវបង្ខំចិត្តចុះផ្សាយការសុំទោសដោយនិយាយថា "យើងបានប្រព្រឹត្តនូវកំហុសមួយក្នុងនាមជាអ្នកកាសែតអាជីព"។



*ចូរផ្ទៀងផ្ទាត់ព័ត៌មានលម្អិតឲ្យបានម៉ត់ចត់*

វាអាក្រក់គ្រប់គ្រាន់ណាស់ទៅហើយក្នុងការប្រព្រឹត្តកំហុស ក្នុងពេលដែលយើងកំពុងប្រញាប់ប្រញាល់បញ្ចប់រឿងឲ្យហើយមុនឱសានវាទប្រចាំថ្ងៃ។ ប៉ុន្តែការដែលយើងធ្វេសប្រហែស ឬខ្ជិលច្រអូសក្នុងការផ្ទៀងផ្ទាត់ព័ត៌មាន វាមិនមែនជាលេសសម្រាប់ប្រព្រឹត្តកំហុសនោះឡើយ។

## ការផ្ទៀងផ្ទាត់ (Verification)

លើសពីនេះទៅទៀត កុំចុះផ្សាយនូវអ្វីដែលមានភាពចម្រូងចម្រាស ដោយមិនបានធ្វើការផ្ទៀងផ្ទាត់ជាមុន។ ពេលណាដែលអាចធ្វើទៅបាន សូមធ្វើការផ្ទៀងផ្ទាត់ដោយទៅមើលឲ្យឃើញផ្ទាល់ភ្នែកខ្លួនឯង។ បើអ្នកមិនអាចធ្វើដូច្នោះបានទេ សូមសួរសាក្សីឲ្យជួយបញ្ជាក់។ ជាមួយគ្នានោះ ស្វែងរកឯកសារនានាដែលអះអាងថាព័ត៌មានហ្នឹងវាពិត។

ក្នុងគ្រាមួយដែលមានការប្រយុទ្ធផ្ទៃក្នុងយោធានៅប្រទេសកម្ពុជា មន្ត្រីម្នាក់នៅខេត្តសៀមរាបនិយាយប្រាប់អ្នកកាសែតម្នាក់ថា គ្មានបញ្ហាអ្វីកើតឡើងទេនៅក្នុងប៉ែកនោះនៃប្រទេស។ មន្ត្រីនោះនិយាយថា ការវាយប្រយុទ្ធគ្នាមានតែនៅក្នុងក្រុងភ្នំពេញទេ។ ប៉ុន្តែ អ្នកយកព័ត៌មានបានស្តាប់ឮស្នូរកាំភ្លើងពីចម្ងាយ។ អ្នកយកព័ត៌មាននោះមិនជឿនូវអ្វី ដែលមន្ត្រីនោះនិយាយប្រាប់គាត់ទេ។ អ្នកយកព័ត៌មាននោះ ក៏ទៅកាន់មន្ទីរពេទ្យ។ នៅទីនោះគាត់បានឃើញក្រុមវេជ្ជបណ្ឌិតកំពុងព្យាបាលក្មេង

ប្រុសម្នាក់ ដែលរបួសដោយសារគ្រាប់កាំភ្លើង។ សាច់ញាតិរបស់ក្មេងប្រុសនោះនិយាយថា កសិករ វៃយចំណាស់ពីរនាក់ត្រូវបានគេសម្លាប់។ ប៉ុន្តែ អ្នកយកព័ត៌មានមិនបានឃើញទាហានរបួសម្នាក់ ណាទេ។ គាត់ក៏បន្តដំណើរទៅកាន់មន្ទីរពេទ្យ យោធានៅក្រៅក្រុង។ នៅទីនោះ គាត់បានប្រទះ ឃើញទាហានរបួស ដែលបានប្រាប់គាត់ថា មាន ទាហានផ្សេងទៀត ត្រូវបានសម្លាប់។ អ្នកយកព័ត៌មាន បានបន្តធ្វើការផ្ទៀងផ្ទាត់អំពីមរណភាពនោះ ដោយ ធ្វើដំណើរទៅកាន់វត្តដែលនៅទីនោះ សាកសពកំពុង ត្រូវបានគេបូជា។

ព្យុះស៊ូណាមិ នៅឆ្នាំ ២០០៤ បានធ្វើឲ្យមនុស្ស រាប់សិបពាន់នាក់ស្លាប់នៅទ្វីបអាស៊ី ប៉ុន្តែនៅប្រទេស មីយ៉ាន់ម៉ាឯណោះវិញ ពួកមន្ត្រីប្រកាសថា មានមនុស្ស ស្លាប់មិនដល់ ១០០ នាក់ផង។ ក្រុមអ្នកសារព័ត៌មាន មិនជឿទេ។ អ្នកយកព័ត៌មានស្ត្រីម្នាក់បានជំនះ ការលំបាក ដោយធ្វើដំណើរយ៉ាងវែងឆ្ងាយពីក្រុង យ៉ាងហ្គូន ទៅកាន់ឆ្នេរតំបន់ទំនាបអ៊ីរ៉ាវ៉ាឌី។ នាង ធ្វើដំណើរតាមរថយន្តបឺសអស់រយៈពេលបីម៉ោង និងធ្វើដំណើរថ្មើរជើងអស់ជាច្រើនម៉ោងក្រោយមក ទៀត។ តាមការសង្កេតរបស់នាង និងតាមរយៈការ សម្ភាសន៍ជាមួយអ្នកភូមិ នាងអាចផ្ទៀងផ្ទាត់បានថា គឺពិតជាមានចំនួនមនុស្សស្លាប់តិចតួចមែននៅតាម បណ្តាកន្លែងដែលនាងបានទៅដល់។ ក្រោយមក ទៀត មន្ត្រីអង្គការសង្គ្រោះអន្តរជាតិមួយបានធ្វើការ សន្និដ្ឋានមួយផ្ទុយពីនេះទៅវិញ ក្រោយពីបានជជែក ជាមួយអ្នកនេសាទ ហើយធ្វើការប៉ាន់ប្រមាណថា តួលេខអ្នកស្លាប់យ៉ាងតិចណាស់ ក៏ដប់ដងច្រើនជាង នូវអ្វីដែលគេបានស្មានទុកពីមុនដែរ។

សូមផ្ទៀងផ្ទាត់លើឯកសារផង ព្រោះបើមិនធ្វើ ដូច្នោះទេ អ្នកអាចក្លាយខ្លួនជាជនរងគ្រោះនៃកល- ល្បិចមួយជាមិនខាន។ នាពេលយប់មួយ អ្នកកាសែត កម្ពុជាម្នាក់បានទទួលហ្វាក់ស៍ពីមនុស្សម្នាក់ ដែល ប្រកាសថា ខ្លួនជាប្រធានថ្មីរបស់គណបក្សកាន់ អំណាច។ ហ្វាក់ស៍នោះនិយាយថា សមាជិកបក្ស បានបោះឆ្នោតជ្រើសរើសប្រធានថ្មីក្នុងកិច្ចប្រជុំ ពិសេសមួយនៅតំបន់ដាច់ស្រយាលនៃប្រទេស។ ព័ត៌មាននោះមិនអាចផ្ទៀងផ្ទាត់បានទេ ប៉ុន្តែកាសែត នោះនៅតែចុះផ្សាយរឿងនោះដដែល។ វាជាកំហុស មួយ។ នៅថ្ងៃបន្ទាប់មក មន្ត្រីគណបក្សកាន់អំណាច និយាយថាគ្មានការប្រជុំបែបនោះទេ។

ការលែលកជាមួយពាក្យចចាមអារ៉ាម គឺជាភាព ប្រឈមមួយក្នុងចំណោមភាពប្រឈមលំបាកៗ ជាច្រើន ដែលអ្នកកាសែតតែងជួបប្រទះ ជាពិសេស ក្នុងពេលឱសានវាទប្រចាំថ្ងៃខិតជិតមកដល់។ អ្នកនយោបាយ និងមនុស្សដទៃ ដែលមានរបៀបវារៈ បម្រើផលប្រយោជន៍ផ្ទាល់ខ្លួន តែងព្យាយាមប្រើ- ប្រាស់អ្នកសារព័ត៌មាន ដើម្បីធ្វើឲ្យគូបដិបក្ខរបស់ ខ្លួនមានមុខមាត់អាក្រក់។ កុំចុះផ្សាយពាក្យចចាម- អារ៉ាមឲ្យសោះ។ សូមទាក់ទងប្រភពដោយផ្ទាល់។ ទាមទារឲ្យគេបង្ហាញភស្តុតាង។ សួរមនុស្សដែលជា ប្រភពនៃពាក្យចចាមអារ៉ាម។ បើសិនជាអ្នកមិនអាច អះអាងបញ្ជាក់អំពីព័ត៌មាននោះបានទេ កុំយកវាទៅ ចុះផ្សាយឲ្យសោះ។

កំហុស ជារឿងអាម៉ាស់សម្រាប់កាសែត និង ប៉ះពាល់កេរ្តិ៍ឈ្មោះរបស់វា។ តែវាមិនចប់ត្រឹមហ្នឹង ទេ។ វាក៏អាចជារឿងដែលត្រូវបង់ថ្លៃច្រើនផងដែរ។ កាសែតហុងកុងមួយបានចុះផ្សាយរឿងមួយ ដែល និយាយបញ្ជិតបញ្ជៀងថា ព្រះរាជបុត្រាមួយរបស់ ព្រះបាទព្រះនរោត្តម សីហនុ អតីតព្រះមហាក្សត្រ កម្ពុជា មិនមែនជាបុត្រាស្របច្បាប់ទេ។ អតីត ព្រះមហាក្សត្រមានព្រះបន្ទូលថា រឿងហ្នឹងមិនពិតទេ ហើយធ្វើឲ្យខូចខាតនូវព្រះកិត្តិយសរបស់ព្រះអង្គ ទៀតផង។ ព្រះអង្គគំរាមថា នឹងប្តឹងទាររាប់លាន ដុល្លារជាសំណងដល់ការខូចខាត។ ប្រសិនបើ កាសែតតូចមួយ ត្រូវបង់សងការខូចខាតបែបនេះ



*ជាញឹកញយ ប្រភពព័ត៌មានមិនសូវចង់បញ្ចេញឈ្មោះទេ*

វាពិតជាក្ស័យធនជាមិនខាន។ ថ្មីៗនេះ កាសែតមួយនៅក្រុងបាងកកបានរាយការណ៍ថា មានការប្រេះនៅតាមផ្លូវបុះចតហោះហើរនៅឯព្រលានយន្តហោះថ្មី។ ប៉ុន្តែកាសែតនោះមិនបានបង្ហាញឈ្មោះប្រភពព័ត៌មានទេ ហើយក៏មិនបានផ្ទៀងផ្ទាត់ការនិយាយបែបនោះជាមួយអ្នកណាម្នាក់ ដែលបានឃើញស្នាមប្រេះនោះដែរ។ ភ្នាក់ងារគ្រប់គ្រងព្រលានយន្តហោះក៏បានដាក់ពាក្យប្ដឹងកាសែតនោះ។ ប៉ុន្តែក្រោយមកទៀត គេក៏បានដកពាក្យបណ្ដឹងនោះវិញ ហើយកេរ្ដិ៍ឈ្មោះកាសែតនោះ ត្រូវបានស្ដារឡើងវិញខ្លះនៅពេលគេរកឃើញថា ពិតជាមានស្នាមប្រេះខ្លះមែននៅតាមផ្នែកខ្លះរបស់ផ្លូវបុះចតហោះហើរ។

## កម្មវិស័យភាព (Objectivity)

អ្នកសារព័ត៌មានគួរព្យាយាមរាយការណ៍អំពីអង្គហេតុ ឬការណ៍ពិត ក្នុងរបៀបមួយអព្យាក្រឹត ហើយទុកយោបល់ និងអារម្មណ៍ផ្ទាល់ខ្លួននៅក្រៅសាច់រឿង។ បើសិនជាពួកគេប្រឡូកការណ៍ពិតជាមួយយោបល់របស់ខ្លួន អ្នកអាននឹងមិនអាចពឹងពាក់លើសាច់រឿងនោះបានថាជាព័ត៌មានត្រឹមត្រូវជាក់លាក់បានទេ។ អ្នកកាសែតគួរតែទុកឲ្យអ្នកអានរៀបចំយោបល់របស់គេ ដោយផ្អែកលើការណ៍ពិតដែលបានរាយការណ៍ជូនក្នុងរឿងនោះ។

នេះមិនមែនមានន័យថា កាសែតរបស់អ្នកមិនអាចប្រកាន់យកជំហរនៅលើបញ្ហានានានោះឡើយ។ វាអាច ហើយវាគួរតែប្រកាន់យកជំហរ។ ប៉ុន្តែកាសែត

នីមួយៗ គួរតែបង្ហាញឲ្យច្បាស់នូវយោបល់ថាជាជំហរក្រុមនិពន្ធនាយកថាជាអត្ថាធិប្បាយ ហើយដាក់វាឲ្យនៅដោយឡែកពីអត្ថបទដំណឹង។ ធ្វើដូច្នេះ វានឹងពង្រឹងកេរ្តិ៍ឈ្មោះរបស់កាសែត។

នៅតំបន់អាស៊ីអាគ្នេយ៍ បណ្តាកាសែតដែលគ្រប់គ្រងដោយរដ្ឋាភិបាល ឬគណបក្សនយោបាយ រមែងស៊កយោបល់ទៅក្នុង "រឿងដំណឹង" របស់ពួកគេ។

រឿងនៅក្នុងកាសែតជាភាសាខ្មែរមួយ បានហៅមន្ត្រីរដ្ឋាភិបាលម្នាក់ថាជា "ជនមុខលុយ" ជាឪពុកលួយ ដូចក្រពើជុះស្លែ ជាជនផ្តាច់ការគំនិតសក្តិភូមិ "ជាជនកម្មុយនិស្ត"។ រឿងនោះនិយាយថា ព័ត៌មានអំពីភាពពុករលួយនេះ គឺ "យោងតាមមន្ត្រីនានានៅក្រសួងអភិវឌ្ឍន៍ជនបទ"។ ប៉ុន្តែវាមិនបានបង្ហាញឈ្មោះមន្ត្រីទាំងនោះ ឬក៏ផ្តល់ភស្តុតាងអ្វីមួយអំពីការចោទប្រកាន់នោះឡើយ។

ប៉ុន្តែ វាមិនមែនតែចំពោះតែរឿងនយោបាយនោះទេ។ ជាអកុសល អ្នកសារព័ត៌មានជាច្រើនបានស៊កយោបល់របស់គេទៅក្នុងរឿងច្រើនប្រភេទ ក្នុងនោះ មានរឿងកិច្ចការសង្គម កីឡា ឧក្រិដ្ឋកម្ម និងគ្រោះមហន្តរាយផងដែរ។

ការរក្សាឲ្យបាននូវកម្មវិស័យភាពទាំងស្រុងក្នុងការងារសារព័ត៌មាន វាជារឿងមួយពិបាកធ្វើឲ្យបាន។ យើងទាំងអស់គ្នាមានអារម្មណ៍ និងយោបល់ ដែលអាចមានឥទ្ធិពលមកលើរបៀបដែលយើងរាយការណ៍ និងសរសេររឿង។ អ្នកសារព័ត៌មានបំណាន ចេះប្រើភាពងប់ងល់នឹងអាជីពរបស់ខ្លួន។ អ្នកសារព័ត៌មានម្នាក់ដែលខឹង ក្រោយពីបានឃើញនូវការលំបាករបស់អ្នកស្រុកក្រីក្រ អាចសម្រេចចិត្តថា នឹងសរសេររឿង ដើម្បីប្រាប់មនុស្សឯទៀតឲ្យបានដឹង និងដើម្បីបង្ខំរដ្ឋាភិបាលឲ្យចាត់វិធានការ។ ប៉ុន្តែ បើទោះជាអ្នកសារព័ត៌មានមានអារម្មណ៍ខ្លាំងអំពីបញ្ហាណាមួយក្តី គេត្រូវតែរាយការណ៍អំពីរឿងនេះ ឲ្យបានត្រូវជាក់-លាក់ និងទៀងត្រង់មិនលម្អៀងដែរ។

កាលពីប៉ុន្មានឆ្នាំមុន កាសែតកម្ពុជាជាច្រើនចុះផ្សាយច្រើនតែយោបល់តែប៉ុណ្ណោះ។ តែឥឡូវនេះ ពួកគេចុះផ្សាយរឿងដំណឹងច្រើនជាងមុន។ ក្នុងនោះ មិនត្រឹមតែកាសែតឯករាជ្យប៉ុណ្ណោះទេ តែក៏មានកាសែតដែលគាំទ្ររដ្ឋាភិបាល និងប្រឆាំងរដ្ឋាភិបាលផងដែរ។ លោក ប៉ែន សមិទ្ធិ និពន្ធនាយកកាសែតរស្មីកម្ពុជា ដែលជាកាសែតលក់ដាច់ជាងគេ មានប្រសាសន៍ថា នេះក៏ដោយសារថា មនុស្សម្នាឥឡូវចង់អាន "មិនគ្រាន់តែយោបល់ប៉ុណ្ណោះទេ តែគេក៏ចង់អានអំពីអ្វី ដែលបានកើតឡើង ហើយកើតនៅឯណាផងដែរ"។

## បន្ទុកព័ត៌មាន (Attribution)

ប្រសិនបើអ្នកមានវត្តមាននៅព្រឹត្តិការណ៍ដំណឹងណាមួយនោះ អ្នកអាចគ្រាន់តែសរសេរបាននូវអ្វីដែលអ្នកបានឃើញ និងឮនៅទីនោះ។ ប៉ុន្តែក្នុងករណីជាច្រើន ព័ត៌មានរបស់អ្នកចេញពីមនុស្សម្នាក់ផ្សេង ឬពីកន្លែងមួយទៀត។ អ្នកអានមានសិទ្ធិក្នុងការដឹងអំពីប្រភពព័ត៌មាន។ តើវាចេញមកពីសេចក្តីថ្លែងការណ៍ បទសម្ភាសន៍ ឬឯកសារ? អ្នកណាជាអ្នកនិយាយ?

ការប្រាប់អ្នកអានថា តើព័ត៌មានចេញពីណាមកត្រូវបានគេហៅថា បន្ទុកព័ត៌មាន។ បើអ្នកអានដឹងប្រភពព័ត៌មាន ពួកគេអាចវិនិច្ឆ័យបានថា តើព័ត៌មានហ្នឹងគួរជឿបានឬក៏អត់ ឬថាតើព័ត៌មានហ្នឹងសំខាន់ឬមិនសំខាន់។ អ្នកត្រូវតែភ្ជាប់បន្ទុករាល់សម្រង់សម្តីដើមដោយផ្ទាល់ពីប្រភព និងការរ៉ាយរ៉ាប់ និងឬការពន្យល់ទាំងឡាយ អំពីព្រឹត្តិការណ៍ដែលអ្នកខ្លួនឯងមិនបានឃើញដោយផ្ទាល់។ បើសិនជាអ្នកមិនបានភ្ជាប់បន្ទុកព័ត៌មានទេ អ្នកអានសន្មតថាអ្នកយកព័ត៌មាន ឬកាសែតជាប្រភពព័ត៌មាន។

ធម្មតា បន្ទុកព័ត៌មានត្រូវបានគេដាក់ខាងដើម ឬខាងចុងនៃឃ្លា។ ទីតាំងរបស់វាអាស្រ័យទៅតាមស្ទីល ឬក៏ភាពច្បាស់លាស់។ ខាងក្រោមជាឧទាហរណ៍មួយចំនួន ៖

- លោករដ្ឋមន្ត្រីការបរទេសថៃនិយាយថាប្រទេសរបស់លោកនឹងបន្តសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអាស៊ាន។
- ចំនួនទេសចរបរទេសមកទស្សនាទីក្រុងម៉ាន់ដាឡាយ បានកើនឡើងទ្វេដងនេះ បើតាមព័ត៌មានពីការិយាល័យទេសចរណ៍របស់រដ្ឋាភិបាល។

បន្ទុកព័ត៌មានមិនមែនជាការអះអាងថា សម្តី ឬសេចក្តីថ្លែងណាមួយ វាពិតនោះទេ។ វាគ្រាន់តែប្រាប់អ្នកអាននូវអ្វី ដែលមនុស្សម្នាក់ទៀតបាននិយាយ។ អ្នកមិនគួរចេះតែចុះផ្សាយពាក្យពេចន៍ណាមួយ ដោយសារអ្នកអាចសរសេរដាក់បន្ទុកទៅលើមនុស្សម្នាក់ទៀតថាជាអ្នកនិយាយ។ អ្នកមិនគួរចេះតែស្រង់សម្តីមនុស្សណាម្នាក់និយាយអ្វី ដែលគេចង់និយាយនោះឡើយ។ ដំបូង ប្រភពត្រូវតែមានអាជ្ញាចេះដឹងអំពីបញ្ហាដែលគេកំពុងនិយាយ។ បន្ទាប់មកទៀត អ្នកមានការទទួលខុសត្រូវក្នុងការផ្ទៀងផ្ទាត់ថាតើការថ្លែងនោះវាពិតប៉ុណ្ណា។ ប្រសិនបើវាមិនពិតទេ តែអ្នកនៅតែប្រើសេចក្តីថ្លែងនោះ ព្រោះមន្ត្រីជាន់ខ្ពស់ម្នាក់ជាអ្នកនិយាយ អ្នកគួរតែបញ្ចូលទៅក្នុងរឿងនោះនូវឃ្លាមួយ ប្រាប់អ្នកអាននូវអ្វីដែលជាការពិត។ ត្រង់នេះ វាអាចជាបញ្ហាបន្តិចដែរ ជាពិសេសក្នុងស្ថានភាពវិវាទ ដែលមនុស្សពាក់ព័ន្ធក្នុងវិវាទនោះនិយាយផ្ទុយគ្នា។ អ្នកគួរបង្ហាញទាំងសងខាង ហើយប្រាប់អ្នកអានឲ្យច្បាស់ថាខាងណានិយាយថាម៉េច។

អ្នកយកព័ត៌មានគួររំលេចប្រភពដោយប្រាប់ឈ្មោះ មុខរបរ និងសេចក្តីលម្អិតផ្សេងៗទៀតរបស់ប្រភព។ បើអ្នកអានដឹងអំពីប្រភពបានកាន់តែច្រើន វាកាន់តែងាយសម្រាប់ពួកគេក្នុងការសម្រេចថាតើព័ត៌មានវាពិតឬទេ ឬថាតើពួកគេគួរបញ្ចេញប្រតិកម្មបែបណាទៅនឹងព័ត៌មាននោះ។ ឧទាហរណ៍ មនុស្សម្នាក់និយាយថា "សេដ្ឋកិច្ចកំពុងតែចាប់ផ្តើមមានសភាពប្រសើរឡើងវិញហើយ"។ អ្នកអានប្រហែលជានឹងមានប្រតិកម្មបែបផ្សេងទៅវិញទៅនឹងការថ្លែងនោះ ប្រសិនបើប្រធានធនាគារកណ្តាលជាអ្នកនិយាយដូច្នោះវិញ។

ប៉ុន្តែ អ្នកមិនចាំបាច់ដាក់ឈ្មោះ ឬក៏តំណែងពេញរបស់ប្រភពទៅក្នុងសេចក្តីផ្តើមទេ។ ប្រសិនបើឈ្មោះនោះមិនមែនជាឈ្មោះល្បីល្បាញទេ ឬមួយបើតំណែងហ្នឹងវាវែង វាអាចធ្វើឲ្យសេចក្តីផ្តើមពិបាកអានដែរ។ អ្នកអាចដាក់ព័ត៌មានអំពីតំណែងរបស់ប្រភពទៅក្នុងប្រយោគទីពីរបាន។

សូមបៀសវាងនូវសេចក្តីផ្តើមប្រភេទដូចខាងក្រោម ដែលចេញមកពីអង្គភាពព័ត៌មានមួយរបស់ឡាវ ៖

*លោក Bounkham Phommachuk ប្រធានកិសកម្ម និងការដាំព្រៃឈើខេត្ត Borikhamsay បានរាយការណ៍ថា កសិករក្នុងខេត្តចាប់ផ្តើមច្រូតកាត់ស្រូវវស្សាក្នុងខែតុលា។*

ខាងក្រោមជារបៀបត្រឹមត្រូវក្នុងការប្រើបន្ទុកព័ត៌មាន ដូចដែលលោក Ekaphone Phouth-onesy ដែលជាអ្នកយកព័ត៌មានកាសែត Vien-tiane Times និងជាអ្នកធ្លាប់បានឆ្លងកាត់វគ្គហ្វឹកហ្វឺន IMMF បានបង្ហាញ ៖

*យោងតាមសម្តីរបស់មន្ត្រីក្រសួងហិរញ្ញវត្ថុរដ្ឋាភិបាល បានព្រមផ្តល់ជូននិស្សិតពិការនូវប្រាក់ឧបត្ថម្ភប្រចាំខែ ជាផ្នែកនៃការខិតខំលើកទឹកចិត្តរបស់ពួកគេឲ្យចូលរៀន។*



*គំនរបាវអង្ករបង្ហាញព័ត៌មានយ៉ាងណាខ្លះ*

លោក Sila Viengkeo អនុប្រធានការិយាល័យក្រសួងហិរញ្ញវត្ថុ បានបញ្ជាក់អះអាងកាលពីថ្ងៃពុធថា ក្រសួងនឹងចាប់ផ្តើមផ្តល់នូវប្រាក់ឧបត្ថម្ភប្រចាំខែដល់និស្សិតពិការនៅក្នុងខែនេះតែម្តង។

ខាងក្រោមជាឧទាហរណ៍សេចក្តីផ្តើមពីអត្ថបទមួយរបស់កាសែត Bangkok Post ដែលសរសេរដោយឈ្មោះ Parista Yuthamanop ដែលជាអតីតសិក្ខាកាមរបស់ IMMF ម្នាក់ដែរ។ សេចក្តីផ្តើមនេះ បង្ហាញអំពីរបៀបដែលគេដាក់ព័ត៌មានលម្អិតរ៉ាយរ៉ាប់នៅក្នុងកថាខណ្ឌទីពីរ ៖

*ធនាគារពិភពលោក បានសរសើររដ្ឋាភិបាលថៃដែលបានធ្វើឲ្យមានវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រ និងដោះស្រាយបញ្ហានៅក្នុងវិស័យធនាគារ។*

*លោក Jemal-ud-din Kassum អនុប្រធានធនាគាពិភពលោកទទួលបន្ទុកតំបន់អាស៊ីប៉ាស៊ីហ្វិក និយាយថា លោកមានការលើកទឹកចិត្តមែនទែនចំពោះគោលនយោបាយរបស់រដ្ឋាភិបាលដែលផ្តោតទៅលើជនក្រីក្រ និងរបៀបគ្រប់គ្រងតាមបែបធុរកិច្ចរបស់រដ្ឋាភិបាល។*

មិនមែនអ្វីៗទាំងអស់ត្រូវតែមានបន្ទុកព័ត៌មាននោះទេ។ មិនបាច់ដាក់បន្ទុកព័ត៌មានទេ ចំពោះសេចក្តីទាំងឡាយណា ដែលវាច្បាស់ក្រឡែត ងាយនឹងធ្វើការផ្ទៀងផ្ទាត់ ហើយមិនចម្រូងចម្រាស់។ ឧទាហរណ៍ ៖

- គំនរសំរាមនៅរាយប៉ាយតាមដងផ្លូវក្នុងក្រុងប៉ាតាយ៉ា (ទិដ្ឋភាពនេះវាច្បាស់ក្រឡែតរួចមកហើយ ដោយសារការសង្កេតរបស់អ្នកយកព័ត៌មាន)
- មានក្រុមហ៊ុនជាង ១០០ បានចុះបញ្ជីក្នុងផ្សារភាគហ៊ុន (ងាយនឹងផ្ទៀងផ្ទាត់ណាស់)
- មានក្រុមហ៊ុនជាច្រើន កំពុងតែចាប់ផ្តើមទទួលរងនូវផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកលលោក (គ្មានអ្វីចម្រូងចម្រាស់ទេ)

## ក្នុងកំណត់ត្រា និងក្រៅកំណត់ត្រា (On and Off the Record)

ជួនកាល ប្រភពក៏អាចដាក់កំហិតផងដែរ ទៅលើរបៀប ដែលអ្នកអាចប្រើប្រាស់ព័ត៌មានដែលគេផ្តល់ឲ្យ។

ប្រភពមួយ អាចអនុញ្ញាតអ្នកឲ្យប្រើព័ត៌មានទាំងអស់ ព្រមជាមួយនឹងឈ្មោះរបស់គេជាប្រភពនៅក្នុងរឿងនោះផងដែរ។ ក្នុងករណីនេះ បទសម្ភាសន៍របស់អ្នកជាមួយប្រភពនោះ ជាបទសម្ភាសន៍ "ក្នុងកំណត់" ។ ជាទូទៅ បន្ទាប់ពីអ្នកបានបង្ហាញអត្ត-សញ្ញាណរបស់ខ្លួនថាជាអ្នកយកព័ត៌មានរួចហើយ

អ្នកអាចសន្មតបានថា រាល់បទសម្ភាសន៍ស្ថិតក្នុងកំណត់ត្រា។ សូមកុំធ្វើសំណើឲ្យប្រភពព័ត៌មាននិយាយ "ក្រៅកំណត់ត្រា" ឲ្យសោះ។

មានពេលខ្លះ ប្រភពព័ត៌មានអាចប្រាប់ទៅអ្នកថា អ្នកមិនអាចប្រើប្រាស់នៅក្នុងរឿងរបស់ខ្លួននូវអ្វីៗដែលគេបាននិយាយឡើយ។ ក្នុងករណីនេះ បទសម្ភាសន៍របស់អ្នកស្ថិតក្នុងភាព "ក្រៅកំណត់ត្រា"។ ប្រភពអាចមានព័ត៌មានដែលអាចជួយដល់អ្នកឲ្យកាន់តែយល់ស្ថានភាពមួយបានល្អថែមទៀត។ ប៉ុន្តែ ព័ត៌មាននោះអាចមានលក្ខណៈរសើបក្នុងការយកទៅចុះផ្សាយជាសាធារណៈ។ បើមិនដូច្នោះទេ វាអាចធ្វើឲ្យប្រភពនោះមានបញ្ហា ប្រសិនបើអ្នកយកវាទៅប្រើ។ ប្រសិនបើអ្នកយល់ព្រមថានឹងដាក់ព័ត៌មាននោះក្រៅកំណត់ត្រា សូមរក្សានូវពាក្យសន្យារបស់ខ្លួនឲ្យបាន។

ជានិច្ចកាល សូមបញ្ជាក់ឲ្យបានថាជាមុនថា អ្នក និងប្រភពរបស់អ្នក ព្រមព្រៀងគ្នាឲ្យបានច្បាស់នូវលក្ខខណ្ឌនៃបទសម្ភាសន៍។

## ប្រភពអនាមិក
## (Anonymous Sources)

ពេលខ្លះប្រភព ក៏ចង់ផ្តល់ព័ត៌មានដល់អ្នកឲ្យយកទៅចុះផ្សាយដែរ តែគេអាចធ្វើដូច្នោះបានតែក្នុងករណី ដែលអ្នកមិនបង្ហាញឈ្មោះរបស់គេថាជាប្រភពព័ត៌មាននោះ នៅក្នុងរឿងរបស់អ្នក។ អ្នកប្រហែលជាអាចសរសេរថា "យោងតាមសម្តីរបស់មន្ត្រីរដ្ឋាភិបាលម្នាក់ ដែលសុំមិនបញ្ចេញឈ្មោះ"។ គេហៅប្រភពបែបនេះថាជាប្រភពអនាមិក។ ជានិច្ចកាល អ្នកគួរតែស្វែងរកព័ត៌មាន "ក្នុងកំណត់ត្រា" ក៏ប៉ុន្តែវាជាងចាំបាច់ផងដែរ ក្នុងការប្រើប្រាស់ប្រភពអនាមិកផងដែរ បើសិនជាព័ត៌មាននោះវាមានសារៈសំខាន់សម្រាប់រឿងរបស់អ្នក។ អ្នក និងប្រភពរបស់អ្នក គួរតែព្រមព្រៀងគ្នាឲ្យហើយថា តើគេអាចបង្ហាញអត្តសញ្ញាណរបស់ពួកគេបានតាមរបៀបណា។ ធ្វើឲ្យប្រាកដប្រជាតាមតែអាចធ្វើទៅបាន ដោយមិនចាំបាច់លាតត្រដាងអត្តសញ្ញាណរបស់ប្រភព។ ឧទាហរណ៍ ការប្រើពាក្យថា "មន្ត្រីជាន់ខ្ពស់ម្នាក់ក្នុងក្រសួងហិរញ្ញវត្ថុ" វាប្រសើរជាង "មន្ត្រីរដ្ឋាភិបាលម្នាក់"។ កាលណាប្រភពកាន់តែជាក់លាក់ ព័ត៌មានក៏កាន់តែមានភាពគួរទុកចិត្តបានផងដែរ។

ចូរកុំប្រើប្រភពអនាមិកច្រើនពេក។ ព្រោះថា ពេលណាអ្នកដែលនិយាយមិនបញ្ចេញឈ្មោះ ពួកគេអាចមិនមានអារម្មណ៍ទទួលខុសត្រូវចំពោះអ្វីដែលពួកគេនិយាយឡើយ។ ពួកគេអាចធ្វើអត្ថាធិប្បាយរិះគន់ ឬអសុចរិតអំពីអ្នកដទៃ ឬអំពីព្រឹត្តិការណ៍ណាមួយ នៅពេលដែលពួកគេដឹងថា គេនឹងមិនអាចទទួលការបន្ទោសអំពីការធ្វើអត្ថាធិប្បាយនោះទេ។ ពួកគេអាចនិយាយអ្វីក៏បានតាមតែគេចង់ ឲ្យតែមានផលជួយដល់បុព្វហេតុនយោបាយ ឬសង្គមណាមួយ ដែលពួកគេគាំទ្រ។ កាលណាអ្នកប្រើប្រពភអនាមិកកាន់តែច្រើននៅក្នុងរឿងរបស់អ្នក រឿងនោះក៏កាន់តែខ្វះនូវភាពជឿទុកចិត្តដែរ។

ទីភ្នាក់ងារព័ត៌មាន The Associated Press និយាយថា គេប្រើសម្រង់សម្តីអនាមិកតែនៅពេលណាដែលប្រភពនោះ និយាយអំពីអង្គហេតុការណ៍ពិត មិនបញ្ចេញមតិ។ ទីភ្នាក់ងារព័ត៌មាន The Associated Press នេះនិយាយទៀតថា គេប្រើប្រភពអនាមិកតែក្នុងកាលៈទេសៈ (១) ប្រភពជាមនុស្សដែល The Associated Press ស្គាល់; (២) ប្រភពស្ថិតក្នុងស្ថានភាពមួយ ដែលដឹងអំពីព័ត៌មានដែលគេកំពុងផ្តល់; (៣) ព័ត៌មាននោះមានសារៈសំខាន់ចំពោះរឿងរបស់អ្នក; និង (៤) គេមិនអាចរកព័ត៌មាននោះ "ក្នុងកំណត់ត្រា" បាន។

## តុល្យភាព និងភាពត្រឹមត្រូវមិនលម្អៀង (Balance and Fairness)

អ្នកយកព័ត៌មានតែងដឹងថា រឿងនីមួយៗតែងមានជ្រុងលើសពីមួយ។ ហេតុដូច្នេះហើយបានជាគេត្រូវសម្ភាសន៍ប្រភពច្រើនសម្រាប់ធ្វើរឿងរបស់គេ។ ការធ្វើដូច្នេះ វាកាន់តែមានសារៈសំខាន់ពិសេសថែមទៀត នៅពេលដែលពួកគេសរសេរអំពីបញ្ហានយោបាយ បញ្ហាសង្គម យុទ្ធនាការបោះឆ្នោត ឬក៏អំពីព្រឹត្តិការណ៍ផ្សេងទៀត ដែលពាក់ព័ន្ធមនុស្សច្រើននាក់មានយោបល់ខុសៗគ្នា។

រឿងរបស់អ្នកនឹងមានតុល្យភាព ប្រសិនបើវាបង្ហាញនូវជ្រុងទាំងសងខាងនៃបញ្ហាក្នុងរឿងនោះ។ រឿងរបស់អ្នកនឹងមានភាពត្រឹមត្រូវមិនលម្អៀង ប្រសិនបើវាមិនកាន់ជើងភាគីមួយទល់នឹងភាគីមួយទៀត។

និយាយដូច្នេះ មិនមែនមានន័យថា អ្នកត្រូវតែបង្ហាញទស្សនៈស្មើគ្នាពីជ្រុងម្ខាងៗនៃរឿងនោះទេ។ ប៉ុន្តែ អ្នកត្រូវតែដាក់បញ្ចូលនូវការនិយាយយោងខ្លះទៅរកទស្សនៈខុសៗគ្នា។ រឿងមួយស្ដីអំពីយុទ្ធនាការបោះឆ្នោតនឹងមិនមានតុល្យភាពទេ ប្រសិនបើវាមិនមានរួមបញ្ចូលនូវទស្សនៈពីគណបក្សនយោបាយផ្សេងៗគ្នា។

ពេលណាមានការចោទប្រកាន់ធ្ងន់ធ្ងរណាមួយត្រូវបានធ្វើឡើងទៅលើនរណាម្នាក់ អ្នកត្រូវតែស្វែងរកការឆ្លើយតបពីអ្នកនោះ មកដាក់ក្នុងរឿងដែរ។ អ្នកត្រូវតែផ្ដល់នូវឱកាសដល់ជននោះ ទោះប្រុសក្ដីស្រីក្ដី នូវឱកាសការពារខ្លួនរបស់គេទល់នឹងការចោទប្រកាន់នោះ។ ត្រង់នឹងហើយដែលគេហៅថា ភាពទៀងត្រង់។

អង្គភាពព័ត៌មានដែលគ្រប់គ្រងដោយរដ្ឋាភិបាល និងគណបក្សនយោបាយ ក៏គួរព្យាយាមធ្វើយ៉ាងណារក្សាឲ្យបាននូវតុល្យភាព និងភាពទៀងត្រង់ក្នុងការផ្សាយរបស់ខ្លួនដែរ។ បើមិនដូច្នោះទេ អ្នកអានគេនឹងគិតថារឿងដែលគេយកមកចុះផ្សព្វផ្សាយ នឹងវាគ្រាន់តែជាការឃោសនាតែប៉ុណ្ណោះ។ រឿងទាំងឡាយនឹងមានភាពគួរជឿទុកចិត្តបានច្រើន ប្រសិនបើវាមានរួមបញ្ចូលនូវទស្សនៈយោបល់ខុសៗគ្នា បើទោះជាទស្សនៈផ្ទុយគ្នានោះមាននៅខាងចុងនៃរឿងក៏ដោយ។

## ភាពច្បាស់សេចក្ដី (Clarity)

រឿងទាំងឡាយ គួរត្រូវបានសរសេរក្នុងសេចក្ដីដែលមានភាពច្បាស់លាស់ ដើម្បីឲ្យអ្នកអានងាយយល់។ មុននឹងសរសេរឲ្យបានច្បាស់សេចក្ដី អ្នកត្រូវគិតគូរឲ្យបានច្បាស់ជាមុន។ មុននឹងសរសេរអំពីព្រឹត្តិការណ៍នានា អ្នកត្រូវតែយល់អំពីព្រឹត្តិការណ៍ទាំងនោះ។ ដើម្បីធ្វើដូច្នោះបាន ចូរសួរសំណួរល្អៗហើយសួរវាឲ្យបានច្រើន ដើម្បីឈ្លេចយកព័ត៌មានដែលចាំបាច់យកមកសរសេរ។ បន្ទាប់មក ចូរសញ្ជឹងគិតអំពីព័ត៌មាននោះ ឲ្យបានហ្មត់ចត់មុននឹងចាប់ផ្ដើមសរសេរ។ ពេលណាដែលអ្នកយល់ច្បាស់អំពីប្រធានបទហើយ អ្នកអាចជ្រើសរើសយកមុំមេយកមកធ្វើជាសេចក្ដីផ្ដើមបាន។ ជាជំហានក្រោយមកទៀត អ្នកអាចរៀបរៀងសាច់រឿងក្នុងរបៀបតាមលំដាប់លំដោយបាន។

ភាពច្បាស់សេចក្ដីមានន័យថាប្រើប្រាស់នូវភាសាសាមញ្ញដែលមនុស្សទូទៅយល់។ ចូរចៀសវាងនូវអ្វីដែលជាគ្រាមភាសា (jargon) ឬភាសាដែលអ្នកឯកទេស ឬអ្នកកាន់ការការិយាល័យប្រើ។ ភាពច្បាស់សេចក្ដីមានន័យថា និយាយឲ្យចំ។ កុំប្រើពាក្យច្រើនលើសពីសេចក្ដីត្រូវការរបស់អ្នក។ សរសេរឲ្យបានដាក់លាក់។

ក្នុងឧទាហរណ៍ខាងក្រោមនេះ សេចក្ដីផ្ដើមរបស់រឿងរបស់ទីភ្នាក់ងារព័ត៌មានភាសាអង់គ្លេសមួយ

ស្ដាប់ទៅហាក់ ដូចជាមន្ត្រីការិយាល័យពាណិជ្ជកម្ម ជាអ្នកសរសេរអញ្ចឹង ៖

*Malaysia and Myanmar will soon finalize an agreement to facilitate the conduct of barter trade between the two countries, Malaysian International Trade and Industry Minister Rafidah Aziz said Thursday.*

*រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម ម៉ាឡេស៊ី លោក Rafidah Aziz និយាយកាលពីថ្ងៃព្រហស្បតិ៍ ថា ប្រទេសម៉ាឡេស៊ី និងមីយ៉ាន់ម៉ា នៅពេលឆាប់ខាងមុខនេះ នឹងបញ្ចប់ពង្រាងកិច្ចព្រមព្រៀងមួយជាប្រយោជន៍ សម្រួលឲ្យមានការដោះដូរទំនិញរវាងប្រទេសទាំងពីរ។*

តើពាក្យ ២៩ ម៉ាត់ (ជាភាសាអង់គ្លេស) មានន័យថាម៉េច? ចូរសរសេរបែបនេះវិញតែ ១៨ ពាក្យទេ។

*Malaysia and Myanmar soon will complete an agreement to increase their barter trade, Malaysia's trade minister said Thursday.*

*រដ្ឋមន្ត្រីពាណិជ្ជកម្មម៉ាឡេស៊ី និយាយកាលពីថ្ងៃព្រហស្បតិ៍ថា ប្រទេសម៉ាឡេស៊ី និងមីយ៉ាន់ម៉ា ក្នុងពេលឆាប់ៗខាងមុខនេះ នឹងសម្រេចបាននូវកិច្ចព្រមព្រៀងមួយ ដើម្បីបង្កើននូវការដោះដូរទំនិញរវាងប្រទេសទាំងពីរ។*

ភាពច្បាស់សេចក្ដី មានន័យថា ពន្យល់នូវពាក្យវាក្យស័ព្ទ។ ប្រសិនបើអ្នកប្រើពាក្យ "deflation" (បរិត្តផរណា) ក្នុងរឿងអំពីធុរកិច្ច ចូរថែមការពន្យល់ដល់អ្នកអានថា ពាក្យ "Deflation (បរិត្តផរណា) នេះដែលផ្ទុយនឹងពាក្យ "inflation" (អតិផរណា) គឺជាការធ្លាក់ចុះនូវថ្លៃទំនិញ និងសេវាកម្ម" ។

ភាពច្បាស់សេចក្ដី មានន័យថា ប្រើពាក្យ និងសរសេរឃ្លាខ្លីៗ។ ក្នុងភាសាភាគច្រើនរបៀបសរសេរឃ្លាឲ្យបានច្បាស់នោះ គឺតាមរចនាសម្ព័ន្ធ ប្រធាន-កិរិយាសព្ទ-កម្មបទ។

**ឧទាហរណ៍ ៖** *នគរបាលចាប់ខ្លួនបុរសបីនាក់កាលពីថ្ងៃព្រហស្បតិ៍។*
**ប្រធាន ៖** *នគរបាល*
**កិរិយាសព្ទ ៖** *ចាប់ខ្លួន*
**កម្មបទ ៖** *បុរសបីនាក់*

**ឧទាហរណ៍ ៖** *លោកនាយករដ្ឋមន្ត្រីនឹងធ្វើទស្សនកិច្ចនៅប្រទេសចិន។*
**ប្រធាន ៖** *លោកនាយករដ្ឋមន្ត្រី*
**កិរិយាសព្ទ ៖** *នឹងធ្វើទស្សនកិច្ច*
**កម្មបទ ៖** *ប្រទេសចិន*

## ភាពពេញសេចក្ដី (Completeness)

រឿងរបស់អ្នកមិនត្រូវរំលងចោលនូវធាតុផ្សំសំខាន់ណាមួយទេ។ អ្នកមិនគ្រាន់តែត្រូវតែឆ្លើយទៅនឹងសំណួរ 5Ws និង H ប៉ុណ្ណោះទេ។ អ្នកត្រូវជជែកជាមួយប្រភពចម្បងៗ ពិនិត្យមើលឯកសារសំខាន់ៗ និងទៅមើលដែលចាំបាច់នានា ដែលទាក់ទងនឹងសាច់រឿងផងដែរ។ សំណួរថាតើធាតុផ្សំសំខាន់ៗនោះជាអ្វីខ្លះ វាអាស្រ័យថាតើរឿងរបស់អ្នកនិយាយអំពីអ្វី។ ឧទាហរណ៍ អ្នកសរសេររឿងមួយអំពីការសាយភាយជំងឺគ្រុនផ្ដាសាយបក្សីនៅក្នុងខេត្តមួយ។ បើសិនមានវេជ្ជបណ្ឌិត ដែលជាអ្នកឯកទេសឈានមុខលើប្រធានបទនេះ អ្នកគួរនិយាយជាមួយគាត់។ បើមានអ្នកណាម្នាក់ដែលធ្លាប់សរសេរការសិក្សាស៊ីជម្រៅមួយអំពីប្រធានបទនេះ អ្នកគួរអានការសិក្សារបស់គាត់។ បើសិនជាមានមន្ទីរពេទ្យដែលគេកំពុងរក្សាជនរងគ្រោះ ដោយសារជំងឺគ្រុនបក្សី ដើម្បីព្យាបាលអ្នកគួរទៅមើលនៅមន្ទីរពេទ្យនោះ។

# ភាគទី ២

## *ការប្រមូលព័ត៌មាន*

អ្នកសារព័ត៌មានប្រមូលព័ត៌មានតាមរបៀបជាមូលដ្ឋានបីបែប ៖

- ការសង្កេតដោយផ្ទាល់។ អ្នកសារព័ត៌មានមើលឃើញដោយខ្លួនឯង។
- ការសម្ភាសន៍។ ពួកគេជជែកជាមួយមនុស្សដទៃ ហើយសួរសំណួរទៅកាន់ពួកគេ។
- ស្រាវជ្រាវ។ ពួកគេប្រើឯកសារ និងអ៊ិនធឺណិត។

ពេលដែលអ្នកធ្វើការប្រមូលព័ត៌មាន សូមរក្សាគំនិតឲ្យទូលាយ។ កុំចាប់ផ្តើមឡើងដោយសម្រេចភ្លាមថារឿងអ្វី ដែលអ្នកត្រូវសរសេរនោះ ហើយទៅប្រមូលតែព័ត៌មានណាដែលត្រូវនឹងរឿងនោះ ហើយមើលរំលងអ្វីៗផ្សេងទៀត។ ពេលចាប់ផ្តើម សូមបណ្តោយខ្លួនទៅទិសដៅច្រើនមុខព្រួញ។ ក្នុងពេលយកព័ត៌មាន អ្នកប្រហែលជាអាចរកឃើញថា រឿងមែនទែន រឿងដែលសំខាន់ហើយគួរចាប់អារម្មណ៍នោះ ជារឿងខុសពីអ្វីដែលអ្នកបានគិតទុកជាមុនផងក៏មិនដឹង។ ពេលណាអ្នកសម្រេចថា តើត្រូវផ្តោតទៅលើអ្វីហើយ សូមរកមើលនូវសេចក្តីលម្អិតនានាដែលអ្នកត្រូវការសម្រាប់សេចក្តីផ្តើម និងដងខ្លួនអត្ថបទរបស់អ្នក។

# ជំពូកទី ៥ ការសង្កេត

ជាញឹកញាប់ អ្នកមិនអាចមានវត្តមាននៅគ្រប់ព្រឹត្តិការណ៍បានទេ ហើយត្រូវសម្ភាសន៍មនុស្សទាំងឡាយណា ដែលបានចូលរួមក្នុងព្រឹត្តិការណ៍នោះ ឬមួយក៏បានឃើញវា។ ប៉ុន្តែការសង្កេតផ្ទាល់អាចធ្វើទៅបាននៅក្នុងប្រភេទរឿងជាច្រើនផ្សេងៗគ្នា ឧទាហរណ៍ដូចជារឿងអំពីសន្និសីតព័ត៌មាន និងកិច្ចប្រជុំ និងបទពិពណ៌នាអំពីមនុស្ស ឬទីកន្លែង។

ការសង្កេតផ្ទាល់ តែងតែជាវិធីគួរជឿជាក់មួយក្នុងការប្រមូលព័ត៌មាន។ តាមវិធីនេះ អ្នកមិនចាំបាច់ពឹងលើសាក្សីទេ ដោយសារថាពួកគេអាចមិនចងចាំបានសេចក្តីលម្អិតបានត្រឹមត្រូវ ឬពេញលេញបាន។ ការសង្កេតជាវិធីល្អមួយសម្រាប់ផ្ទៀងផ្ទាត់សម្តីរបស់នរណាម្នាក់ទៀតបាន។ តាមរយៈការមើលឃើញដោយផ្ទាល់ភ្នែក អ្នកអាចដឹងបានថា តើការលើកឡើងរបស់គេនោះពិត ឬមិនពិត។

បើសិនជាអ្នកមានវត្តមាននៅនឹងកន្លែងព្រឹត្តិការណ៍ អ្នកអាចប្រមូលនូវសេចក្តីលម្អិតគួរជឿជាក់បាន។ ជាមួយនឹងសេចក្តីលម្អិតបែបនេះ អ្នកអាចគូសវាសផាត់ពណ៌រូបភាព អំពីឆាកព្រឹត្តិការណ៍នោះជូនអ្នកអានរបស់អ្នក។ អ្នកអាចពាំនាំទៅឲ្យពួកគេនូវអ្វី ដែលអ្នកបានឃើញផ្ទាល់នៅទីនោះ។

ឧទាហរណ៍ខាងក្រោមនេះ បង្ហាញអំពីរបៀបដែលអ្នកយកព័ត៌មានម្នាក់រៀបរាប់អំពីភូមិមួយនៅប្រទេសថៃ ក្រោយពីមានមហាព្យុះស៊ូណាមិ ៖

*ភូមិ Ban Nam Khem មើលមួយភ្លែតហាក់ដូចជាទើបនឹងត្រូវបានគេទម្លាក់គ្រាប់បែកលើ។ ទូកត្រូវបានគ្រវែងខ្ទាតពីក្នុងសមុទ្រមកនៅលើគោក ហើយបែកប្រៀកជាបំណែកក្នុងចំណោមផ្ទះបាក់បែកដែរ។ រថយន្តកំពិតខ្ទេចខ្ទាំ ហើយចម្រឹងដែកក្រងេងក្រងង់ សំរាម និងកម្ទេចកម្ទីរ នៅរាយប៉ាយគ្រប់ទិសទី។ ក្លិនសាកសពសាយភាយនៅគ្រប់ទីកន្លែង។*

ហើយខាងក្រោម គឺជាទិដ្ឋភាពដែលអ្នកយកព័ត៌មានម្នាក់រៀបរាប់អំពីផលវិបាក ដែលបង្កដោយព្យុះស៊ីក្លូនណាហ្គីស ទៅលើប្រទេសមីយ៉ាន់ម៉ា ៖

*BOGA LE, Myanmar - ទឹកមិនទាន់ស្រកទៅវិញទេ ហើយមានរថយន្តជំនួយតិចណាស់ដែលបានមកដល់ទីនេះ។ ពេញមួយថ្ងៃសុក្រ គេឃើញមានតែឧត្តម្ភាគចក្រយោធាមីយ៉ាន់ម៉ាមួយគត់ ដែលបានមកទម្លាក់កញ្ចប់មីក្រៀមនៅជិតតំបន់វាលទំនាប ដែលត្រូវទទួលរងការខូចខាំ ហើយត្រូវការជំនួយច្រើនជាងនេះទៅទៀត។ នាង Win Ky យំទួញសោក ក្នុងពេលដែលនាងកំពុងស្វែងរកកូនប្រុសរបស់នាងដែលបានបាត់ខ្លួន ជាមួយនឹងរាង-កាយរងាររញ៉ូរ ហុចដៃសុំអាហារ លុយ ទឹក - ស្អីក៏បានដែរ។*

*ស្ត្រីនោះពោលទាំងក្តីរន្ធត់ថា "ខ្ញុំគ្មាននៅសល់អ្វីទៀតទេ។ អ្វីៗត្រូវបំផ្លាញអស់ហើយ"។*

*ប្រាំមួយថ្ងៃក្រោយពីព្យុះស៊ីក្លូនណាហ្គីស បានបោកបក់មកលើតំបន់ទំនាបឆ្នេររបស់មីយ៉ាន់ម៉ា វាជាការប្រត្យក្សណាស់ ដែលថាការខូចខាតមានទំហំធំធេង ហើយមានជំនួយតិចតួចមែនទែនដែលបានទៅដល់ដៃអ្នកស្រុកអ្នកភូមិរាប់សិបពាន់នាក់នៅតាមតំបន់ឆ្នេរសមុទ្រប៉ែកខាងត្បូងទីក្រុងយ៉ង់ហ្គូន ដែលជារដ្ឋធានីពាណិជ្ជកម្មរបស់ប្រទេសនេះ។*

*ខ្យល់អាកាសផ្ទុកពោរពេញទៅដោយក្លិនរលួយនិងសាកសពនៅទីនេះ ជាផ្នែកនៃស្រុកមួយដែលក្រុមអាជ្ញាធរយោធានិយាយថា មានមនុស្សស្លាប់រហូតទៅដល់ជាង ១០.០០០ នាក់។*

*យ៉ាងណាក្តី វាពិបាកនឹងប៉ាន់ប្រមាណនូវចំនួនមនុស្សស្លាប់ជាក់ស្តែងណាស់ បើទោះជានៅទីនេះគេឃើញមានតែដើមឈើរលំ ផ្ទះបាក់បែកខូចខ្ទាំ សត្វពាហនៈងាប់ហើម ដែលទិដ្ឋភាពនេះស្រដៀងគ្នាទៅនឹងទិដ្ឋភាពក្រោយមានមហាព្យុះស៊ូណាមិកាលពីឆ្នាំ ២០០៤ ដែរ។*



*សិក្ខាកាម IMMF កំពុងធ្វើកម្មសិក្សា*

អ្នកសារព័ត៌មានចំណានៗប្រើប្រាស់នូវវិញ្ញាណទាំងអស់ក្នុងការយកព័ត៌មាន ៖ ចក្ខុវិញ្ញាណ ឃានវិញ្ញាណ សូរ ការស្ទាប ការភ្លក់រសជាតិ។ ចូរសួរខ្លួនឯងដូច្នេះ ៖ តើមនុស្សម្នាកំពុងធ្វើអ្វីហ្នឹង? តើពួកគេកំពុងធ្វើដូចម្តេច? តើខ្ញុំកំពុងឮសូរអ្វីខ្លះ? តើវាមានក្លិនដូចម្តេច? តើអាកាសធាតុមានសភាពដូចម្តេចដែរ? បន្ទាប់មក សូមសរសេរសេចក្តីលម្អិតនៅក្នុងសៀវភៅកំណត់ហេតុរបស់លោកអ្នក។

អ្នកសារព័ត៌មានកំពុងយកព័ត៌មានអំពីយន្ត-ហោះធ្លាក់ អាចពិពណ៌នាអំពីផ្សែងខ្មៅហើរទៅលើមេឃ ក្លិនឥន្ធនៈ ការដែលភ្លៀងកំពុងបង្អុរចុះខ្លាំង ដែលជាហេតុធ្វើឲ្យមានការយឺតយ៉ាវដល់ប្រតិបត្តិការសង្គ្រោះជីវិត។

ការសង្កេតផ្ទាល់ក៏ជួយអ្នកសារព័ត៌មានឲ្យយល់នូវព្រឹត្តិការណ៍មួយ បញ្ហា ឬក៏មនុស្សណាម្នាក់បានកាន់តែច្បាស់ថែមទៀត។ ប្រសិនបើអ្នកសរសេរអំពីរោងចក្រមួយ អ្នកនឹងមានការយល់គ្រាន់បើជាងមុនក្រោយពីបានទៅមើលវាដល់ទីកន្លែង ហើយឃើញ



*កុំគ្រាន់តែនិយាយប្រាប់ថាគាត់ចាស់*

ការផលិតរបស់វា។ បើអ្នកសរសេរអំពីកីឡាករបាល់ទាត់ម្នាក់ អ្នកនឹងអាចមានរឿងមួយ ដែលមានភាពគ្រប់ជ្រុងជ្រោយយកមកសរសេរ បន្ទាប់ពីអ្នកបានឃើញកីឡាករនោះកំពុងលេង។

ពេលសម្ភាសន៍អ្នកដទៃ ចូរសង្កេតមើលនូវប្រតិកម្មរបស់ពួកគេ។ តើពួកគេបែរមុខចេញពេលដែលអ្នកសួរសំណួររសើបៗ? មើលអ្វីៗដែលនៅជុំវិញខ្លួនគេ។ តើតុរបស់គេហ្នឹង វាមានសភាពរញ៉េរញ៉ៃ ឬមានសណ្តាប់ធ្នាប់? តើមានរូបភាពស្អីខ្លះនៅលើជញ្ជាំង?

ទាំងអស់នេះ វាជួយអ្នកឲ្យសរសេរបានកាន់តែជាក់ច្បាស់ក្នុងរឿងរបស់ខ្លួន។ អ្នកសារព័ត៌មានចំណាន មិនមែនប្រាប់យើងថា បុរសម្នាក់ហ្នឹងចាស់ទេ? ពួកគេបង្ហាញឲ្យយើងឃើញថា បុរសម្នាក់ហ្នឹងចាស់ ដោយរ៉ាយរ៉ាប់អំពីសក់ពណ៌ប្រផេះ ស្បែកជ្រីវជ្រួញ និងដំណើរមើកៗរបស់បុរសនោះ។

ប៉ុន្តែ អ្នកក៏ត្រូវចេះជ្រើសរើសដែរ។ មិនមែនសេចក្តីលម្អិតនីមួយៗ វាទាក់ទិននឹងសាច់រឿងទេ។ បើគ្រាន់តែឃើញប្រភេទអាហារនរណាម្នាក់កំពុងបរិភោគពេលថ្ងៃត្រង់ មិនមែនបានន័យថា អ្នកត្រូវតែសរសេរវាបញ្ចូលក្នុងសាច់រឿងនោះទេ។ អាចថាក្នុងពេលសម្ភាសន៍ធុរជនម្នាក់ អ្នកសង្កេតឃើញគាត់ពាក់ក្រវាត់ក ដែលមានរូបដំរីនៅលើនោះ។ ប៉ុន្តែក្រវាត់កហ្នឹងប្រហែលជាមិនបានប្រាប់អ្វីសំខាន់អំពីធុរជននោះទេ។ ដូច្នេះ កុំទៅរវល់រំលឹកវានៅក្នុងរឿងរបស់អ្នក។ ប៉ុន្តែ បើសិនជាធុរជននោះត្រូវបានគេស្គាល់ថាជាអ្នកការពារសត្វព្រៃម្នាក់ដែរ ហើយកំពុងពាក់ក្រវាត់កមានរូបដំរីពីលើវាទៀតនោះ ត្រង់ហ្នឹងហើយជាចំណុចលម្អិតមួយល្អ ដែលគួរដាក់បញ្ចូលទៅក្នុងសាច់រឿង។

អ៊ុង ចាន់សុភា ដែលធ្លាប់ជាសិក្ខាកាមរបស់ IMMF ដែរនោះ បានប្រើនូវការសង្កេតរបស់នាង

ពិពណ៌នាអំពីការប៉ះទង្គិចរវាងប្រពៃណីចាស់ និងថ្មី នៅក្នុងភូមិខ្លង់រៀបតំបន់ Lisu នៅភាគខាងជើងប្រទេសថៃ ៖

*ដៃរបស់នាងកំពុងមមាញឹកដេរក្រណាត់ឆ្នូតពណ៌វែងមួយ Sabai Tip អាយុ ១៨ ឆ្នាំ ស្ថិតក្នុងសម្លៀកបំពាក់ប្រពៃណីជនជាតិ Lisu ដែលមានពណ៌ផ្កាឈូក ខ្មៅ និងខៀវ។ នាងនិយាយថានាងស្លៀកវារាល់ថ្ងៃ បើទោះជានៅផ្ទះក៏ដោយ។ ផ្ទុយទៅវិញ គ្រឿងលម្អលើខ្លួនរបស់នាងសុទ្ធតែជារបស់ទាន់សម័យ : សក់លាប ពណ៌លឿងចាស់ កងដៃទំនើបពីរ ក្រវិលភ្លឺចិញ្ចាច ហើយក្រចកលាបពណ៌ស្វាយ។*

សេចក្តីលម្អិត ក៏អាចជួយរៀបជាឆាកទីកន្លែងសម្រាប់ភ្ជាប់ជាមួយអ្នកអានជាមួយនឹងទីនោះដែរ។ ខាងក្រោមជាឧទាហរណ៍សេចក្តីផ្តើមអត្ថបទពិពណ៌នាមួយ ដែលនិយាយអំពីផលប៉ះពាល់នៃការអភិវឌ្ឍឧស្សាហកម្មទៅលើទីក្រុងជាទីស្រឡាញ់មួយនៅប្រទេសថៃ។ សូមកត់សម្គាល់នូវសេចក្តីលម្អិត ដែលបានមកពីការប្រើវិញ្ញាណទាំងអស់ ៖

*Chiang Mai, Thailand - នៅតាមខ្លោងទ្វារធំៗទាំងប្រាំរបស់ចូលទៅកាន់ទីក្រុងបុរាណ Chiang Mai មនុស្សម្នាបានមកជួបជុំគ្នាកាលពីពេលថ្មីៗនេះ ដើម្បីប្រារព្ធពិធីបុណ្យបុរាណមួយឈ្មោះថា បុណ្យកឋិនទាន។ ព្រះសង្ឃជាច្រើនអង្គស្ថិតក្នុងស្បង់ពណ៌លឿង សូត្រមន្តពរជ័យនៅពេលដែលមនុស្សម្នាជាមួយផ្កា ធូប និងទៀនក្នុងដៃនាំគ្នាបន់ស្រន់សុំទឹកភ្លៀង និងឲ្យទទួលបានផលល្អក្នុងការដាំដុះ។*

*ប៉ុន្តែ ស្នូរស៊ីផ្លេ និងភាពកងរំពងនៃការស្ទះចរាចរនៅក្បែរច្រកចូលនោះ បានលុបបាត់នូវសម្លេងសូត្រមន្តឲ្យពរជ័យ ហើយផ្សែងរថយន្ត និងទោចក្រយានយន្ត ក៏គ្របដណ្តប់ទៅលើក្លិនក្រអូបរបស់ធូបនៅទីនោះដែរ។*

ខាងក្រោមជាឧទាហរណ៍អត្ថបទពិពណ៌នាមួយទៀត ស្តីអំពីការបំពានលើកុមារនៅកម្ពុជា ដែលបានចុះផ្សាយក្នុងកាសែតជាច្រើននៅអាស៊ី ៖

*PHNOM PENH, Cambodia - នាងមានភ្នែកធំៗ ថ្ពាល់របស់នាងពេញក្រពង់ ហើយនាងពាក់អាវយឺតពណ៌ក្រហមប្រាល សំពត់ពណ៌ស ជាមួយនឹងស្បែកជើងសង្រែកថ្មីមួយគូផង។ នៅលើជញ្ជាំងបន្ទប់របស់នាង មានផ្ទាំងគំនូររូបភាពកុមារសប្បាយក្អាកក្អាយ ពន្លឺព្រះអាទិត្យ និងសត្វព្រាបមួយ។ កុមារដទៃទៀត កំពុងប្រៀងលេងនៅខាងក្រៅ។ ប៉ុន្តែ នាងនៅតែសម្លឹងថ្មៃទៅនឹងកម្រាលឥដ្ឋ ដោយមិនខ្វីមើលមករកភ្ញៀវនៅពីមុខនាងនោះទេ។ ក្នុងកិច្ចសន្ទនាជាងមួយម៉ោង នាងមិនត្រូវអាចគេបញ្ចុះបញ្ចូលឲ្យញញឹមបានឡើយ។*

*កុមារីនេះមានអាយុ ១០ ឆ្នាំ។ កាលពីបីសប្តាហ៍មុន នាងបានរត់គេចចេញពីផ្ទះបនមួយ ដែលកន្លែងឪពុករបស់នាងដែលជានគរបាលបានលក់នាងទៅឲ្យគេ។*

# ជំពូកទី ៦
# តិចនិចសម្ភាសន៍

អ្នកយកព័ត៌មានមិនអាចមានវត្តមានគ្រប់ទីកន្លែងដែលព្រឹត្តិការណ៍ធំណឹងកើតឡើងនោះបានទេ។ ជារឿយៗ ពួកគេត្រូវការជជែកជាមួយសាក្សី ឬក៏មនុស្សដែលដឹងអំពីប្រធានបទ។ មានពេលខ្លះទៀត ពួកគេត្រូវនិយាយជាមួយជនរងគ្រោះឧក្រិដ្ឋកម្ម ឬគ្រោះមហន្តរាយ ឬមួយជាមួយនឹងអ្នកណាម្នាក់ដែលត្រូវបានទទួលរងការចោទប្រកាន់ថាបានប្រព្រឹត្តអ្វីមួយខុសផងដែរ។ ដើម្បីបានរឿងល្អមួយមកសរសេរ អ្នកសារព័ត៌មានត្រូវចេះសួរសំណួរដែលត្រូវសួរ និងឲ្យត្រូវរបៀបផងដែរ។

## ការសុំបទសម្ភាសន៍

នៅប្រទេសខ្លះ មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលចូលចិត្តនៅឲ្យឆ្ងាយពីអ្នកសារព័ត៌មាន។ ពួកគេតែងតម្រូវឲ្យអ្នកសារព័ត៌មានផ្ញើសំណួរឲ្យគេជាមុន បើមិនដូច្នោះទេ គេទុកឲ្យអ្នកនាំពាក្យរបស់គេចាត់ការជាមួយសំណួរទាំងនោះ។ ជួនកាល វាស៊ីពេលរាប់ថ្ងៃឯណោះ ទម្រាំនឹងគេឆ្លើយ នោះបើសិនជាគេឆ្លើយមែន។ ក្នុងករណីនេះ អ្នកគួរស្វែងរកកាលវិភាគប្រចាំថ្ងៃរបស់មន្ត្រីនោះ។ ពេលណាដែលមន្ត្រីនោះមានវត្តមានជាសាធារណៈ អ្នកអាចមានឱកាសជួបគាត់ដើម្បីសួរសំណួរ។

ជាប្រការមួយជួយដល់អ្នកដែរ បើសិនជាអ្នកមានប្រភពជាមន្ត្រីថ្នាក់កណ្ដាល។ បើសិនជាអ្នកស្និទ្ធស្នាលជាមួយទីប្រឹក្សារបស់មន្ត្រីម្នាក់ វាអាចជួយអ្នកក្នុងការសុំបទសម្ភាសន៍ជាមួយនឹងមន្ត្រីនោះ។



*មិនមែនមន្ត្រីរដ្ឋាភិបាលទាំងអស់ចូលចិត្តអ្នកសារព័ត៌មានទេ*

បើសិនជាអ្នកចេះគួរសមជាមួយនឹងលេខា ឬជំនួយការ វាអាចដែរថាគេនឹងទូរស័ព្ទឆ្លើយតបមករកអ្នកវិញ។

កិច្ចសម្ភាសន៍ជាច្រើនត្រូវបានគេធ្វើតាមទូរស័ព្ទ។ ធ្វើដូច្នេះវាសន្សំពេលបានផង។ តែពេលណាដែលអាចធ្វើទៅបាន អ្នកគួរទៅសម្ភាសន៍ផ្ទាល់ ជាពិសេសបើអ្នកមិនដែលបានជួបប្រភពនោះពីមុនមក។ ពេលដែលអ្នកជួបផ្ទាល់ជាមួយនឹងប្រភព អ្នកអាចសង្កេតមើលពួកគេ និងបរិស្ថាននៅជុំវិញនោះ យកមកដាក់ក្នុងរឿងបានទៀតផង។ ភាសាកាយវិការជាផ្នែកមួយសំខាន់នៃសារគមនាគមន៍។ អ្នកអាចបង្ហាញនូវការយល់ចិត្តយល់គំនិតនៅពេលបានស្តាប់អ្នកណាម្នាក់ដោយផ្ទាល់ ហើយតាមរយៈប្រតិកម្មរបស់ប្រភពក្នុងពេលសម្ភាសន៍ អ្នកក៏អាចប្រាប់បានដែរថា តើប្រភពនោះស្ងប់ស្ងួលក្នុងចិត្តក្នុងពេលសម្ភាសន៍ ឬមួយថាតើពួកគេនិយាយពិត ឬមិនពិតទៀតផង។

## ត្រៀមជាមុន

កាលណាអ្នកដឹងកាន់តែច្រើនអំពីប្រធានបទដែលអ្នកកំពុងសរសេរ វាកាន់តែងាយនឹងធ្វើឲ្យប្រភពជជែកជាមួយអ្នកដែរ។ នេះមិនមែនបានន័យថាអ្នកត្រូវតែចេះដូចអ្នកឯកទេសទេ។ ប៉ុន្តែបើសិនជាប្រភពឃើញថា អ្នកបានយកពេលវេលាធ្វើការស្រាវជ្រាវប្រធានបទដែលអ្នកកំពុងសរសេរ ពួកគេនឹងមានអារម្មណ៍ថា គេនឹងមិនខាតពេលវេលានិយាយជាមួយអ្នកទេ។ ចូរអានអត្ថបទដែលបានបោះពុម្ពពីមុនមក។ សួរទៅកាន់អ្នកយកព័ត៌មាន និងនិពន្ធនាយកឯទៀត។ ទូរស័ព្ទទៅអ្នកឯកទេស។ ស្រាវជ្រាវតាមអ៊ិនធឺណិត។ កាលណាអ្នកមានសាវតារសាច់រឿងបានកាន់តែច្រើន រឿងរបស់អ្នកក៏កាន់តែមានការផ្តោតគំនិតមូលល្អដែរ។

ជាអ្នកយកព័ត៌មានថៃម្នាក់ ដែលសរសេរដំណឹងហិរញ្ញវត្ថុ នាង Chanyaporn Chanjaroen អានច្រើនណាស់ ហើយថែមទាំងចូលសិក្សាក្នុងថ្នាក់យកព័ត៌មានហិរញ្ញវត្ថុទៀតផង។ ជារៀងរាល់ថ្ងៃ នាងធ្វើការសម្ភាសន៍ជាមួយឈ្មួញផ្សារភាគហ៊ុន និងអ្នករកស៊ីប្តូររូបិយប័ណ្ណបរទេសទៀតផង។ អ្នកទាំងអស់សុទ្ធតែជាមនុស្សដែលរវល់នឹងការងារណាស់។

នាង Chanyaporn និយាយថា "សំណួរទីមួយរបស់ខ្ញុំ គឺខ្ញុំសួរឲ្យចំចំណុចតែម្តង ហើយខ្ញុំគួរតែដឹងមុនថា តើខ្ញុំចង់បានចម្លើយបែបណាពីពួកគេ។ ធម្មតា ខ្ញុំមានតែមួយ ឬពីរនាទីតែប៉ុណ្ណោះជាមួយពួកគេ ដូច្នេះខ្ញុំមិនចង់ធ្វើឲ្យពួកគេមួហ្មងជាមួយនឹងសំណួរល្ងីល្ងើរបស់ខ្ញុំទេ។"

នាងតែងសរសេរសំណួរទុកជាមុន ដើម្បីកុំឲ្យភ្លេច។ នាងរៀបសំណួរទាំងនោះតាមរបៀបរៀបរយមួយ ដោយដាក់សំណួរសំខាន់ជាងគេនៅលើគេបង្អស់។ វាអាចថានាងនឹងមិនសួរសំណួរទាំងអស់ដែលនាងបាយត្រៀមជាមុននោះទេ ដោយសារថាគ្មានពេល ឬមួយអ្នកដែលនាងសម្ភាសន៍បានផ្តល់ចម្លើយទៅនឹងសំណួរពីដំបូងរួចមកហើយ។

មានករណីខ្លះ ដែលក្នុងពេលសម្ភាសន៍កំពុងប្រព្រឹត្តទៅ សំណួរដែលបានត្រៀមជាមុនអាចលែងសូវបានការ ឬមួយបើមិនដូច្នោះទេ សំណួរដែលប្រសើរជាងមុន គួរនឹងលើកយកមកសួរជំនួសវិញ។

អ្នកសម្ភាសន៍គួរតែរក្សាភាពទន់ភ្លន់ ហើយចេះត្រិះរិះឲ្យបានរហ័សរហួនថា តើសំណួរមួយហ្នឹងវានាំទៅដល់ណា។ ពេលដែលអ្នកចាប់ផ្តើមគិតអំពីសំណួរដើម្បីយកទៅសម្ភាសន៍ ចូរកុំគិតតែអំពី 5Ws និង H និងអ្វីដែលអ្នកត្រូវការ ដើម្បីយកទៅសរសេររឿង ប៉ុន្តែ គួរគិតដែរថា ៖ តើអ្នកអានរបស់ខ្ញុំចង់ដឹងអំពីអ្វីខ្លះ? តើពួកគេនឹងសួរអំពីអ្វីខ្លះទៅ ប្រសិនបើពួកគេមានវត្តមាននៅទីនោះដែរ?

គន្លឹះនាំទៅរកការធ្វើសម្ភាសន៍មួយបានជោគជ័យ គឺត្រូវដឹងថា តើប្រធានបទអ្វីខ្លះដែលត្រូវសួរ ហើយនិងការត្រៀមសំណួរចំៗ ដើម្បីគ្របដណ្ដប់ប្រធានបទទាំងនោះ។

## ទៅឲ្យទាន់ពេល

ចំណុចនេះទាក់ទងនឹងការគួរសម និងភាពជាអ្នកអាជីព។ ជាធម្មតា ប្រភពព័ត៌មានរបស់អ្នកជាមនុស្សមមាញឹកណាស់ តែពួកគេមានក្ដីមេត្តាណាស់ទៅហើយ ដែលចែករំលែកពេលរបស់ខ្លួន ដើម្បីមកផ្ដល់កិច្ចសម្ភាសន៍ជាមួយអ្នក។

## ផ្ដើមបទសម្ភាសន៍ ចូរបង្ហាញអត្តសញ្ញាណខ្លួន

ពេលចាប់ផ្ដើមបទសម្ភាសន៍ ចូរបង្ហាញអត្តសញ្ញាណ និងអង្គភាពសារព័ត៌មានរបស់ខ្លួន។ វានឹងជាកំហុសមួយ បើសិនជាយើងស្រង់សម្ដីរបស់អ្នកណាម្នាក់ដែលមិនខ្លួនថា គាត់បាននិយាយទៅកាន់អ្នកសារព័ត៌មាន។ ឲ្យនាមប័ណ្ណទៅគេ។ ពន្យល់ប្រាប់ទៅគេថាតើអ្នកកំពុងសរសេររឿងអ្វី។ ធ្វើដូច្នេះ វានឹងជួយដល់ការផ្ដោតគំនិតក្នុងការសម្ភាសន៍។

ក្នុងស្ថានភាពខ្លះទៀត ដូចជាករណីរបស់នាង Chanyaporn ជាដើម អ្នកត្រូវតែចាប់ផ្ដើមជាមួយនឹងសំណួរភ្លាមៗ ព្រោះថាប្រភពព័ត៌មានរបស់អ្នកមានពេលតិចណាស់។ តែបើមានពេលវិញ អ្នកអាចធ្វើជារបៀបសន្ទនាជាលក្ខណៈទូទៅមួយវិញជាមួយប្រភពរបស់អ្នក ដូចជា អំពីព្យាករណ៍ធាតុអាកាស ក្រុមបាល់ទាត់ជាតិ ឬមួយក៏អំពីអ្វីមួយដែលថ្មីជាដើម។ បន្ទាប់មកទៀត ចូលទៅដល់សំណួររបស់អ្នក ពេលដែលប្រភពរបស់អ្នកទំនងជាត្រៀមខ្លួនស្រួលបួលហើយ។

## ធ្វើកំណត់ត្រា និងឧបករណ៍ថតសម្លេង

ការប្រើឧបករណ៍ថតសម្លេងវាធានាបាននូវភាពជាក់លាក់ត្រឹមត្រូវ (accuracy)។ គ្មាននរណាម្នាក់អាចមកប្រកែកថា អ្នកសារព័ត៌មានស្រង់សម្ដីរបស់គាត់ខុសបានឡើយ។ ដោយប្រើឧបករណ៍ថតសម្លេង អ្នកអាចផ្ដោតអារម្មណ៍បានទៅលើអ្វី ដែលប្រភពព័ត៌មានកំពុងនិយាយ។

ប៉ុន្តែមនុស្សមួយចំនួន ក៏រអើលជាមួយនឹងឧបករណ៍ថតសម្លេងផងដែរ។ ពួកគេអាចមិនចង់និយាយច្រើនទេនៅពេលដែលគេដឹងថា ពាក្យរាល់ម៉ាត់របស់គេត្រូវបានថតទុក។ ការប្រើឧបករណ៍ថតសម្លេង ក៏ស៊ីពេលវេលាដែរ។ ពេលណាដែលអ្នកកំពុងស្ថិតក្នុងឱសានវាទប្រចាំថ្ងៃ អ្នកគ្មានពេលគ្រប់គ្រាន់សម្រាប់រកសម្ដីដើមដែលអ្នកត្រូវការនោះនៅក្នុងឧបករណ៍ថតសម្លេងយកមកប្រើទេ។ ពេលខ្លះ ឧបករណ៍ហ្នឹងក៏អាចមិនដំណើរការដែរ។ ចូរយកទៅជាមួយនឹងខ្លួននូវថ្មថាមពលបន្ថែម។ ជាមួយគ្នានេះ ចូរសរសេរកត់ត្រានូវពាក្យសម្ដីផងដែរ ដោយប្រើនូវគំនូរសម្គាល់ស៊ីគ្នាជាមួយនឹងលេខកុងទ័រលើឧបករណ៍ថតសម្លេង។ ធ្វើដូច្នេះ វានឹងជួយពន្លឿននូវការស្រង់សម្ដីដើមចេញយកមកប្រើ។

ការកត់ត្រា និងស្ដាប់ក្នុងពេលតែមួយ វាមិនមែនជារឿងងាយប៉ុន្មានទេ។ ប្រសិនបើប្រភពនិយាយលឿនពេក ចូរសុំដោយក្ដីគួរសម ឲ្យគេនិយាយយឺតបន្តិចមកវិញ។ បើប្រភពនិយាយអ្វីមួយ ដែលអ្នកកត់មិនទាន់ សូមស្នើឲ្យគេនិយាយឡើងវិញ។ ចូរប្រាប់ទៅគេថា អ្នកចង់កត់ត្រាឲ្យបានជាក់លាក់បំផុតនូវអ្វីដែលពួកគេនិយាយ។ ប្រភពព័ត៌មាន និងឲ្យតម្លៃនូវចេតនាល្អរបស់អ្នក។

ក្នុងករណីណាក៏ដោយ អ្នកត្រូវចេះប្រើសំណេរបំព្រួញ (shorthand)។ អ្នកសារព័ត៌មានភាគច្រើនបង្កើតនូវសំណេរបំព្រួញដោយខ្លួនឯង។ ឧទាហរណ៍ “b/c” មានន័យថា “because” (ពីព្រោះ)។ “Gov” មានន័យថា “Government” (រដ្ឋាភិបាល)។ សញ្ញា “$” មានន័យថា លុយ។

អ្នកមិនចាំបាច់កត់ត្រារាល់ពាក្យទេ។ ចូរកត់ត្រាតែប្រយោគ និងតួលេខសំខាន់ៗ ហើយគូសចំណាំនូវអ្វី ដែលជាអត្ថាធិប្បាយរបស់ប្រភព។ ជាមួយនឹងបទពិសោធន៍ អ្នកនឹងដឹងថាអ្វីដែលជាសម្រង់សម្ដីល្អៗ ហើយកត់ត្រាវាឲ្យបានពេញលេញ។

ខាងក្រោមនេះ ជាឧទាហរណ៍ដែលត្រូវបានដកស្រង់ចេញពីកូនសៀវភៅកំណត់ហេតុរបស់អ្នកយកព័ត៌មាន ដែលយើងបានឃើញរួចមកហើយក្នុងជំពូក ៣ ដែលនិយាយអំពីការធ្លាក់ចុះសេដ្ឋកិច្ចអាមេរិកប៉ះពាល់មកលើឧស្សាហកម្មកាត់ដេររបស់កម្ពុជា។

ជាទូទៅ អ្នកយកព័ត៌មានកត់រំលងគុណនាម (the, a) និងអាយ័តនិបាត (to, in, etc.) (មានន័យថា ទៅកាន់/ទៅរក, ក្នុង) ជាដើម ក្នុងពេលកត់ត្រាសម្ដី ដោយប្រឹងផ្ចង់ស្មារតីទៅលើពាក្យសំខាន់ៗ។ ករណីលើកលែង គឺសម្រង់សម្ដីដើមនេះតែម្ដង ដែលអ្នកយកព័ត៌មានចង់សរសេរឲ្យបានជាក់លាក់នូវរាល់ពាក្យពេចន៍ ដូចដែលបានពោលចេញរួចមក។ អ្នកយកព័ត៌មានប្រើអក្សរកាត់ ដូចជា “econ” សម្រាប់ “economy”, “Camb” សម្រាប់ “Cambodia”, “facts” សម្រាប់ “factories” ជាដើម។

នៅក្នុងគំរូសៀវភៅកត់ត្រានេះ អ្នកយកព័ត៌មានគូសរង្វង់ចំណាំលើសំណួរ ដែលគាត់ចង់សួរលោករដ្ឋមន្ត្រីនៅក្នុងកិច្ចសម្ភាសន៍នោះ។ អ្នកយកព័ត៌មានបានសរសេរកំណត់ចំណាំរំលឹកថា ត្រូវសួរយកនូវតួលេខជាសារវតារ ដែលចាំបាច់សម្រាប់សាច់រឿង ហើយដាក់សញ្ញា # នៅក្បែរនោះ ដើម្បីរំលឹកខ្លួនឯងថាឲ្យបានដឹងភ្លាមថា តើត្រូវធ្វើអ្វីពេលមកដល់ការិយាល័យវិញនោះ។



លោករដ្ឋមន្ត្រីបាននិយាយលើប្រធានបទច្រើនណាស់។ តែអ្នកយកព័ត៌មានសម្រេចចិត្តថាសរសេរអំពីការធ្លាក់ចុះសេដ្ឋកិច្ចអាមេរិក និងផលប៉ះពាល់របស់វាមកលើវិស័យកាត់ដេរនៅកម្ពុជា។ ដូច្នេះ អ្នកយកព័ត៌មានគួសបន្ទាត់មួយជានិច្ច នៅត្រង់ប្រយោគទាំងឡាយណា ដែលទាក់ទងនឹងមូលបទនេះ។ ធ្វើដូច្នេះ វាងាយនឹងមើលឃើញថាតើជាតុផ្សំណាខ្លះ ដែលទាក់ទិនជាមួយនឹងសាច់រឿង។ បន្ថែមលើនេះទៀត អ្នកយកព័ត៌មានគួសគំនូ ☑ នៅត្រង់ណាដែលគេគិតថាជាព័ត៌មាន ដែលមានសក្តានុពលយកទៅធ្វើជាសេចក្តីផ្តើមបាន។

## ចូរសួរសំណួរ "ហេតុអ្វី?" និង "ដោយដូចម្តេច?"

ជាទូទៅ គួរសួរសំណួរទាំងឡាយណាដែលជំរុញឲ្យប្រភពនិយាយតាមបែបពន្យល់ ឬរៀបរាប់ក្បោះក្បាយ។

ចូរចៀសវាងសំណួរណា ដែលនាំមកនូវចម្លើយ "បាទ" "ចាស៎" ឬចម្លើយដែលមានពាក្យតែមួយម៉ាត់។ ឧទារហណ៍ ៖

- អ្នកនឹងចូលប្រកួតជណ្តើមតំណែងក្នុងការិយាល័យសាធារណៈមែនទេ?
- តើអ្នកនឹងសម្រេចបានគោលបំណងហ្នឹងទេ?

ជំនួសមកវិញ គួរសួរសំណួរដែលផ្តើមដោយពាក្យ "ហេតុអ្វី?" ឬ "ដោយដូចម្តេច?" វិញ។ ឧទាហរណ៍ ៖

- ហេតុអ្វីបានជាអ្នកសម្រេចចិត្តចូលប្រកួតយកតំណែងការិយាល័យសាធារណៈនេះ?
- តើអ្នកគ្រោងនឹងសម្រេចបានគោលដៅដោយដូចម្តេចទៅ?

មានពេលផ្សេងទៀត ដែលមានប្រយោជន៍សម្រាប់សួរសំណួរ "បាទ" "ចាស៎" ឧទាហរណ៍នៅពេលដែលប្រភពមិនចង់ឆ្លើយឲ្យបានច្បាស់លាស់។ អ្នកយកព័ត៌មានអាចរៀបឃ្លាសំណួរឡើងវិញក្នុងរបៀបមួយ ដែលធ្វើឲ្យប្រភពគ្មានជម្រើសក្រៅពីការបញ្ជាក់អះអាង ឬបដិសេធ។ ឧទាហរណ៍សំណួរថា ៖ "តើពិតមែន ឬក៏មិនមែន?"

## រក្សាសំណួរឲ្យខ្លី

អ្នកសារព័ត៌មានខ្លះចូលចិត្តឮខ្លួនឯងនិយាយ។ ពួកគេចូលចិត្តសួរសំណួរវែងអន្លាយក្នុងពេលតែមួយ។ ធ្វើដូច្នេះ អាចធ្វើឲ្យប្រភពខ្វះការអត់ធ្មត់ និងវង្វេងវង្វាន់ផងដែរ។ ទម្រាំនឹងពួកគេឆ្លើយសំណួរទីមួយចប់ ពួកគេអាចភ្លេចសំណួរទីពីររួចបាត់ទៅហើយ។
ដូច្នេះចូររក្សាសំណួររបស់អ្នកឲ្យចំៗ ហើយសាមញ្ញ។

## ប្រឹងស្តាប់ តាំងស្មារតី ហើយរក្សាទឹកមុខប្រុងប្រយ័ត្ន

ការងាររបស់អ្នក គឺស្តាប់ប្រភពរបស់អ្នកនិយាយ មិនមែនធ្វើបបកថា ឬប្រកែកជាមួយពួកគេទេ។ សូមទុកមតិផ្ទាល់ខ្លួននៅតែក្នុងខ្លួងឯងទៅបានហើយ។ និយាយដូច្នេះមិនមែនបានន័យថា អ្នកគ្រាន់តែជាអ្នកកត់ត្រាតែប៉ុណ្ណោះនោះទេ។ អ្នកត្រូវតែស្តាប់ដោយប្រុងប្រយ័ត្ន និងដោយត្រិះរិះពិចារណា។ ចូរត្រិះរិះអំពីអ្វីដែលគេកំពុងនិយាយ។ តើចម្លើយ និងអត្ថាធិប្បាយដែលគេនិយាយចេញមកហ្នឹងស្តាប់ទៅយល់ទេ? តើប្រភពហ្នឹងបានឆ្លើយនូវសំណួររបស់អ្នកទេ? ចូរកុំគ្រាន់តែគិតថា តើអ្នកនឹងត្រូវសួរសំណួរអ្វីតទៅទៀត តែក៏សូមពិចារណាផងនូវអ្វីដែលគេកំពុងនិយាយ។



តើមានអ្វីផ្សេងទៀតទេដែលគួរឲ្យចាប់អារម្មណ៍អំពីកម្មបទរបស់អ្នក

ចូរវាស់វែងស្មារតីស្តាប់នូវអ្វីដែលអធម្មតា។ បើសិនជាប្រភពនិយាយអ្វីមួយគួរឲ្យចាប់អារម្មណ៍ ដែលអ្នកមិនបានរំពឹងទុកជាមុន ចូរត្រៀមប្តូរទិសដៅទៅតាមមុំសាច់រឿងថ្មី។ ជារឿយៗ អ្នកសារព័ត៌មានចំណានៗ ទៅធ្វើសម្ភាសន៍ជាមួយនឹងការរំពឹងទុកនូវសាច់រឿងមួយបែប តែចេញមកវិញជាមួយនឹងរឿងមួយដែលផ្ទុយទាំងស្រុងទៅនឹងការគិតទុកជាមុន។

ក្នុងអំឡុងពេលសម្ភាសន៍ ចូរសម្គាល់មើលរបៀបដែលប្រភពឆ្លើយនឹងសំណួរ។ តើប្រភពធ្វើកាយវិការដូចជា ក្តាប់ដៃ ឬចង្អុលម្រាមដៃ ពេលដែលគេនិយាយ? តើប្រភពហ្នឹងធ្វើចលនាដៃជើងក្នុងសភាពប្រាសប្រាល ឬយ៉ាងម៉េច? ក្នុងពេលនោះដែរ ចូរកត់សម្គាល់មើលនូវអ្វីៗជុំវិញគេហដ្ឋាន ឬការិយាល័យរបស់ប្រភពនោះ។ ការកត់ត្រាទុកនូវសេចក្តីពិស្តារបែបនេះ អាចធ្វើឲ្យសាច់រឿងរស់រវើក។

## កុំញញើតនឹងសួរសំណួរ "ភ្លើៗ"

បើសិនជាប្រភពរបស់អ្នកផ្តល់ចម្លើយស្មុគស្មាញ ឬស្រពិចស្រពិល ចូរសួរពួកគេឲ្យពន្យល់ឡើងវិញ។ អ្នកអាចនិយាយដូច្នេះទៅកាន់ប្រភពថា "សូមមេត្តាអធ្យាស្រ័យ ខ្ញុំគ្រាន់តែសូមលោកបញ្ជាក់ឡើងវិញត្រង់ចំណុចនេះ ដើម្បីជាប្រយោជន៍ខ្ញុំបានយល់កាន់តែច្បាស់ ដើម្បីខ្ញុំអាចពន្យល់ទៅដល់ក្នុងភាសាមួយសាមញ្ញទៅដល់អ្នកអាន"។

ពេលដែលប្រភពនិយាយដោយប្រើគ្រាមភាសា ឬភាសាបច្ចេកទេស ចូរកុំញញើតនឹងសួរទៅគេវិញថា តើពួកគេកំពុងនិយាយអំពីអ្វី។ ឧទាហរណ៍ វេជ្ជបណ្ឌិតម្នាក់អាចនិយាយថាជាភាសាអង់គ្លេស “a patient is at elevated risk for myocardial infarction”។ តែបើអ្នកឈ្លេចសួរថា តើវាមានន័យថាម៉េច វេជ្ជបណ្ឌិតនោះអាចនិយាយក្នុងភាសាអង់គ្លេសបែបសាមញ្ញបានថា “a patient is at risk of a heart attack” ដែលជាភាសាខ្មែរមានន័យថា គ្រោះថ្នាក់ជំងឺបេះដូង។

ជារឿយៗ ប្រភពព័ត៌មានចូលចិត្តនិយាយយោងទៅកាន់ក្រុម ឬទីភ្នាក់ងារនានា ដោយប្រើអក្សរកាត់។ ឧទាហរណ៍ ពួកគេអាចនិយាយដូច្នេះថា "យើងសង្ឃឹមថានឹងលើកបញ្ហានេះឯកិច្ចប្រជុំ ADMM+3"។ អ្នកសារព័ត៌មានណាក៏ដោយមានសិទ្ធិគ្រប់បែបយ៉ាងក្នុងការសួរថា តើអក្សរកាត់នឹងមានន័យថាម៉េច? ចម្លើយ គឺកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន (ASEAN Defense Ministers’ Meeting) បូក ចិន ឥណ្ឌា និងជប៉ុន។

ប្រសិនបើប្រភពមួយពន្យល់អំពីដំណើរការស្មុគស្មាញមួយ មិនថាក្នុងវិស័យកមន្តសាល ឬវិស័យវេជ្ជសាស្ត្រក្តី យកល្អថាតាមឡើងវិញ ដើម្បីបញ្ជាក់ជាមួយប្រភពនោះ។ ឧទាហរណ៍ អ្នកអាចប្រាប់ទៅកាន់ប្រភពនោះ ដូច្នេះថា "បើខ្ញុំមិនយល់ច្រឡំទេ លោកមានប្រសាសន៍ថា...." ធ្វើដូច្នេះផ្តល់ដល់ប្រភពនូវឱកាសកែតម្រូវនូវការយល់ច្រឡំណាមួយ។ ប្រភពភាគច្រើនមានចិត្តចង់ជួយឲ្យអ្នកយល់នូវសេចក្តី ដើម្បីធ្វើយ៉ាងណាជួយឲ្យអ្នកសរសេររឿងបានត្រឹមត្រូវមិនខុស។

ពិតណាស់ មានសំណួរល្ងីល្ងើ។ ចូរកុំសួរមន្ត្រីជាន់ខ្ពស់ឲ្យគេប្រកបឈ្មោះរបស់គេដល់អ្នក។ ចូរកុំសួរធនាគារិកថា ស្អីទៅជាអាត្រាការប្រាក់នោះ។ អ្នកគួរតែដឹងចម្លើយទៅនឹងសំណួរទាំងអស់នេះជាមុនឲ្យហើយ។

## របៀបលែលកជាមួយចម្លើយគ្មានអត្ថាធិប្បាយ

ចូរកុំអស់សង្ឃឹម បើសិនជាប្រភពបដិសេធមិនផ្តល់អត្ថាធិប្បាយ។ ចូរសួរសំណួរម្តងទៀតក្នុងរបៀបមួយផ្សេង។ ហើយបើនៅតែមិនកើតទៀត យើងអាចប្រាប់ទៅកាន់ប្រភពនោះថា វាជាប្រយោជន៍របស់គាត់ក្នុងការនិយាយរឿងរ៉ាវពីខាងគាត់ ដើម្បីយកមកបញ្ចូលក្នុងអត្ថបទ។ ពន្យល់ទៅកាន់ពួកគេថា បើសិនជាគេមិនព្រមផ្តល់អត្ថាធិប្បាយទេ យើងនឹងសរសេរថាពួកគាត់មិនព្រមធ្វើអត្ថាធិប្បាយ។ ប្រភពនឹងដឹងខ្លួនថា ធ្វើដូច្នោះវាមិនល្អមុខមាត់សម្រាប់គេទេ ព្រោះអ្នកអាននឹងគិតថាប្រភពនោះមានអ្វីមួយលាក់លៀមជាមិនខាន។ អ្នកអាចប្រាប់ទៅកាន់ប្រភពនោះថា រឿងរបស់អ្នកនឹងមិនមានភាពត្រឹមត្រូវនិងខ្វះតុល្យភាព ប្រសិនបើមិនមានអត្ថាធិប្បាយពីម្ខាងទៀតយកមកបញ្ចូលទេនោះ។

តែយ៉ាងណាក៏ដោយ អ្នកត្រូវតែគោរពសិទ្ធិរបស់ប្រភពក្នុងការមិនឆ្លើយតប។

## ពេលដែលប្រភពនៅតែមិនព្រមឆ្លើយ

អ្នកនយោបាយចូលចិត្តនិយាយច្រើន ដោយមិនបានឆ្លើយទៅនឹងសំណួររបស់អ្នកការសែតទេ។ បើគេនៅតែមិនឆ្លើយចំសំណួរ ចូរសួរសំណួរម្តងទៀត ហើយបើនៅតែមិនកើតទៀត សូមរៀបសំណួរឡើងវិញ។ ជាកិច្ចព្យាយាមចុងក្រោយ ចូរសួរប្រភពព័ត៌មានអំពីពាក្យចចាមអារ៉ាម ឬសម្តីរិះគន់ដែលអ្នកបានឮ។ ប្រសិនបើប្រភពនោះដឹងថាអ្នកបានដឹងរឿងពីភាគីម្ខាងហើយ គេប្រហែលជាអាចផ្តល់ចម្លើយចំៗជាងមុនដល់អ្នក។

## សាកល្បងនៅស្ងៀមស្ងាត់

មានពេលខ្លះ ប្រភពឆ្លើយយ៉ាងខ្លីមិនចប់សព្វគ្រប់ ហើយក៏ស្ងាត់មាត់ឈឹងទៅវិញ។ ក្នុងសភាពបែបនេះ សាកនៅស្ងៀមស្ងាត់មួយភ្លែតសិន ហើយកុំខ្មាសអៀន។ មនុស្សភាគច្រើនមិនចូលចិត្តនៅស្ងៀមមិនមាត់មិនកនោះទេ ដូច្នេះវាអាចថាពួកគេនឹងចាប់និយាយតទៅទៀត។ ភាពស្ងៀមស្ងាត់របស់អ្នកជាសញ្ញាប្រាប់ថា អ្នកកំពុងរង់ចាំការពន្យល់តទៅទៀត។

## ពេលដែលប្រភពនិយាយបួរបាច់ច្រើន

ពេលណាប្រភពព័ត៌មានមួយចេះតែនិយាយបួរបាច់តែពីសតែពាសចាកប្រធានពីការសម្ភាសន៍ អ្នកមានជម្រើសពីរ។ ទីមួយ គឺទុកឲ្យគេនិយាយដោយសង្ឃឹមថាពួកគេនឹងបន្លឺអំពីអ្វីមួយ ដែលគួរឲ្យចាប់អារម្មណ៍។ តែបើពេលវាខ្លី អ្នកត្រូវតែបង្អាក់ពួក

គេក្នុងអាកប្បកិរិយាគោរពគួរសម។ ឧទាហរណ៍ អ្នកអាចនិយាយបានដូច្នេះថា "គួរឲ្យចាប់អារម្មណ៍មែន សូមអរគុណហើយ។ វិលត្រឡប់មកចំណុចខាងដើមនេះវិញ..."។

## សំណួរបន្ថែម : ឈ្លេចយកចំណុចជាក់លាក់

ជារឿយៗ ប្រភពច្រើនផ្តល់ចម្លើយក្នុងរបៀបមួយទូលំទូលាយទូទៅ។ ប៉ុន្តែ អ្នករាយការណ៍ព័ត៌មានត្រូវការសេចក្តីពិស្តារ ដើម្បីយល់សាច់រឿងបានកាន់តែគ្រាន់បើជាងមុន ជាប្រយោជន៍ក្នុងការសរសេរឲ្យអ្នកអានងាយយល់ដែរ។ ត្រូវចេះសួរសំណួរប្រដេញតាមល្អៗ ដើម្បីឈ្លេចយកសេចក្តីពិស្តារយកទៅសរសេរ។

បើសិនជាប៉ូលីសម្នាក់ប្រាប់អ្នកថា មានរថយន្តពីគ្រឿងបានប៉ះទង្គិចគ្នានៅត្រង់ផ្លូវបំបែកធំមួយ អ្នកត្រូវតែសួរថា តើមានអ្នកណារបួសទេក្នុងព្រឹត្តិការណ៍នោះ។ បើគាត់និយាយថាមានមនុស្សរងរបួស ចូរសួរតើពួកគេជានរណា តើគេមានរបួសបែបណាខ្លះ ហើយថាតើពួកគេត្រូវបានដឹកទៅមន្ទីរពេទ្យណា។ តើមានការចោទប្រកាន់បទឧក្រិដ្ឋ ឬផាកពិន័យទេ? តើព្រឹត្តិការណ៍នោះធ្វើឲ្យស្ទះចរាចរប៉ុន្មានម៉ោង?

បើសិនជាអ្នកនយោបាយម្នាក់និយាយថា ជីវិតរបស់គាត់កំពុងស្ថិតក្នុងការគំរាមកំហែង សូមសួរគាត់ឲ្យផ្តល់ឧទាហរណ៍។

បើសិនជានាយកប្រតិបត្តិម្នាក់និយាយថា ក្រុមហ៊ុនរបស់គាត់នឹងបើកសាខាថ្មីចំនួន ១០ ថែមទៀត សូមសួរទៅគាត់ថា គេនឹងបើកសាខាទាំងនោះនៅកន្លែងណា ពេលណា ហើយថាតើគេនឹងរើសមនុស្សប៉ុន្មាននាក់ទៀត ឲ្យចូលបម្រើការងារនៅតាមសាខាទាំងនោះ។ មានតែការប្រមូលសេចក្តីពិស្តារឲ្យបានច្រើនតាមតែអាចធ្វើទៅបានប៉ុណ្ណោះ ដែលអ្នកអាចស្រាយចម្ងល់របស់អ្នកអានបាន។

ភាពប្រឈមមួយក្នុងចំណោមភាពប្រឈមធំៗរបស់អ្នករាយការណ៍ព័ត៌មាន គឺនៅពេលដែលមានដំណឹងត្រូវធ្វើសេចក្តីរាយការណ៍ ស្រាប់តែមានអ្វីផ្សេងមិនបានព្រាងទុកកើតឡើងក្នុងអំឡុងពេលធ្វើបទសម្ភាសន៍ ឬក៏ក្នុងពេលដែលសន្និសីទព័ត៌មានកំពុងតែប្រព្រឹត្តទៅ។ ពេលខ្លះអ្នកត្រៀមខ្លួនមិនទាន់ដើម្បីសួរសំណួរដេញដោលភ្លាមៗទេ ហើយបើសិនជាអ្នកត្រូវការពេលច្រើនទៀតដើម្បីរិះគិត អ្នកអាចចោទសំណួរ ដូចជា ហេតុអ្វីបានជាដូច្នេះ? តើលោកមានន័យថាម៉េច? តើលោកអាចប្រាប់ខ្ញុំថែមទៀតបានទេ? សំណួររបៀបនេះ នឹងធ្វើឲ្យបទសម្ភាសន៍ដំណើរការទៅមុខមិនរអាក់រអួល។

## សំណួរពិបាកៗ

មានពេលខ្លះ អ្នកត្រូវសួរសំណួររសើប ឬពិបាកដែរ។ ទោះជាអ្នកមិនសូវចង់ក៏ដោយ អ្នកត្រូវតែបង្ខំខ្លួនធ្វើដូច្នោះ។ ឧទាហរណ៍ អ្នកអាចមានការខ្មាសអៀនក្នុងការសួរទៅកាន់ជនល្បីឈ្មោះណាម្នាក់អំពីគ្រួសារ ឬជីវិតឯកជនរបស់គេ។ ប៉ុន្តែអ្នកត្រូវចាំថា អ្នកអានគេចង់ដឹង។ ចម្លើយវានឹងធ្វើឲ្យមានភាពខុសគ្នារវាងរឿងធម្មតា និងរឿងមួយដែលល្អ។ អ្នកអាចផ្តើមសំណួរ ដោយនិយាយថា "សូមទោស ប៉ុន្តែខ្ញុំត្រូវតែសួរអ្នកអំពីរឿងនេះ"។ បើមិនដូច្នោះទេ សួរ "តើអ្នកអាចនិយាយបន្តិចបានទេ អំពីរឿងនេះ"?

ពេលខ្លះ អ្នកចាំបាច់ត្រូវតែទាញយកចម្លើយពីជនដែលបានទទួលរងការចោទប្រកាន់ថាបានប្រព្រឹត្តខុសអ្វីមួយ។ ចូរពន្យល់ទៅកាន់ជននោះថា អ្នកចង់សរសេររឿងឲ្យមានតុល្យភាព និងទៀងត្រង់




*កុំពឹងតែទៅលើឯកសារមួយមុខក្នុងការប្រមូលព័ត៌មាន*

ឲ្យជនជាកម្មបទមានអារម្មណ៍ស្រួលក្នុងចិត្ត ទោះជានៅផ្ទះរបស់គេ ឬមួយក៏នៅភោជនីយដ្ឋានក្តី។

អ្នកត្រូវតែត្រៀមដោយប្រុងប្រយ័ត្នសម្រាប់កិច្ចសម្ភាសន៍បែបនោះ។ មនុស្សដែលអ្នកនឹងសម្ភាសន៍នោះ នឹងមានការពេញចិត្តថា អ្នកមានការខិតខំមុននឹងឈានមកដល់ការធ្វើសម្ភាសន៍នេះ។

ហើយថានេះជាឱកាសសម្រាប់គេក្នុងការធ្វើការបកស្រាយបំភ្លឺ ឬកែតម្រូវព័ត៌មាន ដែលអាចគេលើកយកមកផ្សាយខុស។

ក្នុងលក្ខខណ្ឌបែបនេះ ចូរសួរសំណួរជាមូលដ្ឋានសាមញ្ញៗសិន ហើយទុកសំណួរពិបាកៗជាងគេសួរនៅពេលចុងក្រោយ។ បើសិនជនម្នាក់នោះបដិសេធមិនឆ្លើយនឹងសំណួរពិបាកៗ ហើយបញ្ចប់បទសម្ភាសន៍ជាមួយអ្នក យ៉ាងហោចណាស់ ក៏អ្នកទទួលបានព័ត៌មានខ្លះយកមកសរសេរដែរ។

បើសិនជាប្រភពព័ត៌មានដាក់ទូរស័ព្ទចុះ ឬក៏ទាញទ្វារបិទចំពោះមុខអ្នក ចូរកុំខ្វល់ខ្វាយខ្លាំងពេក ព្រោះថា អ្នកជាអ្នកយកព័ត៌មាន ហើយវាជាភារកិច្ចរបស់អ្នកក្នុងការព្យាយាមស្វែងរកចម្លើយ។

អ្នកអាចនិយាយយោងទៅរកអត្ថបទណាមួយដែលជននោះបានសរសេរទេ? តើអ្នកមានដឹងថាតើគេធ្លាប់រៀននៅសាលាណា? តើអ្នកមានបានដឹងអ្វីខ្លះទេ អំពីការចាប់អារម្មណ៍ចំណង់ចំណូលចិត្តរបស់គេក្រៅពីការងារ? តើមនុស្សដទៃមានធ្លាប់និយាយយ៉ាងម៉េចខ្លះអំពីមនុស្សហ្នឹង?

វាអាចស៊ីពេល ទម្រាំនឹងបុគ្គលម្នាក់កក់ក្តៅអារម្មណ៍ក្នុងការផ្តល់បទសម្ភាសន៍។ ក្នុងការសម្ភាសន៍បុគ្គលភាព អ្នកត្រូវសង្កេតមើលថាជនដែលជាកម្មបទបញ្ចេញកាយវិការយ៉ាងណាខ្លះ។ បើមានពេលចូរសាកសង្កេតមើលជននោះនៅផ្ទះ ឬនៅកន្លែងធ្វើការ។ រឿងដែលល្អ គឺជារឿងទាំងឡាយណាដែលបង្ហាញមនុស្សកំពុងធ្វើសកម្មភាព។

## បទសម្ភាសន៍អំពីបុគ្គលភាព

គោលបំណងនៃអត្ថបទអំពីបុគ្គលភាព គឺដើម្បីឆ្លុះបញ្ចាំងអំពីចរិតលក្ខណៈរបស់មនុស្សម្នាក់។ នេះមានន័យថា អ្នកត្រូវធ្វើយ៉ាងណាឲ្យបុគ្គលនោះសម្រួលឥរិយាបថ ហើយនិយាយដោយសេរី។ វាសំខាន់ក្នុងការធ្វើបទសម្ភាសន៍នៅទីណា ដែលធ្វើ

## របៀបបញ្ចប់បទសម្ភាសន៍

សូមអរគុណចំពោះប្រភពដែលបានចំណាយពេលវេលាក្នុងការផ្តល់បទសម្ភាសន៍ តែក៏មិនត្រូវភ្លេចសួរសំណួរបើចុងក្រោយដែរ :

- តើមានអ្វីសំខាន់ទៀតទេ ដែលខ្ញុំភ្លេចមិនបានសួរ?

- តើលោកមានជាយោបល់អ្វីទៀតទេថា តើអ្នកណាផ្សេងទៀត ដែលខ្ញុំគួរសាកសួរ បន្ថែមអំពីរឿងនេះ ?
- តើខ្ញុំអាចទូរស័ព្ទមករកលោកវិញបានទេ ប្រសិនបើខ្ញុំមានសំណួរថែមទៀត ? (បើអាចធ្វើទៅបាន ចូរសុំលេខទូរស័ព្ទនៅផ្ទះ លេខទូរស័ព្ទចល័ត និងអាសយដ្ឋានអ៊ីម៉េល ។ អ្នកក៏អាចស្នើទៅកាន់អ្នកផ្តល់បទសម្ភាសន៍ឲ្យទាក់ទងទៅអ្នកវិញបានដែរ ប្រសិនបើគេមានអ្វីមួយ ដែលត្រូវការស្រាយបំភ្លឺ) ។

# ជំពូកទី ៧ ការប្រើប្រាស់ឯកសារ និងអ៊ិនធឺណិត

ពេលណាដែលអាចធ្វើទៅបាន អ្នកយកព័ត៌មានតែងស្វែងរកឯកសារនានា ដែលជួយអះអាងបញ្ជាក់ ឬបន្ថែមទៅលើអ្វី ដែលមនុស្សម្នាបាននិយាយ ។ ឯកសារ គឺយើងនិយាយសំដៅទៅលើអ្វីក៏ដោយ ដែលមានសេចក្តីជាព័ត៌មានដែលបានសរសេរតាក់តែងនៅក្នុងនោះ ។ វាអាចជាក្រដាសឯកសារមួយសន្លឹក ឬក៏ទិន្នន័យដែលបានតម្កល់ទុកក្នុងកុំព្យូទ័រ ។ ឯកសារអាចជាសេចក្តីប្រកាសព័ត៌មាន សៀវភៅបញ្ជីលេខទូរស័ព្ទ តារាងថវិកា របាយការណ៍ស្ថិតិរដ្ឋាភិបាល អ៊ីម៉េល សារទូរស័ព្ទ ជាដើម ។ រូបថត និងខ្សែអាត់សម្លេង ក៏ជាអង្គធំរសិក្ខបករណ៍ (research materials) ស្រាវជ្រាវមានសារៈសំខាន់ផងដែរ ។

រឿងរបស់អ្នកនឹងកាន់តែមានភាពរឹងមាំ និងគួរឲ្យជឿបាន ប្រសិនបើអ្នកអាចលើកយកឯកសារមកធ្វើជាអំណះអំណាង ។ បើអ្នកណាម្នាក់និយាយអំពីលិខិត ឬឯកសារអ្វីមួយនៅក្នុងកិច្ចសម្ភាសន៍ អ្នកគួរសុំច្បាប់ចម្លងមួយច្បាប់ ក្នុងទម្រង់ផ្តិតចម្លងក្តី ឬជាឌីជីតាល់ក្តី ។ ពេលដែលប្រភពព័ត៌មានឲ្យតម្រុយព័ត៌មានមកអ្នក សូមសួរគេឲ្យបង្ហាញឯកសារជាអំណះអំណាង ។

ជារឿយៗ អ្នកតែងទទួលបានរបាយការណ៍នានាពីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ឬក៏ទីភ្នាក់ងារអន្តរជាតិ ដូចជាធនាគារពិភពលោកជាដើម ។ ចូរមើលថា តើរបាយការណ៍នោះមានសេចក្តីណាដែលខ្លាំងគួរចាប់អារម្មណ៍ទេ ។ សូមផ្តោតការយកចិត្តទុកដាក់ទៅលើអនុសាសន៍ដែលសំដៅធ្វើឲ្យអ្វីៗមានភាពប្រសើរជាងមុន ។ ក្រោមមកទៀត រកមើលសម្រង់សម្តី ឬតួលេខនានាក្នុងឯកសារ ដើម្បីយកមកអះអាងគាំទ្រដល់អនុសាសន៍ទាំងនោះ ។

ទីភ្នាក់ងារនានាតែងផ្សព្វផ្សាយរបាយការណ៍របស់ខ្លួនជាទៀងទាត់ ។ ក្នុងនាមជាអ្នកសារព័ត៌មាន ចូរព្យាយាមស្វែងរកឲ្យបានឯកសារណាដែលសំខាន់មុនពេលដែលវាត្រូវគេផ្សព្វផ្សាយជាផ្លូវការ ។ ធ្វើដូច្នេះ វានឹងផ្តល់ពេលឲ្យអ្នកគ្រប់គ្រាន់ដើម្បីអាន និងយល់សេចក្តីក្នុងរបាយការណ៍នោះ ។ បើសិនជារបាយ-ការណ៍ហ្នឹងមានលក្ខណៈបច្ចេកទេសស្មុគស្មាញខ្លាំងពេក អ្នកគួរសុំឲ្យអ្នកឯកទេសជួយពន្យល់ឲ្យអ្នកបានយល់ ។

មានពេលខ្លះ សៀវភៅ របាយការណ៍ និងឯកសារនានា ត្រូវបានគេបញ្ចេញដោយចំណុះទៅនឹង (embargo) កាលបរិច្ឆេទ ។ វាមានន័យថា អ្នកទទួលបានឯកសារ ឬរបាយការណ៍នោះមែន ប៉ុន្តែអ្នកមិនទាន់ត្រូវបានអនុញ្ញាតឲ្យយកព័ត៌មានពីក្នុងរបាយការណ៍ ឬឯកសារហ្នឹងទៅចុះផ្សាយមុនកាលបរិច្ឆេទ ដែលគេនឹងចេញផ្សាយវាជា



*ម្នាក់ៗសុទ្ធតែមានសក្តានុពលជាកម្មបទសាច់រឿងគួរឲ្យចាប់អារម្មណ៍*

ផ្លូវការនោះបានទេ។ តែបន្ទាប់ពីកាលបរិច្ឆេទកន្លងផុតទៅ ខ្លឹមសារខាងក្នុងនឹងក្លាយទៅជារបស់សាធារណៈ ដែលនរណាក៏អាចមើលបានដែរ។ កាលណាគេឲ្យរបាយការណ៍ ឬឯកសារដល់អ្នកមុនកាលបរិច្ឆេទចេញផ្សាយជាផ្លូវការ វាបានន័យថាគេទុកចិត្តអ្នកហើយ។ ដូច្នេះ ជានិច្ចកាលអ្នកត្រូវតែគោរពនូវលក្ខខណ្ឌដែលមានភ្ជាប់ជាមួយនឹងការដែលគេឲ្យអ្នកទទួលបាននូវឯកសារ ឬរបាយការណ៍មួយហ្នឹង ជាពិសេសបើអ្នកចង់មានឱកាសបែបនេះទៀតនៅពេលខាងមុខ។

សិទ្ធិទទួលបានឯកសារមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ តែអ្នកអាចនឹងមានការភ្ញាក់ផ្អើលនៅពេលដែលអ្នករកឃើញថា តើវាមានអ្វីខ្លះ ដូចជា ៖

- បណ្ណាសារអេចលនទ្រព្យ
- របាយការណ៍ប៉ូលីស
- សំណើច្បាប់
- ឯកសារតុលាការ
- ឯកសារថវិកា
- សេចក្តីប្រកាស និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន
- របាយការណ៍បរិស្ថាន
- សម្បទានព្រៃឈើ
- របាយការណ៍សេដ្ឋកិច្ចរដ្ឋាភិបាល
- កំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សា

វាមិនមែនរឿងងាយនោះទេ ការរកមើលថាតើមានឯកសារអ្វីខ្លះនោះ តែដំបូងឡើយអ្នកត្រូវព្យាយាមស្វែងយល់ថា តើស្ថាប័ននីមួយៗធ្វើការរបៀបម៉េច។ តើព័ត៌មានបែបណាខ្លះដែលពួកគេមានដើម្បីរាយការណ៍ជាទៀងទាត់? តើគេផ្សព្វផ្សាយរបាយកាណ៍ក្នុងទម្រង់អ្វីខ្លះ? តើអង្គភាព ឬមន្ត្រី

ណាមួយជាអ្នកផ្សព្វផ្សាយរបាយការណ៍នោះ?

ពេលអ្នកយកព័ត៌មានដាក់សំណើជាផ្លូវការសុំឯកសារពីរដ្ឋាភិបាល វាតែងតែស៊ីពេលយូរទម្រាំនឹងទទួលបានឯកសារនោះ។ ដូច្នេះពេលខ្លះអ្នកយកព័ត៌មានចាំបាច់ត្រូវមានប្រភពស្និទ្ធស្នាល ដើម្បីជួយពួកគេក្នុងការប្រមូលព័ត៌មាន។

តាមរយៈការស្រាវជ្រាវឯកសារ អ្នកយកព័ត៌មានអាចលាតត្រដាងនូវការប្រព្រឹត្តខុស ឬបំពានអំណាច។ នៅប្រទេសខ្លះ អ្នកសារព័ត៌មានអាចឆែកឯកសារមើលថា តើអ្នកណាខ្លះឲ្យលុយទៅអ្នកនយោបាយ តើរដ្ឋាភិបាលចាយលុយរបៀបម៉េច។ ពួកគេព្យាយាមរកមើលបំណងទាក់ទង ដូចជាថា តើក្នុងចំណោមមនុស្ស ដែលឲ្យលុយទៅរដ្ឋាភិបាល មានអ្នកណាដែលទទួលបានកិច្ចសន្យា ដែលមានតម្លៃទឹកលុយច្រើនពីរដ្ឋាភិបាលទេ? របាយការណ៍បែបនេះ វាបង្ហាញថាអ្នកណាមានឥទ្ធិពល ហើយថាអ្នកណាខ្លះប្រើប្រាស់រដ្ឋាភិបាល ដើម្បីក្លាយខ្លួនជាអ្នកមាន។ នេះហើយជាឧទាហរណ៍នូវអ្វី ដែលគេហៅថា សារព័ត៌មានបែបស៊ើបអង្កេត (investigative journalism)។

## ចូរផ្ទៀងផ្ទាត់

ប្រយ័ត្ន : ឯកសារអាចជាការបំភាន់ ឬក្លែងបន្លំផងដែរ ដូច្នេះអ្នកគួរតែធ្វើការផ្ទៀងផ្ទាត់។ ការផ្ទៀងផ្ទាត់កាន់តែចាំបាច់ថែមទៀតនៅក្នុងសម័យអ៊ីនធឺណិត ព្រោះថាឥឡូវនេះ វាងាយណាស់អ្នកណាក៏អាចចុះផ្សាយ ឬបង្កើតឯកសារ រូបថត ឬរបាយការណ៍នៅលើវ៉ិបសៃត៍បានដែរ។ មិនមែនបានន័យថា រាល់អ្វីដែលមាននៅលើវ៉ិបសៃត៍សុទ្ធតែពិតទេ។ វាដូចគ្នាដែរសម្រាប់រឿងដែលបានចុះផ្សាយក្នុងកាសែតរបស់អ្នកកាលពីមុនមក។ បើសិនជាអ្នកមិនប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ព័ត៌មានពីក្នុងរឿងពីមុនៗមក អ្នកអាចនឹងប្រព្រឹត្តកំហុសនោះឡើងវិញជាមិនខាន។

## គួរសួរនាំមនុស្សម្នាថែមទៀត

រឿងដែលធ្វើឡើងលើមូលដ្ឋានឯកសារតែមួយ វាជារឿងដែលអផ្សុកណាស់សម្រាប់អាន ហើយវាក៏ខ្វះតុល្យភាពដែរ។ យកល្អ គួរស្វែងរកអត្ថាធិប្បាយថែមទៀតពីអ្នកជំនាញ និងមនុស្សទាំងឡាយដែលទទួលរងនូវផលប៉ះពាល់ ដូចដែលបានរៀបរាប់ក្នុងឯកសារនោះ។ ចូរស្វែងរកឧទាហរណ៍ជាក់ស្តែងយកមកបន្ថែមធ្វើឲ្យសាច់រឿងគួរឲ្យចង់អានជាងមុន។ បើរបាយកាណ៍មួយហ្នឹង និយាយអំពីការកាត់បន្ថយភាពក្រីក្រ អ្នកគួរទៅកាន់តំបន់អ្នកក្រីក្ររស់នៅក្នុងសហគមន៍របស់អ្នក ដើម្បីជជែកសួរនាំអំពីការរស់នៅរបស់ពួកគេ។ បើរបាយកាណ៍និយាយអំពីកម្មវិធីកសិកម្មថ្មីសម្រាប់ជួយបង្កើនផលិតផលស្រូវ ចូរសួរនាំកសិករដែលពាក់ព័ន្ធថា តើពួកគេទទួលបានផលប្រយោជន៍យ៉ាងណាខ្លះពីកម្មវិធីនោះ។

# ភាគទី ៣

*ផ្គុំព័ត៌មានចូលគ្នា*

## ភាពប្រឈម

អ្នកសារព័ត៌មានជាច្រើនតែងនិយាយថា អ្វីដែលលំបាកជាងគេនោះក្នុងការសរសេរ គឺសំណួរថា តើត្រូវចាប់ផ្តើមដោយរបៀបណា។ អ្វីដែលសំខាន់ជាងគេបំផុតនោះ គឺពាក្យពេចន៍ប៉ុន្មានម៉ាត់ដំបូងនៅក្នុងរឿងនោះឯង។ បើសេចក្តីផ្តើមអាចទៅគួរឲ្យចាប់អារម្មណ៍ អ្នកអាននឹងអានរឿងនឹងដល់ចប់។ តែបើវាមិនដូច្នោះទេ អ្នកអាចនឹងផ្លាត់ទៅទំព័រមួយទៀតជាមិនខាន។

ពេលដែលគាត់តែងបានសេចក្តីផ្តើមហើយ ភាពប្រឈមបន្ទាប់មកទៀត គឺការរៀបរៀងផ្នែកដទៃទៀតនៃរឿង។

សំណួរសួរថា តើត្រូវរៀបរៀងព័ត៌មានតាមលំដាប់លំដោយបែបណា ដែលស្រួលយល់នោះ? សូម្បីតែអ្នកសរសេរមានបទពិសោធន៍ខ្ពស់ ក៏នៅតែជួបបញ្ហាក្នុងការរៀងរៀងសាច់រឿងដែរ។ ពួកគេប្រមូលបានព័ត៌មានច្រើនហើយ តែវាលំបាកក្នុងការសម្រេចថាតើគួរយកព័ត៌មានណាមកប្រើ ហើយថាគួរទុកព័ត៌មានណាចោលមួយអន្លើសិន។

ក្នុងអត្ថបទពិពណ៌នា សេចក្តីបញ្ចប់របស់រឿងក៏សំខាន់ណាស់ដែរ។ ស្មេរខ្លះបញ្ចប់សាច់រឿងរបស់គេជាមួយនឹងព័ត៌មានមិនសូវមានសារៈសំខាន់។ តែស្មេរខ្លះចូលចិត្តបញ្ចប់សាច់រឿងដោយបន្សល់ទុកនូវស្នាមជិតក្នុងអារម្មណ៍ ដក់ចិត្តអំពីមូលបទសាច់រឿង។ ជួនកាលគេបញ្ចប់ដោយប្រើនូវសម្រង់សម្តីខ្លាំងមួយ។ ជារួម វាជាការលំបាកដែរនឹងរកឲ្យបាននូវសេចក្តីបញ្ចប់មួយ ដែលតម្រូវចិត្តប្រហែលគ្នានឹងសំណួរថា តើចាប់សេចក្តីផ្តើមដោយរបៀបណា។

## ដំណើរការសំណេរ

សំណេរ គឺជាដំណើរការមួយដែលមិនមែនចាប់ផ្តើមពេលអ្នកយកព័ត៌មានអង្គុយចុះក្បែរកុំព្យូទ័រនោះទេ។ សំណេរ គឺជាដំណើរការគិតត្រិះរិះ។ វាចាប់ផ្តើមភ្លាមៗ នៅពេលដែលអ្នកយកព័ត៌មានរំលេចនូវគំនិតសម្រាប់ធ្វើរឿង ហើយវាបន្តរហូតនៅក្នុងដំណាក់កាលប្រមូលព័ត៌មាន ដូចជាចំណុចប្រសព្វរឿង សំណួរដែលត្រូវសួរ ការប្រមូលសេចក្តីពិស្តារ។ អ្នកយកព័ត៌មានប្រមូលព័ត៌មានផង ហើយគិតត្រិះរិះអំពីព័ត៌មាននោះក្នុងពេលជាមួយគ្នាតែម្តង។ បន្ទាប់មក គេធ្វើការវិភាគមើលថា តើព័ត៌មាននោះគួរយល់បានទេ មុននឹងរៀបរៀងវាតាមលំដាប់លំដោយឲ្យអ្នកអានងាយយល់។

មុននឹងធ្វើបានសំណេរល្អមួយ អ្នកសារព័ត៌មានចាំបាច់ត្រូវតែធ្វើការប្រមូលព័ត៌មានឲ្យបានល្អិតល្អន់។ ប្រសិនបើពួកគេមានបញ្ហាក្នុងការសរសេររឿង នោះជាញឹកញយ គឺមកពីពួកគេមិនបានជជែកជាមួយមនុស្សម្នាឲ្យបានច្រើន ឬមួយក៏ពួកគេមិនប្រមូលព័ត៌មានឲ្យបានគ្រប់គ្រាន់។ បើពួកគេមិនបានធ្វើការប្រមូលព័ត៌មានគ្រប់គ្រាន់ទេ រឿងរបស់គេពិតជានៅមានភាពស្រពេចស្រពិលជាមិនខាន។

# ជំពូកទី ៨ : សេចក្ដីផ្ដើម

សេចក្ដីផ្ដើមមានពីរប្រភេទ គឺសេចក្ដីផ្ដើមត្រង់ និងសេចក្ដីផ្ដើមជំអក់។

សេចក្ដីផ្ដើមត្រង់ ប្រាប់អ្នកអានឲ្យដឹងអំពីមូលបទ ឬចំណុចសំខាន់នៃសាច់រឿងភ្លាមៗ គឺនៅក្នុងឃ្លាទីមួយតែម្ដង។

សេចក្ដីផ្ដើមជំអក់ ច្រើនតែចាប់ផ្ដើមជាមួយនឹងនិទានកថា ការដំណាលខ្លីៗ (anecdote) ឬមួយជាមួយនឹងឧទាហរណ៍អំពីមនុស្សណាម្នាក់ស្ថិតក្នុងស្ថានភាពណាមួយ ឬវាអាចចាប់ផ្ដើមជាមួយនឹងការពិពណ៌នាទិដ្ឋភាព។ ទាំងនេះជាការរៀបរាប់រំលេចចំណុចគោលនៃរឿង ឬក៏រៀបឆាកនៃសាច់រឿង។ ក្រោយមកទៀត ស្មេរនឹងប្រាប់អ្នកអានថាអ្វីទៅជាចំណុចសំខាន់របស់រឿងហ្នឹង។

តើសេចក្ដីផ្ដើមប្រភេទមួយណាដែលអ្នកនឹងប្រើវា អាស្រ័យថា តើអ្នកកំពុងសរសេររឿងទាន់ហេតុការណ៍ ឬបទពិពណ៌នា។

## សេចក្ដីផ្ដើមត្រង់ (Direct leads)

សេចក្ដីផ្ដើមត្រង់ស័ក្ដិសមបំផុតសម្រាប់ព័ត៌មានទាន់ហេតុការណ៍។ សេចក្ដីផ្ដើមបែបនេះតែងផ្ទុកនូវព័ត៌មានដែលសំខាន់បំផុតអំពីថា មានអ្វីកើតឡើង គឺព័ត៌មានសំខាន់ៗក្នុង 5Ws និង H។ សេចក្ដីផ្ដើមដែលមានប្រសិទ្ធភាពបំផុតនោះ គឺជាសេចក្ដីផ្ដើមដែលសរសេរក្នុងទម្រង់ ប្រធាន-កិរិយាសព្ទ-កម្មបទ (subject-verb-object) ដែលយើងបាននិយាយនៅខាងដើមរួចមកហើយ។

ចូរក្រឡេកមើលសេចក្ដីផ្ដើមខាងក្រោម ដែលត្រូវបានដកស្រង់ចេញពីកាសែត The Vientiane Times នៅប្រទេសឡាវ :

*រដ្ឋាភិបាលជប៉ុនបានយល់ព្រមផ្ដល់មូលនិធិទ្រទ្រង់គម្រោងសាងសង់បណ្ដាញផ្លូវជនបទនៅខេត្ត Houaphan ដែលជាផ្នែកមួយនៃយុទ្ធនាការកាត់បន្ថយការធ្វើចម្ការអាកៀន។*

សេចក្ដីផ្ដើមនេះមានធាតុផ្សំ អ្នកណា (រដ្ឋាភិបាលជប៉ុន) ស្អី (យល់ព្រមផ្ដល់មូលនិធិទ្រទ្រង់គម្រោងសាងសង់បណ្ដាញផ្លូវជនបទ) នៅឯណា (នៅខេត្ត Houaphan) និងហេតុអ្វី (កាត់បន្ថយការធ្វើចម្ការអាកៀន)។




*ស្រង់កំណត់ហេតុបានល្អជួយដល់ការរៀបឆាកសាច់រឿង*

ខាងក្រោមជាឧទាហរណ៍ពីកាសែត Bangkok Post:

*មនុស្សប្រាំបួននាក់បានស្លាប់ ហើយ ១១ នាក់ផ្សេងទៀតរងរបួស នៅពេលដែលអ្នកបើកបររថយន្តប្រណាំងមួយបានបាត់ម្ចាស់ការ ធ្វើឲ្យរថយន្តជ្រុលទៅបុកហ្វូងទស្សនិកជននៅក្នុងទីលានប្រណាំងរថយន្ត Bangkok Drag Avenue ក្នុងសង្កាត់ Khlong Luang កាលពីយប់ថ្ងៃសៅរ៍កន្លងទៅនេះ។*

សេចក្តីផ្តើមមានធាតុផ្សំ *អ្នកណា* (មនុស្សប្រាំបួននាក់ និង ១១ នាក់ផ្សេងទៀត) ស្អី (ស្លាប់ និងរបួស) នៅឯណា (ទីលានប្រណាំងរថយន្ត Bangkok Drag Avenue ក្នុងសង្កាត់ Khlong Luang) និងពេលណា (កាលពីយប់ថ្ងៃសៅរ៍)។

## សេចក្តីផ្តើមដំអក់ (Delayed leads)

សេចក្តីផ្តើមដំអក់ស៊ីគ្នាជាមួយនឹងបទពិពណ៌នា។ តាមធម្មតា ស្មេរផ្តើមរឿងដោយប្រើប្រាស់ឧទាហរណ៍ ឬការដំណាលណាមួយ ដែលគួរឲ្យចាប់អារម្មណ៍អំពីបុគ្គល ឬព្រឹត្តិការណ៍មួយ ដើម្បីឆ្លុះបញ្ចាំងគំនិតសំខាន់របស់រឿង។

ប៉ុន្តែពេលប្រើសេចក្តីផ្តើមដំអក់ វាជាសារៈសំខាន់ចាំបាច់ក្នុងការឆាប់ទាក់ទាញអ្នកអានចូលទៅដល់ប្រយោគចំណុចសំខាន់នៃសាច់រឿង។ បើមិនដូច្នោះទេ អ្នកអាននឹងច្រលំថាអ្នកកំពុងនិយាយអំពីអ្វី ហើយថាតើពួកគេគួរអានរឿងហ្នឹង។

ពិតណាស់ អ្នកអាចផ្តើមអត្ថបទពិពណ៌នាជាមួយនឹងចំណុចសំខាន់តែម្តង បានជំនួសឲ្យឧទាហរណ៍ ឬការដំណាល ឬការរៀបរាប់អំពីទិដ្ឋភាព។ ប៉ុន្តែធ្វើដូច្នោះមិនសូវមានប្រសិទ្ធភាពទេ។

សេចក្តីផ្តើមដំអក់ដូចខាងក្រោម គឺជាជម្រើសដែលកាសែត The Nation បានជ្រើសយកសម្រាប់រឿងមួយ ដែលនិយាយអំពីស្ត្រីថៃម្នាក់បានរកឃើញកូនស្រីរបស់គាត់ដែលបានបាត់ខ្លួនយូរមកហើយ ៖

*នាង ហួដ ស៊ូសែង (Huad Susaeng) អាយុ ៣១ ឆ្នាំ មើលមិនស្គាល់កុមារីស្គមកំព្រឹង គគ្រិចម្នាក់ដែលនាងបានឃើញ កំពុងសុំទានតាមដងផ្លូវ ខេត្តភូកេត កាលពីសប្តាហ៍កន្លងទៅនេះទេ។ តែពេលនោះ មានអ្វីមួយដែលបន្ទុចដំណើររបស់គាត់ឲ្យមកដាក់ទានកាក់ ១០ បាត ទៅឲ្យកុមារីនោះ។*

*ក្មេងស្រីតូចម្នាក់នោះ ក៏មើលទៅកាន់នាង ហួដ ស៊ូសែង មិនដាក់ភ្នែក ដោយមិនខ្វីរវល់ជាមួយនឹងប្រាក់ដាក់ទានឲ្យនាងនោះទេ។*

*"ម៉ែ?" ជាសំណួរដែលក្មេងស្រីនោះ សួរក្នុងសម្លេងយ៉ាងស្រទន់ ព្រមពេលជាមួយគ្នាដែលទឹកភ្នែកចាប់ផ្តើមហូរលើផ្ទៃមុខរបស់ដ៏ក្រៀមក្រំរបស់នាង។*

*ពាក្យមួយម៉ាត់នេះ - ហើយនិងជំនួបបែបសំណាងមួយក្នុងមួយលានសំណាង - បានបញ្ចប់នូវការព្រាត់ប្រាសដ៏ខ្លោចផ្សាមួយ ដែលបានហែកហួរជីវិតមនុស្សពីរនាក់អស់រយៈពេលបីឆ្នាំ"*

*មន្ត្រីនគរបាលម្នាក់ ដែលនាង ហួដ ស៊ូសែង បានប្រកូកហៅឲ្យជួយនិយាយថា "ពេលដែលយើងទៅដល់កន្លែងនោះ ម្តាយ និងកូន កំពុងអោបគ្នាយំនៅឡើយទេ"។*

*នាង កេសន ម៉ានពូក (Kesorn Manpook) អាយុ ៧ ឆ្នាំ ត្រូវបានក្រុមជនខិលខូចកម្ពុជាមួយក្រុមចាប់ពង្រត់ពីគេហដ្ឋានញាតិសន្តានរបស់នាងនៅខេត្តខុនខេន កាលពីបីឆ្នាំមុន។ នាង ហួដ ស៊ូសែង ត្រូវទទួលរងនូវការគ្រាំគ្រាក្នុងផ្លូវចិត្ត ហើយនាងបានស្វះស្វែងរកកូននាងគ្រប់ច្រកល្ហក*

*តែរកមិនឃើញ ហើយបានបោះបង់ចោលអស់បាត់ទៅហើយនូវសេចក្ដីសង្ឃឹមថានឹងបានឃើញកូនស្រីរបស់គាត់សាជាថ្មីនោះ។*

ក្នុងរឿងនេះ ស្មេរបានចាប់ផ្ដើមជាមួយការរៀបរាប់អំពីការជួបគ្នាដោយចៃដន្យនៅតាមដងផ្លូវ មុននឹងចូលទៅដល់ចំណុចស្នូលនៃសាច់រឿង គឺការដែលម្ដាយនោះ បានចំណាយពេលយូរឆ្នាំក្នុងការស្វែងរកកូនស្រីរបស់គាត់ ដែលត្រូវបានគេចាប់ពង្រត់។

បើសិនជាអ្នកប្រើសេចក្ដីផ្ដើមត្រង់វិញ រឿងនេះនឹងមានទម្រង់ដូចខាងក្រោម ៖

*ស្ត្រីម្នាក់ដែលបានចំណាយពេលបីឆ្នាំស្វែងរកកូនស្រីដែលបានបាត់ខ្លួន បានរកឃើញនាងពីសប្ដាហ៍មុន ក្នុងពេលដែលក្មេងស្រីនោះកំពុងអង្គុយសុំទាននៅតាមដងផ្លូវមួយក្នុងខេត្តកូកេត។*

ប៉ុន្តែសេចក្ដីផ្ដើមរបៀបនេះ ធ្វើឲ្យសាច់រឿងមិនសូវមានឥទ្ធិពលទៅលើអារម្មណ៍អ្នកអានប៉ុន្មានទេ។

របៀបជាទូទៅក្នុងការសរសេរអត្ថបទពិពណ៌នាអំពីនិន្នាការគ្រោះមហន្តរាយ ឬអ្វីមួយ ដែលមានផលប៉ះពាល់ទៅលើមនុស្សច្រើននាក់ គឺការផ្ដើមដោយដំណាលរឿងយ៉ាងខ្លី អំពីមនុស្សម្នាក់ ឬពីរនាក់។

កាសែតភ្នំពេញប៉ុស្តិ៍ បានធ្វើអត្ថបទមួយអំពីក្រុមគ្រួសារក្រីក្រជាច្រើនដែលបានធ្វើចំណាកស្រុកទៅខេត្តរតនៈគីរី ដើម្បីទៅប្រកបមុខរបរជីករកត្បូង ដែលជាមុខរបរប្រកបដោយគ្រោះថ្នាក់មួយ។ អត្ថបទនោះផ្ដើមដោយរៀបរាប់អំពីការរុករកត្បូងរបស់បុរសម្នាក់ ៖

*ក្នុងជម្រៅ ១៥ ម៉ែត្រ ពីមាត់រណ្ដៅដ៏តូចចង្អៀតមួយអ្វី ដែលលោក ពុយ ខ្លាចបំផុតនោះ គឺពន្លឺព្រឹមៗនៃភ្លើងទានរបស់គាត់អាចនឹងរលត់ភ្លឹប ដោយទុកឲ្យគាត់ជាប់នៅក្នុងភាពអន្ធកាលក្នុងរណ្ដៅនោះតែម្នាក់ឯង។*

របៀបមួយទៀតក្នុងសរសេរបទពិពណ៌នា គឺការរៀបរាប់ទិដ្ឋភាព។

ខាងក្រោមជាសេចក្ដីផ្ដើមរឿង "ទីក្រុងភូមាក្បែររាជធានីបាងកក" ដែលសរសេរដោយអ្នកកាសែតថៃម្នាក់ ៖

*លោកសង្ឃកំពុងសូត្រធម៌ប្រោះព្រំក្នុងពិធីមង្គលការគូស្វាមីភរិយាជនជាតិភូមាមួយគូ។ កូនកម្លោះក្នុងសម្លៀកបំពាក់អាវពណ៌សដៃវែង និង*



*ពលករកុមារទាំងនេះអាចជាកម្មវត្ថុជាសេចក្ដីផ្ដើមបាន*

*សារុងពណ៌មាស កូនក្រមុំស្ថិតក្នុងរ៉ូប និងសារុងពណ៌ផ្កាឈូក នាំគ្នាធ្វើការប្តូងសួងដល់ដូនតារបស់គេទាំងសងខាង។ ស្នូរចម្រៀងប្រពៃណី និងសម្លេងភ្ញៀវជជែកគ្នា ឮអ៊ូអរពេញរោងការ។*

ប្រយោគបន្ទាប់មកទៀត គឺនិយាយអំពីគូស្វាមីភរិយាកំពុងទទួលភ្ញៀវដែលមកចូលរួមពិធីមង្គលការ។

*លោក Min Tun Thein អាយុ ២២ ឆ្នាំ និងភិរយារបស់គាត់ Mi Thuzar Tun អាយុ ២០ ឆ្នាំ កំពុងមើលវីដេអូពិធីអាពាហ៍ពិពាហ៍របស់ពួកគេនៅក្នុងបន្ទប់ស្នាក់នៅតូចមួយក្នុងផ្សារលក់បង្គារ។ ពិធីមង្គលការនោះ ត្រូវបានប្រារព្ធឡើងនៅខាងមុខបន្ទប់របស់ពួកគេកាលពីប៉ុន្មានថ្ងៃមុននេះ។ ស្លាក "ស្វាគមន៍" ជាភាសាភូមា នៅព្យួរនៅទីនោះនៅឡើយ។ ស្វាមី និងភរិយាមួយគូនេះ ស្ថិតក្នុងចំណោមពលករអន្តោប្រវេសន៍ភូមាប្រមាណជា ២០០.០០០ នាក់ ដែលកំពុងរស់នៅសង្កាត់ Maha Chai ដែលជាក្រុងកំពង់ផែមួយរបស់ខេត្ត Samut Sakhon។*

មានសេចក្តីផ្តើមផ្សេងទៀត ដែលមានលក្ខណៈជាកិច្ចសន្ទនាដែរ ដែលធ្វើឲ្យអ្នកអានត្រិះរិះគិត និងទាក់ទាញអារម្មណ៍របស់ពួកគេផងដែរ។

ខាងក្រោមនេះ ជាឧទាហរណ៍មួយទៀតពីកាសែត The Nation:

*ចូរសាកនាំគ្នាស្រមៃមើលក្រុងបាងកក ដែលគ្មានបង្គោលអគ្គីសនី គ្មានបណ្តាញខ្សែឋាមពលអគ្គីសនី និងប្រព័ន្ធខ្សែទូរស័ព្ទ។*

*លើកលែងតែមានការប្រឈមផ្នែកផ្លូវច្បាប់ណាមួយ ទស្សនវិស័យបែបនេះ អាចក្លាយជាការពិតនាពេលខ្លីខាងមុខ ដោយសារតែគម្រោងប្រកបដោយមហិច្ឆិតាមួយរបស់រដ្ឋបាលក្រុងបាងកក (Bangkok Metropolitan Administration)។*

*រដ្ឋបាលក្រុងបាងកក អាចនឹងផ្តល់កុងត្រាដល់ក្រុមហ៊ុនសំណង់សហរដ្ឋអាមេរិកមួយឈ្មោះ Pro-Dive Inc. ដើម្បីធ្វើរូងក្រោមដីសម្រាប់លាក់បណ្តាញខ្សែទូរស័ព្ទ និងខ្សែបន្តអគ្គីសនីទៅក្រោមដីកុំឲ្យវានៅកណ្តាលវាលតទៅទៀត។ គម្រោងនេះជាផ្នែកមួយនៃផែនការរបស់រដ្ឋបាលក្រុងបាងកកក្នុងការសំអាតជើងមេឃលើក្រុងបាងកក និងពង្រីកទេសភាពរបស់ទីក្រុង។*

## កុំ "កប់" សេចក្តីផ្តើម

ក្នុងការសរសេររឿងដំណឹងទាន់ហេតុការណ៍ អ្នករាយការណ៍ព័ត៌មានជាច្រើន តែងមិនបានរំលេចចំណុចសំខាន់ ឬមុំនៃរឿងឲ្យនៅក្នុងប្រយោគខាងលើនៃអត្ថបទទេ។ ជួនកាល ពួកគេចាប់ផ្តើមសាច់រឿងអំពីកិច្ចប្រជុំ ដោយនិយាយអំពីអ្នកណាខ្លះដែលបានចូលរួមប្រជុំ ជៀសវាងប្រាប់គេថា គេបានចាត់វិធានការអ្វីខ្លះក្នុងកិច្ចប្រជុំនោះ។ និយាយម្យ៉ាងទៀតឲ្យស្រួលស្តាប់ពួកគេបាន "កប់" ដំណឹងថ្មីៗជ្រៅទៅក្នុងសាច់រឿង។

ចូរនាំគ្នាក្រឡេកមើលសេចក្តីរាយការណ៍មួយនេះពីប្រទេសឡាវ ៖

ប្រធានការិយាល័យផែនការកសិកម្ម និងរុក្ខាប្រចាំខេត្ត Borikhamsay គឺលោក Bounkham Phommachuk បានរាយការណ៍ថា កសិករក្នុងខេត្តនេះ បានចាប់ផ្តើមច្រូតកាត់ស្រូវវស្សាក្នុងខែតុលា នេះហើយ។

មកទល់ពេលនេះ គេបានច្រូតកាត់រួចហើយនៅលើផ្ទៃដី ១៩.៥៣០ ហិកតា (ស្មើនឹង ៨០ ភាគរយ) នៃផ្ទៃដីសរុប ២៤.៧៩២ ហិកតា។

ចូរសាកសរសេរវាតាមរបៀបនេះវិញ ៖

*មន្ត្រីរដ្ឋាភិបាលម្នាក់បាននិយាយថា កសិករខេត្ត Borikhamsay បានប្រូតកាត់ស្រូវរដូវវស្សារបស់គេបានជិត ៨០ ភាគរយ ហើយ។*

*លោក Bounkham Phommachuk ប្រធានការិយាល័យផែនការកសិកម្ម និងរុក្ខា ប្រចាំខេត្តបាននិយាយថា ស្រូវលើផ្ទៃដីប្រមាណ ១៩.៥៣០ ហិកតា នៃផ្ទៃដីសរុប ២៤.៧៩២ ហិកតា ត្រូវបានប្រូតកាត់រួចអស់ហើយ។*

សរសេររបៀបនេះ ធ្វើឲ្យសេចក្ដីផ្ដើមរបស់រឿងងាយអានជាង ដោយយើងបានដកឈ្មោះ និងងារដ៏វែងរបស់មន្ត្រីនោះចេញសិន។ សេចក្ដីផ្ដើមបែបនេះ វាផ្ដោតទៅលើដំណឹង គឺការប្រូតកាត់ ជាជាងផ្ដោតទៅលើមន្ត្រី ដែលគ្រាន់តែជាប្រភពព័ត៌មានមួយតែប៉ុណ្ណោះ។ វាផ្ដោតទៅលើភាពជាក់លាក់ (៨០ ភាគរយ បានប្រូតកាត់រួចហើយ) ជៀសជាងការគ្រាន់តែនិយាយជាទូទៅ (ថាការប្រូតកាត់បានចាប់ផ្ដើមហើយ)។

សូមក្រឡេកមើលឧទាហរណ៍ខាងក្រោមពីកាសែតកម្ពុជាមួយថា តើគេផ្ដើមរឿងដោយរបៀបណា។ "ខ្សែចង្កេះ" គឺសំដៅទៅរកខ្សែដែលជនកម្ពុជាច្រើននាក់ពាក់នៅនឹងចង្កេះ ដោយគេជឿថាវានឹងជួយការពារពួកគេ។

*ឱបាត់ដំបងបណ្ដូលចិត្តអើយ! នេះជាចម្រៀងដ៏ល្បីល្បាញមួយរបស់លោក ស៊ីន ស៊ីសាមុត ច្រៀងយ៉ាងល្បីល្បាញកាលពីទសវត្សរ៍ទី ៦០ និង ៧០។ តាំងពីសម័យសង្គមរាស្ត្រនិយម រហូតមកដល់សម័យបច្ចុប្បន្ន តើមានលោកណាដែលមិនចង់ទៅធ្វើចៅហ្វាយខេត្តបាត់ដំបង? ហើយតើមានលោកប៉ូលីសណា លោកប៉េអឹមណា និងលោកពន្ធដារណាដែលមិនចង់ទៅកាន់ប៉ុស្តិ៍នៅបាត់ដំបង?*



*ខេត្តបាត់ដំបង អ្នកណាក៏ចង់ទៅធ្វើការទីនោះដែរ*

*សេចក្ដីផ្ដើម*

*ពីព្រោះបាត់ដំបង ជាខេត្តដែលមានប្រកសេដ្ឋកិច្ចធំជាងបន្ទាប់ពីភ្នំពេញ និងក្រុងកំពង់ចាម ដូចគ្នានឹងកំពង់សោម។ តែអ្នកទាំងឡាយណាដែលចង់ទៅភាគច្រើន គឺទៅមិនរួច ហើយអ្នកទាំងឡាយណាដែលត្រូវទៅ ត្រូវតែមានខ្សែចង្កេះ ហើយជាទូទៅពួកគេត្រូវមានដុល្លារសម្រាប់បងធំ ដើម្បីមានសំណាង។ ប៉ុន្តែសម្រាប់អាណត្តិទីពីរនេះ បាត់ដំបងជាពិសេសមិនងាយលេបបានងាយដូចអាណត្តិទីមួយទេ ពីព្រោះបាត់ដំបងពេលនេះកំពុងប្រឈមមុខនឹងអសន្តិសុខធ្ងន់ធ្ងរ បន្ទាប់ពីទីក្រុងភ្នំពេញ ដែលសឹងតែរាល់ថ្ងៃមានអំពើចោរកម្ម ឆក់ប្លន់ បាញ់សម្លាប់មនុស្ស ហើយជាពិសេសដែលហេតុការណ៍ពិបាកនឹងបង្ក្រាបដែលជាពួកក្រុមបងធំ ដែលសុទ្ធតែកូនលោកមន្ត្រីខេត្ត និងអស់លោករដ្ឋមន្ត្រីជាដើម។*

*ព័ត៌មានពីអ្នកឆ្លើយឆ្លងព័ត៌មានប្រចាំខេត្តបាត់ដំបង បានរាយការណ៍ថា កាលពីយប់ទី ៣១ ខែកក្កដា នៅប្រហែលម៉ោង ១០ យប់ មានគ្រាប់បែកមួយគ្រាប់ ត្រូវបានគប់ទៅលើដំបូលបារាំបុប្ផាទិព្វ ហើយគ្រាប់បែកនោះ បានរមៀលធ្លាក់ ហើយផ្ទុះធ្វើឲ្យនគរបាលម្នាក់ស្លាប់ ហើយធ្វើឲ្យនគរបាលប្រាំនាក់រងរបួស ជាមួយនឹងប្រជាជនក្បែរនោះ ដែលក្នុងចំណោមនោះមានប្រាំនាក់ត្រូវរបួស។*

ដំណឹងកន្លែងនេះ គឺការផ្ទុះគ្រាប់បែក និងមនុស្សរងរបួស។ ប៉ុន្តែ រឿងនេះមិននិយាយមកដល់ចំណុចទាំងនេះភ្លាមទេ គឺទុករហូតក្រោយពីការអត្ថាធិប្បាយក្នុងប្រយោគមួយដ៏វែងអន្លាយអំពីក្រុងបាត់ដំបងទៅវិញ។

យកល្អ សរសេរដូច្នេះវិញ :

*នគរបាលម្នាក់ត្រូវបានស្លាប់ និងមនុស្ស ១០ នាក់ផ្សេងទៀតរងរបួស នៅក្នុងការវាយប្រហារដោយគ្រាប់បែកមួយទៅលើរង្គសាលរាត្រីមួយនៅក្រុងបាត់ដំបង កាលពីយប់ថ្ងៃទី ៣១ កក្កដា។*

នេះជាឧទាហរណ៍មួយទៀតអំពីការកប់សេចក្ដីផ្ដើមនៅក្នុងកាសែតមួយពីប្រទេសភូមា :

*ក្រុងរ៉ង់ហ្គូន - ពិធីប្រគល់អំណោយលើកទីបួនសម្រាប់សាងសង់វត្ត Thabyinnyu ត្រូវបានប្រារព្ធឡើងនៅអគារទីប្រាំនៃវត្ត Dhammaythaka Sarthintaik ក្នុងសង្កាត់ Mayangon ព្រឹកមិញនេះ ដែលចូលរួមដោយលេខាទីមួយនៃក្រុមប្រឹក្សារដ្ឋដើម្បីសន្តិភាព និងការអភិវឌ្ឍ (Secretary-1 of the State Peace and Development Council) គឺឧត្តមសេនីយឯក Khin Nyunt។*

*ពិធីនេះមានការចូលរួមផងដែរពីសំណាក់វេជ្ជបណ្ឌិត Khin Win Swe ភរិយារបស់លេខាទីមួយ ឧត្តមសេនីយឯក Khin Nyunt, រដ្ឋមន្ត្រីឧស្សាហកម្មទីមួយ លោក U Aung Thaung, រដ្ឋមន្ត្រីរ៉ែ ឧត្តមសេនីយត្រី Onh Myint, រដ្ឋមន្ត្រីព័ត៌មាន ឧត្តមសេនីយទោ Kyi Aung, រដ្ឋមន្ត្រីទទួលបន្ទុកការរីកចំរើនតំបន់ព្រំដែន និងពូជសាសន៍ជាតិ និងកិច្ចការអភិវឌ្ឍន៍ វរៈសេនីយឯក Thein Nyunt, រដ្ឋមន្ត្រីដឹកជញ្ជូន ឧត្តមសេនីយត្រី Hla Myint Swe, រដ្ឋមន្ត្រីសង្គមកិច្ច សង្គ្រោះ និងការផ្លាស់ប្ដូរលំនៅដ្ឋាន ឧត្តមសេនីយត្រី Pyi Sone, រដ្ឋមន្ត្រីថាមពល អគ្គីសនី ឧត្តមសេនីយទោ Tin Htut, រដ្ឋមន្ត្រីកីឡា ឧត្តមសេនីយត្រី Sein Win, រដ្ឋមន្ត្រីសុខាភិបាល ឧត្តមសេនីយទោ Ket Sein, រដ្ឋមន្ត្រីកិច្ចការសាសនា ឧត្តមសេនីយទោ Sein Htwa, ប្រធានគណៈកម្មការអភិវឌ្ឍន៍ក្រុងរ៉ង់ហ្គូន លោកអភិបាល U Ko Lay មន្ត្រីនានាពីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋដើម្បីសន្តិភាព និងការអភិវឌ្ឍក្រុមប្រឹក្សាក្រុង និងស្រុក ដើម្បីសន្តិភាព និងការអភិវឌ្ឍ និងអ្នកអបអរសាទរជាច្រើននាក់ថែមទៀត។*

# កុំ "ញាត់" សេចក្តីផ្តើមឲ្យលើសចំណុះ

មានសារៈសំខាន់ណាស់ក្នុងការដឹងថា តើអ្វីខ្លះដែលគួរត្រូវយកទៅប្រើក្នុងសេចក្តីផ្តើម។ វាមានសារៈសំខាន់ដូចគ្នាដែរក្នុងការដឹងថា តើមានខ្លះដែលមិនគួរយកទៅដាក់ក្នុងសេចក្តីផ្តើម។ ចូរកុំប្រឹង "ញាត់" ទៅក្នុងសេចក្តីផ្តើមនូវគំនិតច្រើនពេក ឬក៏ចំណុចពិស្តារទាំងឡាយណា ដែលមិនសូវមានសារៈសំខាន់ ដែលអាចយកមកនិយាយក្នុងផ្នែកខាងក្រោមទៀតនៃរឿងបាន។ អ្នកមិនចាំបាច់ញាត់ 5Ws និង H ទាំងអស់ទៅក្នុងសេចក្តីផ្តើមទេ ហើយអាចយកធាតុផ្សំរបស់វាខ្លះមកដាក់នៅក្នុងវាក្យខ័ណ្ឌទីពីរ ឬទីបីបាន។

សូមមើលឧទាហរណ៍ខាងក្រោមពីកាសែតភូមាមួយ :

*កាសែតជាច្រើនក្នុងយុគ្គសម័យសភាប្រជាធិបតេយ្យលក់ដាច់ដូចនំផ្ទិនក្តៅៗ ក្នុងទិវាពិព័រណ៍សៀវភៅដ៏កម្រមួយ ហើយអតិថិជនដែលចាប់អារម្មណ៍អាចរកទិញកាសែតទាំងនោះបានទៀតពីការិយាល័យចាងហ្វាងការផ្សាយផងដែរ។*

*ចាងហ្វាងបោះពុម្ពផ្សាយ Zaw បានបើកការតាំងពិព័រណ៍សៀវភៅរបស់ខ្លួនពីថ្ងៃ ៦ ដល់ ២៤ តុលា នៅសាលពិព័រណ៍ Lawkanat នៅលើផ្លូវ Pansodan ក្រុងយ៉ង់ហ្គូន។ នេះជាការតាំងពិព័រណ៍បែបនេះលើកទីបួនហើយ ដែលក្នុងនោះ មានសៀវភៅជាច្រើនក្បាល ដែលនិពន្ធដោយសម្តេចសង្ឃ Ledi Sayadaw ផង។ មិត្តអ្នកអានដែលស្វែងរកសៀវភៅអានថែមទៀត អាចទាក់ទងទៅក្រុមហ៊ុននៅអាសយដ្ឋានផ្ទះលេខ ៨២ ផ្លូវលេខ ៣៧ ក្រុងយ៉ង់ហ្គូន។*

*លេខាធិការគណៈកម្មការការងារ និងជាអនុរដ្ឋមន្ត្រីកសិកម្ម និងធារាសាស្ត្រ ឧត្តមសេនីយត្រី Khin Maung បានរាយការណ៍ជូនលេខាទីមួយ ឧត្តមសេនីយឯក Khin Nyunt អំពីការរីកចំរើនការងារសាងសង់វត្ត និងជូនចំពោះប្រធានអនុកម្មការហិរញ្ញវត្ថុ និងជាអនុរដ្ឋមន្ត្រី ដឹកជញ្ជូនផ្លូវដែក លោក Thura U Thaung Lwin អំពីវិភាគទានទឹកប្រាក់ និងចំណាយនានាលើការសាងសង់វត្ត។*

ក្រោយពីការរៀបរាប់វែងអន្លាយ ដែលមាន ២០៧ ពាក្យ ជាភាសាអង់គ្លេស ដែលក្នុងនោះមានឈ្មោះរបស់មនុស្ស ១៧ នាក់ ដែលមានបរមងារយ៉ាងវែង ទើបយើងទទួលបានដំណឹងខ្លះ ដែលនោះគឺ ៖

*លេខាទីមួយនៃក្រុមប្រឹក្សារដ្ឋ ដើម្បីសន្តិភាព និងការអភិវឌ្ឍ ឧត្តមសេនីយឯក Khin Nyunt និងរដ្ឋមន្ត្រីជាច្រើនរូបទៀត បានទទួលយកវិភាគទានដែលមានជាទឹកប្រាក់សរុប ១៧,៥ លាន គៀត (ឈ្មោះរូបិយប័ណ្ណភូមា)។*

គេអាចសរសេរបានមួយបែបទៀត ដើម្បីឲ្យបានសេចក្តីផ្តើមគ្រាន់បើជាងនេះ :

*លោកឧត្តមសេនីយ Khin Nyunt និងរដ្ឋមន្ត្រីជាច្រើនរូបទៀត កាលពីម្សិលមិញ ប្រមូលបានប្រាក់ ១៧,៥ លាន គៀត ដែលជាវិភាគទានសម្រាប់ការសាងសង់វត្តថ្មីមួយនៅក្នុងសង្កាត់ Mayangon។*

អ្នកអាចគិតថា អ្នកគួររាយនាមមន្ត្រីជាន់ខ្ពស់ទាំងអស់ដែលបានចូលរួម។ អ្នកអាចធ្វើដូច្នោះបាន ប៉ុន្តែសូមធ្វើក្រោយពីអ្នកប្រាប់ដំណឹងថ្មីដល់អានហើយសិន។

ឧទាហរណ៍មួយទៀតបានមកពីកាសែត The Vietnam Times ។ សេចក្តីផ្តើមមានជាតុផ្សំ What, Who និង When រីឯ Where និង Why គេយកទៅដាក់ក្នុងវាក្យខ័ណ្ឌទីពីរវិញ។

ហាណូយ - លោក Marc Olive តំណាងអង្គការសុខភាពពិភពលោកប្រចាំប្រទេសវៀតណាម មានប្រសាសន៍កាលពីម្សិលមិញថា ការបំបៅទារកដោយទឹកដោះម្តាយជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត ក្នុងការការពារពួកគេមិនឲ្យមានជំងឺដោយសារអាហារខ្វះសុវត្ថិភាព។

នៅក្នុងសន្និសីទមួយ ដែលធ្វើឡើងរួមគ្នាដោយអង្គការសុខភាពពិភពលោក និងអង្គការ Unicef ជាការឆ្លើយតបទៅនឹងរឿងអាស្រូវម្សៅទឹកដោះគោខ្វះអនាម័យនៅប្រទេសចិន លោក Marc និយាយគូសបញ្ជាក់អំពីភាពចាំបាច់ក្នុងការឲ្យទារកបៅដោះម្តាយយ៉ាងហោចណាស់ប្រាំមួយខែ ដើម្បីជួយឲ្យរាងកាយ និងខួរក្បាលរបស់ពួកគេមានការលូតលាស់ និងការអភិវឌ្ឍល្អ។

ឥឡូវសូមក្រឡេកមើលសេចក្តីផ្តើមមួយនេះពីកាសែតភាសាអង់គ្លេសមួយនៅប្រទេសថៃ ដែលនិយាយអំពីការដោះដូររូបិយប័ណ្ណ ដែលនោះជាកិច្ចព្រមព្រៀងខ្ចីរូបិយប័ណ្ណបរទេស ដើម្បីយកមកជួយធ្វើឲ្យរូបិយប័ណ្ណក្នុងស្រុកមានស្ថេរភាព។

*ប្រទេសថៃ និងប្រទេសជប៉ុន នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងបឋមមួយ ស្តីពីការរៀបចំឲ្យមានការដោះដូររូបិយប័ណ្ណទ្វេភាគី ក្នុងតម្លៃ ៣ ពាន់លានដុល្លារអាមេរិក (១៣៥ ពាន់លានបាត) នៅពេលដែលរដ្ឋមន្ត្រីហិរញ្ញវត្ថុប្រទេសទាំងពីរជួបគ្នានៅទីក្រុងហូណូលូលូ រដ្ឋហាវ៉ៃ សហរដ្ឋអាមេរិក នៅក្រៅក្របខ័ណ្ឌកិច្ចប្រជុំរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនាសប្តាហ៍ក្រោយនេះ។*



*ជានិច្ចកាលចូរសួរខ្លួនឯងថាតើរឿងនឹងនិយាយអំពីអ្វី*

តើវាមានសារៈសំខាន់ទេ ដែលថាកិច្ចព្រមព្រៀងមួយនឹងត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីទាំងពីរនៅក្រុងហូណូលូលូ ក្នុងអំឡុងកិច្ចប្រជុំរបស់ធនាគារអាស៊ី? តើកិច្ចព្រមព្រៀងខ្លួនឯងនឹងមិនមែនជាដំណឹងទេ ឬយ៉ាងម៉េច? តើអ្វីទៅជាគោលបំណងនៃកិច្ចព្រមព្រៀងនោះ?

សេចក្តីផ្តើមរបស់ទីភ្នាក់ងារព័ត៌មាន ស្តីអំពីរឿងដូចគ្នានេះ មានលក្ខណៈណែន ហើយច្បាស់ជាង :

*ប្រទេសថៃ និងប្រទេសជប៉ុន សម្រេចបាននូវកិច្ចព្រមព្រៀងទូទៅមួយ ធ្វើឲ្យមានការដោះដូររូបិយប័ណ្ណមានតម្លៃ ៣ ពាន់លានដុល្លារ ដើម្បីជួយទ្រទ្រង់ដល់ប្រាក់បាត។*

## តើមានអ្វីខុសគ្នាត្រង់នេះ?

សេចក្តីផ្តើមល្អៗ មិនមែនគ្រាន់តែជាសេចក្តីផ្តើមដែលផ្តល់ព័ត៌មានប៉ុណ្ណោះទេ តែវាជាសេចក្តីផ្តើមដែលកន្ត្រាក់អារម្មណ៍ (interesting) អ្នកអានផងដែរ។ វាមិនគ្រាន់តែផ្ទុកទៅដោយព័ត៌មានសំខាន់ប៉ុណ្ណោះទេ តែកាលណាអាចធ្វើទៅបាន គួរប្រាប់ដល់អ្នកឲ្យបានដឹងថា តើព្រឹត្តិការណ៍មួយហ្នឹង

វាខុសគ្នាពីព្រឹត្តិការណ៍ឯទៀតយ៉ាងដូចម្ដេច។ តើការប៉ះទង្គិចរថយន្តសុទ្ធតែដូចគ្នាទាំងអស់ឬ? មិនមែនទេ។ ចូរត្រិះរិះមើលថា តើការប៉ះទង្គិចដោយរថយន្តមួយកន្លែង ដែលអ្នកកំពុងតែសរសេរវាខុសគ្នាពីគ្រោះថ្នាក់ដោយរថយន្តនៅកន្លែងផ្សេងទៀតដូចម្ដេចខ្លះ។

ជំនួសនឹងការសរសេរថា ៖

*រថយន្តដឹកអ្នកដំណើរមួយគ្រឿងបានដួលផ្ងារពោះឡើងលើនៅក្រៅក្រុងយ៉ាងហ្គុន ក្នុងពេលដែលមានព្យុះភ្លៀងកាលពីម្សិលមិញ ដោយធ្វើឲ្យមនុស្សបីនាក់ស្លាប់។*

ចូរសាកល្បងសរសេរ ដូច្នេះវិញ៖

*រថយន្តដឹកអ្នកដំណើរមួយគ្រឿងបានដួលផ្ងារពោះឡើងលើនៅក្រៅក្រុងយ៉ាងហ្គុន ក្នុងពេលដែលមានព្យុះភ្លៀងកាលពីម្សិលមិញ ធ្វើឲ្យស្ត្រីចំណាស់បីនាក់ស្លាប់ ក្នុងពេលដែលពួកគេកំពុងត្រឡប់ទៅផ្ទះ ក្រោយពីបានចូលរួមបុណ្យសពញាតិរបស់ពួកគេរួចមក។*

សំណេរសេចក្ដីផ្ដើម មិនមែនជារឿងងាយដូចនឹងការធ្វើលំហាត់តាមរូបមន្តនោះទេ។ មិនមែនគ្រប់ពេល ប្រធានបទ Who ត្រូវតែនៅពីមុខ What ហើយ Where ត្រូវតែនៅក្រោយគេជានិច្ចនោះទេ។ លំដាប់លំដោយរបស់វា អាស្រ័យទៅនឹងព្រឹត្តិការណ៍ដំណឹង។

បើសិនជាមានរថយន្តបុកគ្នា ហើយមនុស្សប្អូននាក់ស្លាប់ក្នុងគ្រោះថ្នាក់នោះ សេចក្ដីផ្ដើមរបស់វាប្រហែលជាគេអាចសរសេរបានដូចតទៅ៖

*មនុស្សប្អូននាក់បានបាត់បង់ជីវិតកាលពីម្សិលមិញ នៅពេលដែលរថយន្តមួយគ្រឿងបានរេខុសផ្លូវសើមមួយក្នុងទីក្រុងហូជីមិញ។*

បើសិនជាគ្រោះថ្នាក់រថយន្តកើតឡើង ដោយសារទឹកជំនន់ សេចក្ដីផ្ដើមប្រហែលជាគួរផ្ដោតទៅលើសំណួរ Why វិញ ៖

*ភ្លៀងមួយមេធំ និងទឹកជំនន់ បានរុញច្រានរថយន្តមួយធ្លាក់ពីលើថ្នល់នៅក្រុងហូជីមិញ ពីម្សិលមិញ ដោយបណ្ដាលឲ្យមនុស្សប្អូននាក់ស្លាប់បាត់បង់ជីវិត។*

បើសិនជាមានមន្ត្រីជាន់ខ្ពស់កំពុងជិះក្នុងរថយន្តដែលមានគ្រោះថ្នាក់ សេចក្ដីផ្ដើមប្រហែលជាគួរផ្ដោតទៅលើសំណួរ Who វិញ ៖

*លោក កកក ដែលជារដ្ឋមន្ត្រីហិរញ្ញវត្ថុ បានទទួលមរណភាពក្នុងគ្រោះថ្នាក់រថយន្តនៅក្រុងហូជីមិញកាលពីម្សិលមិញ។*

បើទីតាំងគ្រោះថ្នាក់នោះវាអធម្មតា ហើយមិនមានមនុស្សស្លាប់ទេនោះ អ្នកប្រហែលជាគួរផ្ដោតសេចក្ដីផ្ដើមទៅលើសំណួរ Where វិញ៖

*រថយន្តមួយគ្រឿងបានរេទៅបុកទីអារាមដ៏ល្បីល្បាញមួយនៅទីក្រុងហូជីមិញ និងបណ្ដាលឲ្យមនុស្សប្អូននាក់រងរបួសកាលពីម្សិលមិញ ដោយសារតែអ្នកបើកបរបាត់ម្ចាស់ការ។*

អ្នកត្រូវតែគិតមើលថា ផ្នែកណាមួយនៃព្រឹត្តិការណ៍ដែលសំខាន់ជាងគេ។

# ជ្រើសរើស "មុំ"

ជួនកាល គ្មានរបៀបណាមួយដែលត្រូវតែម្ដងនោះទេសម្រាប់សរសេររឿង។ ពេលខ្លះ រឿងមួយអាចមានចំណុច ឬ "មុំ" គួរឲ្យចាប់អារម្មណ៍ច្រើនខុសគ្នា។

*សេចក្តីផ្តើម*



*រាយជាបញ្ជីនូវចំណុចទាំងឡាយ ដែលអ្នកចង់សរសេរតាមលំដាប់លំដោយនៃសារៈសំខាន់របស់វា*

ទស្សនៈទានរបស់វេជ្ជបណ្ឌិត និងបុគ្គលិកអង្គការជំនួយមនុស្សធម៌ ដែលព្យាយាមគ្រប់គ្រងជំងឺ។ ឬមួយអ្នកអាចសរសេរពីជ្រុងទស្សនៈទានអ្នកវិទ្យាសាស្ត្រ ដែលកំពុងសិក្សាស្រាវជ្រាវអំពីការផ្ទុះជំងឺ ដើម្បីរកឱសថប្រឆាំងនឹងជំងឺគ្រុនចាញ់ឲ្យមានប្រសិទ្ធភាព

ឧទាហរណ៍ អ្នកទើបតែនឹងត្រឡប់មកពីយកព័ត៌មានសន្និសីទសារព័ត៌មានមួយ ដែលធ្វើដោយរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ។ បើសិនជាគាត់បានធ្វើសេចក្តីប្រកាសគោលនយោបាយអ្វីមួយសំខាន់ពិតណាស់ សេចក្តីផ្តើមរបស់អ្នកគួរផ្តើមជាមួយនឹងសេចក្តីប្រកាសនោះ។ ប៉ុន្តែលើកនេះ គាត់មិនបាននិយាយអ្វី ដែលមានសារៈសំខាន់ដុំកំភួននោះទេ។ អ្នកអាចផ្តើមរឿងជាមួយនឹងសុទិដ្ឋិនិយមរបស់គាត់អំពីកំណើនផលិតផលសរុបក្នុងស្រុកសម្រាប់ឆ្នាំក្រោយ។ ឬមួយអ្នកអាចផ្តើមជាមួយអត្ថាធិប្បាយរបស់គាត់អំពីការគ្រប់គ្រងអតិផរណា អំពីទំនាក់-ទំនងពាណិជ្ជកម្មជាមួយចិន។ មុំណាមួយក្នុងចំណោមមុំទាំងនេះ អាចយកមកធ្វើជារឿងមួយល្អបាន។

បើសិនជាអ្នកសរសេរអំពីការផ្ទុះជំងឺគ្រុនចាញ់នៅតាមព្រំដែនថៃ និងភូមា អ្នកអាចសរសេរវាពីទស្សនៈទានរបស់មនុស្សទាំងឡាយ ដែលទទួលរងនូវជំងឺគ្រុនចាញ់ ឬមួយក៏អាចសរសេរពីជ្រុងជាងមុន។

ពេលដែលអ្នកកំពុងព្យាយាមសម្រេច តើមុំមួយណាយកមកធ្វើសេចក្តីផ្តើមសំណួរមួយ ដែលអ្នកគួរសួរខ្លួនឯង គឺ ៖ តើអ្នកណាទៅជាអ្នកអានកាសែតរបស់ខ្ញុំ? តើពួកគេគ្រាន់តែជាអ្នកអានទូទៅធម្មតា? ជាអ្នកអានមានការអប់រំខ្ពស់? ជាអ្នកជំនាញ? ជនបរទេស? ចូររើសមុំណាដែលគួរឲ្យចាប់អារម្មណ៍ជាងគេ ហើយដែលធ្វើឲ្យអ្នកអានរបស់អ្នកចង់អាន។

## គម្រុយសម្រាប់ការរកសេចក្តីផ្តើម

ក្នុងការរកសេចក្តីផ្តើម ចូរសួរខ្លួនឯងថា ៖

- តើអ្នកណាធ្វើអ្វីទៅលើអ្នកណា?
- តើរឿងហ្នឹងនិយាយអំពីអ្វីពិតប្រាកដទៅ?
- តើមានប្រយោជន៍អ្វីក្នុងការសរសេរអំពីរឿងនេះ?

# ជំពូកទី ៩
# ការរៀបរៀងសាច់រឿង

បន្ទាប់ពីអ្នកជ្រើសបានសេចក្ដីផ្ដើមហើយ អ្នកនឹងអាចតម្រែតម្រង់ទ្រង់ទ្រាយដងខ្លួននៃរឿងបាន។ នេះបានន័យថា អ្នកបានប្រាប់អ្នកអានអំពីចំណុចគោល ឬមុំគោលនៃរឿងរួចហើយ បន្ទាប់ពីនេះជាពេលត្រូវពន្យល់អំពីសាច់រឿងដល់អ្នកអាន។ ដងខ្លួននៃសាច់រឿង ត្រូវតែទ្រទ្រង់ដល់សេចក្ដីផ្ដើម។ ដោយវិធីណា? គឺតាមរយៈសេចក្ដីពិស្ដារ, សម្រង់សម្ដីដើម និងសារតារនៃរឿង។

តើអ្នកត្រូវរៀបចំសាច់រឿងតាមលំដាប់លំដោយបែបណា? រឿងល្អ គឺជារឿងដែលបង្ហាញព័ត៌មាន

- តើអ្វីទៅជាចំណុចដ៏គួរចាប់អារម្មណ៍ជាងគេក្នុងព្រឹត្តិការណ៍នេះ?
- តើស្អី ដែលអ្នកអានចង់ដឹងជាងគេអំពីព្រឹត្តិការណ៍នេះ?
- តើស្អីក្នុងព្រឹត្តិការណ៍នេះដែលនឹងមានផលប៉ះពាល់ទៅលើមនុស្សខ្លាំងជាងគេនោះ?
- បើសិនជាអ្នកយកព័ត៌មានអំពីសុន្ទរកថាមួយ ចូរសួរខ្លួនឯងថា : អ្នកណានិយាយអ្វីទៅកាន់អ្នកណា?
- បើសិនជាអ្នកយកព័ត៌មានអំពីកិច្ចប្រជុំ ចូរសួរខ្លួនឯងថា : តើគេបានចាត់វិធានការអ្វីខ្លះ?



*សំណោរដែលបានលើកឡើងក្នុងឃ្លាមួយ គួរតែត្រូវបានឆ្លើយនៅក្នុងឃ្លាបន្ទាប់*

ក្នុងរបៀបមួយដែលទំនងមិនផ្គង។ អ្វីដែលអ្នកសរសេរដាក់ក្នុងវាក្យខ័ណ្ឌមួយ ពិតជាបណ្ដាលឲ្យមាននូវសំណួរពីសំណាក់អ្នកអានត្រឡប់មកវិញជាមិនខាន។ អ្នកគួរឆ្លើយនឹងសំណួរនោះឲ្យបាននៅក្នុងវាក្យខ័ណ្ឌបន្ទាប់មកទៀត។ ហើយចម្លើយនោះនឹងក្លាយជាតម្រុយថា តើអ្នកគួសរសេរអ្វីបន្ទាប់មកទៀត។

## ផ្គុំកំណត់ហេតុ និងគំនិតរបស់អ្នកចូលគ្នា

មុននឹងអ្នកចាប់ផ្ដើមសរសេរ ចូរសញ្ជឹងគិតអំពីមូលបទ ឬមុំនៃសាច់រឿងសិន ហើយបន្ទាប់មកទៀត ចូរគិតមើលអំពីចំណុចគោលសំខាន់ៗ ដែលអ្នកចង់បង្ហាញអំពីមូលបទ ឬមុំនៃសាច់រឿងនោះ។

ចូររៀបរៀងវាទៅតាមលំដាប់លំដោយសារៈសំខាន់។ ចូរសាកល្បងជាដំបូង ដោយមិនបាច់មើលកំណត់ហេតុរបស់ខ្លួន។ អ្នកប្រហែលជាអាចចងចាំបាននូវចំណុចសំខាន់ៗជាច្រើន។ បន្ទាប់មកទៀត ចូរក្រឡេកមើលកំណត់ហេតុ ឬឯកសារនានា ឬក៏ខ្សែអាត់ថតបទសម្ភាសន៍ ដើម្បីមើលថាតើមានអ្វីខ្លះដែលអ្នកអាចភ្លេច។ ចូររកមើលសេចក្ដីពិស្ដារ និងសម្រង់សម្ដីដែលត្រូវការយកមកប្រើ ដើម្បីទ្រទ្រង់ទៅដល់ចំណុចសំខាន់ក្នុងសាច់រឿងនោះ។

អ្នកមិនចាំបាច់ថា ត្រូវតែបញ្ចូលសេចក្ដីពិស្ដារទាំងអស់នោះទេ។ ស្នេរដែលចំណានជ្រើសរើសយកតែសេចក្ដីពិស្ដារណាដែលល្អជាងគេតែប៉ុណ្ណោះ។ ការដែលយើងដឹងថា តើអ្វីខ្លះដែលត្រូវទុកចោល វាមានសារៈសំខាន់ស្មើគ្នាដែរនឹងការដឹងថាតើអ្វីខ្លះដែលត្រូវយកមកបញ្ចូលក្នុងសាច់រឿង។




*អ្នកអតិរក្សហៅក្រុងឈៀងម៉ៃថាជាក្រុងបាងកកថ្មីមួយទៀត*




## រឿងស្តីអំពីដំណឹងទាន់ហេតុការណ៍

ប្រទេសនីមួយៗមានរឿងជាប្រពៃណីរបស់ខ្លួនអំពីថា តើប្រទេសនោះកកើតឡើង ដោយរបៀបណា អំពីវរជន ឬក៏អំពីថាការអនុវត្តវប្បធម៌ជាប្រពៃណីផ្តើមកំណើតមកដោយរបៀបណា។ ពេលដែលយើងនិទានប្រាប់អំពីរឿងបែបហ្នឹង គឺយើងផ្តើមពីចំណុចដើមដំបូងបង្អស់ ហើយបញ្ចប់ជាមួយនឹងលទ្ធផល ឬព្រឹត្តិការណ៍ចុងក្រោយបង្អស់។ ប្រលោមលោកភាគច្រើនក៏សរសេរតាមលំនាំនេះដែរ។

ប៉ុន្តែ រឿងស្តីអំពីដំណឹងទាន់ហេតុការណ៍ សរសេរតាមលំនាំផ្ទុយពីនេះទៅវិញ។ អ្នកអានកាសែតចង់ដឹងភ្លាមៗ អំពីអ្វីដែលទើបតែនឹងកើតឡើង។ គ្រោងនៃរឿងមានឈ្មោះថា "ពីរ៉ាមីដផ្ងារ" ឬមួយក៏ "ត្រីកោណផ្ងារ" ។

ពីរ៉ាមីដផ្ងារនោះ មានជើងកន្ធែកទៅលើ។ ចុះមកខាងក្រោម គ្រោងរបស់វាកាន់តែស្តួចទៅៗ រហូតមកប្រសព្វគ្នាត្រង់ចំណុចមួយនៅខាងចុង។ រូបភាពបែបនេះ មានន័យថា ជាតុផ្សំសំខាន់បំផុតរបស់សាច់រឿង ត្រូវនៅខាងលើគេបង្អស់។ ចុះមកខាងក្រោមបន្តិច គឺមានជាតុផ្សំសាច់រឿងដែលមានសារៈសំខាន់បន្ទាប់បន្សំ រហូតមកដល់ខាងចុងដែលជាកន្លែងសម្រាប់ជាតុផ្សំ ដែលមានសារៈសំខាន់តិចតួចមែនទែន។

ជាទូទៅ សេចក្តីផ្តើម គឺជាការផ្តល់ចម្លើយសំខាន់ជាងគេទៅនឹងសំណួរជាមូលដ្ឋានអំពីព្រឹត្តិការណ៍មួយ នោះគឺ 5Ws និង H ។ កថាខណ្ឌទីពីរ ជាកន្លែងដែលផ្តល់នូវសេចក្តីពិស្តារ ឬមួយក៏សាវតារព្រឹត្តិការណ៍ទាក់ទិននឹងសេចក្តីផ្តើម។ បន្ទាប់មកទៀត គឺការរៀបរៀងព័ត៌មានដែលទ្រទ្រង់ទៅដល់សេចក្តីផ្តើម ដូចជា សម្រង់សម្តីដើម សេចក្តីពិស្តារ និងសាវតារ ឬប្រវត្តិ នៅពីក្រោយព្រឹត្តិការណ៍នោះ។ ក្រោយពីអ្នកបានសរសេរព័ត៌មានអំពីមូលបទធំរួច ហើយ អ្នកឈានទៅសរសេរអំពីមូលបទ ដែលមានសារៈសំខាន់បន្ទាប់បន្សំ។ សម្រង់សម្តីដែលល្អៗដើរតួនាទីទាក់ទាញអារម្មណ៍អ្នកអាន ដូច្នេះ សូមដាក់វាទៅជិតក្បាលនៃរឿងរបស់អ្នក។

ហេតុអ្វីបានជាអ្នកសារព័ត៌មានប្រើទម្រង់ជាពីរ៉ាមីដផ្ការ ?

អ្នកអានមិនមានពេលគ្រប់គ្រាន់សម្រាប់អានរឿងនីមួយៗឲ្យចប់ទេ។ ជារឿយៗ ពួកគេអានតែប៉ុន្មានកថាខណ្ឌដំបូងតែប៉ុណ្ណោះ ដូច្នេះអ្នកត្រូវតែផ្តល់ឲ្យពួកគេនូវព័ត៌មាន ដែលសំខាន់បំផុតមុនគេ។ បើសិនជាគេចង់ដឹងព័ត៌មានពិស្តារថែមទៀត ឬមួយបើគេមានពេល ពួកគេអាចអានបន្តទៀតបាន។ ម៉្យាងវិញទៀត កាសែតក៏មិនសូវសំបូរប្រឡោះក្នុងទំព័ររបស់ខ្លួនសម្រាប់ចុះផ្សាយអត្ថបទដែរ។ ចូរនាំគ្នាក្រឡេកមើលឧទាហរណ៍ល្អៗមួយចំនួន។ រឿងមួយនេះ ដែលយើងបានពិភាក្សានៅក្នុងជំពូកទី៣ រួចមកហើយ បានផ្តល់ឲ្យយើងនូវព័ត៌មានយ៉ាងច្បាស់លាស់ មិនចាកប្រធាន ដោយមិនប្រើពាក្យពេចន៍ច្រើនឥតចាំបាច់នោះទេ។

*សេចក្តីផ្តើមជាការរៀបរាប់ច្បាស់លាស់ អំពីអ្វីដែលបានកើតឡើង និងផ្ទុកទៅដោយព័ត៌មានសំខាន់បំផុតមុនគេ ចុះវាថាបី ? តើព្រឹត្តិការណ៍នេះមានផលប៉ះពាល់បែបណាទៅលើមនុស្សនានា ហើយថាហេតុអ្វីពួកគេគួរខ្វល់ខ្វាយនឹងវា ?*

*សម្រង់សម្តីរបស់លោករដ្ឋមន្ត្រីនិយាយអំពីរោងចក្រ និងសេដ្ឋកិច្ចសហរដ្ឋអាមេរិក សាវតារ និងបរិបទ ស្តីអំពីថាតើឧស្សាហកម្មកាត់ដេរកម្ពុជា និងសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក មានទំនាក់ទំនងនឹងគ្នារបៀបម៉េច*

**កម្មកររោងចក្រកាត់ដេរនៅកម្ពុជា ត្រដរក្នុងការបិញ្ចឹមជីវិត**

*Phnom Penh, Cambodia (AP) - លោក ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និយាយថា ការធ្លាក់ចុះនៃសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក បានបង្ខំឲ្យរោងចក្រកាត់ដេរចំនួន ១២ បិទទ្វារជាបណ្តោះអាសន្នក្នុងឆ្នាំនេះ។*

*លោករដ្ឋមន្ត្រីនិយាយថា កម្មករកាត់ដេរប្រមាណ ៣.០០០ នាក់ត្រូវបានផ្អាកពីការងារជាបណ្តោះអាសន្ន ហើយថានឹងមានការងារច្រើនថែមទៀត ដែលនឹងអាចបាត់បង់ បើសិនជាស្ថានភាពមិនមានភាពប្រសើរឡើងវិញទេនោះ។*

*លោករដ្ឋមន្ត្រីបានបន្ថែមទៀតថា ទន្ទឹមនឹងនេះ កម្មកររាប់ពាន់នាក់ទៀត ត្រូវបានបង្ខំចិត្តធ្វើការតិចម៉ោងជាងមុន ដោយសារថារោងចក្រជាង ២០០ បានកាត់បន្ថយម៉ោងថែម និងវេនការងារពីពីរវេន មកមួយវេនវិញ។*

*លោករដ្ឋមន្ត្រីនិយាយថា "បញ្ហាសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកធ្វើឲ្យយើងមានកង្វល់ច្រើន អំពីប្រតិបត្តិការរបស់រោងចក្រ និងការងាររបស់កម្មករ"។*

*ឧស្សាហកម្មកាត់ដេរនៅកម្ពុជាមានកម្មករធ្វើការប្រមាណ ២០០.០០០ នាក់ ដែលម្នាក់ៗរកចំណូលបានជាមធ្យមតែ ៤០ ដុល្លារអាមេរិក តែប៉ុណ្ណោះក្នុងមួយខែ។ ជាង ៨០ ភាគរយ នៃផលិតផលរបស់ឧស្សាហកម្មនេះ ត្រូវបានគេដឹកទៅលក់នៅសហរដ្ឋអាមេរិក។*

*លោករដ្ឋមន្ត្រីនិយាយថា ជាងពាក់កណ្តាលឆ្នាំបានកន្លងផុតទៅហើយ ប៉ុន្តែកូតាប្រចាំឆ្នាំសម្រាប់ការនាំចេញផលិតផលកាត់ដេរទៅសហរដ្ឋអាមេរិក បំពេញមិនបាន ៤០ ភាគរយផង។ គាត់បានបន្ថែមទៀតថា កូតាក្នុងការនាំចេញផលិតផលកាត់ដេរទៅសហរដ្ឋអាមេរិកនេះ សឹងត្រូវបានបំពេញរួចបាត់ទៅហើយ ត្រឹមខែមិថុនា ឆ្នាំកន្លងទៅនេះ។*

ខាងក្រោមជារឿងពីកាសែត The Cambodia Daily ដែលសរសេរ ដោយលោក កែ គឹមសុង ដែលជាអតីតសិស្សរបស់ *IMMF* ដែរ។

**អ្នកបើកតាក់ស៊ីខឹងសម្បាតាំគ្នាខ្ទប់ចរាចរផ្លូវជាតិលេខ 6A**

*សេចក្ដីផ្ដើមរៀបរាប់យ៉ាងច្បាស់ថាអ្វីដែលធ្វើឲ្យស្ទះចរាចរ*

*អ្នកបើកតាក់ស៊ីប្រហែល ២០ នាក់ ដែលខឹងសម្បានឹងវិធានការថ្មីរបស់សាលាក្រុង ដែលហាមប្រាមតាក់ស៊ីមិនឲ្យចូលក្រុងនាំគ្នាខ្ទប់ផ្លូវជាតិលេខ 6A ធ្វើឲ្យចរាចរស្ទះអស់ពេលមួយម៉ោង កាលពីថ្ងៃអង្គារ៍នេះ។*

*សេចក្ដីពិស្ដារទៅលើសេចក្ដីផ្ដើម ដែលមានលក្ខណៈសាមញ្ញ ហើយច្បាស់*

*រថយន្តពន្លត់អគ្គីភ័យប្រាំមួយគ្រឿងត្រូវបានគេបញ្ជូនទៅកាន់ទីនោះ ដើម្បីបំបែកក្រុមអ្នកបើកតាក់ស៊ី ដែលពេលនោះ កំពុងប្រកែកគ្នាជាមួយនគរបាល និងអាជ្ញាធរ ដែលព្យាយាមហាមពួកគេមិនឲ្យបើកឡានចូលក្នុងក្រុង។*

*នៅក្នុងឧទាហរណ៍មុននេះ សារគៅត្រូវបានគេយកទៅដាក់នៅខាងចុងរឿង។ តែក្នុងរឿងមួយនេះ សារគៅត្រូវតែយកមកដាក់នៅខាងលើ បើមិនដូច្នោះទេ អ្នកអាននឹងមិនយល់សាច់រឿងឡើយ បើគេមិនប្រាប់ថាតើវិវាទនោះកើតអំពីរឿងអ្វី*

*ថ្ងៃអង្គារ៍ គឺជាថ្ងៃដែលចាប់ផ្ដើមការហាមប្រាមរបស់សាលាក្រុង មិនឲ្យតាក់ស៊ីមកពីបណ្ដាខេត្តភាគខាងជើងចូលក្នុងទីក្រុងទេ។ មន្ត្រីបាននិយាយថា ការហាមប្រាមនេះ ត្រូវបានធ្វើឡើង ដើម្បីសម្រាលនូវការកកស្ទះចរាចរ និងរក្សាសោភ័ណភាពរបស់ទីក្រុង។*

*រថយន្តតាក់ស៊ីទាំងអស់ ត្រូវបានតម្រូវឲ្យឈប់សំចតនៅផ្សារព្រែកលាប ដែលស្ថិតនៅចម្ងាយប្រមាណ ៥ គីឡូម៉ែត ពីក្រុង ហើយផ្ទេរអ្នកដំណើររបស់ខ្លួនមករថយន្តប៊ីស ដែលនឹងដឹកជញ្ជូនពួកគេមកកាន់ភ្នំពេញ។*

*ប្រតិកម្មពីសំណាក់ក្រុមអ្នកបើកតាក់ស៊ី រួមជាមួយនឹងសម្រង់សម្ដីពីអ្នកបើកតាក់ស៊ីម្នាក់ផង ប្រតិកម្មពីសំណាក់ក្រុមហ៊ុន រួមជាមួយនឹងសម្រង់សម្ដីពីតំណាងម្នាក់របស់គេផង*

*អ្នកបើកតាក់ស៊ីនិយាយថា វាមិនត្រឹមត្រូវយុត្តិធម៌ទេ ប្រសិនបើក្រុមហ៊ុន Ho Wah Genting Transport Co. មកពីប្រទេសម៉ាឡេស៊ី មានអាជ្ញាប័ណ្ណដឹកអ្នកដំណើរពីភ្នំពេញទៅព្រែកលាប និងពីព្រែកលាបទៅកាន់បណ្ដាខេត្តផងនោះ។*

*លោក ហួន ហាក់ ដែលបើកតាក់ស៊ីដឹកអ្នកដំណើរទៅមកខេត្តកំពង់ចាម និយាយថា "ប្រសិនបើក្រុមហ៊ុន Ho Wah បានការអនុញ្ញាតធ្វើអញ្ចឹង ពួកយើងដែលជាអ្នកបើកបរតាក់ស៊ី នឹងរកលុយលែងបានហើយ ពីព្រោះអ្នកដំណើរនឹងចុះពីប៊ីសមួយទៅឡើងជិះប៊ីសមួយទៀត"។*

*មតិរបស់ភាគីម្នាក់ទៀត ដែលពាក់ព័ន្ធក្នុងរឿងនេះ រួមជាមួយនឹងសម្រង់សម្ដីមួយផង។ ការប្រើសម្រង់សម្ដីទាំងបីនេះ ធ្វើឲ្យរឿងរស់រវើក និងជួយឲ្យអ្នកអានយល់បាននូវឥរិយាបថ និងមនោរម្មណ៍ ដែលពាក់ព័ន្ធក្នុងវិវាទនេះ។*

*លោក ស៊ិន ភារម្យ ជំនួយការនាយកគ្រប់គ្រងក្រុមហ៊ុន Ho Wah និយាយថា អ្នកបើកតាក់ស៊ីមិនគួរលូកលាន់ក្នុងរឿងក្នុងកិច្ចការរបស់ក្រុមហ៊ុនទេ ពីព្រោះក្រុមហ៊ុនបានទទួលការអនុញ្ញាតរួចហើយពីសំណាក់ក្រសួងសាធារណៈការ និងពីសំណាក់សាលាក្រុង ឲ្យធ្វើប្រតិបត្តិការរថយន្តប៊ីស។*

*គាត់និយាយថា ក្រុមហ៊ុនរបស់គាត់បានជួយទៅដល់អ្នកបើកតាក់ស៊ីរួចហើយ តាមរយៈការកាត់បន្ថយចំនួនដឹកជញ្ជូនរបស់ខ្លួនពីព្រែកលាបទៅកាន់បណ្ដាខេត្តពីចំនួន ១២ ជើង មកត្រឹម ៧ ជើង ក្នុងមួយថ្ងៃ។*

*លោក ស៊ិន ភារម្យ និយាយថា "បើយើងមិនអាចវិនិយោគនៅទីនេះបាន យើងនឹងចាកចេញពីទីនេះ ហើយយើងនឹងប្រាប់មិត្តភក្តិយើងកុំឲ្យមក"។*

*លោក ញ៉ែម សារ៉ន ប្រធាននាយកដ្ឋានសាធារណៈការក្រុង និយាយថា អ្នកបើកបរតាក់ស៊ី គួរណាប្រឹងយកចិត្តទុកដាក់ក្នុងការបង្កើនគុណភាពសេវាកម្មរបស់ខ្លួនវិញ ជាជាងប្រឹងបន្ទោសក្រុមហ៊ុន Ho Wah ។*

*គាត់និយាយថា "ខ្ញុំគិតថាមនុស្សម្នាគេនឹងជ្រើសរើសយករថយន្តក្រុមហ៊ុន Ho Wah វិញហើយ ដោយសារថាវាមានសុវត្ថិភាព មានម៉ាស៊ីនត្រជាក់ និងមានផាសុកភាពផង"។*



*អាស៊ីកំពុងអភិវឌ្ឍន៍ទំនើប*

## ពេលដែលមានប្រធានបទច្រើនជាងមួយ

រឿងភាគច្រើនមានប្រធានបទតែមួយទេ។ ប៉ុន្តែពេលខ្លះ ក៏មានចំណុចគោលពីរ ឬបីដែលមានសារៈសំខាន់ស្មើគ្នាដែរអំពីព្រឹត្តិការណ៍មួយ។

ឧទាហរណ៍ សភាធ្វើការអនុម័តច្បាប់ពីរ មួយស្ដីពីការបង្កើនពន្ធលើប្រាក់ចំណូល និងមួយទៀត សំដៅដាក់ក្រោមភាពខុសច្បាប់នូវពលកម្មដែលប្រើប្រាស់កុមារ។ ទាំងពីរនេះមានសារៈសំខាន់ដូចគ្នា។ បើសិនជាអ្នកត្រូវដាក់ធាតុទាំងពីរនេះ នៅក្នុងសេចក្ដីផ្ដើមពាក់កណ្ដាលដំបូងនៃសាច់រឿងត្រូវតែផ្ដោតទៅលើរឿងពន្ធ ហើយពាក់កណ្ដាលទៀតត្រូវផ្ដោតទៅលើការកំហិតអាយុធ្វើការ។

ឧទាហរណ៍សេចក្ដីផ្ដើម ៖

*រដ្ឋសភា ថ្ងៃនេះ បានអនុម័តច្បាប់ពីរដែល និងបង្កើនពន្ធលើប្រាក់ចំណូល និងហាមប្រាមលើពលកម្មកុមារ។*



*ពេលណាដែលអាចធ្វើទៅបាន ចូរព្យាយាមងាកចេញពីការពោកពកូនយកព័ត៌មាន*

ប៉ុន្តែនៅក្នុងតួខ្លួននៃរឿង អ្នកត្រូវតែរក្សាជាតុផ្សំដែលមានទំនាក់ទំនងជាមួយគ្នាឲ្យនៅក្បែរគ្នា។ ចូរបង្ហាញសេចក្ដីពិស្ដារអំពីការយកពន្ធមុន បន្ទាប់មកចូរបង្ហាញសេចក្ដីលម្អិតអំពីច្បាប់ហាមប្រាមពលកម្មកុមារ។ បើសិនជារឿងរបស់អ្នកលោតត្រឡប់ត្រឡិនរវាងជាតុផ្សំតាំងពីរនេះ អ្នកអានពិតជានឹងវង្វេងជាមិនខាន។

## អត្ថបទពិពណ៌នា

អត្ថបទដំណឹងភាគច្រើនត្រូវបានសរសេរតាមស្ទីលពីរ៉ាមីដផ្ការ ប៉ុន្តែមានវិធីច្រើនណាស់សម្រាប់សរសេរអត្ថបទពិពណ៌នា។ ក្រាហ្វិកខាងក្រោមបង្ហាញនូវវិធីជាទូទៅមួយបែបនោះ។

អត្ថបទពិពណ៌នា ភាគច្រើនប្រើសេចក្ដីផ្ដើមដំអក់។ តាមវិធីនេះ ស្ទើរច្រើនតែចាប់ផ្ដើមដោយផ្ដោតទៅលើមនុស្សម្នាក់ ដែលកំពុងជួបបញ្ហាដែលមនុស្សដទៃទៀតកំពុងជួបប្រទះផងដែរ។ ធ្វើដូច្នេះក៏ដោយសារថា អ្នកអានអាចយល់បាននូវស្ថានភាព និងបទពិសោធន៍របស់មនុស្សជាក់លាក់ម្នាក់បានច្បាស់ជាងការថ្លែងប្រាប់អំពីស្ថានភាពទូទៅមួយ។ មនុស្សម្នាក់នោះ ត្រូវបានប្រើជាឧទាហរណ៍ ឬការបង្ហាញអំពីស្ថានភាពទូទៅមួយ។ របៀបជាទូទៅមួយទៀត ក្នុងការផ្ដើមអត្ថបទពិពណ៌នា គឺការរៀបរាបឆាកទស្សនីយភាពនៃរឿង ដូចជាការរៀបរាប់រស់រវើកអំពីទីកន្លែងមួយជាដើម។

នៅបន្ទាប់ពីសេចក្ដីផ្ដើមដំអក់ គឺកថាខណ្ឌ ឬឃ្លាមូលបទ ឬដែលគេហៅម៉្យាងទៀតថាជាកថាខណ្ឌ ឬឃ្លាស្នូល ដែលប្រាប់អ្នកអានឲ្យដឹងថាតើរឿងហ្នឹងនិយាយអំពីអ្វី។ កថាខណ្ឌនេះដើរតួនាទីតភ្ជាប់ពីការរៀបរាប់ក្នុងសេចក្ដីផ្ដើម ជាមួយនឹងដងខ្លួនរបស់សាច់រឿង។ តាមធម្មតា គេដាក់វានៅបន្ទាប់ពីកថាខណ្ឌទីពីរ ឬទីបីខាងលើ។

ផ្នែកដែលនៅសេសសល់របស់រឿងនឹងធ្វើការពន្យល់ទៅដល់សេចក្ដីផ្ដើម និងទ្រទ្រង់វា ដោយប្រើសេចក្ដីពិស្ដារ សម្រង់សម្ដីដើម និងឧទាហរណ៍

ផ្សេងៗទៀត។ ជារឿយៗ បន្ទាប់ពីកថាខណ្ឌស្នូល ស្មេរប្រើនវិលមកសរសេររៀបរាប់អំពីសេចក្ដីលម្អិតថែមទៀតអំពីមនុស្ស ការបង្ហាញ ឬក៏អំពីទិដ្ឋភាពឲ្យបានល្អិតល្អន់ជាងមុន។ អត្ថបទពិពណ៌នាប្រើនតែមាននូវការរៀបរាប់ និងសម្រង់សម្ដីដើមល្អៗ ដែលជួយ "ដាក់ពណ៌" ឲ្យរឿងនោះ។ វាប្រើនតែបញ្ចប់ជាមួយនឹងការបន្សល់ទុកឲ្យអ្នកអាននូវចំណាប់អារម្មណ៍ដក់ជាប់ក្នុងគំនិតអំពីមូលបទរបស់រឿង។

ដូច្នេះ បទពិពណ៌នាមានសេចក្ដីផ្ដើមតួសេចក្ដី និងសេចក្ដីបញ្ចប់ ដែលមានការតាក់តែងប្រកបដោយប្រុងប្រយ័ត្ន ដូចគ្នានឹងកូនរឿងប្រលោមលោកមួយដែរ។

ចូរក្រឡេកមើលឧទាហរណ៍ខាងក្រោម ដែលជារឿងមួយដែលពោរពេញទៅដោយពណ៌លម្អ សម្រង់សម្ដីដើមល្អៗ សេចក្ដីលម្អិតពោរពេញដោយអត្ថន័យ និងសារៈសំខាន់អំពីអ្វី ដែលកំពុងកើតឡើង។ ក្នុងអត្ថបទនេះ ស្មេរបានផ្ដុំចូលគ្នាយ៉ាងប៉ិនប្រសប់នូវការសង្កេតផ្ទាល់ខ្លួន ការស្រាវជ្រាវឯកសារ និងបទសម្ភាសន៍។ នៅក្នុងជំពូកមុននេះ យើងបានឃើញរួចម្ដងហើយ នូវសេចក្ដីផ្ដើមនៃរឿងដែលជាឧទាហរណ៍ល្អមួយ ស្ដីអំពីការសង្កេត និងអំពីរបៀបបង្ហាញឆាកសាច់រឿង។

***ការអភិវឌ្ឍឆាប់រហ័សគំរាមប្រែក្លាយក្រុងបុរាណទៅជាក្រុងបាងកកមួយទៀត***

*ចាប់ផ្ដើមឡើង អ្នកនិពន្ធនាំអ្នកអានទៅដល់ទីកន្លែងសាច់រឿងតែម្ដង តាមរយៈការរៀបរាប់ពិពណ៌នាដោយប្រើញាណទាំងអស់ដែលមាន។ គេទាក់ទាញអ្នកអានឲ្យជក់ចិត្តនឹងសាច់រឿង។*

*Chiang Mai, Thailand - នៅតាមខ្លោងទ្វារធំៗទាំងប្រាំរបស់ចូលទៅកាន់ទីក្រុងបុរាណ ឈៀងម៉ៃ មនុស្សម្នាបានមកជួបជុំគ្នាកាលពីពេលថ្មីៗនេះ ដើម្បីប្រារព្ធពិធីបុណ្យបុរាណមួយឈ្មោះថាបុណ្យកឋិនទាន។ ព្រះសង្ឃជាប្រើនអង្គ ស្ថិតក្នុងស្បង់ពណ៌លឿងសូត្រមន្តពរជ័យនៅពេលដែលមនុស្សម្នា ជាមួយផ្កា ធូប និងទៀនក្នុងដៃនាំគ្នាបន់ស្រន់សុំទឹកភ្លៀង និងឲ្យទទួលបានផលល្អក្នុងការដាំដុះ។*

*ប៉ុន្តែស្នូរស៊ីផ្លេ និងភាពកងរំពងនៃការស្ទះចរាចរនៅក្បែរប្រេកចូលនោះ បានលុបបាត់នូវសម្លេងសូត្រមន្តឲ្យពរជ័យ ហើយផ្សែងរថយន្ត និងទោចក្រយានយន្ត ក៏គ្របដណ្ដប់ទៅលើក្លិនក្រអូបរបស់ធូបនៅទីនោះដែរ។*

*វាក្យខ័ណ្ឌទាំងនេះបន្តការរ៉ាយរ៉ាប់នៅក្នុងសេចក្ដីផ្ដើម ហើយពន្យល់មូលបទសាច់រឿង។ ចូរកត់សម្គាល់មើលអំពីការប្រើភាព*

*ក្នុងឆ្នាំនេះ ក្រុងឈៀងម៉ៃ ដែលជាអតីតរដ្ឋធានីរបស់រាជាណាចក្រឡាណាថៃ ប្រារព្ធខួបលើកទី ៧០២ របស់ខ្លួន។ បន្ទាប់ពីក្រុងបាងកកដែលមានអាយុក្មេងជាងប្រាំឆ្នាំ ឈៀងម៉ៃ ជាក្រុងទីពីររបស់ថៃ ដែលជាទីពេញនិយមដល់អ្នកទេសចរបរទេស។ ទីនេះនៅមានវត្ថុបុរាណជាទីចាប់អារម្មណ៍ជាប្រើន ដូចជា ទីវត្តអារាម វត្ថុសិប្បកម្ម។*

*បញ្ច្រាសគ្នាដាក់លាក់រវាងអតីតកាល និងបច្ចុប្បន្នកាល ដើម្បីបង្ហាញអំពីមូលបទក្នុងរឿង។*

*ភូមិជនជាតិដើមភាគតិច ព្រៃ និងទឹកជ្រោះ។ អ្វីដែលនៅអកិរក្សនៅឡើយនោះ គឺស្រះទឹក ដែលជាផ្នែកមួយនៃមហាកំពែងការពារដែលកំណត់ព្រំដែនរបស់ទីក្រុង។ ត្រូវបានព័ទ្ធជុំវិញដោយព្រៃប្រឹក្សា និងទន្លេពណ៌ផ្កាឈូកឈៀងម៉ៃ ត្រូវបានគេប្រសិទ្ធនាមឲ្យថាជាក្រុងកុលាបប៉ែកឦសាន។*

*ប៉ុន្តែក្រុមអភិរក្សបានឲ្យឈ្មោះវាថាជាក្រុងបាងកកមួយទៀត ដោយសារថាការអភិវឌ្ឍរហ័ស បាននាំមកនូវការស្ទះចរាចរ ការបំពុលបរិយាកាស អគារខុនដូខ្ពស់ៗ ហាងទំនិញធំៗ ហើយទាំងអស់នេះបានគំរាមដល់ប្រពៃណីទំនៀមទម្លាប់បុរាណរបស់ក្រុងនេះ។ រូបគំនូរមួយដែលតាំងនៅ Contemporary Art Museum មានចំណងជើងថា ឈៀងម៉ៃ ឆ្នាំ១៩៩៧ បង្ហាញរថយន្តកំពុងបាញ់ផ្សែងហុយទ្រលោម និងអគារខ្ពស់ៗ បង្ក្រាបទៅលើហ្វូងដំរីដែលកំពុងហូរទឹកភ្នែករហាម។*

| | |
|---|---|
| សេចក្ដីផ្ដើម | ឧទាហរណ៍ជាក់លាក់អំពីនរណាម្នាក់ ⟷ ឬ ⟷ ការដំណាល ⟷ ឬ ⟷ ការរៀបរាប់ពិព័ណ៌នាអំពីព្រឹត្តិការណ៍ ឬកន្លែងមួយ |
| តួសេចក្ដី | វាក្យខណ្ឌមូលបទ៖ តើរឿងនេះនិយាយអំពីអ្វី? |
| | **បរិបទ៖** តើរឿងព្រឹត្តិការណ៍ឬស្ថានការណ៍នេះមានផលប៉ះពាល់ទៅលើមនុស្សដូចម្ដេចខ្លះ?មានមនុស្សប៉ុន្មាននាក់ដែលស្ថិតក្នុងស្ថានភាពប្រហាក់ប្រហែលគ្នានេះដែរ?<br>**សាវតារ៖** តើអ្វីជាបុព្វហេតុបណ្ដាលឲ្យមានព្រឹត្តិការណ៍នេះឡើង?តើវាវិវត្តន៍មកដល់ចំណុចបច្ចុប្បន្នដោយដូចម្ដេច?<br>**ការពន្យល់ផ្សេងទៀត៖** តើមានយោបល់ខុសគ្នាបែបណាខ្លះអំពីព្រឹត្តិការណ៍ដែលបានកើតឡើងមកនេះ? |
| | សេចក្ដីក្បោះក្បាយ សម្រង់សម្ដីដើម ដែលទាក់ទិននឹងឧទាហរណ៍ ការដំណាល ឬការរៀបរាប់ពិព័ណ៌នាក្នុងសេចក្ដីផ្ដើម និងព័ត៌មានបន្ថែមទៀតអំពីរឿង |
| សេចក្ដីបញ្ចប់ | សម្រង់សម្ដីដែលខ្លាំង ការដំណាល ឬការថ្លែងណាមួយដែលមានទំនាក់ទំនងទៅនឹងសេចក្ដីផ្ដើម |

*នេះជាវក្យខ័ណ្ឌបរិបទ និងសាវតារ។ វាបានពន្យល់ថា តើក្រុងឈៀងម៉ៃ បានវិវត្តន៍មកដល់ស្ថានភាពបច្ចុប្បន្ន ដោយរបៀបណា ហើយថា តើវានឹងទៅជាយ៉ាងម៉េចទៀតទៅថ្ងៃមុខ។*

ក្រុងឈៀងម៉ៃ មានការរីកចម្រើនលូតលាស់ ដោយសារមួយផ្នែកកសិធុរកិច្ចរបស់ជប៉ុន និងវត្តមានរោងចក្រជាច្រើនទៀត នៅប៉ែកខាងត្បូងទីក្រុង។ ប៉ុន្តែ មួយផ្នែកនៃការពង្រីកទីក្រុងនេះ កើតមានក៏ដោយសារតែការហូរចូលរបស់អ្នកមានស្តុកស្តម្ភជាច្រើន ដែលបាននាំគ្នាគេចឲ្យផុតពីការលំបាកក្នុងការរស់នៅក្នុងទីក្រុងបាងកកដែរ។ ដូចគ្នានឹងទីក្រុងបាងកកដែរ នៅតាមជាយក្រុងឈៀងម៉ៃ ដីវាលស្រែត្រូវបានប្រែក្លាយទៅជាតំបន់អចលនទ្រព្យគេហដ្ឋានធំល្វឹងល្វើយ តែមិនសូវមានមនុស្សរស់នៅក្នុងសំណង់ទាំងនោះទេ ដោយសារថាវាថ្លៃពេក។

ការធ្លាក់ចុះសេដ្ឋកិច្ចរបស់ថៃនាពេលនេះ បានបន្ទុចបង្អាក់ដល់គម្រោងធំៗមួយចំនួន ប៉ុន្តែគេមិនគួរមន្ទិលសង្ស័យទេថា តើក្រុងឈៀងម៉ៃ នឹងបន្តដំណើរទៅតាមទិសដៅណា នៅពេលដែលសេដ្ឋកិច្ចងើបឡើងវិញនោះ។

*អ្នកនិពន្ធផ្តល់ឧទាហរណ៍ថែមទៀត អំពីបញ្ហាដែលក្រុងឈៀងម៉ៃ បានជួបប្រទះ ស្រដៀងគ្នាទៅនឹងឧទាហរណ៍ដែលបានបង្ហាញនៅវក្យខ័ណ្ឌពីរខាងលើដំបូងដែរ។ ចូរសម្គាល់មើលការប្រើការប្រៀបធៀប (វាលចតរថយន្តដែលមានទំហំធំល្វឹងល្វើយ ដូចតារាងទាត់បាល់) និងសេចក្តីលម្អិតជាក់លាក់ (ផ្លែធុរេន តុក្កតាបារប៊ី ម៉ាស៊ីនបោកគក់) ដើម្បីជួយឲ្យអ្នកអានអាចឆ្លុះបញ្ចាំងរូបភាពក្នុងអារម្មណ៍របស់គេបានផងក្នុងពេលអាន។*

"មហាហាង" របស់ក្រុងឈៀងម៉ៃ បានបើកទ្វារកាលពីបីឆ្នាំមុននេះ។ មិនយូរប៉ុន្មាន កាលពីខែធ្នូកន្លងទៅនេះ ហាងប្រភេទនេះចំនួនបីទៀតក៏បានបើកទ្វារដែរ។ សំណង់ដ៏ធំល្វឹងល្វើយនេះ ដែលប្រៀបបាននឹងឃ្លាំងផ្ទុកឥវ៉ាន់ អមដោយឡាចតរថយន្តទំហំប៉ុនទីលានទាត់បាល់ មានលក់របស់របរសព្វសារពើ តាំងពីផ្លែធុរេន រហូតដល់កូនក្រមុំតុក្កតាបារប៊ី និងម៉ាស៊ីនគក់ខោអាវ។ ជាកន្លែងដែលងាយស្រួលក្នុងការទិញឥវ៉ាន់សព្វសារពើក្នុងតម្លៃថោក ហាងប្រភេទនេះកំពុងគំរាមដល់ការរស់រានរបស់ហាងតូចៗជាលក្ខណៈគ្រួសារ ផ្សារសហគមន៍លក់ដូរទំនិញស្រស់ៗ ដែលមនុស្សម្នាធ្លាប់តែទៅទិញដូរជារៀងរាល់ថ្ងៃកន្លងមក។ ក្នុងការប្រយុទ្ធដណ្តើមទីផ្សាររបស់ពួកគេនៅឈៀងម៉ៃ មហាហាងឈ្មោះ Carrefour និង Auchan ដែលមានប្រភពដើមនៅប្រទេសបារាំង បានបើកទ្វារព្រមគ្នាក្នុងសប្តាហ៍តែមួយ។

*អ្នកនិពន្ធបានដាក់សម្រង់សម្ដីដើមមួយនៅក្នុងផ្នែកមួយខ្ពស់ក្នុងសាច់រឿង ដែលបង្ហាញអំពីគុណតម្លៃមួយថ្មីនៃរបបអ្នកប្រើប្រាស់កំពុងពេញនិយម។*

លោក Philippe Richard នាយកគ្រប់គ្រងរបស់ហាង Auchan ដែលមានបេឡាគិតលុយចំនួន ៥០ កន្លែង និងទីធ្លាតាំងទំនិញចំនួន ១០.០០០ យ៉ាដក្រឡា (ប្រហែល ១០.០០០ ម៉ែត្រក្រឡា) និយាយថា ៖ "គោលបំណងរបស់យើង គឺដាក់តាំងផលិតផលទាំងអស់នៅមួយកន្លែង ហើយទុកឲ្យអតិថិជនជ្រើសរើសតាមចិត្តរបស់គេ។ ជារៀងរាល់ថ្ងៃ មានមនុស្សកាន់តែច្រើនឡើងៗមកទីនេះ"។

ក្រុមហ៊ុនហាង Auchan នេះបានសង់ផ្លូវខាងក្រោមមួយនៅហាយវេក្បែរនេះ ដើម្បីឲ្យអតិថិជនអាចបើករថយន្តចូលមកពីច្រកណាក៏បានដែរ។ តែមហាហាងទាំងអស់នេះ បានធ្វើឲ្យស្ថានភាពចរាចរ និងផ្លូវក្នុងក្រុងឈៀងម៉ៃ កាន់តែយ៉ាប់យ៉ឺន និងគ្រោះថ្នាក់ឡើងៗ។ វាក៏បានបង្កើតផងដែរ នូវសម័យថ្មីមួយនៃប្រៃសណីយ៍កម្ទេចកម្ទី។ នោះ គឺមានខិតប័ណ្ណផ្សាយពាណិជ្ជកម្ម មានពណ៌រលោង តំណាងឲ្យការប្រលងប្រជែង និងលទ្ធិអ្នកប្រើប្រាស់ថ្មីក្នុងក្រុងឈៀងម៉ៃ មានវត្តមានពេញទីក្រុង ត្រូវបានគេដាក់គរលើតុ ញាត់ក្នុងប្រអប់ប្រៃសណីយ៍ ស៊កក្រោមទ្វារការិយាល័យ និងរបងផ្ទះ។

*ត្រង់នេះ គឺមានឧទាហរណ៍ថ្មីថែមទៀត ដើម្បីទ្រទ្រង់ដល់សេចក្ដីផ្ដើម និងមូលបទរបស់សាច់រឿង។ ម្ដងទៀត ចូរកត់សម្គាល់អំពីការប្រើសេចក្ដីពិស្ដារជាក់លាក់។*

បច្ចុប្បន្ននេះ អ្នកស្រាវជ្រាវកំពុងធ្វើតេស្តកម្រិតសំណក្នុងឈាមរបស់នគរបាលចរាចរនៅឈៀងម៉ៃ ដែលជាការធ្វើតេស្តដូចគ្នានៅបាងកក ដែលបានបង្ហាញលទ្ធផលគួរឲ្យញញើត។ ពួកគេក៏កំពុងតាមដានពិនិត្យមើលស្ថានភាពទន្លេ Ping River ដែរ ដែលត្រូវបានបំពុល ដោយសារការប្រើប្រាស់ថ្នាំគីមីសម្លាប់សត្វល្អិតរបស់ប្រជាកសិកររស់នៅប៉ែកខាងលើលំហូរទន្លេ។ ជាមួយនឹងការរីកលូតលាស់របស់ទីក្រុង សំរាមក៏កើនដែរ គឺកើនលើសហួសសមត្ថភាពរបស់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានសម្រាប់ធ្វើប្រព្រឹត្តកម្មសំរាមទាំងនោះទៅទៀត។

*ពីដើមមកដល់ត្រឹមនេះ អ្នកនិពន្ធបានរ៉ាយរ៉ាប់អំពីបញ្ហារបស់ក្រុងឈៀងម៉ៃច្រើនហើយ។ ឥឡូវគាត់ព្យាយាមផ្ដល់តុល្យភាពដល់រឿង តាមការបង្ហាញនូវទិដ្ឋភាពរួមផ្សេងៗទៀត។*

ទោះជាយ៉ាងណាក្តី គេមិនគួរបំផ្លើសបញ្ហាពេកទេ។ តាមការពិត អាជ្ញាធរបានហាមការសាងសង់សំណង់ខ្ពស់ៗក្បែរវត្តអារាម។ ស្រះទឹកដែលជាខ្សែក្រវាត់ព័ទ្ធជុំវិញទីក្រុងបុរាណនេះ ត្រូវបានគេសម្អាតយកសំរាមចេញ ហើយគេថែមទាំងបានបំពាក់នូវប្រព័ន្ធសម្អាតថ្មីឲ្យវាថែមទៀតផង។ បើនិយាយពីចំនួនប្រជាជនវិញ ក្រុងឈៀងម៉ៃ មានត្រឹមតែ ១ ភាគ ១៤ ប៉ុណ្ណោះ នៃចំនួនមនុស្សរស់នៅទីក្រុងបាងកក។

*ឃ្លាដ៏ខ្លីមួយនេះធ្វើជាស្ពានចម្លងរលូនមួយទៅកាន់អនុមូលបទមួយទៀត នោះគឺជាមិនមែនរចនាសម្ព័ន្ធរូបវន្តប៉ុណ្ណោះទេ ដែលផ្លាស់ប្តូរនៅក្រុងឈៀងម៉ៃ សូម្បីបែបផែនជីវភាពរស់នៅ ក៏ទទួលការផ្លាស់ប្តូរដែរ។*

*ការផ្លាស់ប្តូរក្នុងរបៀបរស់នៅត្រូវបានបង្ហាញទាំងក្នុងសាវតារ និងការសង្កេតរបស់អ្នកនិពន្ធ។*

*សម្រង់សម្តីបីឃ្លា ដែលមានន័យខ្លឹមសារខ្លាំងៗ ដែលតាមធម្មតាគេកម្រឮអ្នកបណ្ឌិតសភានិយាយណាស់។*

*អ្វីដែលគួរឲ្យខ្វល់ខ្វាយដល់មនុស្សភាគច្រើននោះ គឺការផ្លាស់ប្តូរយ៉ាងច្រើនក្នុងបែបផែនជីវភាពរស់នៅ។*

*ភាពអាបាយមុខ ដែលជារឿយៗស្រដៀងគ្នានឹងក្រុងបាងកកដែរនោះ រួមមាន ទង្វើពុករលួយមួយកាលពីឆ្នាំមុន ដែលក្នុងនោះ មន្ត្រីយោធា និងបុគ្គលិកសាលាក្រុង ព្យាយាមឈ្លេចយកលុយពីអ្នកលក់ដូរនៅផ្សាររាត្រី ដែលជាកន្លែងពេញនិយមរបស់ទេសចរ។ នៅឆ្នាំមុននោះដែរ នគរបាលម្នាក់ដោយខឹងសម្បា ក្រោយពីមិត្តស្រីរបស់គាត់បាកចេញពីរូបគាត់ទៅស្រឡាញ់បរទេសវិញនោះ បានបាញ់កាំភ្លើងធ្វើឲ្យរបួសទេសចរជនជាតិអ៊ីតាលីពីរនាក់ នៅឯព្រលានយន្តហោះឈៀងម៉ៃ។*

*មនុស្សម្នាកាន់តែច្រើនឡើង មោទនៈនឹងសម្លេងទូរស័ព្ទចល័តរបស់ពួកគេ ដែលជានិមិត្តរូបឋានៈសង្គមថ្មីកំពុងពេញនិយមរបស់យុវជនភ្លើតភ្លើននៅបាងកក។ នៅភោជនីយដ្ឋានមួយ ដែលជំនាញខាងធ្វើម្ហូប “khanthoke” ដែលជាម្ហូបហិលចម្រុះមុខ ហូបជាមួយបាយដំណើប អ្នកដេញហ្គីតារម្នាក់មិនច្រៀងបទក្នុងស្រុកទេ តែបែរជាទៅច្រៀងបទជនបទអាមេរិកាំងរបស់លោក John Denver ទៅវិញ។*

*លោក ឧត្តម រុងរឿងស៊ី Udom Roongruangsi នាយកមជ្ឈមណ្ឌលលើកកម្ពស់សិល្បៈ និងវប្បធម៌នៅសាកលវិទ្យាល័យឈៀងម៉ៃ និយាយថា ៖ "ភាពលោកលន់ថ្មីកំពុងប្លន់យកភាពសាមញ្ញរបស់យើងទៅហើយ"។*

*លោក ឧត្តម កំពុងបង្ហើយកិច្ចការដែលគាត់ចំណាយពេលប្រាំមួយឆ្នាំក្នុងការចងក្រងវចនានុក្រមខ្នាតធំ ស្តីអំពីវប្បធម៌របស់ថៃភាគខាងជើង។ គាត់ហៅសៀវភៅរបស់គាត់ថាជា "ប៉មយាមកំពែងការពារចុងក្រោយមុននឹងអរិយធម៌របស់យើងវិនាសសាបសូន្យ"។*

*លោក ឧត្តម និយាយថា វប្បធម៌ជាប្រពៃណីកំពុងទទួលរងការគំរាមកំហែងមួយផ្នែក ដោយសារប្រព័ន្ធគ្រប់គ្រងនយោបាយបែបមជ្ឈការខ្ពស់របស់ថៃ ដែលតាមរយៈប្រព័ន្ធនេះ ក្រុងឈៀងម៉ៃ ត្រូវបានគ្រប់គ្រងភាគច្រើនដោយមន្ត្រី ដែលក្រុងបាងកកបញ្ជូនមក មិនមែនដោយមនុស្សក្នុងស្រុកទេ។ អ្វីៗដែលជាគុណតម្លៃរបស់ក្រុងបាងកក កំពុងតែធ្វើការគ្របដណ្តប់នៅលើទីនេះ។*

*លោក ឧត្តម និយាយថា "ខ្ញុំព្យាយាមបង្រៀនកូនស្រីរបស់ខ្ញុំនូវភាសាអ្នកភូមិសាន ប៉ុន្តែនាងមិនព្រមទទួលយកទេ ដោយសារតែគ្រូរបស់នាង មិត្តរបស់នាង និងដោយសារតែទូរទស្សន៍"។*

*អ្នកអភិរក្សដទៃទៀត បានអ៊ូរទាំអំពីការសម្តែងវប្បធម៌មួយចំនួន ដែលរៀបចំសម្រាប់ទេសចរដោយមន្ត្រីរដ្ឋាភិបាល ដែលមិនសូវមាន ការយល់ដឹងអំពីវប្បធម៌មូលដ្ឋាន។ ពួកគេនិយាយថា ប្រវត្តិសាស្ត្រ និងបេតិកភ័ណ្ឌរបស់ឃៀងម៉ៃ កំពុងត្រូវបានគេមួលបង្កាច់ ប្រើប្រាស់ បម្រើការកំសាន្ត ដើម្បីរកលុយ ជាជាងដើម្បីអប់រំ និងលើកទឹកចិត្ត ការឲ្យតម្លៃវប្បធម៌។ នៅផ្សាររាត្រី ក្រុមបម្រើការកំសាន្តនាំគ្នាសម្តែង របាំប្រពៃណីលើឆាក ដើម្បីទាក់ទាញអតិថិជនឲ្យចូលភោជនីយដ្ឋាន។ ជនជាតិភាគតិចថៃ ក្នុងសម្លៀកបំពាក់ជនព្រៃភ្នំ លីស៊ុ ត្រូវបានគេឃើញ កំពុងសម្តែងរបាំជនជាតិអាខា។*

*លោក ឧត្តម និយាយថា អ្នកឃៀងម៉ៃ លែងចាត់ទុកវត្តអារាមថាជា ផ្នែកមួយពិតប្រាកដនៃសហគមន៍របស់គេទៀតហើយ។ គាត់និយាយថា ផ្ទុយទៅវិញ ពួកគេទៅកាន់វត្តអារាម តែពេលណាដែលគេចង់បំពេញ តម្រូវការណាមួយតែប៉ុណ្ណោះ "ដូចគ្នានឹងពួកគេទៅហាងគុយទាវ តែពេលណាដែលពួកគេឃ្លានតែប៉ុណ្ណោះ"។*

*កាលពីទិវាបុណ្យកឋិនថ្មីៗនេះ គូស្វាមីភិរយាមួយគូបានបើករថយន្ត Honda Accord មួយថ្មីស្រឡាង មកឈប់នៅខ្លោងទ្វារក្រុងដែលមាន អាយុកាលតាំងពីសតវត្សរ៍ទី ១៣ មកម្ល៉េះ ហើយ ២០ វិនាទីក្រោយមក ក៏បាកចេញទៅវិញ បន្ទាប់ពីដាក់កញ្ចប់វិភាគទានមួយនៅក្នុងប្រអប់ ក្បែរនោះ។ នៅពីលើឧឃោសនស័ព្ទ ដែលកំពុងបំពងសម្លេងសូត្រមន្ត របស់លោកសង្ឃ គឺមានបដាពណ៌លឿងមួយ ដែលអំពាវនាវឲ្យមនុស្សម្នា ចូលមកធ្វើការបន់ស្រន់។ នៅពីលើបដានោះទៀត គឺមាននិមិត្តរូបរបស់ ក្រុមហ៊ុនទូរស័ព្ទដៃធំមួយ។ តែប៉ុន្មានជំហានពីទីនោះ នារីយក្មេងបីនាក់ កំពុងជជែកសប្បាយក្អាកក្អាយពេល ដែលពួកគេមើលទៅកាន់ការផ្សាយ ពាណិជ្ជកម្មរបស់មហាហាង ដោយមិនខ្វីរវល់នឹងសូរពេងនៃសម្លេង សូត្រមន្តនោះឡើយ។*

*អ្នកនិពន្ធចាប់ផ្តើមបញ្ចប់ សាច់រឿងដោយវិលទៅរកឆាក ទីតាំងនៅពីខាងដើមអត្ថបទ វិញ ជាមួយនឹងការរៀបរាប់ ក្បោះក្បាយជាក់លាក់។ ការសង្កេតទៅលើនារីយក្មេង ធ្វើឲ្យអ្នកអានត្រិះរិះគិតអំពី រឿងនេះ ព្រមពេលជាមួយគ្នា ដែលគេហៀបនឹងបញ្ចប់អាន រឿង។ អត្ថបទពិពណ៌នាមួយ នេះ មានសេចក្តីផ្តើមដែល មានសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់ ដែលមាន រចនាសម្ព័ន្ធរៀបចំយ៉ាងប្រយ័ត្ន ប្រយែង។ វាកសាងឡើងនៅ ជុំវិញមូលបទសំខាន់តែមួយ។ សម្រង់សម្តីដើម និងសេចក្តី ក្បោះក្បាយ ធ្វើឲ្យអ្នកអាន ចង់អានដល់ទីបញ្ចប់។ ហើយសម្រង់សម្តីដើម និង សេចក្តីក្បោះក្បាយទាំងអស់ នោះ សុទ្ធតែទាក់ទងទៅនឹង មូលបទតែម្តង។*

# ទ្រង់ទ្រាយផ្សេង ៗទៀត

រឿងមានច្រើនប្រភេទ ហើយរបៀបតាក់តែងវាក៏មានច្រើនដែរ។ វាជាការលំបាកមួយក្នុងការបង្រៀនអំពីការសរសេរអត្ថបទពិពណ៌នាតាមទ្រឹស្តីក្នុងសៀវភៅ។ ប្រសិនបើអ្នកមិនប្រាកដក្នុងខ្លួនថាតើត្រូវរៀបចំអត្ថបទពិពណ៌នាមួយដោយរបៀបណានោះ យកល្អគួររកនិពន្ធនាយក ឬអ្នកបង្វឹកចំណានណាម្នាក់ឲ្យជួយមើលរឿងរបស់អ្នក។ ប្រភេទអត្ថបទពិពណ៌នាដទៃទៀត មានដូចជា ៖

- អត្ថបទដំណឹងពិពណ៌នា ឬអត្ថបទដំណឹងវិភាគ គឺវាចាប់យកព្រឹត្តិការណ៍ថ្មីមួយដែលគេទើបតែធ្វើសេចក្តីរាយការណ៍ព័ត៌មានហើយ មកពន្យល់បន្ថែមថា តើវាកើតឡើងដោយរបៀបណា តើវាមានន័យយ៉ាងដូចម្តេច ហើយថាតើអាចនឹងមានអ្វីទៀតកើតឡើង។ ឧទាហរណ៍ ដូចជាថាហេតុអ្វីបានជាមានក្មេងស្លាប់ក្នុងរដូវទឹកជំនន់ខែវស្សានៅប្រទេសវៀតណាម ឬមួយក៏ថា តើការដែលប្រទេសមួយចូលជាសមាជិកថ្មីរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ វាមានន័យដូចម្តេចទៅសម្រាប់ប្រទេសនោះ។
- រឿងចំណាប់អារម្មណ៍របស់មនុស្ស គឺក្នុងនោះអាចមានរឿងគ្រប់បែបយ៉ាង តាំងពីអំពីសត្វ អំពីក្មេង អំពីសោកនាដកម្ម អំពីជោគជ័យលើការលំបាកមួយ ហើយវាអាចជារឿងកំសត់ ឬកំប្លែងចង់សើច។ អត្ថបទរឿងប្រភេទនេះ វាធ្វើឲ្យមនុស្សរំជួលចិត្ត។
- អត្ថបទពិពណ៌នាបុគ្គលភាព គឺជាប្រភេទអត្ថបទ ដែលរំលេចនូវបុគ្គលិកលក្ខណៈរបស់មនុស្សណាម្នាក់
- អត្ថបទស៊ើបអង្កេត ជាប្រភេទរឿងដែលមានភាពស្មុគស្មាញ។ រឿប្រភេទនេះត្រូវបានសរសេរឡើង បន្ទាប់ពីមានការរៀបចំផែនការល្អិតល្អន់ ការទៅមើលដល់ទីកន្លែងកើតហេតុ ការសម្ភាសន៍ការស្រាវជ្រាវឯកសារ និងការវិភាគគ្រប់ជ្រុងជ្រោយជាដើម។ រឿងបែបនេះច្រើនតែរាយការណ៍អំពីអ្នកណាម្នាក់នៅក្នុងរដ្ឋាភិបាល ឬក្នុងសហគមន៍ធុរកិច្ចប្រឹងរក្សាទុកជាកិច្ចការសម្ងាត់។

# ជំពូកទី ១០ ការប្រើប្រាស់សម្រង់សម្ដីដើម

សម្រង់សម្ដីដើមមានសារៈសំខាន់ត្រង់ថា វាបន្ថែមទម្ងន់នៃភាពជឿជាក់បានទៅក្នុងសាច់រឿង។ វាផ្ដល់ការទ្រទ្រង់ពង្រឹងថែមទៀតផងដែរដល់ព័ត៌មាននៅក្នុងសេចក្ដីផ្ដើម។ ជាងនោះទៅទៀត គឺវាបន្ថែមការសង្កត់ធ្ងន់ទៅលើចំណុចគោលធំៗ ដែលបានលើកឡើងក្នុងសាច់រឿង។ តាមរយៈសម្រង់សម្ដីដើម អ្នកអានអាច "ស្ដាប់ឮ" ពីប្រភពព័ត៌មាន ដោយផ្ទាល់តែម្ដង ហើយតាមរយៈនោះ ពួកគេក៏អាចស្វែងយល់បានអំពីឥរិយាបថ អត្តចរិត និងអាវេគរបស់ប្រភពនោះដែរ។ សម្រង់សម្ដីដើមបន្ថែមនូវចម្រុះភាព និងល្បឿនលំហូរក្នុងសាច់រឿង។ ក្នុងន័យនេះ អ្នកអានមិនមែនទទួលបានតែព័ត៌មានមួយបន្ទាត់នោះទេ។



*រឿងដែលអត់មានសម្រង់សម្ដីដើម វាគួរឲ្យធុញនឹងអាន*

## ពេលណាគួរ និងពេលណាមិនគួរ ប្រើសម្រង់សម្ដីដើម

ចូរប្រើតែសម្រង់សម្ដីដើមណា ដែលសង្ខេបស្ថានភាពមួយបានល្អ ដែលមានផ្ទុកទៅដោយអារម្មណ៍ ឬរូបភាពល្អៗ ឬមួយជាសម្រង់សម្ដីដែលរំលេចនូវអត្តចរិតរបស់មនុស្សម្នាក់។

ខាងក្រោមនេះ ជាសម្រង់សម្ដីដើមមួយចំនួន ដែលបានមកពីអ្នករស់រានមានជីវិតផុតពីព្យុះស៊ីក្លូនមួយនៅប្រទេសមីយ៉ាន់ម៉ា។ អ្នកយកព័ត៌មានឲ្យទីភ្នាក់ងារព័ត៌មាន *Agence France-Presse (AFP)* បានប្រមូលសម្រង់សម្ដីនេះមក។ សម្រង់សម្ដីទីមួយ គឺបានមកពីបុរសម្នាក់ដែលនៅរស់រានមានជីវិតតែម្នាក់ឯងគត់ក្នុងចំណោមគ្រួសាររបស់គាត់។

*បុរសម្នាក់អាយុ ២០ ឆ្នាំ បានពោលថា "ខ្យល់ព្យុះបានបោកបក់មកលើភូមិរបស់យើង នាំមកនូវផ្ទាំងរលកទឹកដ៏ធំមួយមកជាមួយផង ហើយទាញយកអ្វីៗគ្រប់បែបយ៉ាងចូលទៅក្នុងសមុទ្រវិញអស់"។*

*"លំនៅដ្ឋាននិងអគារនានា ត្រូវបានដួលរលំ ហើយមនុស្សម្នា ត្រូវបានកម្លាំងទឹកអូសយកទៅជាមួយ។ ខ្ញុំមានជីវិតនៅរស់ ដោយសារតែបានតោងជាប់ដើមឈើធំមួយតែប៉ុណ្ណោះ"។*

សម្រង់សម្ដីបន្ទាប់មកទៀត បានបន្សល់ទុកជាមួយអ្នកអាននូវរូបភាពប្រហាក់ប្រហែលគ្នានេះដែរ៖

*យុវវ័យម្នាក់ដែលបានរស់រានមានជីវិតពីគ្រោះមហន្តរាយនោះ និយាយថា "ផ្ទាំងរលកទាំងនោះខ្លាំងមែនទែន គឺខ្លាំងរហូតដល់*

*ថ្នាក់វាអាចបកយកសម្លៀកបំពាក់ចេញពីខ្លួនខ្ញុំអស់រលីង។ ខ្ញុំនៅខ្លួនទទេ ពេលដែលនៅតោងតោកយ៉ោកជាប់នឹងដើមឈើ"។*

មួយទៀតនេះ ជាសម្រង់សម្ដីដើមពីសំណាក់ជនជាតិថៃម្នាក់ ដែលបានអត្ថាធិប្បាយអំពីការជាប់ឆ្នោតរបស់លោក បារ៉ាក់ អូបាម៉ា ជាប្រធានាធិបតីទី ៤៤ របស់សហរដ្ឋអាមេរិក។

ជនជាតិថៃឈ្មោះ ប្រាធា កាន់ចាណាណុន អាយុ ២៩ ឆ្នាំ ដែលកំពុងអង្គុយក្នុងហាងកាហ្វេ *Starbucks* ក្នុងក្រុងបាងកកនិយាយថា "គួរឲ្យជាទីសង្ឃឹមមែន។ គាត់ពិតជាប្រធានាធិបតីសកលរបស់អាមេរិក ដែលពិភពលោកមិនដែលមានពីមុនមក។ គាត់ធ្លាប់មានកុមារភាពនៅអាស៊ី មានឪពុកដើមកំណើតអាហ្វ្រិក និងមានឈ្មោះជាអ្នកមជ្ឈិមបូព៌ា។ គាត់ពិតជាប្រធានាធិបតីសកលមែន"។

សម្រង់សម្ដីបែបនេះ វាពោរពេញដោយពណ៌ ហើយមានអត្ថន័យជ្រៅជ្រះជាងការគ្រាន់តែនិយាយថា "ប្រជាជននៅក្រុងបាងកកមានសេចក្ដីត្រេកអរនឹងលទ្ធផលការបោះឆ្នោតនោះណាស់"។ សម្រង់សម្ដីនេះ ក៏មានចង្វាក់លើកដាក់គួរឲ្យចាប់អារម្មណ៍ផងដែរ។

សម្រង់សម្ដីខាងក្រោម ត្រូវបានដកស្រង់ចេញពីកាសែត Bangkok Post។ វាបានលាតត្រដាងនូវអារម្មណ៍ជ្រាលជ្រៅរបស់ឧត្ដមសេនីយត្រីយោធាម្នាក់ ដែលត្រូវបានគេផ្ទេរបាត់តាំងឲ្យទៅមើលការខុសត្រូវកីឡាប្រដាល់អេរ៉ូប៊ិកវិញ បន្ទាប់ពីគាត់មានការពាក់ព័ន្ធក្នុងវិវាទនយោបាយ។

*ក្រោយពីបានដឹងថា គាត់ត្រូវបានមេទាហានរបស់គាត់ចាត់តាំងឲ្យទៅកាន់ការងារថ្មី លោកឧត្ដមសេនីយត្រីយោធាថៃ ឈ្មោះលោក ខាទិយ៉ា សាវ៉ាស់ឌីពុន មានប្រសាសន៍ថា "វាជារឿងគួរឲ្យអស់សំណើចដែលគេបញ្ជូនរូបខ្ញុំជាយុទ្ធជនឲ្យទៅរាំនៅឯផ្សារ។ លោកនាយមេទាហានចង់ឲ្យខ្ញុំធ្វើជាអ្នកបង្ហាញដឹកនាំអ្នករាំរបាំអាអេរ៉ូប៊ិក។ ខ្ញុំបានត្រៀមរៀបចំរបាំមួយរួចជាស្រេចហើយ។ វាមានឈ្មោះថារបាំគប់គ្រាប់បែកដៃ"។*

ជានិច្ចកាល ចូរស្វែងរកសម្រង់សម្ដីដែលល្អបំផុត។ សម្រង់សម្ដីដែលល្អនៅពីខាងដើមរឿងជួយទាក់ទាញការចាប់អារម្មណ៍របស់អ្នកអាន។ សម្រង់សម្ដីល្អៗនៅកណ្ដាលសាច់រឿងជួយរក្សាអ្នកអានឲ្យអានបន្ត។ ហើយសម្រង់សម្ដីល្អនៅចុងសាច់រឿងនឹងបន្សល់ទុកនូវការដក់អារម្មណ៍យូរអង្វែងអ្នកអានជាមួយនឹងអត្ថបទនោះ។

ពេលដែលអ្នកប្រើសម្រង់សម្ដីទៅទ្រទ្រង់ដល់សេចក្ដីផ្ដើម ចូរធ្វើយ៉ាងណារើសយកសម្រង់សម្ដីណាដែលបន្ថែមនូវព័ត៌មានថ្មីៗ។ ចូរកុំគ្រាន់តែប្រើសម្រង់សម្ដី ដែលគ្រាន់តែថាឡើងវិញនូវព័ត៌មានដូចគ្នា ដែលមានរួចមកហើយនៅក្នុងសេចក្ដីផ្ដើមដូចក្នុងរឿងខាងក្រោមនេះជាឧទាហរណ៍ស្រាប់ ៖

*ភ្នំពេញ, កម្ពុជា - ប្រទេសកម្ពុជាប្រកាសកាលពីម្សិលមិញថា ខ្លួនបានលុបបំបាត់អស់ហើយនូវជំងឺស្វិតដៃជើង ដោយក្លាយខ្លួនជាប្រទេសចុងក្រោយគេបង្អស់នៅតំបន់ប៉ាស៊ីហ្វិកប៉ែកខាងលិច ដែលបានលុបបំបាត់ជំងឺនេះអស់ទាំងស្រុង។*

*លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និយាយថា គាត់មានមោទនភាព "ក្នុងការប្រកាសទៅកាន់ពិភពលោកទាំងមូលថាជាលើកដំបូង ហើយក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលជំងឺគ្រុនស្វិតដៃជើងត្រូវបានលុបបំបាត់ចេញអស់ពីក្នុងប្រទេស"។*

កុំយកមកប្រើឲ្យសោះនូវសម្រង់សម្ដីណាដែលធុញមិនគួរចង់អាន ពិបាកនឹងយល់ ឬក៏គ្រាន់តែថ្លែងលើងវិញនូវអ្វី ដែលវាមានលក្ខណៈច្បាស់ក្រឡែតទៅហើយ។ ក្នុងករណីបែបនេះ ចូរគ្រាន់តែតាក់តែងព័ត៌មាននោះ តាមពាក្យខ្លួនឯងវិញទៅបានហើយ។ អ្នកយកព័ត៌មានជាច្រើនអ្នកប្រើ

សម្រង់សម្ដីដើម ក៏ព្រោះតែពួកគេមានវារួចស្រេច ហើយនៅក្នុងកូនសៀវភៅកំណត់ហេតុរបស់គេប៉ុណ្ណោះ។ ពួកគេចង់បង្ហាញអ្នកអានថា គេបានសម្ភាសន៍ ប្រភពព័ត៌មានសម្រាប់រឿងរបស់ពួកគេ។ ចូរចៀសវាងទម្លាប់គិតបែបនេះ។

ចូរក្រឡេកមើលឧទាហរណ៍ខាងក្រោម ស្ដីអំពីរបៀបអាក្រក់ក្នុងការប្រើសម្រង់សម្ដីក្នុងរឿងមួយចំនួន។ មួយនេះជាសម្រង់សម្ដីរបស់រដ្ឋមន្ត្រីវៀតណាមម្នាក់ ៖

*"ការកែច្នៃអង្ករគ្រាប់ធញ្ញជាតិស្បៀងអាហារ កាហ្វេនិងតែ ឈើនិងផលិតផលព្រៃដទៃទៀត នឹងត្រូវបានចាត់ទុកថាជាធុរកិច្ចមានពលកម្មប្រកបដោយប្រពលភាព"។*

នេះជារបៀបនិយាយបង្វែរជានមួយ ដែលពួកការិយាធិបតេយ្យករចូលចិត្តប្រើ។ អ្នកគួរតែសរសេរវាដោយប្រើពាក្យរបស់ខ្លួនឲ្យបានច្បាស់ និងយ៉ាងសាមញ្ញ ប៉ុន្តែមុនដំបូងបង្អស់ អ្នកត្រូវស្វែងយល់ឲ្យប្រាកដជាមុនសិនថា តើលោករដ្ឋមន្ត្រីចង់និយាយអំពីអ្វី។

មួយនេះទៀតជាសម្រង់សម្ដីពីមន្ត្រីម្នាក់របស់អង្គការសហប្រជាជាតិនៅភ្នំពេញ ៖

*"ខ្ញុំសម្លឹងឆ្ពោះទៅរកការពង្រឹងកិច្ចសហប្រតិបត្តិ-ការ និងជំនួយរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការមូលនិធិបរិស្ថានពិភពលោក"។*

នេះជាសម្រង់សម្ដីដ៏ក្រៀមផ្អេះ និងគួរឲ្យធុញមិនចង់អាន។ វាក៏មានភាពស្រពិចស្រពិលណាស់ដែរ ហើយនេះគ្រាន់តែជាព័ត៌មានសាវតារតែប៉ុណ្ណោះ មិនមែនជាអ្វីដែលអ្នកគួរដកស្រង់ជាសម្ដីដើមនោះទេ ៖

*"ការបំណាយលើបំណើផលិតភ្លាមៗ ក្នុងការទិញដូរនីមួយៗ មានតម្លៃពី ៤០ ទៅ ៥០ បាត បើប្រៀបធៀបទៅនឹង ៧ ដុល្លារអាមេរិក នៅប្រទេសសិង្ហបុរី និង ១២ ដុល្លារ នៅសហរដ្ឋអាមេរិក"។*



*មិនមែនមនុស្សគ្រប់រូបចង់ឲ្យគេដកស្រង់សម្ដីទេ*

ជាមួយនឹងបទពិសោធន៍ អ្នកនឹងអភិវឌ្ឍន៍បាននូវការយល់ដឹងថា តើពេលណាគួរ និងពេលណាដែលមិនគួរដកស្រង់សម្ដីដើមរបស់នរណាម្នាក់។

## ចៀសវាងការផ្ដើមរឿងជាមួយនឹងសម្រង់សម្ដីដើម

ជាទូទៅ អ្នកមិនគួរផ្ដើមរឿងជាមួយនឹងសម្រង់សម្ដីដើមទេ។ អ្នកអាននឹងវិលវល់ច្របូកច្របល់ ប្រសិនបើអ្នកធ្វើដូច្នោះ។ គេអាចមិនយល់ថា តើអ្នកណាកំពុងនិយាយ ឬមួយថាតើរឿងនេះកំពុងនិយាយអំពីអ្វី។

ខាងក្រោមនេះ ជាសេចក្ដីផ្ដើមរឿងនៅក្នុងកាសែតមួយនៅប្រទេសឡាវ ៖

*"អ្វីដែលធ្វើឲ្យខ្ញុំមួម៉ៅហ្មងនោះ គឺជាសារព័ត៌មានបរទេសតែងតែព្យាយាមចោទប្រទេសឡាវ ដោយមិនបានគិតគូរអំពីការណ៍ពិត ដោយគ្រាន់តែសរសេរតាមការស្រមើស្រមៃរបស់ពួកគេតែប៉ុណ្ណោះ" លោក Oneneua Phommachanh អភិបាលខេត្តចម្ប៉ាសាក់ មានប្រសាសន៍ក្នុងការបើកវគ្គហ្វឹកហ្វឺនអ្នកសារព័ត៌មាននៅភូមិប៉ាក់សេ នៅព្រឹកជាមួយគ្នាដែលមានពួកចោរឆ្លងចូលទឹកដីឡាវតាមច្រកព្រំដែនឡាវ-ថៃ ឈ្មោះ Vang Tao-Chong Mek។*

រហូតមកដល់ចុងនៃឃ្លាយ៉ាងវែង ទើបយើងដឹងថា អ្វីដែលលោកអភិបាលខេត្តនិយាយមានការទាក់ទិនជាមួយនឹងចោរឆ្លងដែន។ យ៉ាងណាក៏ដោយក៏នៅមិនទានច្បាស់ថាតើអ្វីបានកើតឡើងនោះ។ "ការណ៍ពិត " ស្អីទៅ? "ការស្រមើស្រមៃ" ស្អីទៅ? សម្រង់សម្ដីនឹងមានភាពច្បាស់លាស់ជាងមុន ប្រសិនបើអ្នកអាចពន្យល់ជាមុននូវបរិបទដែលគេបានពោលសម្រង់សម្ដីមួយឡើង។

ចូរសរសេរប្រយោគនេះឡើងវិញដូច្នេះ ៖

*លោក Oneneua Phommachanh អភិបាលខេត្តចម្ប៉ាសាក់ បានរិះគន់បណ្ដាញព័ត៌មានបរទេសអំពីការផ្សព្វផ្សាយរបស់ពួកគេអំពីការវាយប្រហារទៅលើប៉ុស្តិ៍ព្រំដែនមួយនៅប្រទេសឡាវ។*

*លោកអភិបាលនិយាយថា អ្នកយកព័ត៌មានបរទេសបានបង្ហាញឧបទ្ទវហេតុនោះ វាជាការវាយប្រហារដោយក្រុមឧទ្ទាមមកលើរដ្ឋាភិបាល តែលោកបានប្រកែកថា នោះគ្រាន់តែជាសកម្មភាពចោរប្លន់មួយប៉ុណ្ណោះ។*

*"អ្វីដែលធ្វើឲ្យខ្ញុំមួម៉ៅហ្មង..."*

## តើអ្នកណាកំពុងនិយាយ?

បើសិនជាអ្នកមានសម្រង់សម្ដីដើមពីមនុស្សផ្សេងៗគ្នា ចូរកុំគ្រាន់តែដាក់វាតម្រៀបគរលើគ្នាក្នុងអត្ថបទរឿងនោះ។ អ្នកអាននឹងភាន់ច្រឡំថា តើអ្នកណាជាអ្នកនិយាយ។ មុននឹងដាក់សម្រង់សម្ដីរបស់មនុស្សម្នាក់ទៀតក្នុងសាច់រឿង ចូរធ្វើការណែនាំអំពីមនុស្សនោះសិន ដើម្បីឲ្យគេដឹងថាអ្នកណាកំពុងនិយាយ។

***ខុស ៖** លោកអភិបាលខេត្តនិយាយថា "ខ្ញុំមិនសប្បាយចិត្តទេជាមួយនឹងកញ្ចប់ថវិកាថ្មីនេះ ពីព្រោះវានឹងបង្កក្ដីវេទនាដល់ប្រជាជនក្រីក្រ"។*

"កញ្ចប់ថវិកានេះ ជាយថាហេតុនឹងបង្ខំរដ្ឋាភិបាលឲ្យតម្លើងពន្ធដារ" លោកប្រធានព្រឹទ្ធសភានិយាយបន្ថែម។

***ត្រូវ ៖** លោកអភិបាលខេត្តនិយាយថា "ខ្ញុំមិនសប្បាយចិត្តទេជាមួយនឹងកញ្ចប់ថវិកាថ្មីនេះ ពីព្រោះវានឹងបង្កក្ដីវេទនាដល់ប្រជាជនក្រីក្រ"។*

លោកប្រធានព្រឹទ្ធសភានិយាយ បន្ថែមដូច្នេះថា "កញ្ចប់ថវិកានេះ ជាយថាហេតុនឹងបង្ខំរដ្ឋាភិបាលឲ្យតម្លើងពន្ធដារ" ។

## ពាក្យ "និយាយ" វាគ្រប់គ្រាន់ណាស់ទៅហើយ (“Said” is enough)

ក្នុងករណីភាគច្រើនបំផុត ចូរប្រើសម្រង់សម្ដីដើមជាមួយនឹងពាក្យ "និយាយ" ទៅបានហើយ។ វាជាពាក្យសាមញ្ញច្បាស់ ហើយមានលក្ខណៈអព្យាក្រឹតទៀតផង។ ចូរកុំបារម្ភថាអ្នកប្រើពាក្យ "និយាយ" ច្រំដែលច្រើនដងពេក អ្នកអានគេនឹងយល់ហើយ។ ពាក្យដូចជា “claimed” “declared” “asserted” ឬ “argued” សុទ្ធតែមានអត្ថន័យខុសគ្នាទាំងអស់។ ឧទាហរណ៍ នៅពេលណាអ្នកសរសេរថា មនុស្សណាម្នាក់ “claimed” នោះមានន័យថា អ្នកកំពុងសម្ដែងក្ដីមន្ទិលសង្ស័យទៅលើអ្វីដែលជននោះបាននិយាយ។

## កុំដូរសម្រង់សម្ដីដើមឲ្យសោះ!

អព្ភន្តរសញ្ញា " " ដែលមាននៅពីមុខ និងពីក្រោយសម្រង់សម្ដីដើម មានន័យថា ពាក្យពេចន៍ទាំងអម្បាលមាណដែលស្ថិតក្នុងចន្លោះនោះ សុទ្ធសឹងតែជាពាក្យដើមទាំងស្រុង ដែលប្រភពបានពោលចេញមក។ ចូរកុំដូរសម្រង់សម្ដីឲ្យសោះ បើទោះជាថាអ្នកចង់ធ្វើឲ្យវាកាន់តែច្បាស់ ងាយយល់ដល់អ្នកអានក៏ដោយ។

ក៏ប៉ុន្តែអ្នកអាចលប់ចេញនូវស្នូរ ដូចជា “ums” និង “ahs” និងបំណែកក្នុងសម្ដី ដែលមនុស្សម្នាច្រើនតែប្រើក្នុងការនិយាយ។ ហើយមានអ្នកកាសែតខ្លះដើថាវា អូខេ បើគ្រាន់តែធ្វើការកែតម្រូវកំហុសវេយ្យាករណ៍បន្តិចបន្តួចក្នុងសម្រង់សម្ដីនោះ។

បើអ្នកប្រើសម្រង់សម្ដី ចូរប្រើវាក្នុងទម្រង់ដើមដូចដែលគេបានពោលមកអញ្ចឹង។ បើមិនដូច្នោះទេ ចូរប្រើតែមួយចំណែករបស់វាទៅក៏បានដែរ។ ឬមួយអ្នកក៏អាចសរសេរសម្រាយវា ដោយមិនបាច់ប្រើអព្ភន្តរសញ្ញា។ គេឲ្យការធ្វើដូច្នេះថា ការសរសេរសម្រាយ។

កុំសម្រាយសម្រង់សម្ដីឲ្យហួសពីបរិបទរបស់វា។ នេះមានន័យថា អ្នកប្រាប់ដល់អ្នកអាននូវអ្វី ដែលប្រភពមួយចង់មានន័យ នៅពេលដែលគេធ្វើសេចក្ដីថ្លែងការណ៍ណាមួយ។ ក្នុងបទសម្ភាសន៍មួយ ជាមួយអ្នកប្រភពម្នាក់អាចនិយាយបន្ថែមនូវបរិបទមួយទៅនឹងសម្រង់សម្ដីដែលអ្នកបានប្រើ។ ឬមួយក៏ប្រភពនោះនិយាយលម្អិតបន្ថែម ឬមួយគ្រាន់តែនិយាយកំប្លែងលេងប៉ុណ្ណោះ។ ដូច្នេះ យើងត្រូវតែប្រាប់ដល់អ្នកអាននូវបរិបទនោះ។

ឧទាហរណ៍ អ្នកសម្ភាសន៍កីឡាករបាល់ទាត់ម្នាក់។ កីឡាករនោះ និយាយអំពីកីឡាករដែលមានអាយុជាង ៣៥ ឆ្នាំ ហើយគាត់បន្ថែមថា "ខ្ញុំជាកីឡាករពូកែជាងគេ" ។ អ្នកអាចស្រង់សម្ដីរបស់បាន ប៉ុន្តែអ្នកត្រូវបង្ហាញឲ្យបានច្បាស់នូវអត្ថន័យពេញលេញរបស់របស់សម្រង់សម្ដីនោះ។ បានន័យថា កីឡាករនោះកំពុងនិយាយអំពីសមត្ថភាពរបស់គាត់ក្នុងការលេងបាល់ទាត់ គឺអត់មាននិយាយអំពីអ្វីផ្សេងទេ។ គាត់បានប្រៀបធៀបរូបគាត់ទៅនឹងកីឡាករដទៃទៀតដែលមានអាយុជាង ៣៥ ឆ្នាំ មិនមែនជាមួយកីឡាករទូទៅទេ។

## សូមប្រយ័ត្នជាមួយសម្ដីដើមដោតត្រណោត

សម្ដីដើមអាចជួយធ្វើឲ្យសាច់រឿងរបស់អ្នកកាន់តែមានថាមភាពខ្លាំងថែមទៀត ប្រសិនបើអ្នកចេះប្រើសម្ដីដើមដោយប៉ិនប្រសប់។ ប៉ុន្តែមានអ្នក

សារព័ត៌មានច្រើនអ្នកណាស់ ដែលសរសេររឿង ដោយគ្រាន់តែតម្រៀបសម្ដីដើមគរលើគ្នាពីមួយទៅមួយ។ គេធ្វើដូច្នេះ ជាពិសេសក្នុងការសរសេររឿងអំពីសុន្ទរកថា សេចក្ដីប្រកាស ឬសន្និសីទសារព័ត៌មាន។ របៀបនេះ គេហៅថា សារព័ត៌មានកម្ជិល ហើយវាធ្វើឲ្យរឿងច្របូកច្របល់ និងគួរឲ្យធុញនឹងអានទៀតផង។ អ្នកត្រូវតែបង្ហាញឲ្យច្បាស់ដល់អ្នកអានរបស់អ្នកថា តើមួយណាជាសម្ដីដើម និងមួយណាជាបរិបទ។

# ជំពូកទី ១១ តម្រុយសម្រាប់ការសរសេរបានល្អ

## មូលដ្ឋាន : ការប្រមូលព័ត៌មាន

ចំណុចសំខាន់មួយក្នុងការសំណេរល្អ គឺការយកចិត្តទុកដាក់ចំពោះរបស់ច្រើនមុនៗ។ ក៏ប៉ុន្តែដំបូងគេបង្អស់ អ្នកមិនអាចសរសេររឿងមួយបានល្អទេ ល្ដឹកណាដែលអ្នកមិនបានធ្វើការប្រមូលព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយទេ។ មានតែការប្រមូលយកព័ត៌មានបានគ្រប់ជ្រុងជ្រោយទេ ទើបអ្នកយល់អំពីប្រធានបទបានល្អគ្រប់គ្រាន់នឹងសរសេររឿងមួយបាន។ ការប្រមូលព័ត៌មានបានល្អនឹងនាំមកនូវសេចក្ដីពិស្ដារ សម្ដីដើម និងការផ្ទង់សេចក្ដីដែលធ្វើឲ្យការសរសេរបានល្អ។

យើងបាននិយាយរួចមក ហើយអំពីសារៈសំខាន់ក្នុងការធ្វើរឿងឲ្យមានជីវិតរស់រវើក ដោយប្រើប្រាស់នូវសម្ដីដើម មានថាមភាពសេចក្ដីពិពណ៌នាការដំណាល និងការបង្ហាញឧទាហរណ៍មនុស្សពិតៗ។ យើងក៏បានពិភាក្សាគ្នារួចមកហើយដែរ អំពីសារៈសំខាន់ក្នុងការសរសេរសេចក្ដីពិស្ដារជាក់លាក់ ដែលអាចធ្វើឲ្យអ្នកបានឃើញ ស្ដាប់ឮ និងទទួលអារម្មណ៍បានភ្លាមៗ ជាជាងការបង្ហាញគោលគំនិតទូលំទូលាយស្រពិចស្រពិល។

## ធ្វើឲ្យច្បាស់សេចក្ដី ធ្វើឲ្យសាមញ្ញសេចក្ដី (Clarify, Simplify)

យើងបានរំលឹករួចមកហើយនៅក្នុងជំពូកទី ៤ ថា ការសម្រាយបញ្ជាក់សេចក្ដីឲ្យបានច្បាស់លាស់ជាធាតុផ្សំមានសារៈសំខាន់មួយក្នុងការធ្វើរឿងមួយឲ្យមានថាមភាពខ្លាំង។ ដើម្បីសម្រេចបាននូវភាពច្បាស់លាស់សេចក្ដី អ្នកត្រូវសរសេរឲ្យចំៗតែម្ដង ដោយប្រើទម្រង់ប្រធាន-កិរិយាស័ព្ទ-កម្មបទ (subject-verb-object)។ សរសេរឲ្យចំៗដោយមិនបាច់ប្រើប្រាស់លើសនូវពាក្យដែលមិនចាំបាច់នោះទេ។ ប្រើភាសាប្រចាំថ្ងៃ ហើយចូរចៀសវាងនូវគ្រាមភាសា ឬពាក្យពិសេសរបស់ក្រុមជំនាញណាមួយ។ ដូចគ្នាដែរ ចូរចៀសវាងពាក្យពេចន៍របៀបជាសុភាសិត ដែលជាឃ្លោងឃ្លា ដែលត្រូវបានគេប្រើជាញឹកញាប់ពេកទៅរហូតដល់ថា វាសឹងតែបាត់បង់អត្ថន័យរបស់វាទៅហើយ។ ឧទាហរណ៍ មានអ្នកសារព័ត៌មានខ្លះចូលចិត្តសរសេរឃ្លា ដូចជាថា “sprawling refugee camps,” “posh resorts” និង “political uncertainty fueled by speculation”។

ចូរកុំសរសេរឃ្លាដែលវែង ហើយស្មុគស្មាញ។ ព្យាយាមកុំដាក់គំនិតលើសពីមួយនៅក្នុងឃ្លានីមួយៗ។ ប្រើពាក្យពេចន៍ និងឃ្លោងឃ្លាដែលងាយនឹងយល់។ ចូរកុំព្យាយាមធ្វើឲ្យអ្នកអានមានចំណាប់អារម្មណ៍នឹងអ្នកថាជាមនុស្សចេះប្រើពាក្យធំៗ។ ឧទាហរណ៍ជាជាងប្រើពាក្យ “demobilization”

ចូរសរសេរថា “reducing the size of the military / រំសាយទ័ព” វិញ។ វាវែងបន្តិចមែន តែវាងាយយល់ជាង។ សម្រាយឲ្យសាមញ្ញមានន័យថា ប្រើប្រាស់ពាក្យពេចន៍ខ្លីជាជាងវែង ដូចជា ៖ “rooms” ជំនួសឲ្យ “accommodation” និង “start” ជំនួសឲ្យ “initiate”។

ប្រសិនបើអ្នកជួបការលំបាកក្នុងការសរសេររឿង សូមសាកធ្វើពើថា អ្នកកំពុងប្រាប់រឿងនោះទៅដល់កសិករក្រីក្រម្នាក់មកពីជនបទ ឬក៏ប្រាប់ទៅដល់ពូលក់ទំនិញម្នាក់នៅផ្សារ។ តើអ្នកធ្វើការរៀបរាប់ប្រាប់រឿងនោះដល់ពួកគេបែបណា? សំណេរល្អ គឺជាសំណេរ ដែលមានគុណភាពបែបសន្ទនា ហើយសាមញ្ញ។ វាគួរតែមានលក្ខណៈដូចរបៀបយើងជជែកគ្នាអញ្ចឹង។ ចូរកុំព្យាយាមធ្វើឲ្យអ្នកអានស្ញប់ស្ញែងថា អ្នកជាមនុស្សពូកែប្រើពាក្យបួរបាច់ដូចផ្កា។ អ្នក គឺជាអ្នកសារគមនាគមន៍ និងជាអ្នកនិទានរឿង។ ប្រសិនបើមនុស្សនានាមិនអាចយល់អំពីរឿងរបស់អ្នក ដោយមិនបាច់មើលវចនានុក្រមជាជំនួយអ្នក ពិតជានឹងធ្វើឲ្យខាតបង់ពេលវេលា និងការអត់ធ្មត់របស់គេហើយ។

## ប្រើកិរិយាស័ព្ទ និងនាមខ្លាំងរស់រវើក (Using strong verbs and nouns)

តើតន្ត្រីពិធីអាពាហ៍ពិពាហ៍កំពុងប្រគំ ឬក៏កំពុងបំពងសូរទ្រហឹងអឺងអាប់ (Is the wedding music playing, or is it blasting)?

តើសេដ្ឋកិច្ចកំពុងតែមានភាពប្រសើរ ឬមួយក៏វាកំពុងតែស្ទុះងើបឡើងវិញ (Is the economy improving, or is it rebounding)?

ចូរប្រើកិរិយាស័ព្ទជាក់លាក់។ កិរិយាស័ព្ទសកម្មវាគ្រាន់បើជាងកិរិយាស័ព្ទអសកម្ម។ ការសរសេរថា "នគរបាល*ចាប់ខ្លួន*ជនសង្ស័យ" វាមានលក្ខណៈប្រសើរជាងការសរសេរថា "ជនសង្ស័យ *ត្រូវបានចាប់ខ្លួន* ដោយនគរបាល"។ នាមជាក់លាក់ វាប្រសើរជាងនាមដែលមានលក្ខណៈស្រពិចស្រពិល។ ការសរសេរថា "យុវវ័យម្នាក់" វាគ្រាន់បើជាងការសរសេរថា "បុរសក្មេងម្នាក់"។ ចូរចៀសវៀងការប្រើប្រាស់គុណនាម និងកិរិយាវិសេសច្រើនពេក។ ជារឿយៗ គុណនាម និងកិរិយាវិសេស គ្រាន់តែថែមពាក្យប៉ុណ្ណោះ តែពួកវាមិនសូវមានឥទ្ធិពលប៉ុន្មានទេ។

ការប្រើនាម ឬកិរិយាស័ព្ទខ្លាំងរស់រវើក នឹងអាចធ្វើឲ្យអ្នកអានមានការដក់អារម្មណ៍ជក់ចិត្តយូរអង្វែង ប៉ុន្តែសូមកុំបំផ្លើសឲ្យសោះ។ មិនមែនរាល់ការខ្វែងគំនិតគ្នាក្នុងចំណោមអ្នកនយោបាយសុទ្ធតែជា "ការប្រយុទ្ធក្ដៅគគុក" នោះឡើយ។ ជួនកាលវាគ្រាន់តែជាការប្រកែក ឬការជជែកដេញដោលតែប៉ុណ្ណោះ។ មិនមែនរាល់ការលំបាកសម្រាប់រដ្ឋាភិបាលសុទ្ធតែជា "វិបត្តិ" នោះទេ។ ជួនកាលវាគ្រាន់តែជាបញ្ហាមួយប៉ុណ្ណោះ។ (ដាក់រូបភាពមនុស្សម្នាមើលឈ្មោះបោះឆ្នោត)

## ចូរបង្ហាញ កុំប្រាប់ (Show, Don’t tell)

ចូរប្រើសេចក្ដីពិស្ដារ និងឧទាហរណ៍ជាក់លាក់ ដើម្បីគូសវាសបង្ហាញអំពីចំណុចទូទៅ ហើយប្រើពាក្យ និងឃ្លាចំជាក់លាក់នៅពេលណា ដែលអាចធ្វើទៅបាន ៖

- ចូរកុំគ្រាន់តែប្រាប់អ្នកអានថា ឧទ្យាននោះមាន "សោភ័ណភាពស្អាត"។ ពាក្យមួយម៉ាត់នេះ វាស្រពិចស្រពិលណាស់ដែលពិបាកឲ្យគេស្រមៃមើលថា តើឧទ្យាននោះវាស្អាតយ៉ាងណាខ្លះ។



*អ្នកសារព័ត៌មានត្រូវចេះលៃលកជាមួយតួលេខ*

តើវាមានសោភ័ណភាពស្អាតបែបណាខ្លះ? ចូរពិពណ៌នាអំពីប្រភេទផ្កា ដើមឈើ ស្រះ ពណ៌ និងក្លិននៅទីនោះ។

- ចូរកុំគ្រាន់តែប្រាប់អ្នកអានថា ផ្ទះនោះ "ចាស់"។ ចូរបង្ហាញដល់ពួកគេ ដោយរ៉ាយរ៉ាប់អំពីថ្នាំពណ៌របងប្រេះចាប់ និងបង្អួចបាក់បែក។
- ចូរកុំគ្រាន់តែប្រាប់អ្នកអានថា អ្នកលក់បន្លែនោះ "សប្បាយចិត្ត"។ ចូរបង្ហាញពួកគេ ដោយពិពណ៌នាអំពីស្នាមញញឹមបេញធ្មេញស្វាញ ធ្វើឲ្យផ្ទៃមុខរបស់នាងរីកពីគុម្ពត្របៀកមួយ ទៅដល់គុម្ពត្របៀកមួយទៀត។

ការប្រមូលព័ត៌មានបានល្អ ដែលមានមូលដ្ឋានលើការសង្កេតល្អ នឹងជួយធ្វើឲ្យអ្នកអានមានអារម្មណ៍ថា ពួកគេបានទៅដល់ទីនោះជាមួយអ្នកដែរ។ ចូរធ្វើឲ្យអ្នកអានរបស់អ្នកមើលឃើញ ស្តាប់ឮ ទទួលអារម្មណ៍ ហើយយល់រឿង។

ការបង្ហាញមនុស្សកំពុងធ្វើសកម្មភាព ក៏មានសារៈសំខាន់ណាស់ដែរ។ រឿងល្អៗ ជាពិសេសបទ-ពិពណ៌នា បង្ហាញមនុស្សកំពុងស្ថិតក្នុងសកម្មភាព ដើម្បីធ្វើឲ្យអ្នកអានអាចប្រមើលឃើញទិដ្ឋភាពឆាកទាំងមូលកំពុងមានចលនា។

សេង សោភ័ណ និស្សិតសារព័ត៌មានកម្ពុជា បានធ្វើការពិពណ៌នាអំពីក្មេងស្រីអាយុ ១៧ ឆ្នាំ ម្នាក់

ដែលបានរំលឹក អំពីការដែលនាងត្រូវបានគេលក់ទៅឲ្យផ្ទះបនពេស្យាចារ។ សេង សោភ័ណ ពិតជាអាចគ្រាន់តែសរសេរថា ក្មេងស្រីនោះ "កំពុងយំ" ក៏ប៉ុន្តែនាងសរសេរតាមបែបមួយ ដែលកាន់តែមានប្រសិទ្ធភាពថែមទៀត ៖

*សុខ ណា ច្បាមដៃអាវវែងនៃអៀមពណ៌ឈាមជ្រូករបស់នាងមកជូតទឹកភ្នែកចេញ។*

## របៀបលេលកជាមួយតួលេខ

តួលេខមានសារៈសំខាន់ ពីព្រោះវាជួយអះអាងបញ្ជាក់ដល់អ្នកអានអំពីគោលគំនិតធំក្នុងសាច់រឿង។ ប្រសិនបើអ្នកសរសេររឿងមួយអំពីការរាលដាលជំងឺអេដស៍ អ្នកអានពិតជាចង់ដឹងថា តើមានមនុស្សប៉ុន្មាននាក់ដែលមានវីរុស។ ប៉ុន្តែតួលេខមួយនឹងមិនមានន័យអ្វីទេដល់អ្នកអាន ដរាបណាទាល់តែគេយកវាទៅប្រៀបធៀបជាមួយតួលេខមួយទៀត។ បើអ្នកនិយាយអំពីតួលេខករណីជំងឺអេដស៍ឆ្នាំនេះ ចូរប្រៀបធៀបវាជាមួយតួលេខឆ្នាំមុន ហើយប្រៀបធៀបតួលេខទាំងពីរជាមួយនឹងចំនួនប្រជាជនក្នុងប្រទេស។

ដូចគ្នាដែរជាមួយនឹងការសរសេរអំពីថវិកា។ រឿងនីមួយៗអំពីថវិកាថ្មីរបស់ទីភ្នាក់ងារណាមួយគួរតែយកមកប្រៀបធៀបជាមួយថវិកាកាលពីឆ្នាំមុន។ តើវាច្រើនជាង ឬក៏តិចជាង? តើច្រើនជាង ឬតិចជាងប៉ុន្មាន? បើសិនជាអ្នកមានតួលេខសម្រាប់ត្រីមាសទីមួយឆ្នាំនេះ ចូរប្រៀបធៀបវាជាមួយត្រីមាសទីមួយកាលពីឆ្នាំមុន។

វាមានសារៈសំខាន់ដូចគ្នាដែរក្នុងការរាយការណ៍ព័ត៌មានអំពីតម្លៃផ្សារភាគហ៊ុន។ ចូរកុំគ្រាន់តែប្រាប់អ្នកអានអំពីតម្លៃថ្មីនៃទំនិញបរិភោគប្រើប្រាស់។ អ្នកគួរតែធ្វើការប្រៀបធៀបវាជាមួយនឹងតម្លៃចាស់ ដើម្បីឲ្យអ្នកអានដឹងថា តើវាមានភាពខុសគ្នាដូចម្តេចខ្លះ ហើយសាកល្បងគណនាមើលភាគរយដែលខុសគ្នា។

រាយការណ៍តែអំពីតួលេខមួយមុខ មិនទាន់គ្រប់គ្រាន់ទេ។ អ្នកចាំបាច់ត្រូវតែពន្យល់ផងដែរអំពីហេតុផលនៅពីក្រោយតួលេខ ដែលមានការប្រែប្រួលនោះ។ ហេតុអ្វីបានជាករណីឆ្លងវីរុស HIV មានការកើនឡើង? ហេតុអ្វីបានជាថវិកាឆ្នាំនេះកើនខ្ពស់ជាងឆ្នាំមុន? បើមិនមានចម្លើយទៅនឹងសំណួរទាំងនេះទេ តួលេខទាំងអស់នេះមិនមានន័យប៉ុន្មានទេ។

ចូរសាកអានរឿងមួយនេះ អំពីការផលិតស្រូវវដូវវស្សា ដែលបានចុះផ្សាយក្នុងកាសែតមួយនៅឡាវ ហើយចាំមើលថា តើលោកអ្នកមិនងោកងងុយដេកឬអត់ ៖

*ខេត្ត Houaphan បានដាំស្រូវបាន ៩.០០០ ហិកតា ដែលស្មើនឹង ៨០ ភាគរយ នៃផ្ទៃដីសរុប ខេត្ត Sayaboury ធ្វើបាន ១១.៧០០ ហិកតា ស្មើនឹង ៥៣,៩ ភាគរយនៃផ្ទៃដីសរុប ខេត្ត Phongsaly ធ្វើបាន ២.៣០០ ហិកតា ស្មើនឹង ៤០ ភាគរយ នៃផ្ទៃដីសរុប ខេត្ត Xieng Khuang ធ្វើបាន ១២,១៥៥ ហិកតា ស្មើនឹង ៨៥ ភាគរយ នៃផ្ទៃដីសរុប ខេត្ត Khammuan ធ្វើបាន ៣៥,៨០០ ហិកតា ស្មើនឹង ៥០ ភាគរយ នៃផ្ទៃដីសរុប ខេត្ត Savannakhet ធ្វើបាន ៨៥,០០០ ហិកតា ស្មើនឹង ៧៩ ភាគរយ នៃផ្ទៃដីសរុប ខេត្ត Saravan ធ្វើបាន ៣០,០០០ ហិកតា ស្មើនឹង ៦៤ ភាគរយ នៃផ្ទៃដីសរុប ខេត្ត Champasak ធ្វើបាន ៤៦,០០០ ហិកតា ស្មើនឹង ៥៦ ភាគរយ នៃផ្ទៃដីសរុប ខេត្ត Attapeu ធ្វើបាន ៨,០០០ ហិកតា ស្មើនឹង ៦០ ភាគរយ នៃផ្ទៃដីសរុប។*

ក្នុងនេះមានព័ត៌មានច្រើនជ្រុលហួសហេតុ។ វាប្រហែលជាប្រសើរជាង បើសិនជាដាក់តួលេខទាំងអស់នេះទៅលើតារាង ឬក្រាហ្វិកវិញ។

អ្នកប្រហែលជាប្រមូលបានទិន្នន័យច្រើនមែន ប៉ុន្តែអ្នកមិនចាំបាច់ផ្ទេរកំណត់ហេតុទាំងអម្បាលមាណ ដែលអ្នកមានក្នុងកូនសៀវភៅកំណត់ហេតុយកព័ត៌មានរបស់អ្នកដាក់ចូលទៅក្នុងរឿងទេ។ ប្រើតែតួលេខដែលសំខាន់ជាងគេទៅបានហើយ។ ពេលណាដែលអាចធ្វើទៅបាន ចូរប្រើលេខមូលតែម្តងទៅ។ ឧទាហរណ៍ ជាជាងសរសេរថា ប្រជាជនមានចំនួន ១១.២៣៥.៦៨៤ ចូរសរសេរថា "១១,២" លាននាក់វិញ។ ជាជាងនិយាយថា ក្នុងចំណោមទេសចរទាំងអស់ ៤៨.៧៥ ភាគរយ ជាជនជាតិជប៉ុន ចូរសរសេរថា "ជិតពាក់កណ្តាល" នៃអ្នកទេសចរទាំងអស់ជាជនជាតិជប៉ុន។

ពេលខ្លះ តួលេខពិបាកនឹងយល់ណាស់ដរាបណាយើងយកវាមកប្រៀបផ្ទឹមនឹងអ្វីមួយផ្សេងទៀត ដែលយើងអាចប្រមើលចេញជារូបភាព។



*សូមបង្ហាញ កុំប្រាប់*

ឧទាហរណ៍ ក្នុងដងខ្លួនមនុស្សមានសរសៃឈាម ដែលមានប្រវែងសរុបរាប់សិបពាន់គីឡូម៉ែត្រ។ ច្រើនមែន តែពិបាកនឹងប្រមើលជារូបភាពណាស់។ ចូរសាកល្បងសរសេរថា "ក្នុងដងខ្លួនមនុស្សមានសរសៃឈាមច្រើនណាស់ ដែលបើសិនជាគេយកវាមកតភ្ជាប់គ្នាតែមួយខ្សែ វាអាចព័ទ្ធជុំវិញផែនដីបានពីរជុំងណោះ"។ ធ្វើដូច្នេះ តួលេខក្លាយទៅជារូបភាពដែលងាយយល់ជាងមុន។

អ្នកយកព័ត៌មានម្នាក់ ត្រូវបានគេប្រាប់ថា សរសៃដែកក្នុងអគារធំមួយ ទ្រទម្ងន់ធ្ងន់របស់អគារ ហូតដល់បង្កើតបានជាកម្លាំងមួយ ដែលមានថាមពលស្មើនឹង ៨ លានផោន។ ប៉ុន្តែ តើកម្លាំង ៨ លានផោន មានន័យដូចម្តេច? គាត់បានសួរដូច្នេះទៅកាន់វិស្វករមួយរូប ដែលបានបកស្រាយថា "កម្លាំងបែបនោះ គឺវាប្រៀបបាននឹងទម្ងន់របស់រថយន្តចំនួន ២២០ ដាក់គរលើគ្នា"។ ការប្រៀបធៀបបែបនេះ អាចជួយឲ្យអ្នកអានយល់បានថា តើកម្លាំងនោះ វាខ្លាំងប៉ុណ្ណា។

## ចង្វាក់ចុងចួន និងចម្រុះភាព
## (Rhythm and Variety)

សំណេរល្អ គឺជាសំណេរដែលមានចង្វាក់ចុងចួន។

*First there was the Green Revolution.*
*Now comes the Gene Revolution.*

លោក ប៊ូ សារឿន ដែលជាអតីតអ្នកយកព័ត៌មានកាសែត Phnom Penh Post បានសរសេរសេចក្តីផ្តើមនេះសម្រាប់រឿងរបស់គាត់មួយ ដែលនិយាយអំពីការផ្លាស់ប្តូររបៀបធ្វើកសិកម្មនៅប្រទេសថៃ។

អានមួយភ្លែតទៅ វាប្រៀបបានដូចជាចង្វាក់ចុងចួនដូច្នោះឯង។ ឃ្លានីមួយៗមានទម្រង់ស្រដៀងគ្នា ដែលរំលេចឲ្យឃើញនូវភាពខុសគ្នា រវាងពាក្យពីរសំខាន់នោះ គឺរវាងពាក្យ green និង gene។ សេចក្ដីផ្ដើមនេះបានត្រួសត្រាយគន្លងសាច់រឿងមួយ ស្ដីអំពីស្បៀងអាហារ ដែលគេដាំដុះដោយប្រើគ្រាប់ពូជ ដែលត្រូវបានកែច្នៃជាលក្ខណៈវិទ្យាសាស្ត្រ។

មួយវិញទៀត វាមានសារៈសំខាន់ដែរក្នុងការតាក់តែងឃ្លាឲ្យមានប្រវែងខុសៗគ្នា។

វាមិនមែនជាប្រការមិនល្អនោះទេក្នុងការសរសេរឃ្លាវែង ដូចជាឃ្លានេះជាដើម ឲ្យតែវាមានលំហូរល្អ ហើយឲ្យតែវាផ្ដល់ដល់អ្នកអាននូវព័ត៌មានមានសារៈសំខាន់ និងជាទីចាប់អារម្មណ៍។ ប៉ុន្តែបន្ទាប់ពីឃ្លាវែង ចូរបន្តដោយប្រើឃ្លាខ្លីវិញភ្លាម។

# សូរស័ព្ទ

សូរស័ព្ទ (មានន័យសំដៅលើវេទនារម្មណ៍ ឬ ស្ទីល) នៃរឿងគួរតែមានលក្ខណៈសមរម្យដែរ។ បើអ្នកសរសេរអំពីគ្រោះថ្នាក់មួយដែលធ្វើឲ្យមនុស្សច្រើននាក់ស្លាប់បាត់បង់ជីវិត សូរស័ព្ទរបស់វាត្រូវតែមានលក្ខណៈម៉ឺងម៉ាត់។ បើសិនជាអ្នកសរសេរបទពិពណ៌នាអំពីបុរសម្នាក់លក់ស្វាកៅស៊ូ ដើម្បីចិញ្ចឹមជីវិត សូរស័ព្ទរបស់វាគួរមានលក្ខណៈស្រាល និងលំហែ។

# ការសរសេរឡើងវិញ

ពេលណាដែលអ្នកសរសេរចប់រឿងមួយ ចូរកុំអាលពេញចិត្តដោយងាយពេក។ មើលវាឡើងវិញ ហើយកែសម្រួលវាដោយតឹងរ៉ឹងបំផុត។ ចូរសួរខ្លួនឯងថា តើខ្ញុំសរសេរបានច្បាស់ទេ? តើខ្ញុំអាចសរសេរវាឲ្យកាន់តែងាយស្ដាប់បានទេ?

# សៀវភៅស្ទីល

ជារឿងធម្មតា ការសរសេរតែងមានកំហុសវេយ្យាករណ៍ និងការប្រកបពាក្យ។ ប៉ុន្តែពាក្យ និងសំណង់ឃ្លាខ្លះអាចមានជម្រើសជំនួស ហើយក៏មានវិធីផ្សេងៗគ្នាដែរក្នុងការប្រើវណ្ណយុត្តិ។ ដើម្បីឲ្យមានសង្គតិភាព អង្គភាពសារព័ត៌មានទាំងអស់ គួរតែមានកូនសៀវភៅវិធានមួយ ស្ដីអំពីក្រឹត្យក្រមក្នុងការប្រកបពាក្យ ការប្រើវណ្ណយុត្តិ តួលេខ ជាដើម។ ក្នុងការប្រណិបត្តិតាមសៀវភៅស្ទីល អ្នកយកព័ត៌មាន និងនិពន្ធនាយក នឹងសរសេរក្នុងរបៀបតែមួយ ហើយកាសែត ក៏មើលទៅមានសង្គតិភាព និងលក្ខណៈអាជីពដែរ។

*រឿងសាមញ្ញ តែគួរឲ្យធុញ*

# ជំពូកទី ១២
# សេចក្តីប្រកាសព័ត៌មាន

មានរឿងច្រើន ដែលត្រូវបានសរសេរចេញពីសេចក្តីប្រកាសព័ត៌មាន ដែលទទួលបានពីប្រភពផ្សេងៗ ក្នុងនោះ មានរដ្ឋាភិបាល ធុរកិច្ច អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារអន្តរជាតិ ដូចជាអង្គការសហប្រជាជាតិជាដើម។

ប៉ុន្តែក្នុងករណីភាគច្រើន អ្នកមិនគួរគ្រាន់តែសរសេរសេចក្តីប្រកាសព័ត៌មានឡើងវិញទេ។ អ្នកគួរតែចាត់វាទុកថា គ្រាន់តែជាចំណុចចាប់ផ្តើមប៉ុណ្ណោះ។ ប្រភពនានាតែងសរសេរសេចក្តីប្រកាសព័ត៌មាន ដើម្បីលើកតម្កើងខ្លួនគេ លើកតម្កើងកិច្ចការ បុព្វហេតុ ឬផលិតផលរបស់ពួកគេតែ



*តើរឿងនេះនិយាយអំពីធុរកិច្ចខ្នាតតូច ឬអំពីគ្រោះថ្នាក់ដល់សុខភាព ដោយសាការជក់បារី?*

ប៉ុណ្ណោះ។ ដូច្នេះ ជារឿយៗព័ត៌មានមិនទាន់ពេញលេញទេ ឬជាព័ត៌មានតមួយជ្រុង។ ឬបើមិនដូច្នោះទេ សេចក្តីប្រកាសព័ត៌មាននោះសរសេរមិនបានគ្រប់ជ្រុងជ្រោយ ខ្វះសេចក្តីពិស្តារដែលចាំបាច់ក្នុងការសរសេររឿង។

អ្នកសារព័ត៌មានចំណានតែងប្រើភាពច្នៃប្រឌិត និងជំនាញយកព័ត៌មាន ដើម្បីផលិតរឿងល្អចេញពីសេចក្តីប្រកាសព័ត៌មានធម្មតា។ គេព្យាយាមផ្តល់ដល់អ្នកអានរបស់គេនូវរូបភាពក្នុងសាច់រឿងឲ្យបានពេញលេញ ជាជាងសរសេររឿងដែលមានលក្ខណៈតែមួយជ្រុងនោះ។

បើអាចធ្វើទៅបាន អ្នកគួរទូរស័ព្ទទៅប្រភពសេចក្តីប្រកាសព័ត៌មាននោះ ដើម្បីសុំការស្រាយបំភ្លឺ ឬក៏សេចក្តីពិស្តារបែមទៀត។ ចូរប្រើពុទ្ធិ ឬការស្រាវជ្រាវរបស់ខ្លួនឯង ហើយថែមសារជាតិ និងបរិបទទៅនឹងប្រធានបទ ដែលបានលើកឡើងនៅក្នុងសេចក្តីប្រកាសព័ត៌មាននោះ។ ចូរស្វែងរកអត្ថាធិប្បាយពីអ្នកដទៃ ដែលអាចយល់ទាស់នឹងព័ត៌មាននៅក្នុងសេចក្តីប្រកាសនោះ ឬមួយជាអ្នកដែលអាចផ្តល់ទស្សនៈផ្សេងទៅវិញ។ បើសិនជាមានមនុស្សដែលនឹងទទួលរងផលប៉ះពាល់ ដោយសារប្រធានបទក្នុងសេចក្តីប្រកាសនោះ ចូរយកអត្ថាធិប្បាយពីគេផង។

សេចក្តីប្រកាសជាច្រើន ត្រូវបានសរសេរតាមភាសា ដែលមានលក្ខណៈការិយាធិបតេយ្យ និងបច្ចេកទេស។ ដូច្នេះ ចូរកុំភ្លេចសួរខ្លួនឯង និងប្រាប់ទៅអ្នកអានថា តើអ្វីដែលគេបានសរសេរមកហ្នឹងអាចយល់បានទេសម្រាប់មនុស្សទូទៅ?

ខាងក្រោមនេះជាចំណុចទាំងឡាយដែលអ្នកត្រូវចោទសួរខ្លួនឯង នៅពេលណាដែលនាយកនិពន្ធយកសេចក្តីប្រកាសមួយសន្លឹកមកទម្លាក់លើតុអ្នក ៖

- សួរខ្លួនឯងថា តើក្នុងសេចក្តីប្រកាសនោះមានអ្វីដែលជាព័ត៌មានថ្មី និងគួរឲ្យចាប់អារម្មណ៍?



*បញ្ហាសន្តិសុខស្បៀងនឹងនៅតែជារឿងមានសារៈសំខាន់*

- ឆែកព័ត៌មានឡើងវិញម្ដងទៀតថា តើវាទៀងត្រង់ត្រឹមត្រូវទេ ?
- អនុវត្តន៍រូបមន្ត 5Ws និង H ហើយមើលថានៅខ្វះអ្វីទៀត ?
- រកមុំចំណាប់អារម្មណ៍មនុស្ស
- ទូរស័ព្ទទៅបុគ្គលដែលមានឈ្មោះលើសេចក្ដីប្រកាសនោះ ដើម្បីសួរព័ត៌មានបន្ថែម
- សម្ភាសន៍ប្រភពដទៃទៀតរក " ជ្រុងម្ខាងទៀត " នៃរឿងមកសរសេរបំពេញបន្ថែម ។

ចូរក្រឡេកមើលសេចក្ដីប្រកាសមួយចំនួន ហើយគិតមើលថា តើយើងនឹងលៃលកជាមួយវាដោយវិធីណា ។

នៅទំព័របន្ទាប់នេះ គឺជាសេចក្ដីប្រកាសចេញពីភ្នាក់ងារមួយរបស់អង្គការសហប្រជាជាតិ ។ សេចក្ដីប្រកាសនេះ មានព័ត៌មានល្អមួយចំនួន ហើយដោយច្នៃវាតែបន្តិច អ្នកនឹងប្រក្លាយវាទៅជារឿងល្អមួយបាន ។

ជាបឋម អ្នកចាំបាច់ត្រូវទូរស័ព្ទទៅការិយាល័យរបស់កម្មវិធីស្បៀងអាហារពិភពលោក (World Food Program) ដើម្បីសុំការស្រាយបំភ្លឺមុននឹង

អ្នកអាចសរសេររឿងមួយឲ្យបានច្បាស់។ ឧទាហរណ៍ គេអាចចោទសួរថាតើប្រជាជនទាំង ៤០.០០០ នាក់នោះ បានទទួលអង្ករហើយ ឬនៅ? បើនៅទេ តើពេលណាទើបពួកគេនឹងទទួលបាន? តើពួកគេនៅខេត្តណា? តើភាគច្រើននៃពួកគេជាកសិករឬ? សេចក្តីប្រកាសនិយាយថា មានប្រជាជនជាង ៣០០.០០០ នាក់ បានភៀសខ្លួនចេញពីលំនៅដ្ឋានរបស់ខ្លួន ហើយកំពុងតែខ្វះស្បៀងអាហារ។ ដូច្នេះ តើបានន័យថាម៉េចទៅការដែលថា មនុស្ស ៤០.០០០ នាក់"ជាអ្នករងគ្រោះខ្លាំងជាងគេ" នោះ? នៅក្នុងកថាខណ្ឌចុងក្រោយគេពាក្យថា "ជួសជុលការខូចខាតដោយសារទឹកជំនន់នៅកម្រិតគ្រួសារ" “repairing flood damage at household level” និង"ធ្វើការស្តារយូរអង្វែងនូវហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន" “undertaking long-term rehabilitation of rural infrastructure” មានន័យដូចម្តេច? អ្នកចាំបាច់ត្រូវដឹងការស្រាយបំភ្លឺទាំងនេះ ដើម្បីអ្នកអាចយកទៅពន្យល់ប្រាប់អ្នកអានបាន។

## *សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី ៧ កញ្ញា*

## *កម្មវិធីស្បៀងអាហារពិភពលោក បញ្ជូនស្បៀងទៅចែកជូនអ្នករងគ្រោះទឹកជំនន់ ៤០.០០០ នាក់ នៅកម្ពុជា*

*ភ្នំពេញ - ដោយមានទឹកជំនន់ថ្មីមួយកំពុងគំរាមកំហែងដល់ប្រទេសកម្ពុជា កម្មវិធីស្បៀងអាហារពិភពលោក នៃអង្គការសហប្រជាជាតិបានបញ្ជូនស្បៀងសង្គ្រោះបន្ទាន់ទៅចែកដល់ប្រជាជនប្រមាណ ៤០.០០០ នាក់ ដែលផ្ទះ និងស្បៀងបម្រុងរបស់ពួកគេ ត្រូវបានលិចលង់ ឬក៏ត្រូវបានទឹកហូរយកទៅបាត់អស់។*

*នៅក្នុងដំណាក់កាលឆ្លើយតបបន្ទាន់ទៅនឹងវិបត្តិនេះ កម្មវិធីស្បៀងអាហារពិភពលោកកំពុងបញ្ជូនអង្ករ ៥០០ តោន - ដែលបរិមាណនេះ វាសមល្មមនឹងសម្រាប់អង្ករទទួលបានម្នាក់ៗ ហូបបានមួយខែ - ទៅចែកជូនជនកម្ពុជា ដែលត្រូវបានមន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយកម្ពុជាចាត់ទុកថាជាក្រុមទទួលរងគ្រោះទឹកជំនន់ធ្ងន់ធ្ងរជាងគេ។ ព្រមពេលជាមួយគ្នានេះដែរ ទីភ្នាក់ងារនេះកំពុងធ្វើប្រតិបត្តិការមួយ ដើម្បីវាយតម្លៃសេចក្តីត្រូវការស្បៀងនៅក្នុងតំបន់លិចទឹកនានា ដើម្បីបើកយុទ្ធនាការធំជាងនេះទៅថ្ងៃមុខ បើសិនជាមានការចាំបាច់។*

*អ្នកស្រី Rebecca Hansen ប្រធានការិយាល័យកម្មវិធីស្បៀងអាហារពិភពលោកនិយាយថា "យើងត្រូវតែត្រៀមខ្លួនសម្រាប់ទឹកជំនន់ថ្មីទៀត ក្នុងវេលានេះនៃឆ្នាំ"។ អ្នកស្រីធ្វើការកត់សម្គាល់ថា អង្ករទាំង ៥០០ តោននេះ បានមកពីមូលនិធិសម្រាប់ផែនការបន្ទាន់ ដែលអនុញ្ញាតឲ្យកម្មវិធីស្បៀងអាហារពិភពលោក អាចឆ្លើយតបបានភ្លាមៗក្នុងរយៈពេល ២៤ ម៉ោង ទៅនឹងការសង្គ្រោះជនរងគ្រោះពីមហន្តរាយ។*

*អ្នកស្រី Hansen និយាយបន្ថែមថា "យើងមានការខ្វល់ខ្វាយ ដោយសារថាប្រជាជនដែលត្រូវការជំនួយនេះ ទើបតែនឹងបញ្ចប់ការកសាងសហគមន៍របស់ពួកគេឡើងវិញក្នុងពេលថ្មីៗកន្លងមកនេះ បន្ទាប់ពីមានទឹកជំនន់ធំមួយនៅតំបន់ដីសណ្តទន្លេមេគង្គកាលពីឆ្នាំមុន។ ជីវភាពរបស់ពួកគេងាយផុយស្រួយខ្លាំងណាស់នឹងទ្រាំទ្រជាមួយនឹងសភាពការណ៍គួរឲ្យរន្ធត់នេះ"។*

*មានមនុស្សជាង ៣០០.០០០ នាក់ នៅប៉ែកបូព៌ា និងខាងត្បូងប្រទេសកម្ពុជា ដែលត្រូវបានគេជន្លៀស*

*ចេញពីផ្ទះរបស់ពួកគេ ហើយពួកគេកំពុងរងទុរ្ភិក្ស ខ្វះស្បៀងអាហារ។ មន្ត្រីរដ្ឋាភិបាលទទួលបន្ទុកចាត់ចែងគ្រោះមហន្តរាយបានប្រមាណថា មានមនុស្ស ១,២ លាននាក់ ដែលទទួលរងការប៉ះពាល់តិចក្តីច្រើនក្តីពីសំណាក់ទឹកជំនន់នេះ។*

*កាលពីឆ្នាំមុន ទឹកជំនន់ដ៏ចម្លែកមួយនៅតំបន់ទន្លេមេគង្គ ដែលបានបំផ្លាញផ្ទះអស់រាប់ពាន់ខ្នង និងស្រូវរបស់កម្ពុជាអស់ជាង ២០០.០០០ ហិកតា។ ក្នុងគ្រោះមហន្តរាយធម្មជាតិមួយនេះ - ដែលមានសភាពអាក្រក់បំផុតនៅក្នុងតំបន់ ក្នុងរយៈពេល ៧០ ឆ្នាំកន្លងមកនេះ - មានមនុស្ស ៣៤៧ នាក់ស្លាប់ ដែលក្នុងនោះ ៨០ ភាគរយ ជាកុមារ។*

*ឆ្នាំនេះប្រទេសកម្ពុជា ត្រូវបានឡោមព័ទ្ធទៅដោយទឹកជំនន់ផង និងភាពរាំងស្ងួតផង នៅតាមតំបន់ផ្សេងៗគ្នា។ ឧប្បត្តិហេតុធម្មជាតិផ្ទួនៗគ្នានេះ បានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់សន្តិសុខស្បៀងនៅកម្ពុជា ដែលជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្របំផុតនៅអាស៊ី។*

*កម្មវិធីស្បៀងអាហារពិភពលោក កំពុងបញ្ចប់ប្រតិបត្តិការសង្គ្រោះបន្ទាន់រយៈពេលមួយឆ្នាំ ដែលមានតម្លៃទឹកប្រាក់ ៩ លានដុល្លារអាមេរិក នៅក្នុងប្រទេសកម្ពុជា ដោយបានធ្វើការចែកចាយស្បៀងសង្គ្រោះបន្ទាន់ទៅដល់ប្រជាជន ៥០០.០០០ នាក់ នៅក្នុងវគ្គទីមួយនៃប្រតិបត្តិការ មុនមានវគ្គទីពីរ ដែលក្នុងនោះ មានប្រជាជន ២៥០.០០០ នាក់ ទទួលជំនួយស្បៀងអាហារសម្រាប់ការជួសជុលការខូចខាតដោយទឹកជំនន់ក្នុងកម្រិតគ្រួសារ។ ក្នុងវគ្គទីបី ដែលគេរំពឹងថានឹងចប់ក្នុងខែនេះ មនុស្ស ១១៥.០០០ នាក់ ទទួលបានស្បៀងអាហារសម្រាប់ការងារស្តាររយៈពេលយូរអង្វែងនូវហេដ្ឋារចនាសម្ព័ន្ធជនបទ។*

បើមានសេចក្តីពិស្តារថែមទៀត វានឹងធ្វើឲ្យរឿងកាន់តែរឹងមាំថែមទៀត។ តើពេលណាទឹកជំនន់ថ្មីអាចនឹងមកដល់ទៀត? តើភ្លៀងធ្លាក់ហើយ ឬនៅ?

សេចក្តីប្រកាសព័ត៌មាននេះ មានសម្រង់សម្តីដើមដ៏មានទម្ងន់មួយពីលោកស្រី Hansen ដែលអ្នកអាចប្រើបាន។ អ្នកអាចសួរគាត់ឲ្យផ្តល់សេចក្តីពិស្តារថែមទៀត ដែលនឹងធ្វើរឿងឲ្យកាន់តែរឹងមាំឡើង។ ឧទាហរណ៍ តើលោកស្រីបានទៅមើលតាមមូលដ្ឋាន ដែលប្រជាជនទើបតែនឹងបញ្ចប់ការសង់ផ្ទះឡើងវិញ ឬទេ? តើលោកស្រីបានឃើញអ្វីខ្លះ? តើប្រជាជនទាំងនោះនឹងធ្វើអ្វីទៅ បន្ទាប់ពីពួកគេអស់របបស្បៀងក្នុងរយៈពេលមួយខែនេះ? តើមានអ្វីដែលអាចធ្វើបាន ដើម្បីជួយពួកគេឲ្យគេចផុតពីផលប៉ះពាល់ ដោយសារទឹកជំនន់នៅពេលអនាគត? ឬមួយក៏ការផ្តល់ជំនួយស្បៀងជាកិច្ចការតែមួយមុខ ដែលអង្គការសហប្រជាជាតិអាចធ្វើបាន?

អ្នកក៏អាចទូរស័ព្ទទៅសួរមន្ត្រីអង្គការក្រៅរដ្ឋាភិបាល ឬមន្ត្រីរដ្ឋាភិបាល ដែលពួកគេបានធ្វើការជាមួយជនរងគ្រោះធ្ងន់ធ្ងរបំផុត។ សួរពួកគេថា តើពួកគេបានឃើញអ្វីខ្លះពេល ដែលពួកគេទៅមើលជនរងគ្រោះទាំងនោះ។ តើពួកគេយល់ឃើញដូចម្តេចដែរ អំពីការឆ្លើយតបរបស់កម្មវិធីស្បៀងអាហារពិភពលោកទៅនឹងវិបត្តិនេះ? តើជំនួយនោះគ្រប់គ្រាន់ទេ? តើវាជាប្រភេទជំនួយដែលត្រូវនឹងសភាពការណ៍នោះទេ? តើជំនួយនោះ គួរត្រូវបានផ្តល់ឆាប់ជាងនេះទេ? ចូរចាំថា នេះជាសេចក្តីប្រកាសពីកម្មវិធីស្បៀងអាហារពិភពលោក ដែលស្រដៀងគ្នានឹងអង្គការដទៃទៀតដែរ មានគោលគំនិតរបស់ខ្លួន ហើយនឹងនិយាយតែល្អអំពីខ្លួនឯងតែប៉ុណ្ណោះ។ ក្នុងនាមជាអ្នកសារព័ត៌មាន ការងាររបស់អ្នក គឺផ្តល់ឲ្យអ្នកអាននូវបំណុចទស្សនៈខុសៗគ្នា។

រឿងរបស់អ្នកពិតជានឹងកាន់តែគួរចាប់អារម្មណ៍ថែមទៀត ប្រសិនបើអ្នកទៅជួបសួរនាំជាមួយមនុស្សក្នុងចំណោមមនុស្សទាំង ៤០.០០០ នាក់នោះ

ហើយធ្វើការពិពណ៌នាអំពីអារម្មណ៍ និងស្ថានភាពរស់បច្ចុប្បន្នរបស់ពួកគេផង។ តើពួកគេ ត្រូវរស់ដោយរបៀបណាទៅ? តើពួកគេមានអារម្មណ៍យ៉ាងណាចំពោះលទ្ធភាពថា អាចនឹងមានទឹកជំនន់ថ្មីមួយទៀត? អ្នកអាចចាប់ផ្តើមរឿង ដោយរៀបរាប់អំពីនរណាម្នាក់ដែលទទួលរងទុក្ខពិតប្រាកដ ដែលអាចធ្វើឲ្យអ្នកអានអាចរំលែកសមានចិត្តជាមួយបាន។ ធ្វើដូច្នេះ វាខ្លាំងជាងផ្តើមរឿងដោយសេចក្តីប្រកាសអំពីប្រតិបត្តិការចែកអង្ករទៅទៀត។

ជួនកាល អ្នកមិនទាន់មានពេលទៅមើលកន្លែងដែលរងទឹកជំនន់ទេ។ ឬមួយក៏អ្នកមានអារម្មណ៍ថាអ្នកត្រូវតែសរសេរអំពីប្រតិបត្តិការរបស់កម្មវិធីស្បៀងអាហារពិភពលោកភ្លាមៗ ដោយសារថាកាសែតឯទៀត នឹងសរសេររឿងនេះក្នុងពេលនេះដែរ។ ក្នុងករណីនេះ សាកជជែកជាមួយប្រភពនានាតាមទូរស័ព្ទ ហើយសរសេររឿងជាមួយនឹងអ្វីដែលអ្នកមានមុនសិនទៅ។ បន្ទាប់មក ចូរធ្វើដំណើរទៅកាន់កន្លែងរងគ្រោះដោយសារទឹកជំនន់ ដើម្បីសរសេរបទពិពណ៌នាពីទីកន្លែងកើតហេតុតែម្តង។

ខាងក្រោមនេះ ជាសេចក្តីប្រកាសព័ត៌មានមួយទៀតពីអាជ្ញាធរទេសចរណ៍របស់ថៃ ៖

# *សេចក្តីប្រកាសព័ត៌មាន*

## *ទេសចរកើនដល់ប្រាំលាននាក់ក្នុងរយៈពេលប្រាំមួយខែដំបូង*

*បាងកក, ប្រទេសថៃ ថ្ងៃទី ១១ កញ្ញា - ដំណើរមកដល់ប្រទេសថៃនៃទេសចរបរទេសក្នុងអំឡុងខែមករា ដល់ខែមិថុនា មានសរុប ៥.០០៣.៦៩១ នាក់ ដែលកើន ៧,៨៦ ភាគរយ ប្រៀបទៅនឹងរយៈពេលដូចគ្នានេះក្នុងឆ្នាំ ២០០០។*

*ចំនួនទេសចរមកពីផ្សារធំៗ រួមមាន ពីអាស៊ីបូព៌ា (២.៩៨៦.៧០៣នាក់) អ៊ឺរ៉ុប (១.១៧៥.៤៣៦នាក់) ទ្វីបអាមេរិក (៣២៦.៧៨៧ នាក់) ទ្វីបអូសេអានី (២០០.៤០៧ នាក់) អាស៊ីខាងត្បូង (១៧២.២៤៧ នាក់) មជ្ឈិមបូព៌ា (៩៩.៥៨១ នាក់) និងអាហ្វ្រិក (៤២.៥៣០ នាក់)។*

*តំបន់ទីផ្សារទាំងអស់ សុទ្ធតែបានបង្ហាញកំណើនខ្លាំង។ ការមកដល់របស់ភ្ញៀវពីអាស៊ីបូព៌ាកើន ៦,០៩ ភាគរយ ពីទ្វីបអឺរ៉ុប ៨,៥៨ ភាគរយ ពីទ្វីបអាមេរិក ១២,៩៦ ភាគរយ ទ្វីបអូសេអានី ១៦,៥៨ ភាគរយ អាស៊ីខាងត្បូង ៦,៣៨ ភាគរយ មជ្ឈិមបូព៌ា ២២,៥២ ភាគរយ និងអាហ្វ្រិក ១៥,០២ ភាគរយ។*

*លោក Pradech Phayakvichien អភិបាលអាជ្ញាធរទេសចរណ៍ថៃបានអធិប្បាយថា "យើងមានសេចក្តីរីករាយក្រៃលែង ដោយបានឃើញនូវកំណើនខ្លាំង ដូច្នេះមកពីផ្សារធំៗរបស់យើង ដោយសារមានការគាំទ្ររឹងមាំពីសំណាក់រដ្ឋាភិបាល និងសហប្រតិបត្តិការពីសំណាក់សាធារណជន និងសាខាឯកជន និងវិស័យនានា"។*

*ភ្ញៀវជប៉ុនជាប្រភពផ្សារធំជាងគេបង្អស់ ដែលមានចំណែក ១២,២៣ ភាគរយ (ឬ ៦១១.៩០២ នាក់) នៃចំនួនភ្ញៀវបរទេសសរុប ដែលមកកាន់ប្រទេសថៃក្នុងអំឡុងដំណាក់កាលនេះ។ ចំនួនខ្ពស់បន្ទាប់ គឺជនជាតិម៉ាឡេស៊ី (១០,២៧ ភាគរយ ឬ ៥១៤.១២២ នាក់) តៃវ៉ាន់ (៧,៤៤ ភាគរយ ឬ ៣៧២.០៧០ នាក់) ចិន (៦,៧៧ ភាគរយ ឬ ៣៣៨.៥៧៨ នាក់) និងសឹង្ហបូរី (៦,៥៣ ភាគរយ ឬ ៣២៦.៧៥៧ នាក់)។*

*ក្នុងរយៈពេល ខែមករា ដល់ខែមិថុនា នេះដែរ ចំនួនទេសចរនារីបានកើន ៨.៦ ភាគរយ (ដល់ ២.០០៥.៩៥៧ នាក់) ដែលនេះជាកំណើនខ្ពស់ជាងកំណើន ៧,៣៧ ភាគរយ (២.៩៩៧.៧៣៤ នាក់) នៃទេសចរបុរស។*

*ភ្ញៀវដដែលៗមានសរុប ៥២,៩៤ ភាគរយ (ឬ ២.៦៤៨.៩៦៧ នាក់) នៃចំណែកទីផ្សារទាំងអស់ ហើយបានបង្ហាញឲ្យឃើញកំណើនល្អក្នុងចំនួន ២០,៨៤ ភាគរយ នៅពេលដែលភ្ញៀវលើកទីមួយធ្លាក់ចុះបន្តិចជិត ៣,៧៧ ភាគរយ (សរុប ២.៣៥៤.៧២៤ នាក់។ ភ្ញៀវដែលធ្វើដំណើរម្នាក់ឯង មានចំណែកទីផ្សារច្រើនបន្តិចដែរក្នុងចំនួន ៥៨,៧២ ភាគរយ (ឬ២.៩៣៧.៩៧១ នាក់) នៃចំនួនភ្ញៀវសរុប ហើយកើនជិត ១៣,៣០ ភាគរយលើសឆ្នាំមុន ដែលជាកំណើនមួយខ្ពស់ជាងកំណើន ០,៩៦ ភាគរយ ក្នុងចំណោមភ្ញៀវដែលធ្វើដំណើរជាផ្នែកនៃទេសចរក្រុម (២.០៦៥.៧២០ នាក់)។*

*អ្នកធ្វើដំណើរធុរកិច្ច និងប្រតិភូសន្និសីទកើនបន្តិច ប្រហែល ៣,៦៩ ភាគរយ ឬ ៤៤១.៣៣៩នាក់ និង ០,៩៩ ភាគរយ ឬ ៤៥.៣២៨ នាក់ តាមលំដាប់លំដោយ។*

*តាមចំណាត់ថ្នាក់វ័យ ភាគច្រើននៃភ្ញៀវមកប្រទេសថៃ មានអាយុរវាង ២៥ ទៅ ៣៤ ឆ្នាំ (មានចំនួន ២៦,៧៣ ភាគរយ ឬ ១.៣៣៧.៤៥៨ នាក់នៃចំនួនភ្ញៀវសរុប) និង ៣៥ ទៅ ៤៤ ឆ្នាំ (២៤,០៦ ភាគរយ ឬ ១.២០៣.៩៥៧ នាក់)។*

*កុមារវ័យក្រោម ១៥ ឆ្នាំ និងភ្ញៀវវ័យចាស់ ៦៥ ឆ្នាំ និងលើសពីនេះ ក៏បង្ហាញឲ្យឃើញនូវកំណើន ៦,៧៣ ភាគរយ និង ៦,៥៥ ភាគរយ តាមលំដាប់លំដោយផងដែរ ដែលនេះចង្អុលបង្ហាញនូវកម្លាំងរបស់ប្រទេសថៃជាគោលដៅមួយសម្រាប់គ្រួសារ និងនិវត្តន៍ជនមកកំសាន្ត។ កំណើនខ្លាំងមួយចំនួន ១១,០៨ ភាគរយ ក្នុងចំណោមនិស្សិតធ្វើដំណើរ ក៏បង្ហាញឲ្យឃើញដែរថា មុខមាត់ប្រទេសក៏កំពុងតែផ្លាស់ប្ដូរជាវិជ្ជមានដែរ។*

*រយៈពេលស្នាក់នៅជាមធ្យមកើនពី ៨ ថ្ងៃ ពីខែមករា ដល់ ខែមិថុនា ឆ្នាំមុន ទៅដល់ ៨,១១ ថ្ងៃ ក្នុងអំឡុងខែមករា និងខែមិថុនា ឆ្នាំនេះ។ កំណើននេះ ឆ្លើយតបទៅនឹងការខិតខំរបស់អាជ្ញាធរទេសចរណ៍ថៃក្នុងការលើកទឹកចិត្តទេសចរឲ្យស្នាក់នៅបានយូរបន្តិច។*

*រីឯផ្សារទេសចរចេញក្រៅប្រទេសវិញ ចំនួនទេសចរថៃធ្វើដំណើរទៅក្រៅស្រុក មានសរុប ១.០៧២.៤៧៩ នាក់ ក្នុងចន្លោះខែមករា ដល់មិថុនា ដែលនេះជាកំណើន ៩,០៣ ភាគរយ ពីលើចំនួនក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។*

*អាជ្ញាធរទេសចរណ៍ថៃបានព្យាករណ៍ទុកថា ចំនួនភ្ញៀវមកដល់ប្រទេសថៃនឹងមានសរុបប្រហែល ១០,៣ លាននាក់ ក្នុងឆ្នាំនេះ កើនប្រហែល ៨,៣២ ភាគរយ ហើយដែលនឹងនាំមកនូវចំណូលប្រមាណ ៣២០.១២៤ ពាន់លានបាត ដល់សេដ្ឋកិច្ចរបស់ប្រទេស។*

**ទាក់ទងការិយាល័យដំណឹងបរទេស**
**ទូរស័ព្ទ ៖ ៦៦២ ៦៩៤-១២២២**
**លេខបន្ត ១៥៤០-៣**
**ផ្នែកទាក់ទងសាធារណៈ**
**ទូរសារ ៖ ៦៦២ ៦៩៤-១៣២៥**
**អ៊ីម៉េល ៖ prdiv3@tat.or.th**

សេចក្ដីប្រកាសមួយនេះ មិនខុសគ្នាពីបញ្ជីស្ថិតិមួយទេ។ ប៉ុន្តែបើយើងពិនិត្យឲ្យជិតដល់បន្តិច និងទូរស័ព្ទមួយពីរថែមទៀត យើងអាចនឹងផលិតរឿងមួយល្អបាន។

ជាបឋម សេចក្ដីប្រកាសនេះមិនបានឆ្លើយសំណួរជាមូលដ្ឋានដែលបានលើកឡើងក្នុងឃ្លាដំបូងបង្អស់នោះទេ ៖ ថាហេតុអ្វីបានជាចំនួនទេសចរកើនជាពិសេសមកពីតំបន់មជ្ឈិមបូព៌ា អូសេអានី និងអាហ្វ្រិក? មន្ត្រីណាមួយនៅអាជ្ញាធរទេសចរ ពិតជាអាចឆ្លើយនឹងសំណួរនេះបាន។

អ្នកក៏ប្រហែលជាចង់សួរផងដែរថា តើតួលេខពីខែមករា ដល់ ខែមិថុនា ឆ្នាំនេះ មានលក្ខណៈដូចម្ដេចដែរ បើប្រៀបទៅនឹងឆ្នាំមុនៗផ្សេងទៀត មិនមែនត្រឹមតែឆ្នាំកន្លងទៅនេះទេ។ តើវាជាចំនួនសរុបខ្ពស់បំផុតមិនដែលមានឬ? តើមានប៉ុន្មានភាគរយក្នុងចំណោមភ្ញៀវទាំងអស់នោះ ដែលជាទេសចរ ធៀបទៅនឹងភ្ញៀវធុរកិច្ច និងមនុស្សដទៃទៀត? តំបន់អាមេរិក និងអូសេអានី មិនមែនជាវាក្យស័ព្ទដែលមនុស្សទូទៅប្រើនោះទេ? តើគេសំដៅទៅទីណា?

សម្រង់សម្ដីដើមពីប្រធានអាជ្ញាធរទេសចរណ៍ថៃ មិនសូវជាគួរឲ្យចាប់អារម្មណ៍ប៉ុន្មានទេ។ វាគ្រាន់តែជាការដែលរដ្ឋាភិបាលនិយាយសរសើរខ្លួនឯងតែប៉ុណ្ណោះ។ ដូច្នេះ អ្នកគួរតែស្វែងរកសំដីដើមណាមួយល្អពីប្រភពណាមួយ ដែលអ្នកនឹងទូរស័ព្ទទៅសុំព័ត៌មានបន្ថែម។

នៅឯខាងចុងសេចក្ដីប្រកាសព័ត៌មាន ទើបមានអ្វីម៉្យាងដែលគួរឲ្យចាប់អារម្មណ៍។ នោះ គឺក្មេងមនុស្សចាស់ និងសិស្សកាន់តែច្រើនឡើង បានមកទស្សនាប្រទេសថៃ។ នេះចង្អុលបង្ហាញថា "មុខមាត់ប្រទេសកំពុងមានការប្រែប្រួលជាវិជ្ជមាន"។ អ្នកប្រហែលជាដឹងហើយថា ប្រទេសថៃល្បីឈ្មោះក្នុងការទាក់ទាញភ្ញៀវបុរសបានច្រើនជាងភ្ញៀវនារី។ អ្នកប្រហែលជាចង់សួរទៅកាន់មន្ត្រីរបស់ភ្នាក់ងារទេសចរណ៍ថា បើសិនជានេះ គឺអ្វីដែលគេនិយាយសំដៅទៅលើ តើមុខមាត់របស់ប្រទេសវានឹងផ្លាស់ប្ដូរដោយដូចម្ដេច និងដោយហេតុអ្វី?

ហើយអ្នកក៏ប្រហែលជាចង់សួរទៅកាន់អ្នកវិភាគក្រៅរដ្ឋាភិបាលដែរថា តើទម្រង់រូបភាពភ្ញៀវមកកាន់ប្រទេសថៃ មានការប្រែប្រួលមែនឬ។ ហេតុអ្វីបានជាមានទេសចរក្មេង ចំណាស់ និងនិស្សិត មកលេងប្រទេសថៃកាន់តែច្រើនឡើង? អ្នកអាចចោទសំណួរនេះ ទៅកាន់ក្រុមហ៊ុនទេសចរឯកជន អ្នកវិភាគទេសចរ ស្ថាប័នហិរញ្ញវត្ថុ និងអ្នកផ្សេងទៀត។

ជួនកាលពួកគេអាចនិយាយថា និន្នាការមិនមែនវិជ្ជមានដូចដែលសេចក្ដីប្រកាសបានលើកឡើងនោះទេ។ ឬមួយក៏សេចក្ដីប្រកាសនោះបានរំលងចោលនូវការណ៍សំខាន់ណាមួយផងក៏មិនដឹង។ ឬមួយក៏ពួកគេអាចឯកភាពជាមួយនឹងការលើកឡើងក្នុងសេចក្ដីប្រកាសនោះ ហើយផ្ដល់អត្ថាធិប្បាយដែលអាចយកមកប្រើការបានក្នុងរឿងផងដែរ។ ធ្វើដូច្នេះ វានឹងធ្វើឲ្យរឿងរបស់អ្នកកាន់តែខ្លាំង ហើយពេញលេញជាងមុនផង។

មួយទៀត ប្រសិនបើអ្នកអាចរកឃើញក្មេង មនុស្សចំណាស់ និងនិស្សិតខ្លះក្នុងចំណោមទេសចរនោះ ដើម្បីសួរនាំអំពីការទាក់ទាញរបស់ប្រទេសថៃ ហើយថាហេតុអ្វីបានជាពួកគេមកទស្សនាប្រទេសនេះ នោះអ្នកអាចនឹងបញ្ចូលទៅក្នុងសាច់រឿងនូវមនុស្សពិតៗ ជាជាងការគ្រាន់តែសរសេរផ្អែកលើស្ថិតិ និងការវិភាគ។

# ជំពូកទី ១៣ ការយកព័ត៌មាន អំពីកិច្ចប្រជុំ សុន្ទរកថា សន្និសីទព័ត៌មាន

អង្គភាពសារព័ត៌មាននានា បានរឿងភាគច្រើនពីកិច្ចប្រជុំ សុន្ទរកថា និងសន្និសីទព័ត៌មាន។ ក្នុងករណីទាំងអស់ អ្នកយកព័ត៌មាន ជាបឋមត្រូវត្រៀមខ្លួនដោយព្យាយាមស្វែងយល់អំពីបញ្ហាដែលគេនឹងលើកឡើង និងអំពីវាគ្មិនពាក់ព័ន្ធ។ មានតែធ្វើដូច្នេះទេ ទើបអ្នកយកព័ត៌មានអាចសួរនូវសំណួរល្អៗ និងផ្តល់ជូនអ្នកអាននូវអត្ថបទរឿង ដែលច្បាស់លាស់ និងមានលក្ខណៈពេញលេញបាន។

## កិច្ចប្រជុំ

បើសិនជារដ្ឋាភិបាល ឬស្ថាប័នធ្វើសេចក្តីសម្រេចចិត្តនយោបាយណាមួយ បើកការប្រជុំ ចូរផ្តោតលើវិធានការដែលគេបានប្រកាន់យក និងផលប៉ះពាល់ ដែលអាចកើតមានទៅលើមនុស្សម្នាទូទៅ។ តើមានការបោះឆ្នោតសម្រេចទេ? តើគណៈកម្មាធិការមានបានសម្រេចផ្តល់ជាអនុសាសន៍ឲ្យមានការតម្លើងប្រាក់បៀវត្សរ៍ឲ្យគ្រូបង្រៀនទេ? ឬមួយ ដើម្បីតម្លើងពន្ធលើហាងទំនិញ? ឬមួយក៏អនុម័តថវិកាថ្មី? បើមិនមានចំណាត់ការវិធានការអ្វីទេ ចូរផ្តោតទៅលើថាហេតុអ្វីបានជាមិនមានការចាត់វិធានការអ្វីមួយ ឬមួយក៏ផ្តោតទៅលើការជជែកដេញដោល ដែលកើតមានក្នុងកិច្ចប្រជុំនោះ។

នៅក្នុងរឿងស្តីពីកិច្ចប្រជុំ គួរមាន ៖

- អ្នកណាខ្លះចូលប្រជុំ
- គោលបំណងនៃកិច្ចប្រជុំ
- តើវិធានការអ្វី ត្រូវបានគេប្រកាន់យក
- ហេតុអ្វីបានជាគេសម្រេចប្រកាន់យកវិធានការនោះ
- អត្ថាធិប្បាយពីសំណាក់អ្នកចូលរួមប្រជុំ ឬអ្នកសង្កេតការណ៍
- តើអ្នកណាខ្លះដែលនឹងទទួលផលប៉ះពាល់ពីសំណាក់វិធានការ និងការអត្ថាធិប្បាយ
- ប្រសិនបើគ្មានវិធានការណាមួយត្រូវបានគេប្រកាន់យកទេ តើមានការព្រមព្រៀងជាទូទៅណាមួយទេថា គេគួរតែប្រកាន់យកវិធានការមួយ?
- ប្រសិនបើគ្មានវិធានការណាមួយ ត្រូវបានគេប្រកាន់យកទេ តើមាននរណាម្នាក់និយាយអ្វីសំខាន់ ឬគួរជាទីចាប់អារម្មណ៍ទេ?
- រំលឹកសាវតារអំពីបញ្ហានេះ

សេចក្តីផ្តើមខាងក្រោមពីកាសែតភាសាឡាវមួយប្រាប់យើងថា អ្នកណាខ្លះចូលរួមកិច្ចប្រជុំ និងប្រធានបទទូទៅ ដែលពួកគេបានពិភាក្សា។ ប៉ុន្តែវាមិនបានប្រាប់យើងទេថា តើពីគេអ្នកចូលរួមក្នុងកិច្ចប្រជុំនោះ បាននិយាយអ្វីខ្លះអំពីប្រធានបទនោះ។ នេះជាកំហុសមួយដែលគេតែងប្រទះឃើញក្នុងចំណោមអ្នកសារព័ត៌មានអាស៊ីអាគ្នេយ៍។

*លោកវរៈសេនីយឯក Bouasieng Champaphanh ប្រធានអនុកម្មការ និងលោកឧត្តមសេនីយទោ Serirath Thinrath លេខាអនុកម្មការថៃ បានរួមគ្នាជជែកគ្នាអំពីស្ថានការណ៍នៅ Vang Tao ដែលបានកើតឡើងនៅថ្ងៃទី ៣ កក្កដា ទៅកាន់ក្រុមអ្នកសារព័ត៌មានឡាវ និងថៃ ក្នុងអំឡុង*

ពេលសន្និសីទគណៈកម្មធិការរក្សាសន្តិសុខ ថៃ-ឡាវ។

ទាល់តែអានមកដល់ខាងចុងនៃរឿង ទើបយើងដឹងបានបន្តិចអំពីស្ថានការណ៍នោះ។ "ក្រុមចោរប្រដាប់អាវុធ" បានធ្វើការវាយប្រហារទៅលើប៉ុស្តិ៍យាមព្រំដែនមួយ ហើយចាប់មន្ត្រីគយធ្វើចំណាប់ខ្មាំងទៀតផង។ លោកវរៈសេនីឯកឡាវនិយាយថា ទាហានឡាវ និងថៃ ឥឡូវនេះកំពុងសហការគ្នាដើម្បីរក្សាសន្តិភាពនៅតាមព្រំដែន។ ព័ត៌មាននោះគួរតែត្រូវបានគេយកទៅដាក់ក្នុងសេចក្តីផ្តើមវិញ។ ខាងក្រោមនេះជាអត្ថបទទាំងស្រុងមួយទៀតស្តីអំពីរឿងកិច្ចប្រជុំ ដែលត្រូវបានដកស្រង់ចេញពីកាសែតភាសាអង់គ្លេសរបស់ឡាវមួយ ៖

## *យុវនារីកាន់តែច្រើនជក់បារី*

*នៅក្នុងកិច្ចប្រជុំមួយ ដើម្បីរៀបចំគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងថ្នាំជក់នៅប្រទេសឡាវ ដែលបានធ្វើឡើងនៅសណ្ឋាគារ The Lao Plaza Hotel លោកវេជ្ជបណ្ឌិត Somchai Pholseena ប្រធានមណ្ឌលអប់រំព័ត៌មានអំពីសុខភាព និយាយថា ចំនួនយុវវ័យជក់បារី ជាពិសេសក្នុងចំណោមយុវនារី មានការកើនឡើងច្រើន។*

*កិច្ចប្រជុំនេះបានទទួលការគាំទ្រពីសំណាក់អង្គការ Advantist Development Relief Agency (ADRA) និងមានមនុស្ស ៤០ នាក់ពីក្រសួងសុខាភិបាល និងនាយកដ្ឋានពាក់ព័ន្ធនានាចូលរួមផង។ តំណាងអង្គការអន្តរជាតិមួយចំនួនក៏មានវត្តមានក្នុងកិច្ចប្រជុំនោះ ដែលមានលោកអនុរដ្ឋមន្ត្រីសុខាភិបាលជាប្រធានគណៈអធិបតី។*

*របៀបវារៈ រួមមាន កិច្ចពិភាក្សា និងការបង្ហាញរបាយការណ៍ស្តីអំពីស្ថានភាពទូទៅនៃថ្នាំជក់លើសកលលោក និងការគ្រប់គ្រងរបស់វា ស្ថានភាពថ្នាំជក់ និងការគ្រប់គ្រងរបស់វានៅប្រទេសឡាវ ផលអាក្រក់របស់ថ្នាំជក់មកលើសុខភាព ព័ត៌មានស្តីអំពីពន្ធនាំចូលថ្នាំជក់ និងយុទ្ធសាស្ត្រ និងគោលនយោបាយសម្រាប់គ្រប់គ្រងថ្នាំជក់នាពេលអនាគត។*

*ក្នុងចំណោមផ្ទៃដីសរុបរបស់ឡាវ ប្រមាណជា ៧.៥០០ គីឡូម៉ែត្រក្រឡា ត្រូវបានប្រើប្រាស់សម្រាប់ដាំថ្នាំជក់។ នៅតំបន់ទីប្រជុំជនប្រមាណជា ២៥ ភាគរយ នៃបុរសឡាវ និង ១,៥ ភាគរយ នៃនារីឡាវ ជាអ្នកជក់បារី។ នៅតំបន់ជនបទ ៣០ ភាគរយនៃចំនួនស្ត្រីជក់បារី។ ក្នុងចំណោមអ្នកជក់បារីទាំងអស់ពី ៧០ ទៅ ៩០ ភាគរយ ជាសមាជិកក្រុមជនជាតិដើមភាគតិច។*

*ប្រទេសឡាវមានរោងចក្រផលិតបារីពីរ ដែលផលិតបារី ម៉ាក Adeng និង Dokmaydeng។ ទីភ្នាក់ងារពីរជាអ្នកនាំចូលបារី 555 និង Malboro។*

សេចក្តីផ្តើមនិយាយថា គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីធ្វើគោលនយោបាយស្តីពីការគ្រប់គ្រងការជក់បារី។ ប៉ុន្តែ គ្មានត្រង់ណាមួយសោះក្នុងសាច់រឿង ដែលគេបានប្រាប់អ្នកអានថា តើកិច្ចប្រជុំនោះសម្រេចបានអ្វីខ្លះ? បើសិនជាគេធ្វើគោលនយោបាយមួយមែន តើវាមានអ្វីខ្លះទៅក្នុងនោះ? គោលនយោបាយណាមួយក៏ដោយ តែងមានផលប៉ះពាល់របស់វាទៅលើមនុស្សជាច្រើន។ បើសិនជាកិច្ចប្រជុំមិនបានធ្វើគោលនយោបាយនោះទេ ហេតុអ្វីបានជាមានការខកខាន?

សេចក្តីផ្តើមនេះមានគំនិតត្រូវបន្តិចបន្តួចដែរ។ វាបាននិយាយដល់សេចក្តីថ្លែងគួរឲ្យចាប់អារម្មណ៍មួយ ដែលត្រូវបានគេធ្វើឡើងក្នុងកិច្ចប្រជុំនោះ។ ប៉ុន្តែព័ត៌មាននោះ មិនត្រូវបានគេពន្យល់ឲ្យបានក្បោះក្បាយបន្តិចសោះក្នុងផ្នែកដទៃទៀតនៃរឿងទេ។ ហេតុអ្វីបានជានារីកាន់តែច្រើនឡើងជក់បារី? តើការជក់បារីក្នុងចំណោមនារី កើនប៉ុន្មានទៅ? តើមានមធ្យោបាយណាសម្រាប់គ្រប់គ្រងបញ្ហានេះត្រូវបានគេពិភាក្សាក្នុងកិច្ចប្រជុំនោះទេ?

រឿងនេះប្រាប់អ្នកអានអំពីរបៀបវារៈនៃកិច្ចប្រជុំ ប៉ុន្តែវាមិនបាននិយាយសោះ តើស្អីជាមតិធំៗ ដែលត្រូវបានគេលើកឡើងក្នុងកិច្ចប្រជុំនោះទេ។ តើសមាជិកក្នុងកិច្ចប្រជុំយល់ស្រប ឬខ្វែងគំនិតគ្នា លើទស្សនៈរបស់ពួកគេ ស្តីពីបញ្ហា និងវិធីសម្រាប់គ្រប់គ្រងថ្នាំជក់ ឬទេ?

រឿងនេះផ្តល់ឲ្យយើងនូវការណ៍ ឬអង្គហេតុបន្តិចបន្តួចដែរ អំពីភាគរយនៃអ្នកជក់ និងប្រភេទបារី។ ប៉ុន្តែសារៈតារសំខាន់មួយ ត្រូវបានគេរំលងបាត់ ៖ តើស្អីទៅជានយោបាយបច្ចុប្បន្នលើការគ្រប់គ្រងថ្នាំជក់? ហើយស្អីទៅជាបរិបទនៃរឿងនេះ? ហេតុអ្វីបានជារដ្ឋាភិបាលគិតគូរអំពីរឿងនេះនៅពេលនេះ?

ឥឡូវសូមក្រឡេកមើលរឿងខាងក្រោមស្តីពីកិច្ចប្រជុំការទូតសំខាន់មួយ ដែលកាន់តែពិបាកធ្វើសេចក្តីរាយការណ៍ និងកាន់តែសាំញ៉ាំក្នុងការសរសេរ។

ចូរកត់សំគាល់របៀបដែលអ្នកសរសេរប្រើប្រាស់ពុទ្ធិសារៈតាររបស់គាត់អត្ថាធិប្បាយ ដែលគេធ្វើនាកិច្ចប្រជុំហើយ និងសម្ភាសន៍ជាមួយអ្នកចូលរួមនៅក្រោយកិច្ចប្រជុំ ដើម្បីឲ្យគេផ្តល់នូវរូបភាពមួយពេញលេញ និងមានអត្ថន័យ ស្តីអំពីអ្វីដែលបានកើតឡើង។

អ្នកយកព័ត៌មានដកស្រង់សម្តីដើមមនុស្សប្រាំពីរនាក់ទាំងមានឈ្មោះ និងទាំងអ្នកសុំមិនបញ្ចេញឈ្មោះ។ លើសពីនេះទៀត គាត់សម្ភាសន៍ប្រភពច្រើនទៀតក្នុងថ្ងៃនោះ ដើម្បីសិក្សាឲ្យយល់ថាអ្វីបានកើតឡើង ហើយហេតុអ្វីបានជាវាមានសារៈសំខាន់។

រឿងនោះហូរដោយរលូន ហើយយ៉ាងទំនងពីប្រធានបទមួយទៅដល់ប្រធានបទមួយ ចាប់ពីប្រធានបទសំខាន់ជាងគេបំផុត ទៅដល់ប្រធានបទដែលមិនសូវមានសារៈសំខាន់។ អ្នកយកព័ត៌មានរក្សាព័ត៌មាន ដែលប្រទាក់ប្រទងគ្នាឲ្យនៅជាមួយគ្នា។ គាត់ឆ្លើយក្នុងលំដាប់លំដោយ សមទំនងចំពោះសំណួរទាំងឡាយណា ដែលអ្នកអានអាចចោទសួរ។ ពិតណាស់ ដើម្បីរៀបរៀងរឿងមួយឲ្យបានល្អ អ្នកយកព័ត៌មានក៏ត្រូវតែត្រៀមខ្លួនឲ្យបានល្អ ហើយក្តាប់បញ្ហាឲ្យបានណែនជាមុនផងដែរ។



*ចូរត្រៀមខ្លួនសួរសំណួរល្អៗទៅកាន់វាគ្មិន*

## ស.រ.អា អះអាងចំពោះសម្ព័ន្ធមិត្តថា ខ្លួនមានការតាំងចិត្តចំពោះសន្តិសុខរបស់អាស៊ី និងធ្វើឲ្យទំនាក់ទំនងកាន់តែប្រសើរ

សេចក្តីផ្តើមមានពីរឃ្លា ត្រូវបានគេប្រើដើម្បីរាយការណ៍អំពីការវិវត្តពីរ នោះគឺអ្វីដែលកិច្ចប្រជុំសម្រេចបាន និងអ្វីដែលកិច្ចប្រជុំមិនអាចសម្រេចបាន។ តែចូរកត់សម្គាល់ថា គោលគំនិតទាំងពីរក្នុងសេចក្តីផ្តើមនេះ ត្រូវបានសរសេរយ៉ាងច្បាស់ ហើយសាមញ្ញបំផុត។

កថាខណ្ឌទាំងនេះ រាប់ទាំងសម្រង់សម្តីដើមមួយផង ធ្វើជាជន្ទល់ទ្រទ្រង់ដល់ផ្នែកដំបូងគេក្នុងសេចក្តីផ្តើម។ អ្នកអានហ្មត់ចត់ម្នាក់ ច្បាស់ជានឹងសួរថា ស្អីទៅវេទិកាតំបន់អាស៊ាន? អ្នកអាននឹងដឹងបានតាមរយៈសេចក្តីផ្តើមថា វាជាកិច្ចប្រជុំសន្តិសុខ។ អ្នកយកព័ត៌មានបានឆ្លើយនឹងសំណួរនេះ ហើយធ្វើដូច្នេះ វាជួយទ្រទ្រង់ដល់សេចក្តីផ្តើម ("ប្រជាជាតិអាស៊ី និងអឺរ៉ុប")។
អ្នកយកព័ត៌មានបានទ្រទ្រង់សេចក្តីផ្តើមជាមួយនឹងអត្ថាធិប្បាយរបស់ចិន។ ឥឡូវនេះ គាត់ទ្រទ្រង់វាដោយប្រើអត្ថាធិប្បាយពីម្ខាងទៀត គឺសហរដ្ឋអាមេរិក។ គាត់មិនមានលទ្ធភាពសម្ភាសន៍លោក Powell ទេ ប៉ុន្តែគាត់បានសួរអ្នកចូលរួមម្នាក់ទៀតអំពីអ្វីដែលលោក Powell បាននិយាយ។

Hanoi, Vietnam (AP) - សហរដ្ឋអាមេរិក និងចិនបានអះអាងបញ្ជាក់ដល់ប្រជាជាតិអាស៊ី និងអឺរ៉ុប នៅក្នុងកិច្ចចរចាសន្តិសុខ កាលពីថ្ងៃពុធ ថា ពួកគេនឹងព្យាយាមបញ្ចប់ភាពតានតឹងថ្មីៗនេះរបស់ពួកគេ។ ប៉ុន្តែ វេទិកានេះមិនសម្រេចបានក្នុងការព្យាយាមបញ្ចុះបញ្ចូលកូរ៉េខាងជើង ឲ្យបើកកិច្ចសន្ទនាឡើងវិញបានទេ។

លោក Tang Jiaxuan រដ្ឋមន្ត្រីការបរទេសចិន និយាយថា ប្រទេសរបស់គាត់វាយតម្លៃចំពោះទំនាក់ទំនងរបស់ខ្លួនជាមួយសហរដ្ឋអាមេរិក ហើយនឹងធ្វើការជាមួយក្រុងវ៉ាស៊ីនតោន ដើម្បីធានាឲ្យបាននូវសន្តិភាព និងស្ថិរភាពក្នុងតំបន់។

លោក Tang និយាយក្នុងសុន្ទរកថាទៅកាន់វេទិកាតំបន់អាស៊ាន (ASEAN Regional Forum) ថា "បន្ទាប់ពីឆ្លងកាត់ដំណាក់កាលលំបាកមួយរួចមក ទំនាក់ទំនងចិន-អាមេរិក ដែលតែងចាប់យកការយកចិត្តទុកដាក់របស់ពិភពលោក កាលពីពេលថ្មីៗនេះ បានឈានទៅរកភាពប្រសើរឡើងវិញហើយ"។

វេទិកានេះ ដែលរៀបចំដោយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ មានការចូលរួមពីសំណាក់សហរដ្ឋអាមេរិក ចិន រុស្ស៊ី កូរ៉េខាងត្បូង សហគមន៍អឺរ៉ុប និងប្រជាជាតិច្រើនទៀត។

អ្នកការទូតអាស៊ានម្នាក់និយាយថា លោករដ្ឋមន្ត្រីការបរទេសអាមេរិក Colin Powell បានអះអាងដល់វេទិកានេះថា បានដាក់អាទិភាពចំពោះទំនាក់ទំនងជាមួយប្រទេសចិន និងតំបន់អាស៊ី-ប៉ាស៊ីហ្វិកទាំងមូលផងដែរ។

*សារតៅរនេះសំខាន់ណាស់សម្រាប់ជួយឲ្យយល់សាច់រឿង។ វាប្រាប់ដល់អ្នកអាននូវអ្វី ដែលបានលើកឡើងក្នុងសេចក្ដីផ្ដើម គឺថាសហរដ្ឋអាមេរិក និង ចិន កំពុងព្យាយាមធ្វើឲ្យទំនាក់ទំនងរវាងគេប្រសើរឡើងវិញ។ សារតៅរនេះសាមញ្ញ ហើយខ្លី គឺគ្រប់គ្រាន់ល្មម ដើម្បីនឹងយល់រឿងនេះបាន។*

អ្នកនាំពាក្យថៃ លោក Norachit Singhaseni និយាយថា ក្នុងកិច្ចជំនួបជាមួយរដ្ឋមន្ត្រីការបរទេសថៃ Surakiart Sathirathai លោក Powell សង្កត់ធ្ងន់ថា "សហរដ្ឋអាមេរិក នៅតែមានការប្ដេជ្ញាចិត្តចំពោះតំបន់នេះ ហើយថារដ្ឋបាលលោក Bush ផ្ដោតការយកចិត្តទុកដាក់មកលើអាស៊ីខ្លាំងណាស់"។

ទំនាក់ទំនងអាមេរិក-ចិន បានធ្លាក់យ៉ាប់យ៉ឺនខ្លាំងក្នុងប៉ុន្មានខែនេះ ដោយសារមានការដាក់ឲ្យជាប់ពិរុទ្ធបទចារកម្មចំពោះវិជ្ជាករអាមេរិកជាច្រើនរូប វិវាទពាក់ព័ន្ធយន្តហោះស៊ើបការអាមេរិកមួយគ្រឿង គម្រោងប្រព័ន្ធមីស៊ីលការពាររបស់អាមេរិក និងបញ្ហាសិទ្ធិមនុស្ស។

*កថាខណ្ឌទាំងពីរនេះពន្យល់បរិបទ និងសំណួរ "ចុះវាយ៉ាងម៉េច" តើទំនាក់ទំនងប្រសើរឡើងវិញរវាងសហរដ្ឋអាមេរិក និងចិន មានន័យដូចម្ដេចសម្រាប់អាស៊ីអាគ្នេយ៍។*

នៅពេលដែលត្រូវបានគេសួរអំពីជំហររបស់ប្រជាជាតិអាស៊ី លោក Norachit និយាយថា "យើងចង់ឃើញសហរដ្ឋអាមេរិក និងចិនបើកឡើងវិញនូវកិច្ចពិភាក្សាការទូតធម្មតា ហើយវាទំនងជាមានដូច្នេះមែន ដូច្នេះយើងសូមស្វាគមន៍ចំពោះការវិវត្តបែបនេះ"។

ទាំងប្រទេសចិន និងសហរដ្ឋអាមេរិកដើរតួនាទីសេដ្ឋកិច្ច និងសន្តិសុខយ៉ាងសំខាន់ក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានប្រជាជនរស់នៅជាង ៥០០ លាននាក់ និងផ្លូវចរាចរសមុទ្រសំខាន់ៗរបស់ពិភពលោកទៀតផង។

*ឥឡូវនេះអ្នកសរសេរឈានចូលទៅផ្នែកទីពីរនៃសេចក្ដីផ្ដើមវិញម្ដង។*

កូរ៉េខាងជើងចូលរួមជាលើកទីពីរក្នុងកិច្ចពិភាក្សាសន្តិសុខ ដែលរៀបចំដោយសមាគមអាស៊ាន ប៉ុន្តែលើកនេះ រដ្ឋមន្ត្រីការបរទេសកូរ៉េខាងជើង លោក Pak Nam Sun មិនមកចូលរួមទេ តែបានបញ្ជូនលោក Hur Jong ដែលជាមន្ត្រីជាន់ទាបម្នាក់មកជំនួសវិញ។ ជាលទ្ធផល ពុំមានជំនួបរវាងសហរដ្ឋអាមេរិក និងកូរ៉េខាងជើង ត្រូវបានធ្វើឡើងទេ។

*កថាខណ្ឌទាំងពីរទ្រទ្រង់ដល់សេចក្ដីផ្ដើមត្រង់តែម្ដង។*

លោក Hur បានសម្លាប់បោលនូវសេចក្ដីសង្ឃឹមថា នឹងមានកិច្ចសន្ទនាឡើងវិញឆាប់រហ័សរបស់ប្រទេសកូរ៉េខាងជើង ជាមួយសហរដ្ឋអាមេរិក និងកូរ៉េខាងត្បូង។

*អ្នកយកព័ត៌មានល្អ តែងតែស្វែងរកជ្រុងទាំងសងខាងនៃរឿង។ គាត់ទទួលបាននូវអត្ថាធិប្បាយនេះ ដោយសួរថា តើសហរដ្ឋអាមេរិកឆ្លើយចំពោះការចោទប្រកាន់របស់កូរ៉េខាងត្បូងដូចម្ដេចទៅ?*

លោក Rodolfo Severino អគ្គលេខាធិការសមាគមអាស៊ាន និយាយក្នុងការរម្លឹកឡើងវិញនូវការកត់សម្គាល់របស់លោក Hur នៅក្នុងកិច្ចប្រជុំសន្តិសុខថា "ពួកគេនៅតែប្រកាន់ជំហរថា សហរដ្ឋអាមេរិកកំពុងដាក់លក្ខខណ្ឌមួយចំនួនទៅលើការបើកឡើងវិញនូវការចរចា"។

លោក Severino និយាយថា "សហរដ្ឋអាមេរិកនិយាយថាទេ ពួកគេមិនបានដាក់លក្ខខណ្ឌអ្វីទាល់តែសោះ។ ពួកគេគ្រាន់តែរង់ចាំចម្លើយមួយពីកូរ៉េខាងជើង ចំពោះសំណើសុំឲ្យមានការសន្ទនាឡើងវិញតែប៉ុណ្ណោះ"។

លោក Severino និយាយថា ប្រតិភូរបស់កូរ៉េខាងជើងនៅរក្សាភាពស្ងប់ស្ងៀមដដែល បន្ទាប់ពីប្រទេសជាច្រើននៅឯកិច្ចប្រជុំនោះនាំគ្នា សម្ដែងសេចក្ដីសង្ឃឹមថានឹងមានការបើកឡើងវិញនូវការចរចារវាងកូរ៉េខាងជើង និងកូរ៉េខាងត្បូង។

*ព័ត៌មានទ្រទ្រង់សេចក្ដីផ្ដើមថែមទៀត។*

មន្ត្រីកូរ៉េខាងត្បូងម្នាក់និយាយដោយមិនបញ្ចេញឈ្មោះថា ពិតណាស់ "ពួកគេ (កូរ៉េខាងជើង) ប្រកាន់ទស្សនៈអវិជ្ជមានខ្លាំងណាស់អំពីកិច្ចសន្ទនានេះ"។

សូម្បីលោក Tang រដ្ឋមន្ត្រីការបរទេសចិន ក៏និយាយដែរថា គាត់នឹង "រីករាយកាលណានឹងឃើញមានភាពប្រសើរថែមទៀត" ក្នុងទំនាក់ទំនងរបស់កូរ៉េខាងជើងជាមួយប្រទេសផ្សេងទៀត។

*សាវតារថែមទៀត ដែលធ្វើឲ្យអ្នកអានកាន់តែយល់សាច់រឿង។ កិច្ចចរចាលើកមុនស្ដីពីបញ្ហាកូរ៉េទទួលបានជោគជ័យ តែមិនមែនលើកនេះទេ។ រឿងសំខាន់ពេលនេះមានលក្ខណៈពេញលេញហើយ។*

វត្តមានរបស់កូរ៉េខាងជើងនៅឯកិច្ចចរចាសន្តិសុខ កាលពីមួយឆ្នាំមុន បាននាំឲ្យមានការឈានទៅមុខក្នុងទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក និងកូរ៉េខាងត្បូង ហើយនោះជាការបើកប្រកដ៏កម្រមួយឆ្ពោះទៅរកពិភពលោកខាងក្រៅសម្រាប់ប្រជាជាតិកុម្មុយនិស្តមួយនេះ ដែលធ្លាប់ធ្វើសង្គ្រាមជាមួយកូរ៉េខាងត្បូងកាលពីទសវត្សរ៍ឆ្នាំ ១៩៥០។

*អ្នកសរសេរឆ្លងទៅដល់ប្រធានបទ មិនសូវមានសារៈសំខាន់នៃកិច្ចប្រជុំនោះ។ ឃ្លាដែលថា "ក៏សម្រេចបានការរីកចម្រើនតិចតួចដែរលើបញ្ហាសន្តិសុខមួយទៀត..." បង្កើតបាននូវអន្តរកាល ស្ពានចម្លងរលូនមួយទៅកាន់ប្រធានបទមួយទៀត។ សាវតារ និងសារៈសំខាន់ត្រូវបានគេលើកឡើងយ៉ាងច្បាស់ និងយ៉ាងសាមញ្ញ។*

*កិច្ចសន្ទនាលើកនេះ សម្រេចបានការរីកចម្រើនតិចតួចដែរលើបញ្ហាសន្តិសុខមួយទៀតនៅអាស៊ី នោះ គឺវិវាទលើបណ្តាកោះទាំងឡាយក្នុងសមុទ្រចិនខាងត្បូង។ ការប្រជែងដណ្តើមកម្មសិទ្ធិទឹកដីពីសំណាក់ប្រទេសចិន និងប្រទេសមួយចំនួនក្នុងអាស៊ាន បានបណ្តាលឲ្យមានការប៉ះទង្គិចផ្នែកអាវុធខ្លះៗរួចមកហើយ កាលពីប៉ុន្មានឆ្នាំកន្លងទៅ។*

*ការវិវត្តក្នុងថ្ងៃនោះត្រូវបានគេធ្វើសេចក្តីរាយការណ៍ ៖ ហេតុអ្វីបានជាមានការរាំងខ្ទប់ដល់ការរីកចម្រើន និងលទ្ធភាពដែលអាចនាំឲ្យមានដំណោះស្រាយ។*

*លោក Nguyen Dy Nien រដ្ឋមន្ត្រីការបរទេសវៀតណាម ដែលជាប្រធានកិច្ចប្រជុំសន្តិសុខនោះ និយាយថា ប្រទេសទាំងនោះ កំពុងប្រជុំឲ្យមាន "ក្រមប្រតិបត្តិ" (code of conduct) ដើម្បីចៀសវាងការប៉ះទង្គិចថែមទៀត ក៏ប៉ុន្តែប្រទេសទាំងនោះនៅតែជំទាស់គ្នាលើបញ្ហានានា រាប់ទាំងតំបន់ភូមិសាស្ត្រដែលក្រមនោះនឹងគ្របដណ្តប់ទៅលើ។*

*គាត់និយាយថា ឥឡូវនេះ ប្រទេសទាំងនេះកំពុងពិចារណាសំណើមួយពីប្រទេសហ្វីលីពីន ដើម្បីបំបែកនូវភាពទាល់ច្រក។*

*អ្នកយកព័ត៌មានបន្តចូលទៅប្រធានបទបន្ទាប់បន្សំមួយទៀត។ ប្រធានបទមួយនេះ មានសារៈសំខាន់កាន់តែតិចជាងវិវាទក្នុងសមុទ្រចិនខាងត្បូង ពីព្រោះការជំទាស់ទៅនឹងផែនការអាវុធមីស៊ីលរបស់ស.អា.រ ត្រូវបានគេធ្វើសេចក្តីរាយការណ៍ពីមុនរួចមកហើយ។*

*លោក Louis Michel រដ្ឋមន្ត្រីការបរទេសប្រទេសប៊ែលហ្ស៊ិក ដែលតំណាងឲ្យសហគមន៍អឺរ៉ុប និយាយថា ក្នុងអំឡុងកិច្ចប្រជុំនោះ បណ្តាប្រទេសនានារាប់ទាំងសហគមន៍អឺរ៉ុបផង បានលើកការជំទាស់ទៅនឹងផែនការរបស់ស.អា.រ ក្នុងការធ្វើប្រព័ន្ធមីស៊ីលការពារ។*

*លោក Michel ប្រាប់អ្នកយកព័ត៌មានថា "យើងត្រូវតែពិភាក្សាជាមួយមេដឹកនាំសហរដ្ឋអាមេរិក អំពីប្រព័ន្ធមីស៊ីលការពារ ពីព្រោះវាអាចមានបច្ច័យអាក្រក់ខ្លះទៅលើដំណើរការកាត់បន្ថយសព្វាវុធដែរ"។*

*ក្នុងសុន្ទរកថារបស់គាត់ លោក Tang រដ្ឋមន្ត្រីការបរទេសចិន បានរម្លឹកឡើងវិញនូវការព្រមានរបស់ចិនថា ប្រព័ន្ធមីស៊ីលការពារនឹងធ្វើឲ្យខូចខាតដល់សន្តិភាព និងស្ថិរភាពក្នុងតំបន់។ គាត់និយាយថា វានឹង "មិននាំផលល្អណាមួយដល់ការជឿទុកចិត្តគ្នា និងសហប្រតិបត្តិការរវាងបណ្តាប្រទេសនានាឡើយ"។*



*សួរសំណួរខ្លី ហើយឲ្យបានរហ័ស*

# សន្និសីទ

សន្និសីទជាពិធីដែលពិបាកយកព័ត៌មាន។ សន្និសីទជាការជួបប្រជុំ ដែលច្រើនតែរៀបចំដោយពួកបណ្ឌិតសភា អង្គការមិនមែនរដ្ឋាភិបាល ក្រុមប្រកបរបរអាជីព និងរដ្ឋាភិបាល។ ជារឿយៗគេរៀបចំសន្និសីទ ដើម្បីដោះដូរគំនិត តែមិនសូវជាសម្រេចវិធានការអ្វីបានទេ ឬក៏គ្មានសោះតែម្តង។

បើសិនជាសន្និសីទមានវាគ្មិនសំខាន់ អ្វីដែលគេនិយាយនោះ ហើយអាចជាចំណុចផ្តោតយកចិត្តទុកដាក់សម្រាប់សរសេររឿង។ បើមានអ្នកចូលរួមមួយចំនួនផ្តល់សំណើជាដំណោះស្រាយដល់បញ្ហាណាមួយ នោះក៏អាចជាចំណុចដៅសម្រាប់សរសេររឿងដែរ។ ចូរព្យាយាមសួរនាំអ្នកចូលរួមក្នុងពេលសម្រាកប្រជុំ។ ឲ្យពួកគេនិយាយលម្អិតបន្ថែមនូវគំនិតដែលពួកគេបានលើកឡើង ហើយសួរពួកគេមើលថា តើគួរធ្វើដូចម្តេចខ្លះ ដើម្បីដោះស្រាយនូវបញ្ហាណាមួយនោះ។

សន្និសីទមិនមែនជាកន្លែងដែលផលិតរឿងល្អទេ ប៉ុន្តែវាជាកន្លែងល្អមួយសម្រាប់ជួបជាមួយអ្នកឯកទេស ហើយជជែករកគំនិតសរសេររឿង។

ដូចគ្នានឹងការសរសេររឿងអំពីកិច្ចប្រជុំដែរ អ្នកគួរចៀសវាងសរសេរសេចក្តីផ្តើមណា ដែលមានតែ Who, Where និង When។ ឧទាហរណ៍ អត្ថបទខាងក្រោមនេះពីកាសែតភាសាវៀតណាមួយ ៖

*សន្និសីទ ដើម្បីពិនិត្យឡើងវិញនូវយុទ្ធនាការប្រឆាំងគ្រឿងញៀន និងអំពើអបាយមុខសង្គមក្នុង*

*បំណោមសមាជិកចលនាពលករ ដែលត្រូវបានរៀបចំឡើងដោយ Central Trades Union បានបញ្ចប់ទៅនៅក្រុង Quang Tri កាលពីថ្ងៃទី ២០ មីនា។*

ក្រោយមកទៀត រឿងនេះបានស្រង់សម្ដីដើមរបស់មន្ត្រីម្នាក់ដែលបាននិយាយថា "អំពើអបាយមុខសង្គម" មិនបានថមថយទេ ដោយសារតែសមាជិកខ្លះនៃចលនានេះ មិនគិតថាវាមានភាពបន្ទាន់ក្នុងការបាត់ការបញ្ហានេះទេ។ មន្ត្រីនោះបានលើកសំណើសម្រាប់ដោះស្រាយបញ្ហានេះ ដែលគំនិតនេះគួរត្រូវបានយកទៅធ្វើជាសេចក្ដីផ្ដើមវិញ។

## សុន្ទរកថា និងសន្និសីទព័ត៌មាន

### *ចូរស្វែងរកតុល្យភាព*

ចូរចាំទុកថា ធម្មតាវាគ្មិនតែងមានគោលបំណងច្បាស់លាស់មួយក្នុងការធ្វើសុន្ទរកថា ឬក្នុងសន្និសីទព័ត៌មានមួយ។ ពួកគេមានសារដែលគេចង់ឲ្យបណ្ដាញសារព័ត៌មានជួយផ្សព្វផ្សាយបន្ត។ អាចថាបានថា ពួកគេកំពុងប្រឹងលើកតម្កើងមុខមាត់គណបក្ស ឬពាយនាយផលិតផលរបររកស៊ីរបស់គេក៏ថាបាន។ ក្នុងស្ថានភាពបែបនេះ អ្នកកាសែតបំណាននឹងដឹងភ្លាមថា ពេលនេះគេនឹងទទួលបានតែជ្រុងម្ខាងនៃរឿងទេ។ ដូច្នេះអ្នកត្រូវត្រៀមខ្លួនសួរវាគ្មិននូវសំណួរល្អៗ ដើម្បីជជីកយកព័ត៌មានថែមទៀត ហើយដើម្បីដេញដោលសំដីរបស់ពួកគេ។ ចំណុចដែលអ្នកត្រូវផ្ដោតលើសម្រាប់យកមកសរសេររឿង គឺចម្លើយរបស់វាគ្មិនទៅនឹងសំណួររបស់អ្នក តែមិនមែនអ្វីដែលគេបាននិយាយរួចហើយក្នុងសុន្ទរកថារបស់គេនោះហើយទេ។

បើសិនជាវាគ្មិនធ្វើអត្ថាធិប្បាយលើរឿងចម្រូងចម្រាស់ណាមួយ អ្នកគួរតែបញ្ចូលក្នុងរឿងរបស់អ្នកនូវអត្ថាធិប្បាយពីសំណាក់គូបដិបក្ខរបស់គេ ឬមួយក៏អត្ថាធិប្បាយពីអ្នកឯកទេស ឬពីសំណាក់មហាជនដែលមានទស្សនៈផ្ទុយ។ នេះជាការសរសេរឲ្យមានតុល្យភាព។

## ចូរផ្ដោតលើអ្នកណានិយាយអ្វី

ក្នុងរឿងដែលសរសេរអំពីសុន្ទរកថា និងសន្និសីទព័ត៌មាន គួរមាន ៖

- អ្នកណានិយាយ (ឈ្មោះ តំណែង និងអង្គភាព)
- អ្វីដែលវាគ្មិនបាននិយាយ (ចំណុចសំខាន់) រាប់ទាំងសម្រង់សម្ដីល្អៗផង
- នៅទីណា និងពេលណា ដែលសុន្ទរកថា ឬសន្និសីទព័ត៌មាន ត្រូវបានធ្វើឡើង
- អ្នកណាបានស្ដាប់ខ្លះ (សវនាជន) ហើយតើពួកគេមានប្រតិកម្មបែបណាខ្លះ
- អត្ថាធិប្បាយ ឬប្រតិកម្មពីសំណាក់អ្នកឯទៀតដែលពាក់ព័ន្ធនឹងបញ្ហានោះ

សេចក្ដីផ្ដើមត្រូវផ្ដោតលើចំណុចពីរមុនគេ នោះគឺអ្នកណានិយាយអ្វី Who said What?

គេច្រើនឃើញថា ជារឿយៗសេចក្ដីផ្ដើមរបស់រឿងដែលសរសេរអំពីសុន្ទរកថា និងសន្និសីទព័ត៌មានតែងតែមានឈ្មោះវាគ្មិន កាលវេលា ទីកន្លែង និងថាតើវាគ្មិននោះនិយាយទៅកាន់នរណា (when, where and to whome he or she is speaking to) តែមិនបានសរសេរបង្ហាញអំពីចំណុចសំខាន់នៃអ្វីដែលវាគ្មិនបាននិយាយនោះទេ។ ចូរសួរខ្លួនឯងល់មើល តើអ្វីដែលសំខាន់ចាប់អារម្មណ៍ជាងគេ ឬក៏ដែលអធម្មតាដែលវាគ្មិនបាននិយាយ? ឧទាហរណ៍ តើវាគ្មិននោះបានផ្ដល់គំនិតអ្វីមួយជាដំណោះស្រាយដល់បញ្ហាទេ? តើវាគ្មិនមានធ្វើ

អត្ថាធិប្បាយអ្វីលើភាពចម្រូងចម្រាសនោះទេ? បើមាន សូមដាក់ព័ត៌មានបែបនេះទៅក្នុងសេចក្តីផ្តើម។

ទីកន្លែងដែលវាគ្មិនបាននិយាយ និងព័ត៌មានស្តីអំពីអ្នកចូលរួម គេអាចយកវាទៅដាក់ក្នុងកថាខណ្ឌទីពីរ ឬទីបីក៏បានដែរ។ ធ្វើបែបនេះ សេចក្តីផ្តើមនឹងមានភាពសាមញ្ញ ហើយច្បាស់សម្រាប់អ្នកអានយល់។

សូមផ្តោតទៅលើតែចំណុចសំខាន់បានហើយ។ កុំបេះតែកត់គ្រប់ចំណុចដែលគេនិយាយដូចចុះបញ្ជីនោះ។ កិច្ចការរបស់អ្នក គឺជ្រើសយកនូវអ្វីដែលសំខាន់ និងគួរឲ្យចាប់អារម្មណ៍ដល់អ្នកអានទៅបានហើយ។

ជួនកាល ចំណុចដែលសំខាន់ជាងគេអាចមាននៅឯចុងបញ្ចប់នៃសុន្ទរកថាដ៏វែងឯណោះ ដូច្នេះចូរប្រយ័ត្ន។ ឧទាហរណ៍ នាយករដ្ឋមន្ត្រីកំពុងចូលរួមពិធីប្រគល់សញ្ញាប័ត្រនៅសាលាវេជ្ជសាស្ត្រ។ គាត់ចំណាយ ៤៥ នាទីដំបូង របស់គាត់និយាយអំពីស្ថានភាពវិស័យសុខាភិបាល។ ដល់ ៥ នាទីចុងក្រោយ គាត់ប្តូរប្រធានបទទៅប្រកាសវិធានការបង្ក្រាបជនអន្តោប្រវេសន៍ខុសច្បាប់វិញ។ គាត់និយាយថា អន្តោប្រវេសន៍ទាំងអស់នឹងត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសរបស់ពួកគេវិញ។

បើសិនជាគាត់មិនបាននិយាយអ្វីសំខាន់អំពីវិស័យសុខាភិបាលទេ ចូរកុំសរសេរសេចក្តីផ្តើមដូចខាងក្រោមនេះឲ្យសោះ៖

*លោកនាយករដ្ឋមន្ត្រីបាននិយាយអំពីការថែទាំសុខភាព ក្នុងពេលដែលគាត់ចូលរួមផ្តល់សញ្ញាប័ត្រដល់និស្សិតសាលាវេជ្ជសាស្ត្រ។*

ចូរសរសេរបែបនេះវិញ

*លោកនាយករដ្ឋមន្ត្រី កាលពីម្សិលមិញបានប្រកាសការបង្ក្រាបជនអន្តោប្រវេសន៍ខុសច្បាប់។*



*សូមផ្តោតទៅលើអ្នកណាដែលនិយាយគួរឲ្យចាប់អារម្មណ៍ជាងគេ*

បន្ទាប់មកទៀត ក្នុងសាច់រឿង អ្នកអាចសរសេរថា លោកនាយករដ្ឋមន្ត្រីធ្វើអត្ថាធិប្បាយបែបនេះ ក្នុងពិធីប្រគល់សញ្ញាប័ត្រនៅសាកលវិទ្យាល័យមួយ។ អ្នករំលឹកបានដែរថា គាត់ចំណាយភាគច្រើននៃពេលរបស់គាត់និយាយអំពីការថែទាំសុខភាព។ កុំគិតខ្លាចនិស្សិតទទួលសញ្ញាប័ត្រខឹង។ ចូរចាំថា អ្នកសរសេរសម្រាប់អ្នកអានទូទៅ មិនមែនសម្រាប់និស្សិតមួយមុខនោះទេ។

ជារឿយៗ វាគ្មិនធ្វើអត្ថាធិប្បាយសំខាន់ណាមួយ តែគេមិនបានលម្អិតក្បោះក្បាយទេ នៅក្នុងសុន្ទរកថារបស់គេ។ ក្រោយពីគាត់អានសុន្ទរកថាចប់ហើយ ចូរសួរគាត់ឲ្យពន្យល់បន្ថែម ឬក៏ផ្តល់ឧទាហរណ៍។ កុំភ្លេចបញ្ជាក់ក្នុងរឿងផងថា គាត់ធ្វើអត្ថាធិប្បាយក្នុងកិច្ចសម្ភាសន៍ជាមួយអ្នក បន្ទាប់ពីគាត់អានសុន្ទរកថាចប់។ បើមិនធ្វើដូច្នោះទេ អ្នកអានដែលមានវត្តមានក្នុងពិធីនោះដែរ អាចយល់ច្រឡំ ហើយនិយាយថាអ្នកសរសេរមិនបានត្រឹមត្រូវ។ តាមធម្មតា អ្នកត្រូវព្យាយាមជជែកជាមួយវាគ្មិន ក្រោយពីគាត់អានសុន្ទរកថាចប់។ តាមរបៀបនេះ អ្នកអាចប្រមូលបានសេចក្តីក្បោះក្បាយ និងសម្តីដើមល្អៗ គួរឲ្យចាប់អារម្មណ៍យកមកប្រើក្នុងរឿង។

## ត្រៀមជាមុន

ជានិច្ចកាល ចូរព្យាយាមរកច្បាប់ចម្លងសុន្ទរកថាឲ្យបានមុននឹងគេយកវាទៅអាន។ កាលណាធ្វើដូច្នេះ អ្នកនឹងមានពេលគ្រប់គ្រាន់សម្រាប់សិក្សាស្វែងយល់អំពីខ្លឹមសារក្នុងសុន្ទរកថានោះ ហើយត្រៀមខ្លួនសួរសំណួរបានល្អៗ។ ប៉ុន្តែ សូមប្រយ័ត្នធ្វើការផ្ទៀងផ្ទាត់វាជាមួយនឹងអ្វី ដែលវាគ្មិនបានអានពិតមែនក្នុងពិធីណាមួយនោះ។ ជាញឹកញាប់ វាគ្មិនច្រើននិយាយក្រៅអត្ថបទ ដែលគេបានត្រៀមទុកជាមុន ឬមួយបើមិនដូច្នោះទេ ពួកគេរំលងផ្នែកណាមួយនោះ ដោយមិនអានវាតែម្តង។ មួយវិញទៀត ប្រសិនបើអ្នកមិនអាចរកបានសុន្ទរកថាមួយច្បាប់មុនទេ អ្នកគួរស្រាវជ្រាវសិក្សាស្វែងយល់ឲ្យបានមុនខ្លះ អំពីបញ្ហាដែលវាគ្មិននឹងអានក្នុងសុន្ទរកថារបស់គេ។ ធ្វើដូច្នេះ កាលណាពេលមកដល់សម្រាប់ធ្វើសុន្ទរកថានោះ អ្នកនឹងដឹងបានថាស្អីទៅជាដំណឹងដែលត្រូវយកទៅសរសេរជារឿងនោះ។

ចូរនាំគ្នាក្រឡេកមើលខាងក្រោម ដែលជាឧទាហរណ៍ល្អមួយ ស្តីអំពីរឿងដែលសរសេរអំពីសុន្ទរកថា។

*Bangkok, Thailand (AP) - នាយករដ្ឋមន្ត្រីថៃ លោក Thaksin Shinawatra បានលាតត្រដាងបង្ហាញគោលនយោបាយនៃរដ្ឋាភិបាលថ្មីរបស់គាត់ ដោយធ្វើការសន្យាយ៉ាងច្រើន ដែលអ្នករិះគន់របស់គាត់និយាយថា គាត់មុខជាពិបាកនឹងបំពេញបានណាស់។*

*អ្នកអានដឹងបានភ្លាមថា សេចក្តីផ្តើមនេះ មិនមែនគ្រាន់តែជាការចម្លងឡើងវិញនូវអ្វី ដែលបាននិយាយក្នុងសុន្ទរកថានោះទេ។*

*ក្នុងសុន្ទរកថាទៅកាន់សម័យប្រជុំជាលើកដំបូងរបស់សភាថ្មី លោក Thaksin និយាយថា គោលនយោបាយនេះ មានគោលដៅបង្កើតការងារ បង្កើនចំណូល និងបញ្ចប់បំណុលរបស់ធនាគារក្នុងប្រទេស ដែលមានតម្លៃជាទឹកប្រាក់ប្រមាណ ជា ២៨,៥ ពាន់លានដុល្លារអាមេរិក ($28.5 billion)។*

*ត្រង់នេះ អ្នកយកព័ត៌មានធ្វើការសង្ខេបភ្លាមនូវចំណុចសំខាន់ៗគោលនយោបាយនោះ។ សម្រង់សម្តីដើមមួយ ត្រូវបានគេប្រើដើម្បីសង្ខេបសុន្ទរកថារបស់លោក Thaksin និងដើម្បីទ្រទ្រង់*

*លោក Thaksin អ្នកនយោបាយ ដែលបានក្លាយខ្លួនពីថៅកែទូរគមនាគមន៍ និយាយថា "រដ្ឋាភិបាលនឹងធ្វើអ្វីៗគ្រប់បែបយ៉ាង*

*ដល់សេចក្តីផ្តើម។ សេចក្តីផ្តើមមិនបានប្រាប់យកគោល-នយោបាយណាមួយជាក់លាក់ទេ ព្រោះវាមិនមានអ្វីថ្មី ការសន្យានានាកាលពីយុទ្ធនាការឃោសនាបោះឆ្នោត ត្រូវបានគេធ្វើសេចក្តីរាយការណ៍ច្រើនលើករួចមកហើយ។ សារតារនេះមានសារៈសំខាន់សម្រាប់អ្នកអានយល់សាច់រឿង។*

*ត្រង់នេះ អ្នកយកព័ត៌មានវិលទៅរកផ្នែកទីពីរក្នុងសេចក្តីផ្តើមវិញ នោះគឺការរិះគន់ទៅលើគោលនយោបាយរបស់លោក Thaksin។ ក្នុងនេះ អ្នកយកព័ត៌មានបានជ្រើសរើសយកសម្តីដើមចំនួនបីខ្លាំងៗយកមកប្រើ។*

ក្នុងអំណាចរបស់ខ្លួន ដើម្បីបង្កើតកាលានុវត្តភាពសម្រាប់ជីវិតថ្មីមួយ។ ប្រទេសថៃ ត្រូវការឲ្យមានការផ្លាស់ប្តូរពីគ្រប់ទិដ្ឋភាពទាំងអស់"។ គណបក្ស Thai Rak Thai របស់លោក Thaksin ដែលដឹកនាំរដ្ឋាភិបាលចម្រុះបានចូលកាន់អំណាច បន្ទាប់ពីបានទទួលជោគជ័យក្នុងការបោះឆ្នោតកាលពីថ្ងៃទី ៦ មករា ដោយឈរលើការសន្យាជាក់-លាក់មួយចំនួន ដូចជា ៖ ការផ្អាកការយកពន្ធដារពីកសិករក្នុងរយៈពេលបីឆ្នាំ ការផ្តល់មូលនិធិអភិវឌ្ឍន៍ចំនួន ២៣.៨០០ ដុល្លារអាមេរិកសម្រាប់ភូមិនីមួយៗក្នុងចំណោមភូមិទាំង ៧៧.០០០ នៅប្រទេសថៃ សេវាពេទ្យមានតម្លៃទាបសម្រាប់អ្នកក្រីក្រ និងការបង្កើតក្រុមហ៊ុនគ្រប់គ្រងសម្បត្តិជាតិមួយ ដើម្បីលៃលកចាត់ចែងបំណុលរបស់ធនាគារ។

ប៉ុន្តែ អ្នករិះគន់បានព្រមានថា គោលនយោបាយប្រជាភិថុតនឹងមានតម្លៃថ្លៃខ្លាំងណាស់។

លោក Chuan Leekpai ដែលជាអតីតនាយករដ្ឋមន្ត្រី និងជាមេបក្សជំទាស់ និយាយទៅកាន់សភាក្នុងពេលពិភាក្សាជេញដោលសុន្ទរកថារបស់លោក Thaksin ថា "គំនិតថ្មី សកម្មភាពថ្មី មិនមែនបានន័យថា វាសុទ្ធតែជាគំនិតត្រឹមត្រូវ ឬសកម្មភាពត្រឹមត្រូវទេ។ សូមលោកចាំថា ប្រទេសនេះមិនមែនមានស្តុកស្តម្ភដូចលោកឯងទេ"។

លោក Chuan និយាយថាការបង្កើតក្រុមហ៊ុនគ្រប់គ្រងសម្បត្តិឲ្យចាត់ចែងបំណុលរបស់ធនាគារឯកជន បានត្រឹមតែជួយដល់ធុរជនជាអ្នកមាន និងបន្ថែមបន្ទុកមកលើរដ្ឋាភិបាលតែប៉ុណ្ណោះ។

លោក Chuan និយាយថា "លោកឯងគ្មានសិទ្ធិអ្វីមកប្រើប្រាស់លុយរបស់អ្នកបង់ពន្ធទៅជួយអ្នកមានទេ"។

*សារតារស្តីពីប្រវត្តិថ្មីៗនៃសេដ្ឋកិច្ចថៃ ជួយឲ្យអ្នកអានយល់អំពីបរិបទនៃអត្ថាធិប្បាយរបស់លោក Chuan និងបរិបទដែលលោក Thaksin កំពុងធ្វើគោលនយោបាយរបស់គាត់។ រឿងនេះវាមានលក្ខណៈពេញ-លេញរួចហើយ។ កាសែតណាដែលនៅសល់ប្រឡោះអាចចុះផ្សាយផ្នែកនៅសេសសល់របស់*

សេដ្ឋកិច្ចថៃ ដែលធ្លាប់លូតលាស់ខ្លាំង បានធ្លាក់ចុះយ៉ាងគំហុកក្នុងអំឡុងវិបត្តិហិរញ្ញវត្ថុអាស៊ី ឆ្នាំ ១៩៩៧-៩៨ នៅពេលក្រុមវិនិយោគបរទេស ដែលជាសរសៃឈាមសម្រាប់ផលិតកម្ម និងការនាំចេញបានដកខ្លួនពីប្រទេសថៃ។ វិបត្តិនេះ ក៏បានលាតត្រដាងផងដែរនូវបក្សពួកនិយម ញាតិសន្តាននិយម និងអំពើពុករលួយសាយភាយក្នុងវិស័យហិរញ្ញវត្ថុ ដែលកំពុងតែត្រដររងើបឡើងវិញនៅឡើយ។ លោក Thaksin និយាយថា "កិច្ចការបន្ទាន់ និងសំខាន់បំផុតរបស់រដ្ឋាភិបាល គឺពន្លឿនការដោះស្រាយបញ្ហាសេដ្ឋកិច្ចដោយប្តូរនូវរចនាសម្ព័ន្ធសេដ្ឋកិច្ច រដ្ឋបាល សង្គម និងនយោបាយ។ កិច្ចការទាំងអស់នេះ ត្រូវតែបានអនុវត្តន៍ឡើងព្រមពេលជាមួយគ្នាតែម្តង"។

*រឿងដែលនិយាយអំពីចំណុចលម្អិតទាំងឡាយដែលមិនសូវមានសារៈសំខាន់ទាក់ទិននឹងគោលនយោបាយរបស់លោក Thaksin និងអាចថែមបាននូវការរិះគន់ពីអ្នកដទៃណាម្នាក់ទៀតផងដែរ។*

ក្នុងចំណោមកិច្ចសន្យាដែលគាត់បានធ្វើ មានការបង្កើតធនាគារភូមិផ្តល់កម្ចីឥណទានដល់ធុរកិច្ចតូចតាច អភិវឌ្ឍន៍សហគ្រិនផ្ទះខ្នាតតូចដែលដឹកនាំដោយអ្នកអាជីព ដែលមិនស្ថិតក្រោមអន្តរាគមន៍នយោបាយ បង្ក្រាបការជួញដូរគ្រឿងញៀន និងលើកទឹកចិត្តដល់ការចូលរួមរបស់មហាជនក្នុងយុទ្ធនាការរបស់រដ្ឋាភិបាលប្រឆាំងនឹងអំពើពុករលួយ។

គាត់ក៏បានសន្យាផងដែរថា នឹងបង្កើនវិន័យសារពើពន្ធ ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បីកាត់បន្ថយចំណាយរដ្ឋ និងដើម្បីធ្វើឲ្យប្រព័ន្ធប្រមូលពន្ធកាន់តែមានប្រសើរជាងមុន។

កាលពីថ្ងៃអាទិត្យកន្លងទៅនេះ អនុប្រធានគណបក្សដៃគូរដ្ឋាភិបាលចម្រុះរបស់ លោក Thaksin បានបន្ថែមសម្លេងរបស់គាត់ទៅក្នុងការបំពងការរិះគន់ទៅលើការរិះគន់ចំពោះគោលនយោបាយប្រជាភិថុត។

លោក Chalerm Yubamrung អនុប្រធានគណបក្ស New Aspiration Party និយាយថា ការសន្យារបស់លោក Thaksin គាត់តែងឡើង ដើម្បីអូសទាញសម្លេងឆ្នោត ហើយជាផលចុងក្រោយវានឹងកាន់តែបង្កើនបន្ទុកបំណុលសាធារណៈថែមទៀត។ គាត់និយាយថា គោលនយោបាយសំដៅបញ្ចប់ បំណុលនៅជនបទមិនមែនជារឿងថ្មីទេ ហើយវាតែងតែមិនមានការគិតគូរឲ្យបានល្អជាមុនឡើយ។



*គោលបំណងនៃពិធីមួយសំខាន់ដូចគ្នានឹងវត្តមាននៃអ្នកចូលរួមដែរ*

រឿងនេះនឹងកាន់តែខ្លាំង សាមញ្ញ និងច្បាស់ជាងមុនថែមទៀត បើគេគ្រាន់តែនិពន្ធកែសម្រួលវាបន្តិចបន្តួច។ ឧទាហរណ៍ គេអាចកែសេចក្ដីផ្ដើមឲ្យទៅជា ៖

*លោកនាយករដ្ឋមន្ត្រី Thaksin Shinawatra បានប្រកាសគោលនយោបាយសេដ្ឋកិច្ច និងសង្គមនៃរដ្ឋាភិបាលថ្មីរបស់គាត់កាលពីថ្ងៃច័ន្ទ ដោយធ្វើការសន្យាយ៉ាងច្រើន ដែលអ្នករិះគន់និយាយថា វានឹងពិបាកបំពេញបានណាស់។*

តែទោះជាយ៉ាងណាក៏ដោយ រឿងនេះនៅតែជាគំរូល្អមួយសម្រាប់គិត មុនឈានទៅសរសេររឿងអំពីសុន្ទរកថាណាមួយ។

## ពិធីផ្លូវការ

អ្នកយកព័ត៌មានច្រើនប្រព្រឹត្តកំហុសក្នុងការយកព័ត៌មានពិធីផ្លូវការ ដូចគ្នានឹងកំហុសក្នុងការយកព័ត៌មានអំពីសុន្ទរកថា និងសន្និសីទព័ត៌មានដែរ។ សេចក្ដីផ្ដើមរបស់គេ ច្រើនតែផ្ដោតទៅលើមន្ត្រីជាន់ខ្ពស់ចូលរួមក្នុងអង្គពិធី និងថា តើមន្ត្រីនោះដឹកនាំធ្វើជាអធិបតីនៃអង្គពិធីនោះដូចម្ដេចខ្លះ។ តើអាហ្នឹងជារឿងមែនឬ? ចុះចំណែកឯសាលារៀនមួយថ្មី ដែលទើបតែនឹងត្រូវបានសម្ពោធនោះវាយ៉ាងម៉េចទៅវិញ? តើវាមានន័យថា ក្មេងៗក្នុងភូមិនឹងមានលទ្ធភាពទៅចូលរៀនជាលើកដំបូងឬយ៉ាងណា?

ជានិច្ចកាលត្រូវគិតថា ៖ *ស្អីសំខាន់ជាងគេដែលបានកើតនៅទីនេះ ហើយថាតើវាមានឥទ្ធិពលយ៉ាងណាខ្លះទៅលើមនុស្សម្នាក្បែរនោះ?*

ថ្មីៗនេះ សិស្សសារព័ត៌មានមួយក្រុមមកពីប្រទេសមីយ៉ាន់ម៉ា ត្រូវបានគេប្រគល់ឲ្យនូវកំណត់ហេតុមួយចំនួន ដើម្បីសរសេររឿងមួយ (ជាលក្ខណៈសមតិកម្ម) អំពីការសម្ពោធរោងភាពយន្តថ្មីមួយនៅក្រុង Moulmein នៅប៉ែកខាងកើតប្រទេសមីយ៉ាន់ម៉ា។ ភាគច្រើននៃសេចក្ដីផ្ដើមរបស់គេផ្ដោតទៅលើមន្ត្រីយោធាម្នាក់ ដែលជាគណៈអធិបតីក្នុងពិធីនោះ។ សេចក្ដីផ្ដើមមួយសរសេរថា មន្ត្រីយោធានោះ "បានកាត់ខ្សែបូនៅខាងមុខរោងភាពយន្តថ្មី ហើយផ្ដល់អំណោយដល់មនុស្សគ្រប់គ្នាដែលមានវត្តមាននៅទៅនោះ"។

តាមពិតទៅ អ្វីដែលសំខាន់ និងគួរចាប់អារម្មណ៍នោះ គឺនៅត្រង់ថាតើការសម្ពោធនេះនឹងមានឥទ្ធិពលមកលើប្រជាជនដូចម្ដេចខ្លះ ៖

*មានមនុស្សម្នាចូលចិត្តភាពយន្តប្រមាណ ៤០០ នាក់ បានប្រញាប់ប្រញាល់ទៅកាន់រោងភាពយន្ត Superstar Movie កាលពីថ្ងៃច័ន្ទនេះ ដែលជារោងភាពយន្តលើកដំបូង ដែលត្រូវបានសម្ពោធនៅក្រុង Moulmein ចាប់តាំងពីឆ្នាំ ១៩៧១ មក។*

# ជំពូកទី ១៤ ការសរសេរសម្រាប់ការផ្សាយតាមរលកធាតុអាកាស

អ្នកសារព័ត៌មានការផ្សាយតាមរលកធាតុអាកាសអាចប្រើបានភាគច្រើននៃគោលការណ៍ទាំងឡាយស្ដីពីការយកព័ត៌មាន និងសរសេរព័ត៌មាន ដែលយើងបានពិភាក្សាកន្លងមកនេះ។ ក៏ប៉ុន្តែមានភាពខុសគ្នាសំខាន់ៗមួយចំនួន រវាងការសរសេរសម្រាប់សារព័ត៌មានបោះពុម្ព និងសារព័ត៌មានផ្សាយតាមរលកធាតុអាកាស។

អ្នកសារព័ត៌មានផ្នែកបោះពុម្ព សរសេររឿងដែលអ្នកអានរបស់គេពេលយកទៅអាន អាចប្រមើលឃើញនូវរូបភាព អំពីទិដ្ឋភាពនានានៅក្នុងសតិបាន។ រីឯអ្នកសារព័ត៌មានផ្សាយតាមរលកធាតុអាកាសវិញ គេនិយាយទៅកាន់អ្នកស្ដាប់ និងទស្សនិកជនរបស់គេ។

អ្នកសារព័ត៌មានវិទ្យុ និងទូរទស្សន៍ ចាក់ផ្សាយខ្សែអាត់ ឬបង្ហាញរូបថត ឬវីដេអូព្រឹត្តិការណ៍ដំណឹង ដើម្បីឲ្យអ្នកស្ដាប់ និងទស្សនិកជនរបស់គេអាចឮ ឬមើលឃើញព្រឹត្តិការណ៍នោះដោយផ្ទាល់តែម្ដង។ អ្នកសារព័ត៌មានការផ្សាយដែលចំណានៗ គេមិនពិពណ៌នារ៉ាយរ៉ាប់អំពីខ្សែអាត់ វីដេអូ ឬរូបភាពដែលគេថតបាននោះទេ។ ផ្ទុយទៅវិញ គេជួយធ្វើការពន្យល់ឲ្យអ្នកស្ដាប់ និងទស្សនិកជនរបស់គេយល់អំពីអំពីខ្សែអាត់ វីដេអូ និងរូបភាពទាំងនោះ។



*រឿងផ្សាយតាមរលកធាតុអាកាសត្រូវតែធ្វើយ៉ាងណាឲ្យងាយយល់ភ្លាមៗ*

# សរសេរការផ្សាយឲ្យបានច្បាស់ ព្រោះឱកាសមានតែម្តងទេ

អ្នកអានកាសែតអាចចំណាយពេលច្រើនប៉ុន្មានដងក៏បានដែរសម្រាប់អានរឿងមួយ។ ពួកគេអាចវិលទៅអានរឿងមួយដដែលហ្នឹងពីរ ឬបីដងក៏បានដែរ។ តែចំពោះអ្នកស្តាប់វិទ្យុ ឬទូរទស្សនិកជនវិញ មិនអាចធ្វើដូច្នេះបានទេ។ ពួកគេមានឱកាសតែម្តងទេ សម្រាប់ស្តាប់ឮរឿងផ្សាយតាមរលកធាតុអាកាស។ ម៉្យាងវិញទៀត រឿងនីមួយៗដែលផ្សាយតាមវិទ្យុ ឬទូរទស្សន៍ច្រើនតែខ្លីៗ។ អ្នកសារព័ត៌មានការផ្សាយតាមរលកធាតុអាកាសមានពេលតិចណាស់ សម្រាប់ប្រាប់រឿងរបស់គេទៅកាន់អ្នកស្តាប់ និងទូរទស្សនិកជន។

នេះមានន័យថា អ្នកសារព័ត៌មានការផ្សាយតាមរលកធាតុអាកាស ត្រូវតែសរសេរឲ្យបានកាន់តែច្បាស់ កាន់តែសង្ខេប និងកាន់តែសម្រាំងខ្លាំងណាស់ក្នុងការយករឿងមកផ្សាយ។ គេត្រូវប្រើភាសាសាមញ្ញសម្រាប់មហាជនទូទៅហើយ ប្រើវាក្នុងស្ទីលសន្ទនា។ ការប្រើឃ្លាក្នុងទម្រង់ត្រង់ហើយសាមញ្ញជាប្រការល្អបំផុត។ ឃ្លាមួយត្រូវហូរទៅកាន់ឃ្លាមួយទៀត ប្រៀបដូចជាយើងនិយាយប្រាប់អ្នកណាម្នាក់អំពីព្រឹត្តិការណ៍នោះដូច្នោះ។ ពេលដែលឮការផ្សាយ អ្នកស្តាប់ត្រូវតែអាចយល់សាច់រឿងបានពេញលេញភ្លាមៗ។

សម្រាំងយកតែព័ត៌មានដែលសំខាន់បំផុតពីឯកសារ ឬពីសន្និសីទ ឬច្បិចយកតែមូលបទសំខាន់បំផុតចេញពីព្រឹត្តិការណ៍ស្មុគស្មាញណាមួយទៅបានហើយ។ បន្ទាប់មកទៀត បង្ហាញព័ត៌មាន ឬមូលបទសំខាន់បំផុតក្នុងឃ្លាពីរ ឬបីដំបូងនៃរឿង។ ធ្វើដូច្នេះ អ្នកស្តាប់ និងទូរទស្សនិកជននឹងយល់បានភ្លាមថាហេតុអ្វីបានជារឿងនេះសំខាន់ ឬគួរជាទីចាប់អារម្មណ៍ ហើយពួកគេនឹងបន្តស្តាប់តទៅទៀត។

សាវតារ និងសេចក្តីក្បោះក្បាយលម្អិតផ្សេងទៀត ដូចជាអាយុមនុស្ស អាសយដ្ឋាន ស្ថិតិ ជាដើម ដែលយើងធ្លាប់ឃើញក្នុងអត្ថបទកាសែត មិនបាច់យកមកបញ្ចូលក្នុងអត្ថបទផ្សាយតាមរលកធាតុអាកាសទេ។ ព័ត៌មានបែបនេះនឹងធ្វើឲ្យអត្ថបទរឿងផ្សាយតាមរលកធាតុអាកាសកាន់តែវែង និងសាំញ៉ាំថែមទៀតតែប៉ុណ្ណោះ។

## ផ្តោតលើបច្ចុប្បន្នកាល

ពេលដែលមនុស្សម្នាបើកវិទ្យុ ឬទូរទស្សន៍ ឬ ដោនឡូតផត់ខាសត៍ពីអ៊ីនធឺណិត ពួកគេពិតជាចង់បានព័ត៌មានថ្មីបំផុត ព័ត៌មានដែលកើតក្នុងថ្ងៃនោះម៉ោងនោះតែម្តង។ ដូច្នេះ អ្នកសារព័ត៌មានផ្សាយតាមរលកធាតុអាកាសត្រូវផ្តោតទៅលើសភាពការណ៍ថ្មីៗបំផុត។

## វិធានមួយចំនួនសម្រាប់អនុវត្តន៍

ដើម្បីសរសេររឿងល្អមួយសម្រាប់ការផ្សាយតាមរលកធាតុអាកាស គេត្រូវ ៖

- រក្សាឃ្លានីមួយៗឲ្យខ្លី ហើយប្រើសំណង់ឃ្លាតាមទម្រង់សាមញ្ញ គឺទម្រង់ប្រធាន-កិរិយាស័ព្ទ-កម្មបទ។
- បង្ហាញតែគំនិតមួយបានហើយក្នុងឃ្លាមួយ។
- ប្រើកិរិយាស័ព្ទដែលប្រកបដោយអត្ថន័យខ្លាំង ហើយប្រើគុណនាម និងកិរិយាវិសេសតែពេលណាចាំបាច់បានហើយ។
- ពេលណាដែលអាចធ្វើទៅបាន ប្រើឃ្លាក្នុងបច្ចុប្បន្នកាល ដើម្បីធ្វើឲ្យឃ្លាមានឥទ្ធិពលនឹងភាពបន្ទាន់។
- ចៀសវាងការប្រើពាក្យស្មុគស្មាញដែលជនទូទៅមិនយល់។ ចៀសវាងភាសាផ្លូវការ



*រូបភាពក្នុងទូរទស្សន៍វាជំនួសឲ្យការសរសេររ៉ាយរ៉ាប់*

ដែលមន្ត្រីរដ្ឋាភិបាល និង "អ្នកជំនាញ" បច្ចេកទេសចូលចិត្តប្រើ។ ចូរប្រើពាក្យ "carry out" ជំនួសឲ្យ "implement" ឬ "buildings" ជំនួសឲ្យ "facilities"។

- ជាទូទៅ គួរចាប់ផ្តើមឃ្លាជាមួយនឹងប្រភពព័ត៌មាន។ ធ្វើដូច្នេះ វាងាយសម្រាប់អ្នកស្តាប់តាមព័ត៌មាន។ វាខុសគ្នាទៅនឹងអត្ថបទបោះពុម្ព ដែលគេច្រើនតែដាក់ប្រភពនៅខាងចុងឃ្លាទៅវិញ។
- ដាក់ពាក្យដែលសំខាន់បំផុតនៅដើមឃ្លា។ កុំសរសេរថា "ការប្រែប្រួលក្នុងស្ថានភាពដីកំពុងតែបង្កការលំបាកដល់អ្នកស្រុកក្នុងការដាំដុះស្បៀងអាហារ " (Changes in the soil are making it more difficult for the villagers to grow food)។ ចូរសរសេរបែបនេះវិញ "ការដាំដុះស្បៀងអាហារកាន់តែជួបការលំបាកសម្រាប់អ្នកស្រុក ដោយសារតែការប្រែប្រួលក្នុងស្ថានភាពដី" (Growing food is now more difficult for the villagers because of changes in the soil)។
- បំព្រួញឲ្យខ្លីនូវងាររបស់មន្ត្រី ឬឈ្មោះរបស់អង្គការដែលវែងៗ។ ជំនួសឲ្យការសរសេរថា "នាយកផ្នែកនាំចេញនៃនាយកដ្ឋានគយ" គ្រាន់តែសរសេថា "មន្ត្រីគយ" ទៅបានហើយ។

ចូរក្រឡេកមើលឧទាហរណ៍ខាងក្រោម ដែលជារឿងក្នុងការផ្សាយមួយតាមទូរទស្សន៍នៅប្រទេសមីយ៉ាន់ម៉ា ៖

*ឧត្តមសេនីយទោ Sein Htwa រដ្ឋមន្ត្រីក្រសួងសុខុមាលភាពសង្គម សង្គ្រោះបន្ទាន់ និងការតាំងទីលំនៅ បានទទួលគណៈប្រតិភូរបស់បេសកកម្មគម្រោង Southeast Asia Region Human Trafficking Elimination ASEAN-Australia Project Identification ដែលដឹកនាំដោយបណ្ឌិត Dr. Michael Dalton នៅសណ្ឋាគារ Mya Yeik Nyo Royal Hotel's Pyaysaung នៅវេលាម៉ោង ១៨:៣០ នាទី ម៉ោងនៅក្នុងស្រុក។*

សេចក្តីផ្តើមនេះវែងអន្លាយហើយស្មុគស្មាញ រួមដោយឈ្មោះវែងៗបី និងពាក្យពេចន៍ ដែលមានអ្នកស្តាប់តិចនាក់ណាស់ ដែលអាចយល់បាន។ តើស្អីជាដំណឹងនៅក្នុងនេះ? តើការដែលមានកិច្ចជំនួបនោះឬ? តើពួកគេបាននិយាយអំពីអ្វីខ្លះ? តើពួកគេបានឯកភាពគ្នាបាត់វិធានការអ្វីមួយទេ? ហើយក្រុមនេះជាអ្នកណាទៅ ហើយថាហេតុអ្វីបានជាពួកគេមកធ្វើទស្សនកិច្ចនៅប្រទេសមីយ៉ាន់ម៉ា?

ប្រយោគទីពីរនៃអត្ថបទនេះបានរាយយ៉ាងវែងអន្លាយនូវឈ្មោះ និងងារមន្ត្រីប្រាំពីរនាក់ ដែលលោកឧត្តមសេនីយទោបានអញ្ជើញចូលរួមអាហារពេលល្ងាច។ ឯកថាខណ្ឌទីបី មានរាយឈ្មោះមន្ត្រីពីរនាក់ទៀត និងកន្លែងមួយចំនួនដែលគណៈប្រតិភូបានទៅទស្សនា។

តើអ្នកស្តាប់អាចយល់សាច់រឿងបានទេ?

ឥឡូវនេះ ចូរក្រឡេកមើលរឿងពីរទៀតដែលយើងបានឃើញរួចមកហើយនៅខាងដើមសៀវភៅនេះ ហើយគិតមើលថា តើយើងអាចប្រែក្លាយវាឲ្យទៅជាអត្ថបទរឿងសម្រាប់ការផ្សាយតាមរលកជាតុអាកាស ដោយរបៀបណា។

ខាងឆ្វេងជាអត្ថបទដើមសម្រាប់ការបោះពុម្ព។ នៅខាងស្តាំ យើងសូមបង្ហាញរបៀបមួយដែលគេអាចសរសេរអត្ថបទនេះសម្រាប់ការផ្សាយតាមរលកជាតុអាកាស។

### *សំណេរអត្ថបទបោះពុម្ព*

លោក ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និយាយកាលពីម្សិលមិញថា ការធ្លាក់ចុះនៃសេដ្ឋកិច្ច របស់សហរដ្ឋអាមេរិក បានបង្ខំឲ្យរោងចក្រកាត់ដេរ ចំនួន ១២ បិទទ្វារជាបណ្ដោះអាសន្នក្នុងឆ្នាំនេះ។

លោករដ្ឋមន្ត្រីនិយាយថា កម្មករកាត់ដេរប្រមាណ ៣.០០០ នាក់ ត្រូវបានផ្អាកពីការងារជាបណ្ដោះ-អាសន្ន ហើយថានឹងមានការងារច្រើនថែមទៀត ដែលនឹងអាចបាត់បង់ បើសិនជាស្ថានភាពមិនមាន ភាពប្រសើរឡើងវិញទេនោះ។

លោករដ្ឋមន្ត្រីបានបន្ថែមទៀតថា ទន្ទឹមនឹងនេះ កម្មកររាប់ពាន់នាក់ទៀត ត្រូវបានបង្ខំចិត្តធ្វើការ តិចម៉ោងជាងមុន ដោយសារថារោងចក្រជាង ២០០ បានកាត់បន្ថយម៉ោងថែម និងវេនការងារពី ពីរវេនមកមួយវេនវិញ។

លោករដ្ឋមន្ត្រីនិយាយថា "បញ្ហាសេដ្ឋកិច្ចនៅ សហរដ្ឋអាមេរិក ធ្វើឲ្យយើងមានកង្វល់ច្រើនអំពី ប្រតិបត្តិការរបស់រោងចក្រ និងការងាររបស់ កម្មករ"។

ឧស្សាហកម្មកាត់ដេរនៅកម្ពុជាមានកម្មករធ្វើការ ប្រមាណ ២០០.០០០ នាក់ ដែលម្នាក់ៗរកចំណូល បានជាមធ្យមតែ ៤០ ដុល្លារអាមេរិក តែប៉ុណ្ណោះ ក្នុងមួយខែ។ ជាង ៨០ ភាគរយ នៃផលិតផល របស់ឧស្សាហកម្មនេះ ត្រូវបានគេដឹកទៅលក់នៅ សហរដ្ឋអាមេរិក។

លោករដ្ឋមន្ត្រីនិយាយថា ជាងពាក់កណ្ដាលឆ្នាំ បានកន្លងផុតទៅហើយ ប៉ុន្តែកូតាប្រចាំឆ្នាំសម្រាប់ ការនាំចេញផលិតផលកាត់ដេរទៅសហរដ្ឋអាមេរិក បំពេញមិនបាន ៤០ ភាគរយផង។ គាត់បានបន្ថែម ទៀតថា កូតាក្នុងការនាំចេញផលិតផលកាត់ដេរ ទៅសហរដ្ឋអាមេរិកនេះ សឹងត្រូវបានបំពេញរួចបាត់ ទៅហើយ ត្រឹមខែមិថុនា ឆ្នាំកន្លងទៅនេះ។

### *សំណេរផ្សាយតាមរលកធាតុអាកាស*

*រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មប្រទេសកម្ពុជា និយាយថា រោងចក្រកាត់ដេរចំនួន ១២ បានបិទ ទ្វារជាបណ្ដោះអាសន្នក្នុងឆ្នាំនេះ ដែលបណ្ដាល ឲ្យកម្មករ ៣.០០០ នាក់ បាត់បង់ការងារធ្វើ។*

*លោក ចម ប្រសិទ្ធ ថ្ងៃនេះ បានបន្ទោស ការបិទទ្វារនេះ ទៅលើការធ្លាក់ចុះសេដ្ឋកិច្ចនៅ សហរដ្ឋអាមេរិក។ ហើយគាត់និយាយទៀតថា ការងារច្រើនទៀតនឹងត្រូវបាត់បង់ បើសិនជា ស្ថានភាពមិនមានភាពប្រសើរឡើងវិញទេ។*

*លោករដ្ឋមន្ត្រីនិយាយថា មានកម្មកររាប់ពាន់ នាក់ទៀត ដែលកំពុងធ្វើការម៉ោងកាន់តែតិចជាង មុន ដោយសាររោងចក្រកាត់ដេរជាង ២០០ ក្នុង ប្រទេសបានកាត់បន្ថយវេន និងការងារលើសម៉ោង។*

*ឧស្សាហកម្មកាត់ដេរប្រទេសកម្ពុជា ជួល កម្មករជាង ២០០.០០០ នាក់។ ជាង ៨០ ភាគរយ នៃផលិតផលកាត់ដេរ ត្រូវបានគេនាំចេញទៅលក់ នៅសហរដ្ឋអាមេរិក។ លោក ចម ប្រសិទ្ធ និយាយ ថា គាត់កំពុងមានក្ដីបារម្ភចំពោះសុខុមាលភាព ទាំងរបស់ប្រតិបត្តិកររោងចក្រ និងកម្មករ។*

[ឧទាហរណ៍នេះបង្ហាញឲ្យឃើញយ៉ាងច្បាស់ ថា សំណេររឿងដដែល តែសម្រាប់ផ្សាយតាម រលកធាតុអាកាស មានភាពស្រាល និងសង្ខេប ជាងសំណេរបោះពុម្ព។ សំណេររឿងផ្សាយ តាមរលកធាតុអាកាសមួយនេះ មានប្រវែង ៤០ ភាគរយ ខ្លីជាងសំណេរដើមដែលសម្រាប់ បោះពុម្ព។]

ក្នុងរឿងសម្រាប់ផ្សាយតាមរលកធាតុអាកាស យើងធ្វើឲ្យអ្នកស្តាប់របស់យើងចាប់អារម្មណ៍នឹងសេចក្តីផ្តើមដែលមានអង្គហេតុខ្លី តែច្បាស់។ ចូរសង្កេតមើលសំណង់ឃ្លា ដែលមានលក្ខណៈសាមញ្ញ។

យើងផ្តើមជាមួយលោករដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ហើយធ្វើដូច្នេះ អ្នកស្តាប់ដឹងបានភ្លាមនូវប្រភពព័ត៌មាន។ សេចក្តីផ្តើមក្នុងសំណេរដើមសម្រាប់បោះពុម្ព បានលើកឡើងអំពីរោងចក្រផងនិងសេដ្ឋកិច្ចអាមេរិកផង។ រីឯក្នុងសំណេរសម្រាប់ការផ្សាយតាមរលកធាតុអាកាសវិញ ការលើកឡើងអំពីសេដ្ឋកិច្ចអាមេរិក ត្រូវបានទុកសម្រាប់កថាខណ្ឌទីពីរវិញ ដើម្បីទុកសេចក្តីផ្តើមឲ្យនៅខ្លី និងងាយអាន។ ដោយហេតុផលដូចគ្នានេះដែរ យើងទុកឈ្មោះលោករដ្ឋមន្ត្រីមកដាក់នៅក្នុងកថាខណ្ឌទីពីរវិញ។

ក្នុងកថាខណ្ឌទីពីរ យើងបង្ហាញយ៉ាងច្បាស់នូវឈ្មោះលោករដ្ឋមន្ត្រី និងកាលវេលាដែលគាត់និយាយ។ យើងប្រើ "ថ្ងៃនេះ" ពីព្រោះអ្នកយកព័ត៌មានការផ្សាយតាមរលកធាតុអាកាស នឹងចាំបាច់ត្រូវផ្សាយរឿងរបស់គាត់ក្នុងថ្ងៃជាមួយគ្នា ដែលព្រឹត្តិការណ៍បានកើតឡើង។

ក្នុងកថាខណ្ឌទីបី ពាក្យ "ហើយ" ជាស្ពានចម្លងទៅកាន់ព័ត៌មានបន្ទាប់ទៀត។ ក្នុងសារព័ត៌មានផ្សាយតាមរលកធាតុអាកាស វាជាប្រការល្អក្នុងការផ្តើមឃ្លាជាមួយពាក្យ "ហើយ" ដើម្បីរក្សាឃ្លាឲ្យនៅខ្លី។

ក្នុងកថាខណ្ឌទីបួន ជាថ្មីម្តងទៀតយើងប្រើឃ្លាក្នុងបច្ចុប្បន្នកាល ដើម្បីប្រាប់អ្នកអានថា ព្រឹត្តិការណ៍ទាំងអស់នឹងកំពុងតែកើតឡើងក្នុងថ្ងៃនេះតែម្តង។

ក្នុងកថាខណ្ឌចុងក្រោយ យើងប្រើសារតារតិចតួចជាងក្នុងសំណេរការផ្សាយបោះពុម្ពទៅទៀត ពីព្រោះ ទីមួយ យើងមានពេលតិចក្នុងមាតិកាការផ្សាយតាមរលកធាតុអាកាស និងទីពីរ អ្នកស្តាប់នឹងមិនចងចាំសេចក្តីក្បោះក្បាយច្រើននោះទេ។

ខាងក្រោមនេះ ជាសំណេរបោះពុម្ពមួយទៀតសម្រាប់ជាឧទាហរណ៍។

***អ្នកបើកតាក់ស៊ីខឹងសម្បានាំគ្នាខ្ទប់ចរាចរផ្លូវជាតិលេខ 6A***

*អ្នកបើកតាក់ស៊ីប្រហែល ២០ នាក់ដែលខឹងសម្បានឹងវិធានការថ្មីរបស់សាលាក្រុង ដែលហាមប្រាមតាក់ស៊ីមិនឲ្យចូលក្រុង នាំគ្នាខ្ទប់ផ្លូវជាតិលេខ 6A ធ្វើឲ្យចរាចរស្ទះអស់ពេលមួយម៉ោងកាលពីថ្ងៃអង្គារ៍នេះ។*



*អ្នកណាក៏ចង់ជំនះការកកស្ទះចរាចរដែរ*

*រថយន្តពន្លត់អគ្គីភ័យប្រាំមួយគ្រឿង ត្រូវបានគេបញ្ជូនទៅកាន់ទីនោះ ដើម្បីបំបែកក្រុមអ្នកបើកតាក់ស៊ី ដែលពេលនោះ កំពុងប្រកែកគ្នាជាមួយនគរបាល និងអាជ្ញាធរ ដែលព្យាយាមហាមពួកគេមិនឲ្យបើកឡានចូលក្នុងក្រុង ។*

*ថ្ងៃអង្គារ៍ គឺជាថ្ងៃដែលចាប់ផ្តើមការហាមប្រាមរបស់សាលាក្រុងមិនឲ្យតាក់ស៊ីមកពីបណ្តាខេត្តភាគខាងជើងចូលក្នុងទីក្រុងទេ ។ មន្ត្រីបាននិយាយថា ការហាមប្រាមនេះត្រូវបានធ្វើឡើង ដើម្បីសម្រាលនូវការកកស្ទះចរាចរ និងរក្សាសោភ័ណភាពរបស់ទីក្រុង ។*

*រថយន្តតាក់ស៊ីទាំងអស់ ត្រូវបានតម្រូវឲ្យឈប់សំចតនៅផ្សារព្រែកលាប ដែលស្ថិតនៅចម្ងាយប្រមាណ ៥ គីឡូម៉ែត្រពីក្រុង ហើយផ្ទេរអ្នកដំណើររបស់ខ្លួនមករថយន្តប៊ីស ដែលនឹងដឹកជញ្ជូនពួកគេមកកាន់ភ្នំពេញ ។*

*អ្នកបើកតាក់ស៊ីនិយាយថា វាមិនត្រឹមត្រូវយុត្តិធម៌ទេ ប្រសិនបើក្រុមហ៊ុន Ho Wah Genting Transport Co. មកពីប្រទេសម៉ាឡេស៊ី មានអាជ្ញាប័ណ្ណដឹកអ្នកដំណើរពីភ្នំពេញ ទៅព្រែកលាប និងពីព្រែកលាប ទៅកាន់បណ្តាខេត្តផងនោះ ។*

*លោក ហួន ហាក់ ដែលបើកតាក់ស៊ីដឹកអ្នកដំណើរទៅមកខេត្តកំពង់ចាម និយាយថា "ប្រសិនបើក្រុមហ៊ុន Ho Wah បានការអនុញ្ញាតធ្វើអញ្ចឹង ពួកយើងដែលជាអ្នកបើកបរតាក់ស៊ី នឹងរកលុយលែងបានហើយ ពីព្រោះអ្នកដំណើរនឹងចុះពីប៊ីសមួយទៅឡើងជិះប៊ីសមួយទៀត" ។*

*លោក ស៊ិន ភារម្យ ជំនួយការនាយកគ្រប់គ្រងក្រុមហ៊ុន Ho Wah និយាយថា អ្នកបើកតាក់ស៊ីមិនគួរលូកលាន់ក្នុងរឿងក្នុងកិច្ចការរបស់ក្រុមហ៊ុនទេ ពីព្រោះក្រុមហ៊ុនបានទទួលការអនុញ្ញាតរួចហើយពីសំណាក់ក្រសួងសាធារណៈការ និងពីសំណាក់សាលាក្រុង ឲ្យធ្វើប្រតិបត្តិការរថយន្តប៊ីស ។*

*គាត់និយាយថា ក្រុមហ៊ុនរបស់គាត់បានជួយទៅដល់អ្នកបើកតាក់ស៊ីរួចហើយ តាមរយៈការកាត់បន្ថយចំនួនដឹកជញ្ជូនរបស់ខ្លួនពីព្រែកលាបទៅកាន់បណ្តាខេត្ត ពីចំនួន ១២ ជើង មកត្រឹម ៧ ជើង ក្នុងមួយថ្ងៃ ។*

*លោក ស៊ិន ភារម្យ និយាយថា "បើយើងមិនអាចវិនិយោគនៅទីនេះបាន យើងនឹងចាកចេញពីទីនេះ ហើយយើងនឹងប្រាប់មិត្តភ័ក្តិយើងកុំឲ្យមក" ។*

*លោក ញ៉ែម សារ៉ែន ប្រធាននាយកដ្ឋានសាធារណៈការក្រុង និយាយថា អ្នកបើកបរតាក់ស៊ីគួរណាប្រឹងយកចិត្តទុកដាក់ក្នុងការបង្កើនគុណភាពសេវាកម្មរបស់ខ្លួនវិញ ជាជាងប្រឹងបន្ទោសក្រុមហ៊ុន Ho Wah ។*

*គាត់និយាយថា "ខ្ញុំគិតថាមនុស្សម្នាគេនឹងជ្រើសរើសយករថយន្តក្រុមហ៊ុន Ho Wah វិញហើយ ដោយសារថាវាមានសុវត្ថិភាព មានម៉ាស៊ីនត្រជាក់ និងមានផាសុកភាពផង" ។*

រឿងនេះ ក៏អាចយកទៅក្រឡៃចេញជាកញ្ចប់រឿងសម្រាប់ផ្សាយតាមរលកជាតុអាកាសបានដែរ ។ កញ្ចប់រឿង គឺជាការផ្តុំចូលគ្នាមុនការផ្សាយ ដែលក្នុងនោះ មានសម្លេងរបស់អ្នកយកព័ត៌មានយ៉ាងហោចណាស់សម្រង់សម្តីដើមមួយពីអ្នកណាម្នាក់ ដែលពាក់ព័ន្ធក្នុងរឿងនេះ ហើយពេលខ្លះបន្ថែមដោយសម្លេងនៅពីក្រោយនោះផង ។ រឿងពេងចក្រកាត់ដេរគ្រាន់តែជាសេចក្តីសង្ខេបការណ៍មួយចំនួនមួយប៉ុណ្ណោះ ដូច្នេះវាសក្តិសមនឹងការផ្សាយដោយសម្លេងតែមួយ ដោយអ្នកអានព័ត៌មានតែម្នាក់ ។

សម្រាប់កញ្ចប់ការផ្សាយមួយ ការសរសេរមិនចាំបាច់ថាឲ្យខ្លីមែនទែនដូចមាតិកាដំណឹងទេ ដោយសារថា អ្នកមានពេលច្រើនទៀតសម្រាប់បន្ថែមនូវសេចក្តីក្បោះក្បាយផ្សេងទៀត ។ ប៉ុន្តែក្បួនជាមូលដ្ឋាននៅប្រើដដែល គឺថាយើងត្រូវសរសេររឿងសម្រាប់ការ

ផ្សាយតាមរលកធាតុអាកាស តាមរបៀបមួយឲ្យសាមញ្ញ និងទំនងតាមតែអាចធ្វើទៅបាន។

សម្រាប់ការផលិតកញ្ចប់ការផ្សាយ អ្នកមានលទ្ធភាពប្រើសម្លេងដើមរបស់មនុស្សម្នា បញ្ចូលទៅក្នុងរឿងតែម្តង។ អ្នកគួរតែព្យាយាមទុកឲ្យមហាជននិយាយសាច់រឿងរបស់គេក្នុងសម្លេងដើមរបស់គេឲ្យបានវែងតាមតែអាចធ្វើទៅបាន។ សម្រង់សម្លេងដើមខ្លីៗក្នុងកញ្ចប់ការផ្សាយ ត្រូវបានគេឲ្យឈ្មោះថា "ក្លីប" (clips)។

ដូច្នេះ ចូរក្រឡេកមើលថា តើគេធ្វើរឿងនេះរបៀបម៉េច។

តែសូមកុំភ្លេចថា រឿងនេះកំពុងត្រូវបានផ្សាយក្នុងថ្ងៃជាមួយគ្នានឹងព្រឹត្តិការណ៍ដែរ។

*ជារឿយៗ គេទុកឲ្យអ្នកអានដំណឹងអានសេចក្តីផ្តើមណែនាំរឿងដល់អ្នកស្តាប់។ បន្ទាប់មកទៀត អ្នករាយការណ៍ព័ត៌មានផ្តល់សេចក្តីលម្អិតអំពីរឿងនោះ។ ចូរកត់សំគាល់ថា យើងទុកឈ្មោះផ្លូវជាតិទៅខាងក្រោយ ដើម្បីធ្វើឲ្យសេចក្តីផ្តើមមានភាពសាមញ្ញងាយយល់។ ក្នុងនេះ គេប្រើពាក្យធម្មតាៗ ដូចជា "បំបែក " (break up) ជំនួសឲ្យ "ដេញបង្ក្រាប " (disperse) "ព្យាយាម" (trying) ជំនួសឲ្យ "ប៉ុនប៉ង" (attempting) "ឡាន" (cars) ជំនួសឲ្យ "យានយន្ត" (vehicles) ហើយដូចគ្នានឹងរឿងបោះពុម្ពដែរ គេប្រើសារតារនៅប៉ែកខាងលើនៃរឿង ដើម្បីឲ្យអ្នកស្តាប់ងាយយល់ផង។*

***អ្នកអានដំណឹង***

*ថ្ងៃនេះ ចរាចរត្រូវបានរាំងខ្ទប់អស់ជាងមួយម៉ោងនៅលើផ្លូវជាតិមួយចូលមកកាន់រាជធានីភ្នំពេញ នៅពេលដែលមានអ្នកបើកតាក់ស៊ី ២០ នាក់ ខឹងសម្បា នាំគ្នាធ្វើបាតុកម្ម។ លោក កែ គឹមសុង អ្នកយកព័ត៌មានរបស់យើងធ្វើសេចក្តីរាយការណ៍ពីកន្លែងកើតហេតុ។*

***អ្នករាយការណ៍ព័ត៌មាន លោក កែ គឹមសុង***

*ការរាំងខ្ទប់ចរាចរលើផ្លូវជាតិ ៦អា ត្រូវបានបញ្ចប់បន្ទាប់ពីរថយន្តពន្លត់អគ្គីភ័យ ៦ គ្រឿង បានទៅដល់កន្លែងកើតហេតុ ដើម្បីបំបែកហ្វូងអ្នកបើកតាក់ស៊ី ដែលបានប្រកែកជាមួយនគរបាល ដែលព្យាយាមឃាត់រថយន្តរបស់ពួកគេមិនឲ្យចូលទៅកាន់ទីក្រុង។ ថ្ងៃនេះ ជាការចាប់ផ្តើមនៃបម្រាមរបស់ក្រុង មិនឲ្យរថយន្តតាក់ស៊ីមកពីបណ្តាខេត្តភាគខាងជើងចូលរាជធានីភ្នំពេញឡើយ។ មន្ត្រីសាលាក្រុងនិយាយថា បម្រាមនេះនឹងជួយកាត់បន្ថយភាពណែនណាន់ចរាចរ ហើយធ្វើឲ្យទីក្រុងកាន់តែមានសោភ័ណភាពជាងមុនថែមទៀត។ ឥឡូវនេះ តាក់ស៊ីត្រូវឈប់សំចតនៅផ្សារព្រែកលាប ចម្ងាយប្រហែល ៥ គីឡូម៉ែត្រ ខាងក្រៅរាជធានី។ បន្ទាប់មក អ្នកដំណើរត្រូវជិះរថយន្តប៊ីសបន្តមកកាន់រាជធានី។*

*មានអារម្មណ៍ទោមនស្សច្រើនណាស់ ជាពិសេសចំពោះក្រុមហ៊ុនដឹកជញ្ជូន Ho Wah Genting ដែលជាក្រុមហ៊ុនប៊ីសមកពីប្រទេសម៉ាឡេស៊ី ដែលបានទទួលអាជ្ញាប័ណ្ណដឹកជញ្ជូនអ្នកដំណើរពីភ្នំពេញទៅព្រែកលាប ហើយបន្តទៅតាមខេត្តផ្សេងៗទៀត។*

*លោក ហួន ហាក់ អ្នកបើកតាក់ស៊ីលើផ្លូវកំពង់ចាម ពន្យល់អំពីមូលហេតុការធ្វើបាតុកម្ម ដូច្នេះថា ៖*

***ឃ្លីបសម្ដីលោក ហួន ហាក់ ៖***

*ឃ្លីបសម្លេងរបស់លោក ហួន ហាក់ ធ្វើឲ្យយើងស្ដាប់ឮនូវភាពខឹងសម្បារបស់អ្នកបើកតាក់ស៊ី។ ដូច្នេះ ឥទ្ធិពលមនោរម្មណ៍របស់ការផ្សាយតាមរលកធាតុអាកាសមានសភាពខ្លាំងជាងអត្ថបទបោះពុម្ពផ្សាយ។*

*"ពួកគេកំពុងតែយកបាយចេញពីមាត់របស់យើងហើយ។ ប្រសិនបើគេអនុញ្ញាតឲ្យក្រុមហ៊ុន Ho Wah ធ្វើដូច្នេះពួកយើងអ្នកបើកតាក់ស៊ីនឹងរកលុយលែងបានទៀតហើយ ពីព្រោះអ្នកដំណើរនឹងចុះពីលើរថយន្តប៊ឹស ហើយទៅឡើងជិះអាមួយទៀតជាមិនខាន"។*

***សម្លេងលោក កែ គឹមសុង ម្ដងទៀត ៖***

*ក៏ប៉ុន្ដែមានប្រសាសន៍ក្នុងនាមឲ្យក្រុមហ៊ុនរថយន្តប៊ឹស លោក ស៊ីន ភារម្យ នាយកចាត់ចែងរបស់ក្រុមហ៊ុន បានធ្វើការជំទាស់ចំពោះទស្សនៈខាងលើយ៉ាងខ្លាំង។*

***ឃ្លីបសម្ដីរបស់លោក ស៊ីន ភារម្យ ៖***

*ឃ្លីបសម្លេងពីរទៀតជួយធ្វើឲ្យរឿងកាន់តែគួរឲ្យចាប់អារម្មណ៍ និងបន្ថែមតុល្យភាពឲ្យវាផងដែរ តាមរយៈការបង្ហាញនូវទស្សនៈខុសៗគ្នា។ រឿងមានទម្ងន់កាន់តែខ្លាំង ហើយយើងស្ដាប់ឮនូវសម្លេងរបស់មនុស្សនិយាយផ្ទាល់តែម្ដង។*

*"នែអ្នកទាំងអស់ហ្នឹង គ្មានសិទ្ធិអីមកលូកលាន់ក្នុងកិច្ចការរបស់យើងទេ។ យើងទទួលបានការអនុញ្ញាតពីក្រសួងសាធារណៈការ និងសាលាក្រុងសម្រាប់រត់ប៊ឹសដឹកអ្នកដំណើរ។ យើងបានជួយដល់ពួកដល់អ្នកបើកតាក់ស៊ីរួចហើយ ដោយបន្ថយចំនួនជើងដឹកជញ្ជូនរបស់ក្រុមហ៊ុនពី ១២ ជើង មកត្រឹម ៧ ជើង ក្នុងមួយថ្ងៃ។ បើយើងមិនអាចវិនិយោគបាននៅទីនេះ យើងនឹងចាកចេញទៅវិញ ហើយប្រាប់មិត្តរបស់យើងថាកុំឲ្យមកទីនេះទៀត"។*

***អ្នករាយការណ៍ព័ត៌មាន លោក កែ គឹមសុង ៖***

*ហើយលោក ញ៉េម សារ៉ែន ប្រធាននាយកដ្ឋានសាធារណៈការក្រុងហាក់ដូចជាមានសមានចិត្តតិចតួចណាស់ ចំពោះការតវ៉ារបស់អ្នកបើកតាក់ស៊ី។*

***ឃ្លីបសម្ដីរបស់លោក ញ៉េម សារ៉ែន ៖***

*"ពួកគេគួរតែនាំគ្នាប្រឹងធ្វើការបង្កើនគុណភាពសេវាកម្មរបស់ខ្លួនវិញជាជាងបន្ទោសក្រុមហ៊ុន Ho Wah។ ខ្ញុំគិតថាមនុស្សម្នាគេនឹងជ្រើសរើសយករថយន្តក្រុមហ៊ុន Ho Wah វិញហើយ ដោយសារថាវាមានសុវត្ថិភាព មានម៉ាស៊ីនត្រជាក់ និងមានផាសុកភាពផង"។*

***សម្លេងលោក កែ គឹមសុង បញ្ចប់សេចក្ដីរាយការណ៍ ៖***

*សម្លេងបិទមិនបាច់មានក៏បានដែរ ប៉ុន្ដែបើមានជាប្រការល្អ ព្រោះវាបង្ហាញនូវការបញ្ចប់ដោយរលូននូវការផ្សាយរឿងមួយនេះ។*

*កែ គឹមសុង ធ្វើសេចក្ដីរាយការណ៍ពីចំណុចកើតហេតុ ដែលឥឡូវនេះចរាចរចូលទៅកាន់ទីក្រុងភ្នំពេញ ត្រូវបានបើកឲ្យដំណើរការឡើងវិញហើយ...*

# ភាគទី ៧

# ជំពូកទី ១៥ ក្រមសីលធម៌

## ការទទួលខុសត្រូវក្រមសីលធម៌

ពីដើមរហូតមកដល់ទីនេះ យើងបានជជែកអំពីជំនាញរបស់អ្នកសារព័ត៌មាន ៖ ការសង្កេត កត់ត្រា សរសេររឿង។ ប៉ុន្តែអ្នកសារព័ត៌មានល្អ ក៏ត្រូវប្រដាប់ដោយជំនាញលើសពីជំនាញបច្ចេកទេសទៅទៀតដែរ។ និយាយឲ្យចំ ពួកគេត្រូវមានក្រមសីលធម៌ ដោយដឹងភាពខុសគ្នារវាងអាកប្បកិរិយាត្រឹមត្រូវ និងខុសឆ្គង ហើយតែងព្យាយាមយកអស់សមត្ថភាពធ្វើអ្វីដែលត្រូវ។

នៅខាងដើមសៀវភៅនេះ យើងបាននិយាយថា អ្នកសារព័ត៌មានមានកិច្ចការសំខាន់ច្រើន ក្នុងនោះរឿងរបស់ពួកគេអាចទៅដល់មនុស្សជាច្រើន ហើយមានឥទ្ធិពលទៅលើមតិ និងទង្វើរបស់អ្នកទាំងនោះទៀតផង។ ដូច្នេះ វិស័យសារព័ត៌មានអាចជាឧបករណ៍មានអំណាចមួយបម្រើដល់សាធារណជន។ អំណាចនេះកើតមានជាមួយនឹងការទទួលខុសត្រូវផងដែរ នោះ គឺការទទួលខុសត្រូវក្នុងទង្វើប្រកបដោយសច្ចធម៌ ឯករាជ្យ និងត្រឹមត្រូវ។

ពេលណាអ្នកសារព័ត៌មានអសីលធម៌ ពួកគេអាចធ្វើឲ្យជនានុជនច្រើននាក់ទទួលផលអាក្រក់តាមរយៈសំណេររបស់ពួកគេ។ ពួកគេអាចបង្គ្រោះដល់រឿងរបស់ខ្លួន ដល់ប្រភពដែលធ្លាប់តែផ្តល់ព័ត៌មានឲ្យ និងដល់សង្គមទូទៅទៀតផង។

## សូមនិយាយតែការពិត

កុំកុហកឲ្យសោះ ដើម្បីយករឿងមកសរសេរ។ ពេលណាណែនាំខ្លួនចំពោះប្រភពណាមួយ ចូរប្រាប់ឈ្មោះរបស់ខ្លួន ឈ្មោះរបស់អង្គភាពឲ្យបានច្បាស់លាស់ ហើយប្រាប់គេថា តើយើងកំពុងធ្វើរឿងអ្វី។ កុំតាំងខ្លួនជាវេជ្ជបណ្ឌិត ឬជាមន្ត្រីរដ្ឋាភិបាល ដើម្បីប្រមូលព័ត៌មាន ឬចូលទៅកាន់កន្លែងណាមួយ។ កុំកត់ត្រាព័ត៌មានដោយគ្មានការអនុញ្ញាត។ កាលណាការភូតកុហករបស់អ្នកសារព័ត៌មាន ត្រូវបានគេលាតត្រដាង វានឹងប៉ះពាល់ដល់កិត្តិនាមអង្គភាពរបស់អ្នក។ ប្រភពនានា ក៏នឹងឈប់និយាយជាមួយអ្នកសារព័ត៌មានទៀតដែរទៅថ្ងៃមុខ។

ជានិច្ចកាល ចូរនិយាយតែការពិតក្នុងការសរសេររឿងរបស់អ្នក។ ព្យាយាមធ្វើយ៉ាងណាឲ្យប្រាកដថា ព័ត៌មានក្នុងសាច់រឿងមានភាពទៀងត្រង់ ជាក់លាក់ ពេញលេញ ត្រឹមត្រូវ ហើយមានតុល្យ-ភាព។ ធ្វើយ៉ាងណាកុំឲ្យព័ត៌មាននោះប្រាសចាកភាពជាក់ស្តែង ឬជាពាក្យចចាមអារ៉ាម។ បើក្រោយមកទៀតអ្នកឃើញថា រឿងដែលអ្នកបានចុះផ្សាយនោះវាមិនពិត មិនទៀងត្រង់ ឬនាំឲ្យមានការយល់ខុសក្នុងប្រការណាមួយនោះ ចូរធ្វើការកែតម្រូវឡើងវិញក្នុងកាសែតរបស់អ្នក ដើម្បីឲ្យអ្នកអានបានដឹងការពិតផង។

ចូរចងចាំថា វាមិនសំខាន់ទេត្រង់ថា តើអ្នកមានការយល់ឃើញផ្ទាល់ខ្លួនបែបណាទៅលើបញ្ហាណាមួយនោះ។ យកល្អ ដាក់ទស្សនៈប្លែកៗគ្នាដែលអ្នកប្រមូលបានទៅក្នុងសាច់រឿងទៅ។

មានអ្នកសារព័ត៌មានខ្លះសរសេររឿងដែលច្រើនតែផ្អែកលើនដោយមតិនោះ ដោយសារថា ពួកគេចង់សាយភាយនូវមតិផ្ទាល់ខ្លួន ឬមតិរបស់ក្រុមដែលផ្តល់មូលនិធិផ្គត់ផ្គង់កាសែតរបស់ពួកគេ។ ពួកគេតែងតែធ្វើការរិះគត់ទៅលើមនុស្សដទៃ ក្នុងនោះ មានអ្នកនយោបាយផង ដោយមិនខ្វីខ្វល់ថាមាន ឬមិនមានការពិតក្នុងការរិះគន់របស់ពួកគេទាំងអម្បាលមាណនោះ។ គ្រោះថ្នាក់នៅត្រង់ថា

អ្នកអានច្រើននាក់អាចនឹងគិតថា មតិទាំងនោះជាការពិត ពីព្រោះវាបានបោះពុម្ពផ្សាយក្នុងកាសែតរួចទៅហើយ។

និពន្ធនាយក ចាងហ្វាងកាសែត អ្នកផ្សាយពាណិជ្ជកម្ម ឬក៏អាជ្ញាធរអាចដាក់សម្ពាធមកលើអ្នកឲ្យបញ្ចូលមតិបែបណានោះ ទៅក្នុងសាច់រឿងរបស់អ្នក។ ពួកគេក៏ចង់ឲ្យអ្នកសរសេរអំពីរឿងដែលគ្មានការពិតក៏មានដែរ។ យើងដឹងថា ពេលខ្លះវាមានការពិបាកនឹងប្រកែកណាស់។ តែកាលៈទេសៈបែបនេះហើយដែលអ្នកត្រូវតែរិះគិតអំពីការទទួលខុសត្រូវចំពោះអាជីពរបស់ខ្លួន និងចំពោះសង្គម។

អ្នកកាសែតខ្លះជាស្មេរ ដែលច្រើនតែសរសេរអត្ថបទសម្តែងមតិផ្ទាល់ខ្លួន ចុះផ្សាយក្នុងខ្ទង់ ឬទំព័រណាមួយជាប្រចាំ។ វាមិនជាបញ្ហាទេ ដរាបណាដែលខ្ទង់អត្ថបទបែបនឹងវាស្ថិតនៅដោយឡែកពីទំព័រអត្ថបទដំណឹង។ ក៏ប៉ុន្តែមតិរបស់ស្មេរ ក៏ត្រូវតែ



*វិស័យសារព័ត៌មានអាចឧបករណ៍ប្រកបដោយអំណាចមួយដែរក្នុងការបម្រើសាធារណជន*

មានការណ៍ពិត និងទឡ្ហីករណ៍រឹងមាំមកគាំទ្រផងដែរ ពីព្រោះថាស្មេរមិនមែនចេះតែមានសេរីភាពសាយភាយភាពលម្អៀងរបស់ខ្លួនទៅឲ្យអ្នកផ្សេងអាននោះទេ។

ពេលណាដែលអ្នកចុះផ្សាយព័ត៌មានដែលខុសការពិត ហើយប៉ះពាល់ដល់កេរ្តិ៍ឈ្មោះអ្នកដទៃនោះជាការបរិហារកេរ្តិ៍។ នៅប្រទេសខ្លះ ជនដែលទទួលរងការប៉ះពាល់កេរ្តិ៍ឈ្មោះបែបនេះ អាចទៅតុលាការហើយប្តឹងអ្នក និងអង្គភាពរបស់អ្នកពីបទបរិហារកេរ្តិ៍បាន។ ប្រសិនបើអ្នកប្តឹងនោះឈ្នះក្តី តុលាការអាចនឹងបង្គាប់ឲ្យអង្គភាពសារព័ត៌មានរបស់អ្នកបង់ប្រាក់សន្ធឹកសន្ធាប់ដល់ដើមបណ្តឹងជាការសងដល់ការខូចខាតកេរ្តិ៍ឈ្មោះរបស់គេ។ ដូច្នេះ វាអាចបង្កនូវការខូចខាតដល់ទាំងកេរ្តិ៍ឈ្មោះ និងស្ថានភាពហិរញ្ញវត្ថុអង្គភាពសារព័ត៌មានរបស់អ្នក រហូតដល់ថា វាអាចត្រូវបិទទ្វាររកស៊ីលែងកើតទៀតផង។ ច្បាប់បរិហារកេរ្តិ៍មានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ យកល្អ មើលច្បាប់ក្នុងប្រទេសដែលអ្នកកំពុងធ្វើការនោះឲ្យបានយល់ល្អិតល្អន់ឲ្យហើយ។

## កុំបំផ្លើស ឬបង្កើតអារម្មណ៍អាក្រក់

យើងដឹងហើយថា អធិករណ៍ ឬវិវាទ បង្កើតជាដំណឹង ហើយរឿងនិយាយអំពីវិវាទជួយលក់កាសែតឆាប់ដាច់។ ជម្លោះពូជសាសន៍ សាសនា នយោបាយ និងបញ្ហាដទៃទៀត អាចបណ្តាលឲ្យមានអំពើហិង្សាតាមដងផ្លូវ។ អ្នកសារព័ត៌មានប្រកបដោយសីលធម៌នឹងមិននិយាយបំផ្លើសអំពីជម្លោះនៅក្នុងរឿង ឬក្នុងរូបថតរបស់គេទេ ពីព្រោះថា ធ្វើបែបនោះ វាអាចនឹងធ្វើឲ្យស្ថានការណ៍កាន់តែអាក្រក់ថែមទៀត។ ដូចគ្នានេះដែរ ពួកគេមិនប្រើរឿងរបស់ខ្លួនទៅបង្កការស្អប់ខ្ពើមប្រជាជន ឬក្រុមដែលមានពូជសាសន៍ ឬជំនឿសាសនាផ្សេងនោះឡើយ។

## បម្រើសាធារណជន កុំបម្រើខ្លួនឯង

អ្នកសារព័ត៌មានល្អ គឺជាអ្នកសារព័ត៌មានដែលបម្រើប្រយោជន៍សាធារណៈ។ ដូច្នេះ កុំប្រើអាជីពដើម្បីប្រយោជន៍ផ្ទាល់ខ្លួននោះ។ កុំប្រើព័ត៌មានពីប្រភពរបស់អ្នក ដើម្បីរកលុយ។ កុំចងទំនាក់ទំនងធុរកិច្ចជាមួយប្រភពព័ត៌មានរបស់អ្នកឲ្យសោះ។ កុំបណ្តោយខ្លួនឲ្យគេប្រើប្រាស់សម្រាប់ជាប្រយោជន៍របស់ក្រុមនយោបាយ ឬសង្គមណាមួយឲ្យសោះ។

ប្រយ័ត្ន កុំបណ្តោយខ្លួនឲ្យធ្លាក់ទៅក្នុងស្ថានភាពមួយ ដែលអ្នកអាចជួបនឹងទំនាស់ផលប្រយោជន៍។ បើសិនជាអ្នកធ្វើការឲ្យរដ្ឋាភិបាល អ្នកមិនគួរសរសេរអំពីរដ្ឋាភិបាលទេ។ បើអ្នកសរសេរអំពីរដ្ឋាភិបាល អ្នកពិបាកនឹងសរសេរក្នុងរបៀបមួយ ប្រកបដោយសត្យានុម័ត ឬដោយអព្យាក្រឹតអំពីរដ្ឋាភិបាលបានណាស់។ ក្នុងហេតុផលដូចគ្នានេះដែរ បើសិនជាអ្នកធ្វើយុទ្ធនាការនយោបាយឲ្យគណបក្សនយោបាយណាមួយ អ្នកមិនគួរសរសេរអំពីនយោបាយទេ។

កុំយកលុយ កាដូ ឬគុណប្រយោជន៍ពីអ្នកដទៃ ក្នុងនោះមានមន្ត្រីរដ្ឋាភិបាល អ្នកនយោបាយ និងធុរជន។ អ្នកទាំងនេះនឹងនិយាយថាពួកគេឲ្យរបស់ទាំងនេះ ទៅអ្នកក្នុងន័យសម្តែងសន្តានចិត្តល្អ ឬក៏ជួយឧបត្ថម្ភដល់ថ្លៃធ្វើដំណើររបស់អ្នក។ តែតាមការពិត ពួកគេព្យាយាមធ្វើឥទ្ធិពលទៅលើអ្នកថា តើរឿងប្រភេទណាដែលអ្នកគួរសរសេរ។ និយាយឲ្យចំ ពួកគេឲ្យសំណូកដល់អ្នក។ យើងទាំងអស់គ្នាដឹងថា វាជាកាលំបាកមួយសម្រាប់អ្នកសារព័ត៌មានជាច្រើនក្នុងប្រទេសមួយចំនួនក្នុងអាស៊ីអាគ្នេយ៍ក្នុងការប្រកែកចំពោះសំណូក ព្រោះថាពួកគេទទួលបានប្រាក់បៀវត្សរ៍តិចតួចណាស់។ ពួកគេត្រូវបង់ថ្លៃផ្ទះ និងចិញ្ចឹមគ្រួសាររបស់គេដែរ។ ក្នុងស្ថានភាពនីមួយៗ អ្នកត្រូវតែធ្វើការវិនិច្ឆ័យដោយខ្លួនឯងថា តើគួរធ្វើរបៀបណា? ប៉ុន្តែ វាមានសារៈសំខាន់ក្នុងការព្យាយាមធ្វើយ៉ាងណាឲ្យទៅដល់ឧត្តមគតិនោះ គឺឯករាជ្យភាព។ អ្នកមិនត្រូវគិតថា សំណូកជាផ្នែកមួយធម្មតានៃប្រាក់ចំណូលរបស់អ្នកទេ។

## កុំលួចស្នាដៃរបស់អ្នកដទៃ

កុំយករឿង និងរូបថតរបស់អ្នកដទៃទៅចុះផ្សាយក្នុងកាសែត វិទ្យុ ឬការផ្សាយទូរទស្សន៍របស់អ្នកឲ្យសោះ ដរាបណាដែលអ្នកទទួលបានការអនុញ្ញាតពីម្ចាស់ដើមជាមុនសិន ហើយកាលណាបានការអនុញ្ញាតហើយ អ្នកត្រូវផ្តល់កិត្តិយសដល់ម្ចាស់ដើម ដោយប្រាប់អ្នកអាន អ្នកស្តាប់ និងទស្សនិកជនថា រឿងនោះគឺម្ចាស់ដើមជាអ្នកផលិត។ ប្រការនេះរាប់ទាំងអត្ថបទ និងរូបភាព ដែលបានចុះផ្សាយលើអ៊ិនធឺណិតផងដែរ។



*ចូរគោរពដល់ឯកជនភាពរបស់បុគ្គល បង្ហាញអ្នករងគ្រោះ ដោយសារជម្ងឺអេដស៍តែពីក្រោយខ្នងបានហើយ*

បើអ្នកមិនធ្វើដូច្នេះទេ នោះវានឹងបានន័យថា អ្នកកំពុងភូតកុហកទៅដល់អ្នកអានរបស់អ្នក ហើយ ថែមទាំងបានបំពានសិទ្ធិរបស់អ្នកកាសែត ដែលអ្នក បានលួចការងាររបស់គេទៀតផង។

យើងដឹងថាមានពេលខ្លះ វាមិនងាយនោះទេ។ កាសែតតូចៗខ្លះនិយាយថា ពួកគេត្រូវតែលួចរឿង និងរូបថតពីការផ្សាយដទៃទៀត ពីព្រោះពួកគេ មិនមានធនធានថវិកា ឬបុគ្គលិកគ្រប់គ្រាន់ ដើម្បី ប្រមូលព័ត៌មាន និងរូបថតដោយខ្លួនគេបានទេ។ ក៏ប៉ុន្តែលួចការងាររបស់អ្នកដទៃ គឺជាកំហុសសីលធម៌ មួយក្នុងចំណោមកំហុសសីលធម៌យ៉ាងអាក្រក់បំផុត ច្រើនទៀតក្នុងអាជីពសារព័ត៌មាន។ យើងហៅការ ប្រព្រឹត្តបែបនេះថា ការលួចចម្លងស្នាដៃនិពន្ធ (plagiarism)។ នៅប្រទេសខ្លះ អ្នកអាចត្រូវបាន គេប្តឹងទៅតុលាការ ដោយសារលួចចម្លងស្នាដៃ និពន្ធ។

## ប្រកាន់ភាពត្រឹមត្រូវមិនលម្អៀង

ក្នុងជំពូកមួយខាងដើម យើងបាននិយាយអំពី សារៈសំខាន់ក្នុងការរក្សាតុល្យភាព និងភាពត្រឹមត្រូវ មិនលម្អៀង។ ក្នុងនោះ រួមមាន ការធ្វើរឿងឲ្យមាន លក្ខណៈពេញលេញ ដោយមិនរំលងបោលនូវ ការណ៍ពិតសំខាន់ណាមួយទេ។ បន្ថែមលើនេះទៀត គឺការព្យាយាមធ្វើយ៉ាងណារកចម្លើយ ឬអាត្ថាធិប្បាយ ពីជនដែលត្រូវបានគេចោទប្រកាន់ថាបានប្រព្រឹត្ត កំហុស។ ពេលណាអ្នកចុះផ្សាយរឿងអំពីឧក្រិដ្ឋកម្ម ឬក៏រូបថតអ្នកពាក់ព័ន្ធក្នុងឧក្រិដ្ឋកម្ម កុំទាន់ចាត់ទុក ថា ពួកគេមានពិរុទ្ធភាពដោយគ្រាន់តែប៉ូលីសចាប់ ខ្លួនពួកគេនោះ។ ជនណាក៏ដោយត្រូវមានសិទ្ធិ ការពារខ្លួនរបស់គេចំពោះមុខតុលាការ។ ពួកគេនៅ តែជាមនុស្សមិនទាន់មានកំហុស ដរាបណាទាល់តែ តុលាការបានពិនិត្យភស្តុតាងរួច ហើយសម្រេចថា គេពិតជាមានពិរុទ្ធភាព។

## រក្សាភាពគប្បី និងមានសមានចិត្ត

ចូរប្រកាន់ភាពគប្បីក្នុងការចុះផ្សាយរឿង និង រូបថតរបស់អ្នក។ ចូរចៀសវាងការប្រើពាក្យពេចន៍ អសុរស ដូចជា ពាក្យប្រទេចផ្តាសារ ឬមួយការ ពិពណ៌នាគ្រោតគ្រាតអំពីទង្វើសេពសន្ថវៈ ឬក៏ រាងកាយមនុស្សជាដើម។ គួរចៀសវាងនូវភាសា អាសគ្រាម ឬមួយដែលបង្កក្តីរន្ធត់ ជាពិសេសពេល យកព័ត៌មានអំពីគ្រោះថ្នាក់ ឧក្រិដ្ឋកម្ម និងគ្រោះ មហន្តរាយ។ ចូររិះគិតអំពីអារម្មណ៍ញាតិសន្តាន របស់ជនរងគ្រោះផង។ សួរខ្លួនឯងមើលតើអ្នកមាន អារម្មណ៍យ៉ាងណាដែរ ប្រសិនបើវាជាប្អូនស្រីរបស់ អ្នកដែលបានស្លាប់ ហើយរូបថតសពរបស់នាងត្រូវ បានគេយកមកចុះផ្សាយក្នុងកាសែត? តើអ្នកចាំ បាច់ត្រូវប្រើក្នុងអត្ថបទរបស់អ្នកនូវឈ្មោះ ឬរូបថត យុវតីម្នាក់ ដែលជាជនរងគ្រោះអំពើរំលោភសេព សន្ថវៈទេ បើសិនជាធ្វើដូច្នោះ វានឹងនាំភាពអាម៉ាស់ ដល់នាងក្នុងចំណោមសហគមន៍ ដែលនាងកំពុង រស់នៅ? ក្នុងប្រទេសជាច្រើន ការចុះផ្សាយព័ត៌មាន បែបនេះ ជាអំពើខុសច្បាប់ផងដែរ។

យើងទាំងអស់គ្នាដឹងថា រឿងដែលមានពាក់ព័ន្ធ ផ្លូវភេទ និងដែលមានស្នាមឈាមលាយឡំ វានឹង ជួយដល់ការលក់កាសែតឲ្យដាច់ដាច់។ ប៉ុន្តែ ក្នុង នាមជាអ្នកសារព័ត៌មាន កិច្ចការរបស់អ្នកមិនមែន លក់កាសែតទេ។ កិច្ចការរបស់អ្នក គឺផ្តល់ព័ត៌មាន ដល់អ្នកអានតាមរបៀបមួយ ដែលមានការទទួល ខុសត្រូវ។

## គោរពសិទ្ធិឯកជនភាពរបស់អ្នកដទៃ

មនុស្សទាំងឡាយមានសិទ្ធិរស់នៅឋាកផុតពីការបៀតបៀនពីសំណាក់អ្នកដទៃមកលើជីវិតឯកជនរបស់គេ។ រឿងបំផ្លើសបម្រើផ្លូវអារម្មណ៍ទាក់ទិននឹងជីវិតឯកជនរបស់អ្នកដទៃ មិនគួរត្រូវបានយកមកចុះផ្សាយក្នុងទំព័រកាសែតទេ។ គិតទៅមើល តើអ្នកមានអារម្មណ៍យ៉ាងណា បើសិនជាកាសែតមួយលាតត្រដាងអំពីជីវិតស្នេហា ឬក៏បញ្ហាសុខភាពផ្ទាល់ខ្លួនរបស់អ្នកឲ្យពិភពលោកទាំងមូលដឹងឮនោះ?

មានករណីលើកលែងខ្លះដែរ។

មន្ត្រីរដ្ឋាភិបាលមានតិចតួចជាងនូវសិទ្ធិរក្សាឯកជនភាព ពីព្រោះពួកគេជាមន្ត្រីសាធារណៈដែលទទួលប្រាក់បៀវត្សរ៍ពីការបង់ពន្ធរបស់ពលរដ្ឋ ហើយដូច្នេះរាល់ទង្វើរបស់ពួកគេ អាចមានផលប៉ះពាល់ទៅលើមនុស្សដទៃ។ អ្នកឯទៀត តួយ៉ាងដូចជាតារាភាពយន្ត ក៏ត្រូវបានគេរំពឹងទុកថាជីវិតរបស់គេអាចក្លាយជាចំណាប់អារម្មណ៍របស់សាធារណជនដែរ។ កាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ កាសែតថៃមួយចំនួន បានវែកមុខលោកសង្ឃព្រះពុទ្ធសាសនាមួយចំនួន ដែលបានសេពសន្ថវៈជាមួយស្ត្រីពេស្យា។ កាសែតទាំងនោះធ្វើដូច្នេះពិតជាត្រឹមត្រូវ។ ទង្វើដូច្នេះជារឿងដែលសាធារណជនត្រូវខ្វាយខ្វល់ ព្រោះថាប្រជាជនថៃបានប្រគេនប្រាក់កាស និងទ័យទានច្រើនណាស់ដល់ព្រះសង្ឃដើម្បីគាំពារពួកគេក្នុងនាមពួកគេជាមេដឹកនាំសហគមន៍ និងក្នុងនាមពួកគេជាគ្រូផ្នែកសីលធម៌។

## គោរពប្រភពព័ត៌មានរបស់អ្នក

លោកអ្នកមានការទទួលខុសត្រូវមិនត្រឹមតែចំពោះសាធារណជនទេ តែក៏ចំពោះប្រភពព័ត៌មានរបស់លោកអ្នកផងដែរ។ ឧទាហរណ៍ ប្រសិនបើប្រភពផ្តល់ព័ត៌មានសើបណាមួយដល់អ្នកក្នុងលក្ខខណ្ឌថាអ្នកបង្ហាញឈ្មោះពួកគេនោះ អ្នកត្រូវតែរក្សាការសន្យារបស់អ្នកចំពោះពួកគេ។ អ្នកមិនអាចលាតត្រដាងឈ្មោះរបស់ប្រភពក្នុងរឿងរបស់អ្នក ឬដោយប្រការណាមួយបានឡើយ។ បើអ្នកធ្វើផ្ទុយនឹងការសន្យា វានឹងនាំឲ្យមានផលប៉ះពាល់អាក្រក់ទៅលើជីវិតឯកជន និងជីវិតអាជីពរបស់ប្រភព ឬមួយដល់ជីវិតរបស់ពួកគេទៀតផង។

## ពិភាក្សាជាមួយសហសេវិក

ពេលណាពេបប្រទះនឹងបញ្ហាសីលធម៌ កុំព្យាយាមដោះស្រាយតែម្នាក់ឯង ចូរពិភាក្សាជាមួយសហសេវិក។ សាកត្រិះរិះគិតមើលថា ជម្រើសដែលអ្នកប្រកាន់យកនឹងបង្កផលប៉ះពាល់ដល់អ្នកដទៃបែបម៉េចខ្លះ? អ្នកណានឹងឈ្នះ? អ្នកណានឹងចាញ់? អ្នកណានឹងទទួលការឈឺចាប់? ពិចារណាមើលថាតើអ្នកសារព័ត៌មានឯទៀតដោះស្រាយបញ្ហាស្រដៀងគ្នានេះដោយវិធីណា។



*សួរខ្លួនឯងមើលថា តើអ្នកមានការទទួលខុសត្រូវយ៉ាងណាខ្លះចំពោះប្រភពព័ត៌មាន*

# ក្រមសីលធម៌

អង្គភាពសារព័ត៌មានទាំងអស់ គួរតែមានក្រមសីលធម៌សម្រាប់អ្នកយកព័ត៌មាន និងនាយកនិពន្ធប្រណិបត្តិតាម។ ក្រមសីលធម៌នោះ គួរបញ្ជាក់ឲ្យបានច្បាស់ថា តើអាកប្បកិរិយាបែបណាខ្លះដែលគេអាចរំពឹងទុកពីសំណាក់អ្នកសារព័ត៌មានទាំងអស់ ហើយថាតើអាកប្បកិរិយាបែបណាដែលមិនអាចទទួលយកបាន។ វាគួរតែបញ្ជាក់ផងដែរថា អ្នកដែលបំពានក្រមវិន័យ នឹងអាចទទួលទណ្ឌកម្មបែបណា។ ច្បាប់ចម្លងក្រមសីលធម៌គួរតែត្រូវមាននៅក្នុងសាលផលិតព័ត៌មាន ដើម្បីឲ្យទាំងអស់គ្នាដឹងថា តើក្រមវិន័យនោះចែងថាម៉េចខ្លះ។

# សេចក្តីសន្និដ្ឋាន




*តើរឿងរបស់អ្នកវាងាយយល់សម្រាប់មនុស្សទូទៅដែរ ឬទេ?*

យើងបានសិក្សាដឹងហើយអំពីចំណុចជាមូលដ្ឋាននៅក្នុងសៀវភៅនេះ ប៉ុន្តែនៅមានកិច្ចការច្រើនទៀតសម្រាប់ជាអ្នកសារព័ត៌មានអាជីព។ ឥឡូវនេះ វាស្រេចលើលោក-លោកស្រីថា តើត្រូវធ្វើឲ្យជំនាញការយកព័ត៌មាន និងសរសេរព័ត៌មានរបស់លោក-លោកស្រី កាន់តែប្រសើរបែបណា។ អ្នកត្រូវតែមានឆន្ទៈធ្វើការមិនខ្លាចនឿយហត់ មានភាពរាបសារ និងបើកខ្លួនចំពោះការរិះគន់ពីសំណាក់អ្នកដទៃ។

ជារឿយៗ វាមានប្រយោជន៍ក្នុងការឲ្យអ្នកដទៃអាន និងអត្ថាធិប្បាយលើរឿងរបស់អ្នក។ ទោះជាស្ទីក៏ដោយ អ្នកគ្រាន់តែជាសារគមនាគមន៍ជនប៉ុណ្ណោះ ហើយមានតែអ្នកដទៃទេ ដែលអាចប្រាប់អ្នកបានថា តើអ្នកធ្វើសារគមនាគមន៍ឆ្លើយឆ្លងបានល្អ ឬអត់។ ចូរឲ្យអ្នកយកព័ត៌មាន និងនិពន្ធនាយកឯទៀតក្នុងសាលព័ត៌មានរបស់អ្នក និងមិត្តភក្តិនៅក្រៅការិយាល័យឲ្យជួយអានរឿងរបស់អ្នក។ សួរពួកគេមើលថាតើពួកគេមានយោបល់យ៉ាងម៉េចអំពីរឿងរបស់អ្នក? សួរពួកគេថា បើពួកគេជាអ្នកអានទូទៅ តើពួកគេគិតយ៉ាងម៉េចដែរអំពីរឿងនេះ? ស្តាប់ចំពោះការឲ្យអាត្ថាធិប្បាយរបស់ពួកគេ ហើយធ្វើការកែប្រែក្នុងសាច់រឿងនោះទៅ ប្រសិនបើវាចាំបាច់។

បន្ទាប់ពីរឿងរបស់អ្នកត្រូវបានពិនិត្យកែសម្រួលរួចហើយ ចូរសិក្សាមើលពីភាពខុសគ្នារវាងអ្វីដែលអ្នកបានសរសេរ និងការផ្លាស់ប្តូរដែលនិពន្ធនាយកបានធ្វើ។ ចូរត្រិះរិះពិចារណាមើលថា តើហេតុអ្វីបានជានិពន្ធនាយកធ្វើការផ្លាស់ប្តូរទាំងនោះ និងអំពីរបៀបដែលពួកគេធ្វើរឿងរបស់អ្នកឲ្យកាន់តែប្រសើរជាងមុន។

បើសិនជាអ្នកមិនមាននាយកនិពន្ធល្អៗសម្រាប់រៀនត្រងត្រាប់ជាប្រយោជន៍បានទេ ចូរស្វែងរកឱកាសហ្វឹកហ្វឺនបន្ថែមទៀត ដូចជានៅសកលវិទ្យាល័យ ឬនៅតាមអង្គការបណ្តុះបណ្តាលសារព័ត៌មានផ្សេងៗទៀត។

បើទោះជាអ្នកមិនមាននិពន្ធនាយក ឬគ្រូបង្វឹកល្អៗក៏ដោយ មានលទ្ធភាពច្រើនដែលអ្នកអាចធ្វើខ្លួនឯងបាន។ ប្រហែលជាអ្វីដែលសំខាន់ជាងគេនោះ គឺអានរឿងល្អៗក្នុងកាសែត។ អានរឿងល្អៗទាំងឡាយណាដែលអ្នកឃើញ តាមតែអាចធ្វើទៅបាន។ អានដោយមធ្យ័ត។ សិក្សាអំពីស្ទីលក្នុងការសរសេរទ្រង់ទ្រាយការរៀបចំសាច់រឿង កថាខណ្ឌ សាវតារ សំរង់សម្តីដើម ហើយនិងរូបធាតុផ្សេងៗទៀត ដែលយើងបានពិភាក្សារួចហើយក្នុងសៀវភៅនេះ។ អានប្រលោមលោកល្អៗ និងរឿងខ្លីៗ ក៏អាចផ្តល់ឲ្យអ្នកនូវគំនិតសម្រាប់បង្កើនការប៉ិនប្រសប់របស់អ្នកក្នុងការនិទានរឿងផងដែរ

ជាពិសេសក្នុងការសរសេរអត្ថបទពិពណ៌នា។ ពេលណាអ្នកអានរឿងទាំងនោះ សួរខ្លួនឯងថា ហេតុអ្វីបានជាអ្នកនិពន្ធរៀបរៀងរឿងរបៀបនេះ? តើសរសេរបែបហ្នឹងមានប្រសិទ្ធភាពទេ ហើយថា ហេតុអ្វីបានជាវាមានប្រសិទ្ធភាព? ត្រិះរិះមើលថា តើអ្នកអាចប្រើតិចនិកទាំងនេះបែបណាក្នុងការសរសេររឿងរបស់ខ្លួន។

អ្នកអាចអានសៀវភៅសារព័ត៌មានផ្សេងទៀតជាជំនួយផងដែរ។ យើងបានរាយនាមបញ្ជីសៀវភៅមួយចំនួនទៀត ក្នុងផ្នែក Further Reading។ ក្នុងឆ្នាំ ២០០៩ អង្គការ IMMF បានផលិតសៀវភៅវិធានជាន់ខ្ពស់ស្តីពីការយកព័ត៌មាន ដែលក្នុងនោះមានជំពូកនិយាយអំពីការសរសេរបទពិពណ៌នា ការរាយការណ៍ព័ត៌មានស៊ីជម្រៅ សំណេរស្នេរ និងបទវិចារណកថា បទវិភាគ និងអំពីការយកព័ត៌មានក្នុងផ្នែកពិសេសៗ (specialized beats) ដូចជាផ្នែកធុរកិច្ច និងផ្នែកបរិស្ថានជាដើម។

ពេលអ្នកសរសេររឿងចប់ ចូរសាកនិពន្ធកែសម្រួលរឿងនោះដោយខ្លួនឯង ហើយសាកធ្វើដោយតឹងរ៉ឹងបំផុត។ កុំរក្សាពាក្យពេចន៍នៅដដែលដោយគ្រាន់តែអ្នកបានសរសេរវាក្នុងរឿងហើយនោះ។ យើងសង្ឃឹមថា អ្នកនឹងចងចាំចោទសួរខ្លួនឯងរាល់សំណួរទាំងឡាយ ដែលយើងបានលើកឡើងនៅក្នុងសៀវភៅនេះថា តើសរសេរអញ្ចឹងវាដូចអ្វីដែលខ្ញុំចង់និយាយទេ? តើអ្វីៗដែលខ្ញុំបានសរសេរមកនេះ វាមានភាពទៀងត្រង់ជាក់លាក់ និងត្រឹមត្រូវមិនលម្អៀងទេ? តើអ្វីដែលអ្នកអានរបស់ខ្ញុំចង់ និងត្រូវការដឹង? តើអ្វីជាតួនាទីរបស់អ្នកសារព័ត៌មាន?

# ឯកសារអានបន្ថែម

ក្រៅពីសៀវភៅ Getting the Story សៀវភៅទាំងអម្បាលមាណខាងក្រោមនេះ សុទ្ធតែជាភាសាអង់គ្លេស ដែលអាចជាការលំបាកដល់អ្នកទាំងឡាយណា ដែលអង់គ្លេសមិនមែនជាភាសាកំណើតរបស់ខ្លួន។ ភាគច្រើននៃសៀវភៅទាំងនេះនិយាយពីស្ថានភាពសារព័ត៌មាននៅសហរដ្ឋអាមេរិក។ តែយ៉ាងណាក៏ដោយ សៀវភៅទាំងនេះផ្តល់ព័ត៌មានល្អៗបំផុតសម្រាប់ការយកព័ត៌មាន និងសំណេរជាន់ខ្ពស់ ដែលយើងមិនអាចនិយាយដល់ក្នុងសៀវភៅមួយនេះ។

## សៀវភៅ

The AP Broadcast News Handbook, by Brad Kalbfeld. Published in 2000 by McGraw Hill Professional Publishing.

The Associated Press Guide to News Writing (3rd edition), by Rene J. Cappon. Published in 2005 by ARCO.

Getting the Story. This is a textbook and a video tape produced in 1990 by the International Center for Journalists, 1616 H Street, NW, 3rd Floor, Washington DC 20006-4999, USA.

A Handbook for Cambodian Journalists, by Huw Watkin. Published in Phnom Penh in 1998 by the Konrad Adenauer Foundation.

News Reporting and Writing (11th edition), by Melvin Mencher. Published in 2007 by McGraw Hill College Division.

The Newspapers Handbook (3rd edition), by Richard Keeble. Published in 2001 by Routledge, London and New York.

Writing and Reporting News, A Coaching Method (6th edition), by Carole Rich. Published in 2009 by Wadsworth Publishing Co., 10 Davis Drive, Belmont, CA 94002, USA.

## កម្រងកូនសៀវភៅ

អង្គការ International Center for Journalists បានផលិតចេញសៀវភៅមួយចំនួនដូចខាងក្រោមនេះ ៖

The International Center for Journalists has produced the following:

Ten Practical Tips for Environmental Reporting, by Peter Nelson

Ten Practical Tips for Business and Economic Reporting in Developing Countries, by Paul Hemp

Ten Steps to Investigative Reporting, by Lucinda Fleeson

Free and Fair: A Journalist's Guide to Improved Election Reporting in Emerging Democracies, by Lisa Schnellinger

## ទិនានុប្បវត្តិ

The Columbia Journalism Review (http://www.cjr.org) ផ្តល់មគ្គុទេសក៍ក្នុងការយកព័ត៌មានផ្នែកនីមួយៗជាក់លាក់ ដូចជាផ្នែកឧក្រិដ្ឋកម្ម បម្រែបម្រួលអាកាសធាតុ សុខាភិបាល និងផ្នែកផ្សេងទៀត។

The American Journalism Review (http://www.ajr.org) ផ្តល់មគ្គុទេសក៍សម្រាប់អ៊ិនធឺណិត ការស្រាវជ្រាវ ស្ថិតិ សេរីភាពសារព័ត៌មាន។ល។ និង។ល។

The Poyter Institute (http://www.poyter.org) ផ្តល់ការពិភាក្សាអំពីបញ្ហាជាច្រើនទាក់ទិននឹងវិស័យសារព័ត៌មានជាមួយនឹងមគ្គុទេសក៍ណែនាំមានប្រយោជន៍ ដូចជា តារាងជំនួយស្មារតី "tip sheets" ។

The International Center for Journalists (http://www.icfj.org) has links to training tips and online training tools. It also runs www.ijnet.org, the International Journalists' Network.

# សេចក្តីថ្លែងអំណរគុណ

មានមនុស្សច្រើននាក់ដែលសប្បុរសក្នុងការចែករំលែកពេលវេលា និងជំនាញរបស់ពួកគេក្នុងការធ្វើឲ្យគម្រោងមួយនេះចេញជាផ្លែផ្កាបាន ក្នុងនោះ មានការផ្តល់អាត្ថាធិប្បាយលើសេចក្តីព្រាងរបស់សៀវភៅនេះ ការផ្តល់យោបល់ និងការពិនិត្យផ្នែករូបថត។ អ្នកទាំងនោះមាន ៖

**JUDITH CLARKE**, assistant professor of journalism at Hong Kong Baptist University. Meirion Edwards, consultant to The Thomson Foundation.

**MIKEL FLAMM**, IMMF photography trainer and board member.

**DENIS D. GRAY**, Bangkok bureau chief for The Associated Press and IMMF co-president, 1994-2009.

**SARAH MCLEAN**, IMMF project director, 1994-2009.

**GRAHAM WATTS**, IMMF trainer.

យើងមានសេចក្តីដឹងគុណជាអនេកចំពោះអ្នកទាំងអស់គ្នា ដែលបានជួយរកបានឧទាហរណ៍រឿងទាំងអស់ មកដាក់ក្នុងសៀវភៅទាំងពីរក្បាលនេះ និងចំពោះអង្គភាពសារព័ត៌មានទាំងឡាយ ដែលបានផ្តល់ការអនុញ្ញាតឲ្យយកសេចក្តីសង្ខេបរឿងរបស់ពួកគេ ជាពិសេសទីភ្នាក់ងារព័ត៌មាន The Associated Press មកប្រើជាឧទាហរណ៍។

សៀវភៅជាច្រើនផ្សេងទៀត ក៏មានប្រយោជន៍ដែរដល់ការសរសេរសៀវភៅនេះ ដែលភាគច្រើនត្រូវបានរាយនាមក្នុងផ្នែក Further Reading។ ក្នុងនោះ មានសៀវភៅ និងមគ្គុទេសក៍ណែនាំ ដែលផ្តល់ដោយ International Center for Journalists និង Knight International Press Fellowship Program។



## PHOTO CREDITS

**Cover**: *Top left,* MIKEL FLAMM.
*Middle from left,* VINAI DITHAJOHN, WIRUCH THONGCHAEW, DOMINIC FAULDER.
*Bottom from left,* DOMINIC FAULDER, SAROT MEKSOPHAWANNAKUL
*Inset bottom right,* VINAI DITHAJOHN.

VINAI DITHAJOHN 20, 26, 39, 51, 57, 86, 92.
PETER ENG 17.
DOMINIC FAULDER 23, 28, 32, 36, 40, 42, 48, 53, 54, 74, 75, 77, 78, 88, 90, 99, 100, 103, 106.
MIKEL FLAMM 34, 63.
HA HUY HONG 105.
THAKSIN KHAIKAEW 46.
SAROT MEKSOPHAWANNAKUL 59.
OU NEAKIRY 58.
MOEUN NHEAN 9, 96,102.
NICK NOSTITZ 84.
WIRUCH THONGCHAEW 64.
NGUYEN VAN TIEN 60.
TRAN QUANG TUAN XV, 30.
PRAVEJ TUNTRAPIROM 50.
RUNGROJ YONGRIT 70, 94

# អំពីអ្នកនិពន្ធ

**PETER ENG** ជាអ្នកសារព័ត៌មានសញ្ជាតិអាមេរិក និងសមាជិកគណៈនាយករបស់ IMMF។ ពីឆ្នាំ ១៩៨៤ ដល់ ១៩៩៦ គាត់ធ្វើជានាយកនិពន្ធព័ត៌មាននៃការិយាល័យទីភ្នាក់ងារព័ត៌មាន The Associated Press ប្រចាំក្រុងបាងកក។ នៅទីនោះ គាត់ដឹកនាំការរាយការណ៍ព័ត៌មានប្រចាំថ្ងៃពីប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។ ឆ្នាំ ១៩៩៦ គាត់ធ្វើការជាអ្នកសារព័ត៌មានឯករាជ្យ ដោយបានសរសេរអំពីការផ្លាស់ប្តូរផ្នែកសង្គម និងនយោបាយសម្រាប់កាសែតទស្សនាវដ្តីជាច្រើននៅអាស៊ីអាគ្នេយ៍ និងបានសរសេរសៀវភៅមួយចំនួន ដែលបានបោះពុម្ពផ្សាយនៅសហរដ្ឋអាមេរិក និងអាស៊ីផង។ គាត់បានបង្រៀនសារព័ត៌មាននៅ University of Hong Kong និង Internews ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយនៅសហរដ្ឋអាមេរិក និងធ្វើការឲ្យអង្គការជាច្រើនទៀត។ លោក Peter Eng ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រ នយោបាយពី University of Chicago និងជានិស្សិតអាហា-រូបករណ៍ Nieman នៅ Harvard University ទៀតផង។



*ចូររៀសរវៃរកមើលអ្វីដែលអធម្មតា*

JEFF HODSON ជាអ្នកសារព័ត៌មាន និងគ្រូបង្រៀនផ្នែកសារព័ត៌មានសញ្ជាតិអាមេរិក។ គាត់បានបង្រៀនសារព័ត៌មានជាច្រើននៅអាស៊ី ក្នុងនោះមានប្រទេសវៀតណាម និងអាហ្វហ្គានីស្ថានផង។ នៅឆ្នាំ ២០០០ នៅពេលដែលគាត់ត្រូវបានទទួលមូលនិធិផ្គត់ផ្គង់ពី Knight International Journalism Fellow គាត់បានដឹកនាំវគ្គបង្រៀន IMMF នៅតាមប្រទេសមួយចំនួនក្នុងអាស៊ី។ គាត់ជាម្ចាស់សៀវភៅរបស់ IMMF ដែលមានឈ្មោះថា Beyond Basics – An Advanced Journalism Handbook ដែលត្រូវបានបោះពុម្ពផ្សាយឆ្នាំ ២០០៩។ ឆ្នាំ ២០០៣ គាត់ជាសាស្ត្រាចារ្យនៅ Indian Institute of Journalism & New Media ហើយធ្លាប់បង្រៀនសារព័ត៌មាននៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ពីឆ្នាំ ២០០១ និង ២០០២ ទៀតផង។ គាត់ធ្លាប់ធ្វើការឲ្យ Internews, Independent Journalism Foundation និងអង្គការមួយចំនួនទៀត។ គាត់ជាអតីតនិពន្ធនាយករងកាសែត The Cambodia Daily និងធ្លាប់បានដឹកនាំវគ្គហ្វឹកហ្វឺនសារព័ត៌មានឲ្យអង្គភាពសារព័ត៌មានមួយចំនួនផង មានកាសែត Bangkok Post និង The Nation។ អស់រយៈពេលជាងមួយទសវត្សរ៍ គាត់ជាអ្នកយកព័ត៌មាន និងស្មេរ ដែលទទួលបានជ័យលាភីឲ្យកាសែតមួយចំនួននៅសហរដ្ឋអាមេរិក

ក្នុងនោះ មានកាសែត The Seattle Times។ លោក Hodson ទទួលបានសញ្ញាបត្រអនុបណ្ឌិតសារព័ត៌មានពី Northwestern University's Medill School of Journalism។

**DOMINIC FAULDER** ជាអ្នកសារព័ត៌មានសញ្ជាតិអង់គ្លេស ដែលរស់នៅក្រុងបាងកកតាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៨0 មកម្ល៉េះ ហើយធ្លាប់បានរួមវិភាគទានអត្ថបទ រូបថត និងបទវិចារណកថាដល់អង្គភាពសារព័ត៌មានច្រើនរាប់មិនអស់។ គាត់ជាអ្នកឆ្លើយឆ្លងព័ត៌មានពិសេសរបស់ទស្សនាវដ្ដីប្រចាំសប្ដាហ៍ Asiaweek ដោយរាយការណ៍ព័ត៌មានអំពីប្រទេសកម្ពុជា និងមីយ៉ាន់ម៉ា មុននឹងទស្សនាវដ្ដីនេះ ត្រូវបានបិទឆ្នាំ ២00១។ គាត់ធ្លាប់កាន់តំណែងផ្សេងៗក្នុង Foreign Correspondents' Club of Thailand រួមមាន តំណែងជាប្រធានអស់រយៈពេលពីរអាណត្តិផង និងជាសហប្រធាន IMMF ពីឆ្នាំ ១៩៩៤ ដល់ ២00៨។ លោក Faulder ទទួលការអប់រំជាន់ខ្ពស់នៅ St Paul's in London and the University of Warwick។

# កំណត់ត្រា

# កំណត់ត្រា

# កំណត់ត្រា

# កំណត់ត្រា

# វិធានជាមូលដ្ឋាន ស្តីពីការប្រមូល
# និង សរសេរដំណឹង

បោះពុម្ពលើកទីពីរ

"ខ្ញុំធ្លាប់ងឿងឆ្ងល់ថា តើអ្វីទៅដែលធ្វើឲ្យ IMMF លេចត្រដែត ហើយខ្ញុំក៏យល់ឃើញភ្លាមថា វាលេចធ្លោ ក៏ដោយសារតែក្រមសីលធម៌មិនបេះរឹងស្ងួតរបស់អ្នកទាំងឡាយ ដែលគ្រប់គ្រងចាត់ចែងគម្រោងនេះ។ ខ្ញុំពិតជាមិនអាចឲ្យអនុសាសន៍ថា មានវេទិកាណាប្រសើរជាងនេះទេ សម្រាប់ហ្វឹកហាត់អ្នកសារព័ត៌មាននោះ" ។

– Graham Watts, former Deputy World News Editor, *Financial Times*, London

"ខ្ញុំសូមស្ញើចសរសើរមែនទែនចំពោះសមិទ្ធផល ដែលមូលនិធិនេះសម្រេចបានជាមួយនឹងប្រភពធនធានមានកម្រិតនោះ" ។

– David Brown, Agriculture Editor, *The Daily Telegraph*, London

"ខ្ញុំមិនចង់និយាយបំផ្លើសអំពីកិច្ចខិតខំទាំងឡាយរបស់ IMMF ទេ ប៉ុន្តែវាពិតជាអង្គភាពតែមួយគត់ដែលពិតជាមានស្នាដៃក្នុងការហ្វឹកហាត់អ្នកសារព័ត៌មានជំនាន់ក្រោយក្នុងបណ្តាប្រទេស ក្នុងឧបទ្វីបឥណ្ឌូចិន។ អ្នកយកព័ត៌មានរបស់យើង ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលដោយកម្មវិធីរបស់ IMMF មិនត្រឹមតែពេញចិត្តពេញថ្លើមជាមួយអ្វី ដែលពួកគេបានរៀនបេះនោះទេ តែពួកគេក៏ពិតជារីករាយជាមួយការមានឱកាសស្គាល់អ្នកសារព័ត៌មានមកពីបណ្តាប្រទេសជិតខាងផងដែរ" ។

– Pana Janviroj, President, *The Nation*, Bangkok

"ក្នុងទស្សនៈរបស់ខ្ញុំ IMMF បានបំពេញសេវាដែលមិនអាចកាត់ថ្លៃបាន ដោយនាំយកបញ្ហាទាំងឡាយមកពិភាក្សាជាមួយអ្នកសារព័ត៌មាន និងដោយហ្វឹកហាត់ពួកគេឲ្យបេះធ្វើសារគមនាគមន៍កាន់តែមានប្រសិទ្ធភាពថែមទៀត។ ខ្ញុំធ្លាប់បានចូលបង្រៀនក្នុងពីរវគ្គដែរ ហើយជាញឹកញយខ្ញុំតែងតែមានការភ្ញាក់ផ្អើលនៅពេលដែលឃើញថា វគ្គហ្វឹកហ្វឺនទាំងអម្បាលមាណ បានធ្វើឲ្យសិក្ខាកាមបើកភ្នែកកាន់តែយល់ និងគំនិតរបស់គេផ្លាស់ប្តូរខុសពីមុន" ។

– David Nicholson-Lord, London

THE
INDOCHINA
MEDIA
MEMORIAL
FOUNDATION